


# ទស្សនាវដ្ដី
# វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

# មរតកវប្បធម៌អរូបីក្នុងសង្គមខ្មែរ



ឆ្នាំទី៣
លេខពិសេស

ការផ្សាយរបស់វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

ឆ្នាំ២០២៤

# និពន្ធនាយក

*ដោយ ៖ ឯកឧត្តមបណ្ឌិត* **ផុន កសិកា**

# រៀបចំចងក្រង

*ដោយ ៖ លោក* **យិន ពោ**

# រចនាក្រប

*ដោយ ៖ លោក* **ហ៊ាង សុចិត្រា**

| | | |
|---|---|---|
| *អាសយដ្ឋាន* | ៖ | *មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ អូរបែកក្អម ខណ្ឌ សែន សុខ រាជធានីភ្នំពេញ (ជាប់បរិវេណសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មណ្ឌល២)* |
| *គេហទំព័រ* (Website) | ៖ | https://ihss.rac.gov.kh |
| *ហ្វេសប៊ុក*(Facebook) | ៖ | https://web.facebook.com/ *វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម* |

# កថាមុខ

រាជបណ្ឌិត្យសភាកម្ពុជា ជាស្ថាប័នស្រាវជ្រាវវិទ្យាសាស្ត្ររបស់ជាតិ ដែលប្រមូលផ្តុំដោយបញ្ញវន្ត និងអ្នកស្រាវជ្រាវជាន់ខ្ពស់ពីគ្រប់មជ្ឈដ្ឋានក្នុងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានរាជរដ្ឋាភិបាលចាត់ទុកជាធនាគារខួរក្បាលដ៏សំខាន់របស់ជាតិ។

រាជបណ្ឌិត្យសភាកម្ពុជា មានតួនាទីយ៉ាងសំខាន់ក្នុងការសិក្សាស្រាវជ្រាវលើគ្រប់វិស័យទាំងអស់ដើម្បីផ្តល់ជាតុចូលជូនរាជរដ្ឋាភិបាលសម្រាប់បម្រើដល់កិច្ចការស្តារ និងអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ជាមួយគ្នានេះដែរ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម គឺជាសេនាធិការមួយរបស់រាជបណ្ឌិត្យសភាកម្ពុជា ដែលមានភារកិច្ចជាច្រើនស្រាវជ្រាវលើវិស័យមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ក្នុងគោលបំណងរួមចំណែកអភិវឌ្ឍប្រទេសកម្ពុជា អភិវឌ្ឍស្មារតី ចំណេះដឹង ពង្រីកសមត្ថភាពធនធានមនុស្ស ព្រមទាំងបោះពុម្ពផ្សព្វផ្សាយលទ្ធផលនៃការសិក្សាស្រាវជ្រាវរបស់ខ្លួនក្នុងស្មារតីសន្តិភាព អភិវឌ្ឍនភាព ភាពសុខដុមរមនា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក៏ដូចជារាជបណ្ឌិត្យសភាកម្ពុជា។

ស្របតាមតួនាទីភារកិច្ចរបស់ខ្លួន វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គមបានបង្កើតទស្សនាវដ្តីមួយដែលមានឈ្មោះថា «**ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**» ដើម្បីរៀបចំចងក្រង និង បោះពុម្ពផ្សាយលទ្ធផលស្រាវជ្រាវរបស់ថ្នាក់ដឹកនាំ មន្ត្រីវិទ្យាស្ថាន អ្នកស្រាវជ្រាវរបស់រាជបណ្ឌិត្យសភាកម្ពុជាក៏ដូចជាលទ្ធផលស្រាវជ្រាវបែបវិទ្យាសាស្ត្រពីគ្រប់មជ្ឈដ្ឋានផងដែរ។ **ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម** ប្រមូលផ្តុំដោយអត្ថបទទាក់ទងទៅនឹងប្រធានបទណាមួយ របកគំហើញថ្មីៗ និង អត្ថបទទស្សនៈរបស់អ្នកនិពន្ធជាដើម ក្នុងគោលបំណងចែករំលែកចំណេះដឹងទៅកាន់មជ្ឈដ្ឋានអ្នកស្រាវជ្រាវ សិស្ស និស្សិត ក៏ដូចជា អ្នកអានទូទៅផងដែរ។

យើងខ្ញុំសង្ឃឹម និង ជឿជាក់ថា «**ទស្សនាវដ្តីមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម**» នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា ពិតជាផ្តល់នូវមូលដ្ឋានឯកសារសម្រាប់សិស្ស និស្សិត អ្នកស្រាវជ្រាវទូទៅ ធ្វើការសិក្សាស្រាវជ្រាវបន្តទៀត។

**ប្រធានវិទ្យាស្ថាន**

**បណ្ឌិត ផុន កសិកា**

# មាតិកា


*ទំព័រ*

មរតកវប្បធម៌អរូបីក្នុងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង..........១

*ឯកឧត្តមបណ្ឌិត ផុន កសិកា*

ស្វែងយល់អំពីល្បែងបោះអង្គញ់(Understanding on AngkugnGame)..........២២

*ឯកឧត្តមបណ្ឌិតអ៊ុំ ប៉ុម*

*ស្វែងយល់ពីល្បែងបាយខុំ*(Understanding on Baykhom Game) ..........៣៣

*ឯកឧត្តមបណ្ឌិត អ៊ុំ ប៉ុម*

សម្លរម្ជូរខ្ចូរក្តាម(Understanding on Khmer food "Khuor Kdam Food")..........៤៤

*ឯកឧត្តមបណ្ឌិត អ៊ុំ ប៉ុម*

ការប្រតិបត្តិជំនឿអ្នកតាក្នុងសង្គមខ្មែរ..........៥០

*លោកបណ្ឌិត ហែម ឡាច*

ជំនឿបែបជីវចលនិយមក្នុងសង្គមខ្មែរ..........៨៦

*លោកបណ្ឌិត ហែម ឡាច*

បុណ្យភ្ជុំបិណ្ឌ និង ប្រភេទប្រេតទាំង១២ពួកក្នុងជំនឿខ្មែរ..........១០៩

*លោកបណ្ឌិត ហែម ឡាច*

អំពីជំនឿខ្មែរ (ភាគ១)..........១២០

*លោកបណ្ឌិត ក្លាន់ ធុល*

អំពីជំនឿខ្មែរ (ភាគ២)..................................................................................................................១៣៤

*លោកបណ្ឌិត ក្លាន់ ផុល*

អំពីជំនឿខ្មែរ (ភាគ៣)..................................................................................................................១៤៨

*លោកបណ្ឌិត ក្លាន់ ផុល*

លទ្ធិទេវរាជ (ទស្សនវិជ្ជានយោបាយខ្មែរ)..................................................................................១៦១

*លោកបណ្ឌិត ក្លាន់ ផុល*

ស្វែងយល់ពីពិធីបុណ្យភ្ជុំបិណ្ឌ..........................................................................................................១៧៦

*លោកស្រី បណ្ឌិត ជា វណ្ណី*

# មរតកវប្បធម៌អរូបី
# ក្នុងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង

*ដោយ៖* **បណ្ឌិត ផុន កសិកា**

*ប្រធានវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

*រាជបណ្ឌិត្យសភាកម្ពុជា*

Email: kaseka1975@yahoo.com

## សេចក្តីផ្តើម

*មរតកវប្បធម៌អរូបីសំដៅដល់ប្រពៃណី ទំនៀមទម្លាប់របៀបរបបក្នុងសង្គម ល្បែងរបាំ កិច្ចពិធី ឬចំណេះជំនាញប្រពៃណីដូនតានានាជាដើម។ ការទទួលស្គាល់និងប្រតិបត្តិចំពោះមរតកវប្បធម៌អរូបីរបស់អ្នកស្រុកភូមិ ឬមនុស្សក្រុម និងមួយគ្រួសារ តែងតែអនុលោមទៅតាមបរិបទសង្គមនិងបរិស្ថានជុំវិញ ដោយសារតែពួកគេបានទទួលនិងចេះដឹងពីមរតកវប្បធម៌អរូបីនេះតៗគ្នាពីជីដូនជីតាជាច្រើនជំនាន់មក។ ដូចនេះហើយ ការទទួលស្គាល់និងប្រកាន់យកមកប្រតិបត្តិទាំងឡាយបង្ហាញឱ្យឃើញថាជាអត្តសញ្ញាណ និងជាកេរដំណែលដូនតាបន្តមកសម្រាប់ពួកគាត់។ មរកតវប្បធម៌អរូបីមានការទទួលស្គាល់និងប្រតិបត្តិស្ទើគ្រប់កន្លែងនៃប្រទេសកម្ពុជា ជាពិសេសសម្រាប់ប្រជាជននៅស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។*

*ស្រុកកំពង់លែង ស្ថិតក្នុងខេត្តកំពង់ឆ្នាំង មានទីតាំងស្ថិតនៅជាប់ដងទន្លេសាប គឺជាទឹកដីបុរាណចំណាស់មួយ ដែលមានសហគមន៍មនុស្សរស់នៅតាំងពីយូរយារមកហើយ។ មាន បុរាណវត្ថុជាច្រើន រាប់តាំងពីបុរាណវត្ថុដែលមានកាលបរិច្ឆេទតាំងពីសម័យបុរេប្រវត្តិសាស្ត្រ*[1] *ជាពិសេសកុលាលភាជន៍មានទម្រង់ផ្សេងៗគ្នាជាច្រើនជាភស្តុតាង។ អត្ថបទលោក* Lajonquière *ដែលជាអ្នកស្រាវជ្រាវជនជាតិបារាំង មកស្រាវជ្រាវនៅស្រុកកំពង់លែងតាំងពីឆ្នាំ១៩០១ ក៏បាននិយាយអំពីស្ថានីយសំរោងសែននេះដែរ*[2]*។ ដែលនេះវាបានបញ្ជាក់ថាមនុស្សមកតាំងទីលំនៅក្នុងសម័យបុរេប្រវត្តិសាស្ត្រ ប្រកបមុខរបរចិញ្ចឹមជីវិតដោយការធ្វើនេសាទ ដោយផ្អែកលើភស្តុតាងដែលគេរកឃើញវត្ថុបុរាណ ដូចជាផ្លែសន្ទូច ឧបករណ៍ស្មិតសំរិទ្ធ*

[1] Ly Vanna 2002: 13-34.

[2] Lajonquière 1902: 196.

និងស្រទាប់គំនរលាសយ៉ាងក្រាស់។ ភស្តុតាងបុរាណវត្ថុនៅសម័យបន្ទាប់ពីបុរេប្រវត្តិសាស្ត្រ គឺសម័យមុនអង្គរត្រូវបានរកឃើញ និងសិក្សាកត់ត្រាទុកដោយលោក Aymonier (Aymonier, Etienne. (1900). Le Cambodge: Le Royaume Actuel, Tome I, P: 358-363) និងលោក Lajonquière (Lajonquière, Lunet D. (1902). Inventaire Descriftif des Monuments du Cambodge, Tome I, P: 193-202.)។ ភស្តុតាងសំខាន់ៗមានដូចជាប្រាសាទសក្ក (ប្រាសាទប្រុស), ប្រាសាទព្រះស្រី, ប្រាសាទតូច, ប្រាសាទថ្មបុី, ប្រាសាទពណ្ណរាយ និងក្រុមប្រាសាទភ្នំទេពី ព្រមទាំងទួលប្រាសាទ និងគ្រឹះប្រាសាទជាច្រើនទៀត ក្នុងស្រុកកំពង់លែង[3]។ តាមរយៈតឹកតាងខាងលើទឹកដីស្រុកកំពង់លែងមានសហគមន៍មនុស្សរស់នៅបន្តរហូតតាំងពីសម័យបុរេប្រវត្តិ សម័យមុនអង្គរ សម័យអង្គរ សម័យក្រោយអង្គរ និងមកដល់បច្ចុប្បន្ន។ សហគមន៍មនុស្សមួយដែលរស់នៅក្នុងទីដ្ឋានបុរាណបែបនេះ រមែងបន្សល់ស្នាកស្នាមនិងទិដ្ឋភាពដែលបង្ហាញពីការគោរពទទួលស្គាល់ និងប្រតិបត្តិចំពោះមរតកបុរាណទាំងនោះ។ ជាក់ស្តែងប្រជាសហគមន៍រស់នៅក្នុងឃុំច្រណូកនៃស្រុកកំពង់លែងនៅបន្តធ្វើពិធីបុណ្យថ្វាយភ្នំពណ្ណរាយ នៅរៀងរាល់ថ្ងៃទី១៥កើតខែផល្គុន នៅលើភ្នំពណ្ណរាយដែលមានសំណង់ប្រាសាទពណ្ណរាយនៅលើនោះ[4]។ កិច្ចពិធីនេះមានលំនាំនិងរបៀបស្រដៀងគ្នាដែរចំពោះការបន់ស្រន់នៅប្រាសាទអង្គរវត្តរបស់អ្នកស្រុកតំបន់អង្គរឬអ្នកមកពីទីឆ្ងាយៗដែលតែងតែធ្វើពុំដែលដាច់[5]។ មានពិធីមួយប្រភេទទៀតដែលប្រតិបត្តិនៅតំបន់អង្គរដែរ គឺ«ពិធីសុំទឹកភ្លៀង» ដែលធ្វើនៅប្រាសាទបុរាណដែរ គឺប្រាសាទមេបុណ្យខាងកើត និង ប្រាសាទនាគព័ន្ធ[6]។

ក្រៅពីកិច្ចពិធីបុណ្យ នៅមានរឿងព្រេងនិទានទាក់ទងនឹងភ្នំ ដូចជារឿងពុទ្ធិសែននាងកង្រី ដែលជារឿងល្បីល្បាញជាច្រើនជំនាន់មកហើយក្នុងប្រទេសកម្ពុជា។ ដោយសារមានរឿងព្រេងនិទានបែបនេះ ទើបមានឈ្មោះភ្នំមួយក្នុងស្រុកកំពង់លែង ឈ្មោះថា «ភ្នំកង្រី»។

នៅមានប្រវត្តិភូមិដ្ឋាន អូរ ភ្នំ ព្រមទាំង

[3] ផុន កសិកា, «សំណង់ប្រាសាទក្នុងស្រុកកំពង់លែងនៃដែនដីអាណាចក្រចេនឡា» ផ្សព្វផ្សាយក្នុងគេទំព័រវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម។

[4] កិច្ចសម្ភាសជាមួយលោកតាអាចារ្យ មិិន ហួត និងជាព្រឹទ្ធាចារ្យនៅភូមិឯលិច ឃុំច្រណូក ស្រុកកំពង់លែង នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០២២។

[5] រស់ សុខុម «តារាជនៅប្រាសាទអង្គរវត្ត» អត្ថបទចុះផ្សាយក្នុងគេហទំព័រ បណ្ដាញពត៌មានវប្បធម៌ខ្មែរ។

[6] សោម ច័ន្ទវីរៈ «ពិធីសុំទឹកភ្លៀង» អត្ថបទចុះផ្សាយក្នុងគេហទំព័រ បណ្ដាញពត៌មានវប្បធម៌ខ្មែរ។

ចំណោះជំនាញផ្សេងៗទៀតដែលបន្តនៅមានក្នុងស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។

អត្ថបទខ្លីមួយនេះជាអត្ថបទសម្រង់ព័ត៌មាននិងសិក្សាស្រាវជ្រាវដែលបានមកពីការចុះសិក្សាអង្កេតផ្ទាល់ និងសម្ភាសអ្នកពាក់ព័ន្ធរួមមានចាស់ទុំ ព្រឹទ្ធាចារ្យ ឆ្មាំយាមប្រាសាទ និងអាជ្ញាធរមូលដ្ឋាននៅតាមភូមិ និងឃុំគោលដៅនៅស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង។ អត្ថបទនេះបង្ហាញអំពីរឿងព្រេងនិទានទាក់ទងនឹងភ្នំ ទឹកទន្លេនិងភូមិសាស្ត្រ ប្រវត្តិភូមិ ពិធីបុណ្យផ្សេងៗ ចំណេះដឹងផ្សេងៗដែលបង្ហាញអំពីលក្ខណៈអត្តសញ្ញាណនៃមរតកវប្បធម៌អរូបីដែលបានបន្តរហូតមកដល់បច្ចុប្បន្នរបស់អ្នកស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ប្រទេសកម្ពុជា។

## ១. ភូមិសាស្ត្រនិងប្រជាសាស្ត្រនៅស្រុកកំពង់លែង

ស្រុកកំពង់លែងគឺជាស្រុក១ក្នុងចំណោមស្រុកទាំង៧ ក្នុងខេត្តកំពង់ឆ្នាំង ស្ថិតនៅជាប់ដងទន្លេសាប ភាគខាងជើង ជាតំបន់លិចទឹកនៅរដូវវស្សាក្នុងតំបន់ដែលស្ថិតនៅជិតដងទន្លេ។ ស្រុកនេះមានព្រំប្រទល់ខាងកើតជាប់នឹងស្រុកបារាយណ៍ ខេត្តកំពង់ធំខាងលិចជាប់នឹងស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ខាងជើងជាប់នឹងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ និងខាងត្បូងជាប់នឹងស្រុកជលគិរី និងក្រុងកំពង់ឆ្នាំង[7]។ ស្រុកកំពង់លែងមានឃុំចំនួន៩ដូចជាៈឃុំច្រណូក, ឃុំដារ, ឃុំកំពង់ហៅ, ឃុំផ្លូវទូក, ឃុំពោធិ៍, ឃុំប្រឡាយមាស, ឃុំសំរោង, ឃុំស្វាយរំពារ និងឃុំត្រងិល។ សាលាស្រុក ឬ ទីរាជការស្រុកស្ថិតក្នុងឃុំកំពង់ហៅ[8]។

ប្រជាពលរដ្ឋក្នុងស្រុកកំពង់លែងមានចំនួន៥៦៦៤៩ នាក់ មានផ្ទៃដីសរុប ៩៩៧៦៧ គីឡូម៉ែត្រក្រឡា ក្នុងនោះផ្ទៃដីព្រៃឈើចំនួន៦៦៥១៦ហិកតា ផ្ទៃដីព្រៃលិចទឹក៦១០០៥ហិកតា ផ្ទៃដីដាំដុះចំនួន១៩២៦៣ហិកតា ផ្ទៃដីសាងសង់ចំនួន១២១៨ហិកតា និងផ្ទៃដីផ្សេងៗទៀតចំនួន១២៧៧០ហិកតា[9]។ ចម្ងាយពីស្រុកកំពង់លែងមិនឆ្ងាយពីទីរួមខេត្តកំពង់ឆ្នាំងទេ ក៏

[7] កម្មវិធីវិនិយោគបីឆ្នាំរំកិល២០២២-២០២៣ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង, ទំព័រ IV ឆ្នាំ២០២១។

[8] រាជប្រកាសលេខ១២ ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៣៥ ដែលប្រកាសសំរេចទីរាជការស្រុកកំពង់លែងក្នុងឃុំកំពង់ហៅ។

[9] កម្មវិធីវិនិយោគបីឆ្នាំរំកិល២០២២-២០២៣ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង, ទំព័រ២ ឆ្នាំ២០២១។

ប៉ុន្តែពិបាកធ្វើដំណើរ ដោយសារខណ្ឌផ្តាច់ដោយដៃទន្លេសាបចំនួន៣។ ប្រជាពលរដ្ឋនៅស្រុកនេះភាគច្រើនគឺជាកសិករជិត៩០% ដែលប្រកបមុខរបរកសិកម្មធ្វើស្រូវវស្សាផង និង ស្រូវប្រាំងផង។ នៅមានដំណាំរួមផ្សំមួយចំនួនដែលអ្នកស្រុកកំពង់លែងអាចដាំដុះបានដូចជា៖ បន្លែគ្រប់ប្រភេទ ពោតសណ្តែក ល្ពៅ ដំឡូងមី ដំឡូងជ្វា អំពៅ ស្វាយ ស្វាយចន្ទី[10]។ អ្នកស្រុកកំពង់លែងក៏ចិញ្ចឹមសត្វគោ និង ក្របី ជាច្រើនដែរ។

នៅមានរបរនេសាទដែលអ្នកស្រុកកំពង់លែងអាចរកស៊ីបន្ថែមគ្រាន់ចិញ្ចឹមជីវិតជាពិសេសសម្រាប់ប្រជាពលរដ្ឋដែលរស់នៅជាប់តំបន់លិចទឹកនៅរដូវវស្សា។

ប្រជាពលរដ្ឋនៅស្រុកកំពង់លែងក៏នៅមានចំណេះដឹងធ្វើសម្ភារៈ ប្រើប្រាស់ជាប្រពៃណីដូចជាការត្បាញកន្ទេលកក់ជាដើម ដែលជាមុខរបររួមផ្សំបន្ថែមទៀតក្រៅពីការងារធ្វើស្រែ (រូបលេខ១ និង ២)។ នៅមានមុខរបរផ្សេងទៀត ដូចជា៖ លក់ដូរនៅផ្ទះ កម្មករសំណង់ កម្មករកាត់ដេរ សេវាកម្មផ្សេងៗ ចំណាកស្រុក ជាដើម។




---

10 ឯកសារព័ត៌មានស្តីពី ស្ថានភាពស្រុកកំពង់លែង មន្ទីរផែនការខេត្តកំពង់ឆ្នាំង ២០២១។

ផែនទីស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង



*រូបលេខ១៖ ទិដ្ឋភាពវាលស្រែនារដូវប្រាំង ក្នុងស្រុកកំពង់លែង*



*រូបលេខ២៖ សកម្មភាពប្រូកកាត់ដើមកក់សម្រាប់យកទៅត្បាញកន្ទេលកក់*

## ១. រឿងព្រេង

### ១. ១. រឿងព្រេងទាក់ទងនឹងឈ្មោះភ្នំ

**-ប្រវត្តិភ្នំកង្រើ៖**

មានរឿងព្រេងមួយចំនួនដែលអ្នកស្រុកនៅចងចាំ ហើយអ្នកដែលចាំនោះ ច្រើនជាចាស់ទុំដែលមានអាយុច្រើនចាប់ពី ៥០ឆ្នាំឡើងទៅ។ រឿងព្រេងដែលល្បីល្បាញប្រចាំស្រុកកំពង់លែង ក៏ដូចជាល្បីល្បាញ

នៅ ទូទាំងប្រទេសកម្ពុជា គឺ រឿងឫទ្ធិសែន នាង កង្រី ឬ ពុទ្ធិសែននាងកង្រី។ ដោយសារមានរឿងព្រេងនេះហើយ ទើបមានឈ្មោះភ្នំមួយឈ្មោះថា ភ្នំកង្រី។ ភ្នំកង្រីមួយផ្នែកស្ថិតក្នុងឃុំ ត្រងិល និងមួយផ្នែកទៀតស្ថិតក្នុងឃុំពោធិ៍។ នៅចំណុចមួយដែលភ្នំផតចុះ ជាជ្រលង អ្នកស្រុកហៅចំណុចនេះថា «ច្រកបាក់ដាវ»។ នៅចំណុចច្រកបាក់ដាវ គេសង់មេទឹក ឬ ទំនប់ទឹកមួយដែលមានទឹកដក់នៅក្នុងទំនប់អាចទាញទឹកសម្រាប់ប្រើប្រាស់បាន។ លើសពីការប្រើប្រាស់ទឹក ចំណុចទីតាំងច្រកបាក់ដាវគឺជាទីកន្លែងទាក់ទាញដល់អ្នកស្រុកភូមិមកទស្សនា និងហែលនិងលេងទឹក។

**-ប្រវត្តិភ្នំត្រងិល៖**

មានរឿងព្រេងមួយចំនួនដែលទាក់ទងនឹងឈ្មោះភ្នំដែរដូចជាប្រវត្តិភ្នំត្រងិល។ ភ្នំត្រងិលស្ថិតក្នុងភូមិត្រងិល ឃុំត្រងិល។ ភ្នំនេះមិនសូវមានដើមឈើដុះច្រើនទេ (រូបលេខ២៣)។ តាមរយៈលោកអ៊ំ នៅ គិន ដែលជាចាស់ទុំក្នុងភូមិ បានរៀបរាប់ថា «កាលដើមឡើយ អ្នកស្រុកនៅឃុំត្រងិល ប្រកបរបរត្បាញកន្ទេល ដោយប្រើប្រាស់ត្រល់។ នៅពេលប្រើប្រាស់ត្រល់យូរទៅៗ ត្រល់នោះតែងតែមានការសឹករិចរិលជាបន្តបន្ទាប់។ ដោយមូលហេតុត្រល់នេះរិលនិងសឹករិករិល ទើបអ្នកស្រុកដាក់ឈ្មោះភ្នំនេះថា ភ្នំត្រងិល រហូតដល់សព្វថ្ងៃនេះ[11]។

[11] បទសម្ភាសន៍លោក អ៊ូ គន្ធី ជាមេឃុំត្រងិល និងលោក អែម ហេន អាយុ៧៧ឆ្នាំ ជាប្រធានរដ្ឋបាលឃុំត្រងិល។



*រូបលេខ៣៖ ទិដ្ឋភាពវាលស្រែ ភូមិដ្ឋាន និងភ្នំត្រងិលនៅខាងក្រោយ*

- **ប្រវត្តិភ្នំតាតុំ៖**

ភ្នំតាតុំស្ថិតនៅក្នុងភូមិទំនប់ ឃុំត្រងិល ស្រុកកំពង់លែង។ ប្រវត្តិភ្នំតាតុំមានដូចខាងក្រោម[12]៖ តាតុំគឺជាឈ្មោះហ្មរដំរីម្នាក់។ ហ្មរដំរីមានមុខរបរជាអ្នកលក់គ្រឿងដែកដូចជាកំបិត ពូថៅ ផ្ទៃដីងជាដើម ដោយយកដំរីប្រើជាយាន្តជំនិះសម្រាប់ដឹកយកទៅលក់។ លុះដល់ពេលគាត់ជិះដំរីមកដល់អូរមួយមានជម្រៅទឹកជ្រៅពេក ដំរីមិនព្រមឆ្លងទេ។ ឃើញដូចនេះ តាតុំដែលជាហ្មរ កាប់ដំរីឲ្យដំរីដើរទៅមុខ។ ប៉ុន្តែដោយសារកាប់ខ្លាំងពេក ដំរីស្រែក តែគាត់នៅតែកាប់។ ដំរីក៏ហក់ស្ទុះទៅ ហើយធ្វើឲ្យតាតុំធ្លាក់ពីលើខ្នងដំរីស្លាប់ ហើយក្លាយជាភ្នំតាំតុំទៅ។ និយាយពីប្រពន្ធរបស់គាត់ នៅពេលដែលបាត់ប្តីយូរពេក ប្រពន្ធដែលនៅឯផ្ទះ មិនដឹងថាប្តីបាត់ទៅណា ក៏ដើរមកតាម។ យាយដើរមកតាមក៏ឃើញប្តីស្លាប់ ចំណែកដំរីក៏ស្លាប់ដែរ។ ពេលឃើញបែបនេះ យាយយំសោកសង្វេង ឆ្លងទឹកក៏អត់រួចព្រោះទៅមករាល់ដងបានដំរីជិះឆ្លង ដោយសារទឹកអូរជ្រពេក។ ពេលដែលគាត់យំសោកសង្រេង យាយក៏ស្លាប់នៅទីនោះដែរ រួចក៏កើតចេញជាឈ្មោះអ្នកតាមួយឈ្មោះថា យាយតីសង្រេង។ តាមពិតទៅ យាយតីយំសោកសង្រេង បានដាក់ថាយាយតី សង្រេង (ជាឈ្មោះអ្នកតា)។ ចំពោះអូរលង់គឺដំរីលង់ទឹកស្លាប់នៅក្នុងអូរ។ ចំពោះភ្នំតាតុំក៏នៅជាប់នឹងអូរលង់នេះដែរ។ កាលពីមុន មានស្ពានឈើបុរាណមួយឆ្លងកាត់អូរ ដែលគេហៅឈ្មោះថាស្ពានអូរលង់។

---

[12] *សម្ភាសលោក អោក ហៃ ជាឆ្មាំប្រាសាទប្រចាំនៅស្រុកកំពង់លែង នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២។*

*នៅពេលថ្មីនេះ ស្ពានអូរលង់ត្រូវបានសាងសង់ជាស្ពាន ថ្ម មានទំហំធំ ងាយស្រួលក្នុងការធ្វើចរាចរណ៍ទៅមក (រូបលេខ២)។*



*រូបលេខ២៖ ភ្នំតាតុំ និង ស្ពានសង់ឆ្លងកាត់អូរលង់*

**-ប្រវត្តិភ្នំទូកមាស៖**

*ភ្នំទូកមាសជាជួរភ្នំវែងជាងគេក្នុងស្រុកកំពង់លែង។ ភ្នំនេះក៏មានរឿងព្រេងនិយាយតគ្នាមកថា ពីមុនមកមានអ្នកសច្ចំធ្វើទូកអំពីមាសយកមកប្រណាំងនៅវាលក្រោមច្រណូក នៅក្រោយភ្នំពណ្ណរាយ (រូបលេខ៥)។ ពេលគាត់ត្រឡប់ទៅវិញក៏បាក់ច្រវាហើយគាត់ទុកច្រវាចោលនៅទីនេះ ក្រោយមកមានអ្នករកឃើញថាទូកខូច ហើយយកទូកនោះទៅឱ្យជាងធ្វើ ស្រាប់តែអ្នកស្រុកនាំគ្នាទៅរើសឃើញចំណាំងទូកដែលជាងធ្វើនោះ សុទ្ធតែមាស ទើបដឹងថាទូកនោះជាទូកមាស។ ដូច្នេះក៏ហៅភ្នំនេះថាភ្នំទូកមាសរហូតមក[13]។ នៅតែមានការនិយាយតគ្នាមកដល់សព្វថ្ងៃថា នៅតែមានអ្នកមានសំណាងអាចរើសបានកម្ទេចមាសដែលបានមកពីការធ្វើទូកមាសនេះ។ មានអ្នកបានឡើងដល់កំពូលភ្នំនេះនិយាយថា នៅកំពូលភ្នំទូកមាសនេះ មានស្រះធំទំហំប្រហែលច្រើនហិកតានៅលើនោះ ដែលអាចប្រណាំងទូកបាន[14]។*



*[13] សម្ភាសលោកតា គង់ សុំ អាយុ៧២ ភេទប្រុស រស់ភូមិកំពង់បាចិន ឃុំពោធិ៍។*

*[14] សម្ភាសលោក អោក ហៃ ជាឆ្មាំប្រាសាទប្រចាំនៅស្រុកកំពង់លែង នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០២២។*

*រូបលេខ៥៖ ទិដ្ឋភាពភ្នំទូកមាស មើលពីភ្នំពណ្ណរាយ*

## ១. ២. រឿងព្រេងទាក់ទងនឹងឈ្មោះអូរ

*ដូចនៅក្នុងចំណុច១. ១. ប្រវត្តិឈ្មោះភ្នំ បានលើកឡើងអំពីឈ្មោះភ្នំតាតុំ ដែលក្នុងនោះក៏ពាក់ព័ន្ធនឹងអូរឈ្មោះ «អូរលង់»។ មានរឿងដំណាលថា មានដំរីមកលង់ទឹកស្លាប់នៅក្នុងអូរនេះ ទើបគេហៅថា អូរលង់។*

## ១. ៣. រឿងព្រេងទាក់ទងនឹងឈ្មោះភូមិ

- **ភូមិត្របែក៖**

*គឺដោយសារមានរឿងរ៉ាវនិយាយតៗគ្នាមកថា វាទាក់ទងរឿងនាង១២ នាងកច្រើបោះត្រល់ទៅ ហើយត្រល់នោះក៏ធ្លាក់បែក។ ចឹងហើយទើបគេហៅតគ្នាមកដល់សព្វថ្ងៃនេះ គឺភូមិត្របែក[15]។*

- **ភូមិអណ្តូងរនុក៖**

*មានប្រវត្តិទាក់ទងនឹងភូមិនេះថា កាលពីដើមមានអណ្តូងធំមួយ។ កាលនោះដោយខ្លាចគោក្របីធ្លាក់ចូលអណ្តូង អ្នកស្រុកធ្វើរបងព័ទ្ធជុំវិញ និងធ្វើរនុកឈើគ្របពីលើអណ្តូងនោះ។ ដូច្នេះហើយទើបគេហៅថា «ភូមិអណ្តូងរនុក»[16]។*

## ១. ៤. រឿងព្រេងទាក់ទងនឹងភក្ត្រគណេស

*លោកតា ឱម រ៉ូ និង ហ៊ឹ ហោង ជាប្រជាពលរដ្ឋរស់នៅក្នុងភូមិស្វាយរំពារ ឃុំស្វាយរំពារ បានរៀបរាប់អំពីរឿងព្រេងទាក់ទងនឹងព្រះភក្ត្រគណេស ដូចតទៅ៖*

*កាលពីដើមស្តេចបានឡាយព្រះហស្តឱ្យបុរសម្នាក់ដែលមានមហិទ្ធិឫទ្ធិ ឫទ្ធិអំណាច និងមានភាពវៃឆ្លាត បញ្ជូនឱ្យបុរសនោះទៅរៀននៅក្រុងរ៉ូម ប្រទេសអ៊ីតាលី។ នៅពេលបុរសនោះទៅដាន់ទឹកដីទីក្រុងរ៉ូម ទ្វារយន្ត៧ជាន់ក៏របើក ហើយពួកអ្នកយាមជុំវិញវាំងទីក្រុងរ៉ូមមិនដឹងហេតុអ្វីបានជាទ្វាររបើក។ ពេលនោះស្តេចរ៉ូមក៏ឆ្ងល់ជាខ្លាំង តើហេតុអ្វីបានជាទ្វារវាំង៧ជាន់របើកអស់។ ពេលនោះស្តេចក្រុងរ៉ូមក៏បានទូងស្គរ ដើម្បីប្រមែប្រមូលអស់មន្ត្រីតូចធំ អ្នកស្រុកស្រែចម្ការ មកជួបជុំគ្នា។ នៅពេលនោះស្តេចទីក្រុងរ៉ូមក៏សួរទៅអស់មន្ត្រីទាំងអស់ តើបានឃើញមនុស្សណាមកកន្លែងយើងដែរឬទេ? ម្នាក់ៗឆ្លើយថា ទូលបង្គំមិនដែលជួបមនុស្ស*

---

[15] *បទសម្ភាសអ៊ំប្រុស ស៊ុម សុង រស់នៅភូមិត្របែក ឃុំត្រងិល នៅខែសីហា ឆ្នាំ២០២២។*

[16] *បទសម្ភាសន៍លោកតា ម៉ក់ ឡន ព្រះគ្រូសូត្រស្តាំ វត្តត្របែក ហៅវត្តមានគុណ ស្ថិតក្នុងភូមិត្របែកឃុំត្រងិល។*

ណាម្នាក់នោះទេ។ ស្ដេចរ៉ូមសួរគ្រប់គ្នារួច
អស់ ស្រាប់តែមានមនុស្សម្នាក់ដែលបានមក
ក្រោយគេ។ ស្ដេចក៏សួរទៅបុរសនោះ តើ
មានឃើញមនុស្សណាទេ បុរសនោះក៏ឆ្លើយ
ថា ទូលបង្គំឃើញបុរសម្នាក់។ ស្ដេចក៏បញ្ជា
ឱ្យទៅហៅមនុស្សនោះមក។ ពេលនោះ
ស្ដេចរ៉ូមក៏សួរថា អ្នកឯកមកប្រទេសខ្ញុំ ឯង
ចង់បានអ្វី? ទូលបង្គំមកទីនេះ គឺចង់បានវិជ្
ជា។ ស្ដេចរ៉ូមក៏ឆ្លើយទៅបុរសនោះថា ចង់
បានវិជ្ជាអ្វីទៀត បើគន្លឹះយន្តខ្ញុំ៧ជាន់របើក
អស់ហើយ។ ព្រះអង្គកក្រ្តគណោស ទូល
ថ្វាយស្ដេចរ៉ូមថា ទូលបង្គំនៅខ្វះ។ លឺដូច្នេះ
ស្ដេចរ៉ូមក៏អនុញ្ញាតឱ្យនៅរៀនសូត្រ ហើយ
ប្រវត្តិចាក់សាក់ក៏មានរហូតដល់សព្វថ្ងៃ
នេះ។ នៅរៀនយូរទៅស្ដេចក៏ចាក់សាក់ឱ្យ។
សូមបញ្ជាក់ផងដែរ ព្រះអង្គកក្រ្តគណោស
បានរៀបការរួចហើយមុននឹងបញ្ជូនឱ្យទៅ
រៀននៅក្រុងរ៉ូម។ រយះពេលក្រោយមក ព្រះ
អង្គកក្រ្តគណោសឃើញមានទឹកមុខស្រងូត
ស្រងាត់ ស្ដេចរ៉ូមមានការសង្ស័យហេតុអី
មានទឹកមុខស្ងួត ស្ដេចរ៉ូមក៏សួរកក្រ្តគណោស
មានរឿងអី? កក្រ្តគណោសឆ្លើយតបស្ដេចរ៉ូម
ថា ទូលបង្គំនឹកប្រពន្ធនៅស្រុកខ្មែរ រៀបការ
រួចបានបីខែ ស្ដេចចាត់ឱ្យមករៀននៅទីនេះ
ទូលបង្គំនឹកប្រពន្ធនៅឯណោះ។ ស្ដេចរ៉ូមក៏
ប្រាប់កក្រ្តគណោសវិញថា បើចឹងមិនអីទេ ខ្ញុំ
មានកូនស្រីពៅមួយ ខ្ញុំនឹងរៀបអភិសេកកូន
ស្រីជូន។ ក្រោយរៀបអភិសេករួចហើយ

បានរយះពេលបីបួនខែ ព្រះអង្គកក្រ្ត
គណោសនៅតែនឹកប្រពន្ធនៅស្រុកខ្មែរមិន
អាចបំភ្លេចបាន ដោយសារនឹកប្រពន្ធនៅ
ស្រុកខ្មែរខ្លាំងពេកក៏លួចរត់មកស្រុកខ្មែរវិញ។
ពេលលួចរត់មកវិញ អ្នកយាមនៅតាមទ្វារ
យន្ត ដេកលក់អស់រលីង។ ទ្វារយន្តរបើកឯង
តែម្តងក៏ផ្អើលដឹងយល់ស្ដេច។ ស្ដេចក៏ភ្ញាក់
ព្រើតទ្វារយន្តរបើកអស់ ហើយម៉េចចឹងពួក
អ្នកយាមទៅណាអស់ហើយ។ ស្ដេចរ៉ូមក៏ដើរ
មើល គ្មានពីណាងើបទេ ដេកលក់អស់ ក៏នាំ
គ្នាផ្អើល។ ពេលនោះក៏មានការសង្ស័យក៏
ចូលទៅមើលបន្ទប់កូន បាត់បុរសម្នាក់នោះ
បុរសចេញទៅ ទើបបានជាទ្វារយន្តរបើក
ដូចនេះ ក្នុងពេលដែលអ្នកយាមកំពុងដេក
លក់អស់។ ពេលនោះស្ដេច រ៉ូមក៏បញ្ជូនហិប
យន្តដ៏អស្ចារ្យឱ្យមកកាត់ក្បាល ដោយហិប
យន្តនោះពូកែខ្លាំងណាស់ក៏ជួបនឹងព្រះអង្គ
កក្រ្តគណោស ដូចបំណងនៅជិតមាត់ទឹក
ដែលជំនាន់នោះជាមាត់សមុទ្រ ក៏កាត់
ក្បាលយកទៅក្រុងរ៉ូមវិញ ដោយទុកខ្លួនឱ្យ
ដេកស្តូកស្តឹងនៅទីនោះ។ ព្រះអង្គកក្រ្ត
គណោសបានរៀបការរួចហើយមុននឹងស្ដេច
បញ្ជូនទៅរៀននៅក្រុងរ៉ូម និងមានកូនជំដឹង
ក្តីតែមិនដឹងឆ្នាំអីនោះទេ។ កូនក៏សួរទៅម្តា
យថា «ម៉ែ! ចុះឪខ្ញុំនៅឯណា? គេមានឪហៅ
ម៉េចខ្ញុំអត់ចឹង?»។ ម្តាយព្យាយាមមិនប្រាប់
ទេ ប៉ុន្តែថ្ងៃក្រោយសួរទៀត សួររហូតដល់ម្តា
យទ្រាំលែងបានក៏ប្រាប់ទៅកូនថា ពុកកូន

ឯងស្ដេចចាត់ឱ្យទៅនៅប្រទេស រ៉ូម យូរហើយ។ ដោយកូននឹកពុកជាខ្លាំងពេក ក៏សុំម្ដាយទៅរកពុក។ ម្ដាយក៏ពោលពាក្យប្រាប់ទៅកូនថា ណាខ្លា ណាដំរី សត្វសាហាវច្រើនណាស់ កូនឯងទៅប្រយ័ត្នមានគ្រោះថ្នាក់ សូមកូនកុំទៅអី។ ម្ដងហើយម្ដងទៀត កូននៅតែទទូចសុំម្ដាយម្ដង ពីរដង រហូតដល់បីដងក៏មិនបានដែរ។ ពេលនោះកូនក៏សម្រេចចិត្តសុំលាម៉ែទៅមែន ដើម្បីតាមរកឪពុក ទោះបីម៉ែឃាត់យ៉ាងណាក៏ដោយ ព្រោះមានការនឹករលឹកពុកខ្លាំងណាស់។ ជាថៃជន្យអីកូនក៏ដូចជាដឹងដែរ ចេះតែធ្វើដំណើរទៅ លិចអណ្ដែត កាត់វាលចូលព្រៃ ក៏ទៅដល់មាត់ទឹក ក៏ឃើញបុរសម្នាក់អត់ក្បាល។ កូនចេះតែឆ្ងល់ ហេតុអ្វីបានជាបាត់ក្បាលទៅណា? ប៉ុន្តែសាច់នៅស្រស់ ក៏មានការសង្ស័យ ក៏ចយដូចយើងធ្វើធម៌ ប្រហែលជាប្រាំពីរ ប្រាំបីដំហាន ថយចាំមើលគ្រប់៧ថ្ងៃ បើសិនជារូបនឹងស្លាប់សាច់មិននៅស្រស់ទេ។ ដល់ពេលគ្រប់៧ថ្ងៃក៏មកស្ទាបមើលម្តងទៀតសាច់នៅតែស្រស់ញញឹមដដែល។ ពេលនោះក៏បើកខោអាវមើល ពេលបើកខោអាវមើលក៏ឃើញអក្សរគេសាក់ថា «**បើចង់តក្បាល គឺយកក្បាលដំរីមកបន្ទុប គឺរស់ឡើងវិញ**» នេះសុទ្ធតែយ័ន្ត គេសាក់ស្រេចនៅលើរូប។ ពេលនោះកូនក៏យកកក់មកពូតធ្វើជាក្បាលដំរី បន្ទុបរស់ឡើងវិញ។ ស្រាប់តែមានសត្វដំរីមកចុះប្រេងនៅទីនោះ ហើយដំរីស្រែករោត្រហឹងអ៊ឹងកងនៅទីនោះ មកស្រែរ៉ូងរាំងនៅទីនោះដែរ ពេលនោះក៏ទៅកាត់ក្បាលដំរីមកបន្ទុបក្បាលឪពុក។ ពេលបន្ទុបរួច ឪពុកក៏រស់ឡើងវិញ។ ពេលនោះនឹកឃើញមួយទៀត ទៅពូតភក់ ពូតដាក់ឱ្យក្បាលដំរីដែលកាត់នោះ។ ពេលដាក់បន្ទុបដីភក់រួចស្រេច ស្រាប់តែដំរីនោះស្រែករ៉ូងរស់វិញទាំងអស់ ហើយក៏នាំឪពុកចូលវាំង។ ពេលទៅដល់វាំង ក៏ផ្អើលដង្ហែរពេញវាំងទាំងអស់គ្នា។ មានរឿងរ៉ាវបែបនេះហើយ ទើបដង្ហែរព្រះអង្គកគ្រូគណេសរហូតដល់បច្ចុប្បន្ននេះ ហើយក៏មានធ្វើរូបព្រះអង្គកគ្រូគណេសនៅលើភ្នំសព្វថ្ងៃនេះ។ ព្រះអង្គកគ្រូគណេសមានបារមីពូកែសក្តិសិទ្ធិណាស់។ កាលជំនាន់មុន បើមានមនុស្សទៅឈរនៅមុខរូបសំណាកព្រះអង្គ នឹងលើកមកដាក់ថ្នាក់ក្រោមវិញដោយមិនដឹងខ្លួននោះទេ ប៉ុន្តែមិនឱ្យស្លាប់នោះទេ។

បច្ចុប្បន្ននេះ កគ្រូគណេសគឺជាបដិមាធ្វើពីស៊ីម៉ង់ ដែលគេយកទៅតម្កល់នៅភ្នំទូកមាស ត្រង់ចម្រេះភ្នំ ស្ថិតនៅទីតាំងភូមិថ្នល់ ឃុំដា ស្រុកកំពង់លែង (រូបលេខ៦និង៧)។



រូបលេខ២៦៖ បដិមាព្រះកក្រ្កគណេសធ្វើពីថ្ម នៅចម្រេះភ្នំ



រូបលេខ២៧៖ ទីតាំងចម្រេះភ្នំដែលតម្កល់បដិមាព្រះកក្រ្កគណេស

### ១. ៥. រឿងព្រេងទាក់ទងនឹងប្រាសាទសក្ក (ប្រាសាទប្រុស)

ប្រវត្តិប្រាសាទសក្វ[17] តាមការនិយាយតៗ គ្នា ប្រាសាទសក្វនេះ គឺទាក់ទងនឹងរឿងនិទានស្រីដណ្ដឹងប្រុស។ ពេលនោះ បុរសនិងស្ត្រី ធ្វើការភ្នាល់គ្នា។ កាលពីអតីតកាលស្រីដណ្ដឹងប្រុស ដូចនេះ ដើម្បីបំបាត់ ការស្ដីដណ្ដឹងប្រុស ស្ត្រីក៏ចាប់ផ្ដើមធ្វើការភ្នាល់គ្នាជាមួយបុរសដោយការសាងសង់ធ្វើប្រាសាទ ហើយចាប់ផ្ដើមនៅកន្លែងផ្សេងគ្នា ដោយភាគីទាំងពីរសន្យាជាមួយគ្នាពេលឃើញបង្ហោះភ្លើងគោមប្រាសាទនឹងសង់រួច។ ពេលចាប់ផ្តើមធ្វើ បុរសយល់ឃើញថា ស្ត្រីជាអ្នកទន់ខ្សោយជាង ភាគីខាងបុរសធ្វើប្រាសាទសក្វធ្វើទៅមិនសូវខិតខំធ្វើ គឺបបួលគ្នាតែផឹកស៊ី។ បុរសមិនសូវចាប់អារម្មណ៍កិច្ចការដែលត្រូវនោះទេ ពេលយប់គាត់ផ្ដុំគ្នាផឹក អាងមនុស្សស្រីមានកម្លាំងទន់ខ្សោយ មើលស្រាលស្ត្រី។ ចំណែកស្ត្រីមានល្បិច មានភាពវៃឆ្លាត មានប្រាជ្ញា ពួកគេក៏បបួលគ្នារកវិធីធ្វើយ៉ាងណាដើម្បីទទួលបានជោគជ័យ ពេលនោះស្ត្រីក៏បង្ហោះភ្លើងគោម។ បើសិនជាផ្កាយព្រឹករះពីទិសខាងកើត ប្រាសាទនឹងសង់រួច។ ការពិតស្ត្រីសង់ប្រាសាទមិនទាន់រួចទេ តែគាត់បង្ហោះគោម ដើម្បីបញ្ឆោតថាពួកគាត់សង់ប្រាសាទរួចហើយ។ បុរសសក្វៗ[18] ឃើញ

[17] សម្ភាសលោក ប៉ាត សុវណ្ណ គឺជាគណៈកម្មការអាចារ្យវត្តថ្មកង្កែប រស់នៅភូមិកង្កែប ឃុំស្រណូក នៅខែសីហា ឆ្នាំ២០២២។

[18] សក្វមានន័យថា មនុស្សផឹកស៊ី ភាពមិនយកចិត្តទុកដាក់ ក្នុងកិច្ចការងារ ការងារមិនច្បាស់លាស់ ការងារមិនប្រុងប្រយត្ន ធ្វើឱ្យតែរួចពីដៃ។ សក្វ៖ គឺជាពាក្យរបស់អ្នកភូមិកង្កែប «ពាក្យមើលងាយ បន្ទប់បន្ទោស ចំពោះពីណាម្នាក់» ប្រើសំដៅអ្នកធ្វើការអ្វីមួយដោយគ្មានការប្រុងប្រយត្ន គិតតែផឹកស៊ី មិនយកចិត្តទុកដាក់ចំពោះការងារខ្ជីខ្ជា មិនមានភាពម៉ត់ចត់ គឺធ្វើការងារអ្វីមួយឱ្យតែរួចពីដៃ។ អ្នកស្រុកប្រើពាក្យសក្វនេះចំពោះអ្នកណាដែលធ្វើអ្វីមួយមិនសមរម្យជាដើម។ ឧ. អានេះ សក្វដល់ហើយ ឯងសក្វដល់ហើយវើយ។

ផ្កាយព្រឹក រៈគិតថាស្រ្តីក៏រួច ក៏ឈប់សង់។ ចំណែក ស្ត្រីនៅតែសង់រហូតប្រាសាទសង់រួច។ ដូចនេះប្រាសាទនេះឈ្មោះថាប្រាសាទសក្ក។

## ១.៦. ប្រវត្តិទាក់ទងនឹងឈ្មោះបឹង

ប្រវត្តិបឹងកាប់គង់ ឬ កប់គង់ និយាយតគ្នាថា កាលពីសម័យដើម កងទ័ពមិនប្រើកាំភ្លើងទេ គឺប្រើកាំបិត ពូថៅ។ ពេលដែលកាប់ទៅមិនត្រូវមនុស្ស បែរជាត្រូវគងទៅវិញ ដូច្នេះហើយទើបគេហៅកាប់គង់។ រឿងមួយទៀត ទាក់ទងនឹងកាប់គង់ បឹងសម័យពីដើម គេជីកគាស់រំលើងយកដីធ្វើឥដ្ឋប្រាសាទ ពេលជីកដីក៏ជួបប្រទះឃើញគង់នៅទីនោះ ក៏ហៅថា បឹងកប់គង់[19]។

## ១. ៧. ប្រវត្តិទាក់ទងនឹងកង្កែប[20]

ទាក់ទងរឿងកង្កែប[21] ដែលកាលដើមឡើយសុទ្ធតែព្រៃភ្នំ ហើយមានកុលសម្ព័ន្ធដែលរស់នៅជាក្រុម និងមានអ្នកង៉ារ គឺជាអ្នកឃ្វាលដំរីរបស់ស្ដេច។ សំឡេងភាសានិយាយមិនត្រូវតាមសំឡេងអក្សរនោះទេ ឧទាហរណ៍ «ដើង» និយាយថា «ឈើង»។ អ្នកង៉ារនោះមានបុរសស្ត្រីបីរូបបានចេញមកទាក់ដំរី ក្នុងសម័យកាលយសោធបុរៈ។ សម័យបុរេ គឺមិនទាន់មានឧបករណ៍ប្រើប្រាស់ ដូចជា កាំបិត ពូថៅនៅឡើយ។ ហើយសម័យនោះមានអ្នកង៉ារបីរូបបានស្នាក់ នៅទីនេះដោយបង្កើតបានជាកុលសម្ព័ន្ធមួយ ទី១ ឈ្មោះ សំបុទ្ធិ ទី២ឈ្មោះ ឯក ទី៣ ឈ្មោះ ហួត និងស្ត្រីឈ្មោះ មាស។ អ្នកទាំង៤នាក់បានមករស់នៅលើទឹកដីកង្កែបនេះ ចង់សិក្សាវិជ្ជាគុណ។ វិជ្ជាគុណ គឺត្រូវការដើម្បីឱ្យស្បែកស្វិត។ គិតម៉េចដើម្បីឱ្យក្លាយជាមេកន្រ្ទាញដ៏ធំ ដើម្បីកាន់កាប់ទឹកដីនៅទីនេះ ដូចនេះត្រូវការកាប់ដើមឈើធំមកធ្វើជាស្នូកត្រាំខ្លួន ដើម្បីឱ្យខ្លួនខ្លាំងពូកែមានឫទ្ធិបារមី ឈ្នះអស់សត្រូវទាំងឡាយទាំងពួងគ្រប់ទិសទាំង៤។ ដូចនេះសំបុទ្ធិ គិតឃើញថា ដើម្បីឱ្យខ្លួនខ្លាំងពូកែត្រូវត្រាំខ្លួនដោយដឹងខ្លួនឯងខ្លាំងពូកែ ក៏ធ្វើការសាកល្បង ដូចបំណងដែលខ្លួនបានត្រាំនោះទេ។

ពាក្យនេះអ្នកស្រុកស្រណ្ណូកប្រើរហូតដល់សព្វថ្ងៃនេះផងដែរ សម្រាប់ប្រើពាក្យមិនសមរម្យ។

[19] សម្ភាសលោក ប៉ាត សុវណ្ណ គឺជាគណៈកម្មការអាចារ្យវត្តថ្មកង្កែប រស់នៅភូមិកង្កែប ឃុំស្រណ្ណូក នៅខែសីហា ឆ្នាំ២០២២។

[20] មានភូមិមួយឈ្មោះ «ភូមិកង្កែប» ស្ថិតក្នុងឃុំច្រណ្ណូក និងមានភ្នំមួយឈ្មោះភ្នំកង្កែប ដែលមានទីតាំងស្ថិតនៅខាងត្បូងប្រាសាទសក្ក (ប្រាសាទប្រុស)។

[21] សម្ភាសលោក ប៉ាត សុវណ្ណ គឺជាគណៈកម្មការអាចារ្យវត្តថ្មកង្កែប រស់នៅភូមិកង្កែប ឃុំស្រណ្ណូក នៅខែសីហា ឆ្នាំ២០២២។

មានវត្ថុសក្តិសិទ្ធិពីរ គឺកង្កែប និងហ៊ីង។ កង្កែបខ្លាំងពូកែខាងបារ៉ែត។ ដើម្បីឱ្យខ្លួនខ្លាំងពូកែ ក៏បង្កើតកុលសម្ព័ន្ធគ្រប់គ្រងទាំងបីទិស។ ឫទ្ធិនេះមានឫទ្ធិខ្លាំងពូកែណាស់ មិត្តទាំងនោះមានចាម ជ្វា។ បើសិនមិនយកវត្ថុសក្តិសិទ្ធពីនេះមិនបានទេ សេចក្តីស្លាប់នឹងកើតមានជាបន្តបន្ទាប់។ គេរកគ្រូដែលខ្លាំងពូកែជាងនេះទៀត គឺមេកាធាយ[22] (ជាគ្រូរបស់កង្កែប)។ ជាធម្មតាបារ៉ែតនៅទីណាក៏ដោយ ទាំងក្នុងដី និងក្រោមដី គេប្រើមេកាធាយដើម្បីដេញបារ៉ែត។ មេកាធាយ បុរាណហៅថា មេសុទ្ធ ដូចសត្វឃ្មុំធំ។ ចាស់ៗបុរាណនិយាយតគ្នាថា មេកាធាយស៊ីមាស និងស៊ីបារ៉ែត។ តាដំបងប្រាំអាចឈ្នះមេកាធាយបានឱ្យក្លាយជាវត្ថុសក្តិសិទ្ធ។ ដើម្បីខ្លាំងពូកែត្រូវតែចិញ្ចឹមមេកាធាយ (មេកាធយ)។ ពេលព្រះចន្ទពេញវង្ស ចំថ្ងៃអង្គារ មេកាធាយនឹងអស់ ឫទ្ធិ។ តាមការទស្សទាយនៅវេលាថ្ងៃស៊ុយ ថ្ងៃហេង វេលាជោគជ័យ បរាជ័យ គេអាចទាយថា នៅថ្ងៃខែកត្តិក ថ្ងៃពេញបូរមី ត្រូវនឹងថ្ងៃអង្គារ នោះគេអាចដេញមេកាធាយចុះមកបាន។

**១. ៨. ច្រកបាក់ដាវនៃភ្នំកង្រី**

ច្រកបាក់ដាវគឺជាទីតាំងជ្រលងភ្នំនាងកង្រី ដែលមានរឿងដំណាលថា តេជោយ៉តបានកាប់ដាវរបស់ស្តេចសម្រេចឲ្យបាក់នៅទីនេះទើបហៅថា «ច្រកបាក់ដាវ»។ នៅទីតាំងនេះ គេបានសង់មេទឹកធំមួយ (ទំនប់ទឹក) ស្តាត់ទឹកសម្រាប់ប្រើប្រាស់ (រូបលេខ២៨)។



រូបលេខ២៨៖ ទីតាំងច្រកបាក់ដាវ

**១.៨. ប្រវត្តិឈ្មោះស្រុកកំពង់លែង**

គេហៅស្រុកកំពង់លែង ដោយសារពីបុរាណមក ចាស់ៗនិយាយក្នុងរឿងនិទាន (នាងកង្រី)ថា កាលពីដើមភូមិកំពង់បឹងគឺមានបឹង ក្រោយមកហៅថាស្រុកកំពង់លែងវិញដោយសារទាក់ទងនឹងរឿងឫទ្ធិសែននាងកង្រីពេលលែងគ្នានៅទីនេះ គឺពេលដែលឫទ្ធិសែនយកកែវភ្នែកនាង១២ ជិះសេះទៅលែងមក ហើយលែងយកមកវិញ ព្រោះនាងក្លាយជាភ្នំទៅហើយ[23]។

22 សរសេរតាមការអាន។

23 សម្ភាសលោកតា អ៊ុយ ពូន ជាអាចារ្យវត្តកក្តី រស់នៅក្នុងភូមិសំរោង ឃុំពោធិ៍ នៅខែសីហា ឆ្នាំ២០២២។

### ១. ៩. ប្រវត្តិឃុំកំពង់ហៅ

កំពង់ហៅគឺជាឈ្មោះឃុំមួយក្នុងចំណោមឃុំទាំង៩នៃស្រុកកំពង់លែង។ មានកំពង់មួយធំស្ថិតនៅមុខសាលាស្រុកកំពង់លែង។ នៅរដូវវស្សាទូកដរ និងទូកចម្លងផ្សេងៗមកចតនៅកំពង់នេះ។ គេហៅថា «កំពង់ហៅ» ដោយសារទាក់ទងនឹងរឿងព្រេងឫទ្ធិសែននាងកង្រី នៅត្រង់ឈុតដែលនាងកង្រីបក់ដៃហៅឫទ្ធិសែនឲ្យត្រឡប់មកវិញ គឺនាងកង្រីឈរបក់ដៃនៅកំពង់នេះ។

## ២. កិច្ចពិធីបុណ្យផ្សេងៗ

### ២.១.បុណ្យអស្សាឍថ្វាយភ្នំពណ្ណរាយ

ជារៀងរាល់ឆ្នាំនៅថ្ងៃ១៥កើត ខែផល្គុន ប្រជាពលរដ្ឋនៅភូមិឯលិច និងភូមិកណ្ដាល ក្នុងឃុំច្រណូក ស្រុកកំពង់លែង បានប្រារព្ធពិធីបុណ្យឡើងភ្នំពណ្ណរាយ ដើម្បីធ្វើកិច្ចបូជាថ្វាយលោកតាសូរ និងនាងពណ្ណរាយដែលគង់នៅភ្នំនេះ។ កិច្ចពិធីនេះគេមិនធ្វើតែនៅលើភ្នំពណ្ណរាយតែមួយកន្លែងនោះទេ គឺនៅមានបីកន្លែងទៀតគេធ្វើជាបន្តបន្ទាប់គ្នា។ នៅលើភ្នំពណ្ណរាយ គេធ្វើ២យប់២ថ្ងៃ, លោកតាស្មៀន (តាយាមទ្វារ) ឬដំណាក់ដើមពោធិ (១យប់១ថ្ងៃ), លោកយាយសស្តើង (១យប់១ថ្ងៃ), ត្រង់កន្លែងវត្តឈ្មោះបារមីស្រីខ្មៅសារាយអណ្ដែត (១យប់១ថ្ងៃ) ដូច្នេះ សរុបកម្មវិធីបុណ្យមានចំនួន៥យប់៥ថ្ងៃ។ នៅខាងក្រោយប្រាសាទមានពេងអ្នកតាឈ្មោះតាសូរ ដែលអ្នកស្រុកជឿថាជាគូនិងអ្នកនាងពណ្ណរាយ។

#### ក. គ្រឿងរណ្ដាប់ ឬ ដង្វាយ

ដង្វាយ មានបាយសី៥ថ្នាក់(១គូ) បាយសី៣ថ្នាក់(១គូរ) ទៀន៥ធូប៥ ចំនួន១កន្លែង(មួយថាស) ប្រដាប់សំណែនមានក្បាលជ្រូក(១) មាន់ស្ងោរ(១គូ) ចេក(១គូ) មានក្រាស កញ្ចក់ ទឹកអប់ ប្រេងម្សៅ (រូបលេខ៩)។ នៅមានគ្រឿងរណ្ដាប់រៀបចំសែនក្នុងតួប្រាសាទមួយកន្លែងទៀត ដែលមានស្លាធម៌ដូច ផ្កាឈូក ទានធូប។ សូមជម្រាបថា គ្រឿងរណ្ដាប់គេរៀបនៅលើភ្នំពណ្ណរាយកន្លែងផ្សេងទៀត គ្រាន់តែសែនព្រេនក្វេងធម្មតាទេ (រូបលេខ១០)។



រូបលេខ៩៖ គ្រឿងរណ្ដាប់សែនក្នុងខ្ទមអ្នកតា



រូបលេខ១០៖ គ្រឿងរណ្ដាប់រៀបចំសែននៅក្នុងតួប្រាសាទ

#### ខ. រូបសួង

អ្នកស្នងរូបពីរអ្នកតាពីដើមជាមនុស្ស ប្រុសទេ ប៉ុន្តែគាត់បានស្លាប់ទៅ ហើយ បច្ចុប្បន្នជាស្រីដែលមកស្នងរូបបន្ត ឈ្មោះ លោកយាយ **ស កែន** មានអាយុ៨០ឆ្នាំហើយ។ ចូលរូបមានគ្រប់ទីតាំងទាំងបួន។ ចំណែក របាំទូងស្គរ គេលេងតែពីរកន្លែងទេ គឺលើភ្នំ ពណ្ណរាយ ២យប់ និងថ្វាយបារមីវត្ត១យប់។ កិច្ចលើទីតាំងចុងក្រោយ កន្លែងវត្តឯលិច គេ លេងភ្លេងថ្វាយបារមីវត្តរួច ក៏មានរៀបចំ ចង្ហាន់ប្រគេនព្រះសង្ឃដែរ។

**គ. ភ្លេង និង ចម្រៀង**

អ្នករាំ និងលេងភ្លេង សរុបមាន ប្រមាណ៣០នាក់ សុទ្ធតែជាអ្នកភូមិស្រុក នៅម្ដុំនេះ (ជាអ្នកភូមិឯលិច និងភូមិកណ្ដាល) ដែលបានចេះតៗមក។ ឧបករណ៍ភ្លេង មាន៖ គង់(២) ស្គរធំ(១) ទ្រ(១) ស្គរដៃ(៣) អ្នកច្រៀង២(ប្រុសទាំងពីរ) (រូបលេខ១១និង ១២)។ បទចំរៀងដែលយកមកច្រៀង និង លេងថ្វាយ មានបទស្ដេចយាង បទស្ដេចផ្ទុំ បទដំនោរ បទឈឺតមន(ដើតមន) និងបទអុំទូក។ ចំណែកទំនុកច្រៀង គឺអ្នកច្រៀងតាម នឹកឃើញ អង្វករឬអន្ទងតាមកាលទេស។



រូបលេខ១១៖ ឧបករណ៍ភ្លេងសម្រាប់លេងថ្វាយ



រូបលេខ១២៖ ទ្រ និង ស្គរដៃ

**ឃ. កិច្ចពិធី**

នៅវេលាប្រហែលជាម៉ោង៣ទៅ ម៉ោង៣កន្លះ រសៀល អាចារ្យគណកម្មការ អ្នកស្នងរូប អ្នកភ្លេង អ្នកច្រៀង អ្នករាំ រួម ទាំងអ្នកភូមិមានចាស់ក្មេង បានជួបជុំគ្នា ឡើងទៅលើភ្នំពណ្ណរាយ ដើម្បីចាប់ផ្ដើម រៀបចំកិច្ចពិធី។ ជាដំបូងគេយកគ្រឿង រណ្ដាប់ និងដង្វាយរៀបនៅក្នុងរោងអ្នកតា រួចដុតទៀនធូបក្រាបសំពះបួងសួងគ្រប់ៗគ្នា។ អ្នកស្នងរូបអ្នកតា ចាប់ផ្ដើមរៀបចំខ្លួន និងគ្រឿងរណ្ដាប់ដែលបានដាក់មកតាមខ្លួន ជាស្រេច ដែលឃើញមានជើងពានបីថ្នាក់ ធ្វើអំពីស្លាន់ ទឹកអប់ប្រេងម្សៅ ម្លូរស្លា អង្គុយ នៅចំហៀងបន្តិចលើកន្ទេល។ មានអ្នករាំ ឈរតំរៀបគ្នារាងកោងនៅខាងក្រោយរូប ស្នង ក្នុងសំលៀកបំពាក់សមរម្យដោយមាន បង់កក្រមាទម្លាក់មកខាងមុខដូចៗគ្នា (រូប លេខ១៣)។



រូបលេខ១៣៖ លោកតាអាចារ្យសូត្រមុននឹងចាប់ផ្តើមកម្មវិធី

មុននឹងភ្លេងចាប់ផ្តើមប្រគំ អាចារ្យបានសូត្រហៅ និងអញ្ជើញអ្នកតាសូរ នាងពណ្ណរាយ និងម្ចាស់ទឹកម្ចាស់ដីមកចូលរួមទទួលដង្វាយ ហើយសូមសេចក្តីសុខចម្រើនសម្រាប់ឆ្នាំក្រោយបន្តទៀត។ បើតាមពាក្យពេចន៍របស់លោកអាចារ្យបួងសួង កិច្ចនេះគេធ្វើឱ្យអ្នកតា និងនាងពណ្ណរាយដែលបានជួយពួកគាត់រួចពីសេចក្តីទុក្ខកង្វល់មក។ ឧទាហរណ៍ថា ជួយបានសម្រេចទើបធ្វើពិធីសងគុណ។

នៅពេលដែលប្រគំភ្លេងទូងស្គរឡើង អ្នកច្រៀងចាប់ផ្តើមច្រៀង អ្នករាំទះដៃតាមចង្វាក់ព្រមៗគ្នា។ បទភ្លេងនិងទំនុកដូរចុះដូរឡើង ដើម្បីអន្ទង (រូបលេខ១៤និង១៥)។ ក្នុងកិច្ចនេះ ក្រៅពីលោកយាយ **ស កែន** ជារូបស្នង ក៏ឃើញមានចូលមនុស្សស្រីម្នាក់ទៀតដែរ។ ពេលរូបចូល រូបបានយកប្រេងម្សៅដើរលាបឱ្យអ្នកនៅជិតៗនោះ ជាពិសេសស្ត្រីអ្នករាំគាត់លាបម្សៅឱ្យគ្រប់ៗគ្នា។



រូបលេខ១៤៖ ភ្លេងប្រគំ អ្នកចម្រៀងចាប់ផ្តើមច្រៀង



រូបលេខ១៥៖ អ្នកចម្រៀងនិងអ្នកចូលរូបម្នាក់

ពិធីនេះគេធ្វើដល់ម៉ោង៥ល្ងាចទើបចប់សព្វគ្រប់ រួចនាំគ្នាចុះមកវិញ ហើយគេនៅបន្តជួបជុំគ្នានៅក្បែរជើងភ្នំពណ្ណរាយរហូតដល់យប់ ហើយមានរបាំទូងស្គររាំកំសាន្តសប្បាយផង(រូបលេខ១៦)។



រូបលេខ១៦៖ ទិដ្ឋភាពអ្នករៀបចំពិធីបុណ្យជួបជុំគ្នានៅពេងក្បែរជើងភ្នំពណ្ណរាយ

## ២. ២. ពិធីបុណ្យលោកតាត្រក

អ្នកតាត្រកស្ថិតនៅក្នុងភូមិល្វា ឃុំស្វាយរំពារ ស្រុកកំពង់លែង។ អ្នកស្រុកមានជំនឿលើលោកតាត្រក ទើបមានពិធីបុណ្យឡើងអ្នកតាត្រកជារៀងរាល់ឆ្នាំ។ កិច្ចពិធីបុណ្យមិនត្រូវកំណត់យកថ្ងៃណាទេ ប៉ុន្តែអ្នកស្រុកច្រើនប្រារព្ធនៅខែពិសាខ (ក្នុងខែឧសភា) បន្ទាប់ពីពួកគាត់ប្រមូលផលស្រូវប្រាំងរួចរាល់[24]។

មានរឿងតំណាលតៗគ្នាថា កាលពីមុននោះ ក្នុងឃុំស្វាយរំពារ មានលោកតា៣អង្គ គឺលោកតាត្រក លោកតាបាត់ដាន និងលោកតាក្រញ៉ូង (ដំបងក្រញ៉ូង) គឺជាអ្នកការពារភូមិស្រុក ពិសេសការពារអ្នករស់នៅក្នុងឃុំស្វាយរំពារ។ លោកតាបាត់ដានគឺជាអ្នកគន់គូរ ទស្សទាយ។ ពេលមានសឹកសង្គ្រាម និងសត្រូវចូលវាយលុកនៅពេលណា នៅទីតាំងណា ព្រមទាំងជួយគន់គូរមើលថា ត្រូវធ្វើវាយប្រយុទ្ធនៅទីណា កន្លែងណាទើបជោគជ័យ។ ចំណែក លោកតាដំបងក្រញ៉ូងវិញ ពេលជួបសត្រូវគឺលោកតាជាអ្នកវាយប្រយុទ្ធ កាប់ចាក់សត្រូវ។ រីឯលោកតាបាត់ដានវិញ បង្វែងដានសត្រូវ មិនឱ្យដើរចូលភូមិស្រុកបានឡើយ។

ចំពោះការគោរពបូជារបស់អ្នកភូមិល្វា មិនបានធ្វើកិច្ចគោរពបូជាដល់លោកតាទាំងបីនេះទេ ពួកគាត់គោរពតែលោកតាត្រកប៉ុណ្ណោះ។ យើងក៏មិនបានដឹងអំពីមូលហេតុនៃការមិនធ្វើកិច្ចគោរពដល់លោកតា២ទៀតដែរ (លោកតាបាត់ដាន និង លោកតាដំបងក្រញ៉ូង) ប៉ុន្តែអ្នកស្រុកនៅចងចាំប្រវត្តិរឿងលោកតាទាំងបីនេះ ដូចបានរៀបរាប់រួចមកហើយ។

ចំពោះមហិទ្ធិឫទ្ធិរបស់លោកតាត្រកវិញ អ្នកស្រុកមានជំនឿថា ពេលណាបាត់គោក្របី អ្នកស្រុកទៅបន់ស្រន់ នោះគេនឹងរកឃើញគោក្របីនោះ។

## ៣. មុខរបរសិប្បកម្មជាប្រពៃណី

អ្នកស្រុកកំពង់លែងភាគច្រើនចេះត្បាញកន្ទេលធ្វើពីដើមកក់ ព្រោះកន្ទេលគឺជាតម្រូវការចាំបាច់សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ។ បើជាកន្ទេលកក់ មានប្រយោជន៍សម្រាប់សម្រាក ប្រើក្នុងពិធីបុណ្យ អាពាហ៍ពិពាហ៍។ កក់ដែលយកមកត្បាញជាកន្ទេលកក់បានមកពីដាំ មិនបានមកពីដុះធម្មជាតិទេ (រូបលេខ១៧និង១៨)។

ឃុំត្រងិលគឺជាឃុំដែលមានប្រជាជនចូលចិត្តប្រកបមុខរបរត្បាញកន្ទេលកក់។ ភូមិក្នុងឃុំត្រងិលដែលនិយមត្បាញកន្ទេលច្រើនជាងគេគឺភូមិអណ្តូងរនុក។

[24] សម្ភាសលោក អោក ហៃ ឆ្នាំប្រាសាទប្រចាំនៅស្រុកកំពង់លែង នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣។



រូបលេខ១៧៖ តម្បាញកន្ទេលកក់ នៅភូមិត្របែក ឃុំត្រងិល ស្រុកកំពង់លែង



រូបលេខ១៨៖ កន្ទេលកក់ ត្បាញនៅភូមិអណ្ដូងទុក ឃុំត្រងិល ស្រុកកំពង់លែង

## សន្និដ្ឋាន

ជាសរុបមក ស្រុកកំពង់លែងនៅមានប្រវត្តិរឿងរ៉ាងពីបុរាណមកដែលលោកតា លោកយាយ ចាស់ទុំ នៅចងចាំតៗគ្នារៀងមក ដូចជាប្រវត្តិភ្នំ ប្រវត្តិភូមិ ប្រវត្តិបឹង ប្រវត្តិបុរាណដ្ឋានផ្សេងៗដែលពាក់ព័ន្ធនឹងសង្គ្រាម ជាដើម។ រឿងឫទ្ធិសែននាងកង្រីជារឿងព្រេងនិទានជិតដាមក្នុងផ្នត់គំនិតរបស់អ្នកស្រុកកំពង់លែងខ្លាំងជាងរឿងរ៉ាវណាទាំងអស់ រាប់ទាំងឈ្មោះភ្នំនាងកង្រី ភ្នំត្រងិល ភូមិត្របែក ដែលពាក់ព័ន្ធនឹងរឿងព្រេងនេះ។ នៅមានកិច្ចពិធីជំនឿដែលគោរពប្រតិបត្តិតៗគ្នាមក មិនដឹងតាំងពីពេលណាមកទេ។ ចំណែកមុខរបរចិញ្ចឹមជីវិតជាលក្ខណៈប្រពៃណីក៏នៅមានដែរ ដូចជាតម្បាញកន្ទេលកក់។ សិប្បកម្មកន្ទេលកក់នៅស្រុកកំពង់លែងមានភាពល្បីល្បាញ និងនៅមានប្រជាពលរដ្ឋប្រកបមុខរបរនេះជាប់ហូរហែមិនដាច់។ ចំណុចពិសេសមួយទៀត គឺការត្បាញកន្ទេលកក់ គឺយកកក់ដែលដាំដោយខ្លួនឯងមកត្បាញកន្ទេល។

អ្វីៗដែលបានរៀបរាប់និងពណ៌នាខាងលើគឺជាទ្រព្យសម្បត្តិអរូបី (មរតកអរូបី)

ដែលស្ថិតក្នុងការចងចាំរបស់អ្នកស្រុកដែលជាចាស់ទុំហើយនឹងអាចបាត់បង់នៅថ្ងៃណាមួយ។

ដោយសារការសិក្សាស្រាវជ្រាវមានរយៈពេលកំណត់ ការសិក្សានេះមិនអាចសិក្សាប្រមូលទិន្នន័យឱ្យបានអស់ទាំងស្រុងក្នុងស្រុកកំពង់លែងទាំងមូលបានទេ។ ដូច្នេះរាល់ការសិក្សាស្រាវជ្រាវនៅថ្ងៃអនាគតគឺជាការបន្ថែមទិន្នន័យលើការសិក្សាមួយនេះ។

ខ្ញុំក៏នឹងរង់ចាំការផ្តល់មតិកែលំអបន្ថែម ប្រសិនបើអ្នកស្រាវជ្រាវមុននិងក្រោយរកឃើញទិន្នន័យដែលផ្ទុយពីការសិក្សារបស់ខ្ញុំ។

## ឯកសារយោង


-ផុន កសិកា, «សំណង់ប្រាសាទក្នុងស្រុកកំពង់លែងនៃដែនដីអាណាចក្រចេនឡា» អត្ថបទផ្សព្វផ្សាយក្នុងគេហទំព័រ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម។

-រស់ សុខុម, «តារាជនៅប្រាសាទអង្គរវត្ត» អត្ថបទចុះផ្សាយក្នុងគេហទំព័រ បណ្តាញពត៌មានវប្បធម៌ខ្មែរ។

-សោម ច័ន្ទវីរៈ, «ពិធីសុំទឹកភ្លៀង» អត្ថបទចុះផ្សាយក្នុងគេហទំព័រ បណ្តាញពត៌មានវប្បធម៌ខ្មែរ។

- Ly Vanna, Rice Remains in the Prehistoric Pottery Tempers of the Shell Midden Site of Samrong Sen: Implications for Early Rice Cultivation in Central Cambodia, in Aséanie, juin 2002, p. 13-34.

-Aymonier, Etienne. ( 1900 ). Le Cambodge: Le Royaume Actuel, Tome I, P: 258-263.

-Lajonquière, Lunet D. ( 1902 ). Inventaire Descriftif des Monuments du Cambodge, Tome I, P: 193-202.

-ព្រះរាជប្រកាសលេខ១២ ចុះថ្ងៃទី១៣កើត ខែបុស្ស ឆ្នាំចធស័ក ព.ស. ២៤៧៧ (ថ្ងៃ១៧ ខែមករា ឆ្នាំ១៩៣៥)

-ឯកសារព័ត៌មានស្តីពី ស្ថានភាពស្រុកកំពង់លែង មន្ទីរផែនការខេត្តកំពង់ឆ្នាំង ២០២១។
-កម្មវិធីវិនិយោគបីឆ្នាំរំកិល២០២២-២០២៣ ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង, ឆ្នាំ២០២១។

**បទសម្ភាសន៍**

-លោកតាអាចារ្យ ម៉ិន ហួត អាយុ៧៤ឆ្នាំ គណៈកម្មការវត្តប្រណ្ហូក រស់នៅក្នុងភូមិឯលិច ឃុំប្រណ្ហូក ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០២២។
-លោក អោក ហៃ ឆ្មាំប្រាសាទនៃការិយាល័យវប្បធម៌ស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង នៅថ្ងៃទី ២០ ខែមីនា តុលា ឆ្នាំ២០២២។
-លោក អ៊ូ គន្ធី ជាមេឃុំត្រងិល នៅខែសីហា ឆ្នាំ២០២២។
-លោក អែម ហេន អាយុ៧៧ឆ្នាំ ជាប្រធានរដ្ឋបាលឃុំត្រងិល នៅខែសីហា ឆ្នាំ២០២២។
-លោកតា ម៉ក់ ឡូន ព្រះគ្រូសូត្រស្តាំ គង់វត្តត្របែក ហៅវត្តមានគុណ មានព្រះជន្ម៨២ ព្រះវស្សា។ វត្តត្របែកស្ថិតក្នុងភូមិត្របែក ឃុំត្រងិល ស្រុកកំពង់លែង នៅខែសីហា ឆ្នាំ២០២២។
-អ៊ំប្រុស ស៊ុម សុង រស់នៅភូមិត្របែក ឃុំត្រងិល នៅខែសីហា ឆ្នាំ២០២២។
-លោកតា គង់ ស៊ុំ អាយុ៧២ ភេទប្រុស រស់ ភូមិកំពង់បាចិន ឃុំពោធិ៍ នៅខែសីហា ឆ្នាំ២០២២។
-លោកតា អ៊ុយ ពូន អាយុ៦៨ឆ្នាំ ជាអាចារ្យវត្តកក្តី រស់នៅក្នុងភូមិសំរោង ឃុំពោធិ៍ ស្រុកកំពង់លែង សម្ភាសនៅខែសីហា ឆ្នាំ២០២២។
-លោកតា ឌិម រ៉ូ និង ហ៊ុំ ហោង ជាប្រជាពលរដ្ឋរស់នៅក្នុងភូមិស្វាយរំពារ ឃុំស្វាយរំពារ ធ្វើបទសម្ភាសន៍នៅខែសីហា ឆ្នាំ២០២២។
-លោក ប៉ាត សុវណ្ណ គឺជាគណៈកម្មការអាចារ្យវត្តថ្នកង្កែប រស់នៅភូមិកង្កែប ឃុំស្រណ្ហូក នៅខែសីហា ឆ្នាំ២០២២។

# ស្វែងយល់អំពីល្បែងបោះអង្គុញ

( Understanding on Angkugn Game )

*ដោយៈ ឯកឧត្តមបណ្ឌិត* **អ៊ុំ ប៉ុម**

*ជំនួយការរាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*ល្បែងបោះអង្គុញជាល្បែងប្រជាប្រិយមួយក្នុងចំណោមល្បែងប្រជាប្រិយ* (Popular game) *ទាំងឡាយរបស់ខ្មែរដែលគេបានកត់សម្គាល់ឃើញនិងនិយមចូលចិត្តលេងមានដូចជា ល្បែងចោលឈូង លាក់កន្សែង ទាញព្រ័ត្រ ចាប់កូនខ្លែង លេងពួន វាយក្អម ដណ្តើមលេខ រន្ទះកាច់ ស្តេចចង់ ជាដើម។ គេនិយមលេងបោះអង្គុញនៅមុនពេលនិងក្នុងពេលប្រារព្ធពិធីសង្រ្កាន្តឆ្នាំថ្មីដើម្បីបង្កើតបរិយាកាសរីករាយក្នុងចំណោមយុវវ័យនិងប្រជាជនទូទៅ។ គេច្រើនលេងល្បែងបោះអង្គុញតាមវត្តអារ៉ាម សាលារៀនក្នុងភូមិឋានឬតាមទីសាធារណៈដទៃទៀតដែលមានបរិយាកាសអំណោយផល ដូចជាក្រោមម្លប់ឈើធំៗ ទីលានរាបស្មើខ្យល់អាកាសល្អ ហើយគេអាចលេងពេលថ្ងៃឬពេលយប់ក៏បានអាស្រ័យលើលក្ខខណ្ឌតម្រូវឱ្យ។ ទាក់ទងនឹងល្បែងបោះអង្គុញមានសំណួរមួយចំនួនបានចោទសួរឡើងថា តើល្បែងរបស់អង្គុញប្រព្រឹត្តទៅយ៉ាងណា? មានរបៀបលេងជាក់ស្តែងដូចម្តេច? មានវិធានល្បែងបែបណា? ហើយមានសារៈប្រយោជន៍អ្វីខ្លះ? ចម្លើយតបទៅនឹងសំណួរដែលបានចោទឡើងបែបនេះអ្នករៀបរៀងនឹងចូលរួមបកស្រាយនូវចម្ងល់ទាំងនោះទៅតាមអ្វីដែលធ្លាប់បានដឹងឮពីចាស់ទុំនិយាយប្រាប់ ក៏ដូចជាធ្លាប់បានចូលប្រឡូកដោយផ្ទាល់ក្នុងពេលយុវវ័យជាមួយនឹងល្បែងបោះអង្គុញដូចតទៅៈ*

## ១. របៀបលេងបោះអង្គុញ

*ដើម្បីឱ្យល្បែងប្រភេទនេះប្រព្រឹត្តទៅបានចាំបាច់ត្រូវមានមនុស្សពីរក្រុមមាន*

បរិមាណគ្នីគ្នាសមល្មម ពោលគឺ ប្រុសម្នាក់ ស្រីម្នាក់ឬលាយប្រុសស្រីចម្រុះគ្នាទាំងពីរក្រុមក៏បាន ហើយក្រុមនីមួយៗគប្បីមានអ្នកពូកែផ្នែមខាងបោះត្រង់ឬបាញ់ត្រង់ពីរបីនាក់នៅជាប់ជាមួយដើម្បីជួយក្រុមឱ្យសម្រេចបានជោគជ័យ។ ចំពោះមធ្យោបាយលេងល្បែងនេះវិញ គឺផ្លែអង្គញ់[1]។ ផ្លែនេះមានរាងមូលសំប៉ែតរលោងស្រិលនិងមានសម្បុរស្រគាំ។ អ្នកស្រុកតែងយកផ្លែអង្គញ់មកលក់នៅពេលជិតដល់រដូវកាលចូលឆ្នាំម្តងៗ។ បន្ទាប់មកទៀតត្រូវមានអង្គញ់សម្រាប់បោះ (ហៅថាកើយបោះ) និងអង្គញ់សម្រាប់ដាំ (ហៅថាកើយដាំ) ព្រមទាំងមានវិធានសម្រាប់ល្បែងដែលប្រិយមិត្តអ្នកអាននឹងជ្រាបដោយលម្អិតនៅក្នុងចំណុចទីពីរនៃអត្ថបទ។ គេអាចចែកល្បែងបោះអង្គញ់ជាពីរប្រភេទតាមការនិយមចូលចិត្តលេងនោះគឺ៖ ប្រភេទបោះដោះតែម្តងនិងប្រភេទបោះធ្វូងផ្តោះទៅរកជំហានទីប្រាំបីទើបដោះសម្រេចនិងមានឈ្មោះសន្មតហៅផ្សេងៗពីគ្នា ហើយដែលជាកម្មវត្ថុនៃការពិពណ៌នារៀបរាប់នាពេលនេះ[2]។



ការលេងបោះអង្គញ់ក្នុងពិធីសង្ក្រាន្តនៅរាជបណ្ឌិត្យ សភាកម្ពុជា នាថ្ងៃទី១០ ខែមេសា ឆ្នាំ ២០២៣

### ១.១. ជំហានទី១៖ បោះធ្វូង

មុននឹងចាប់ផ្តើមអនុវត្តជំហានទី១ ហៅថាបោះធ្វូងតំណាងក្រុមទាំងពីរត្រូវ «ប៉ាវ» ជាមួយគ្នាសិន។ បើក្រុមណាប៉ាវឈ្នះ អាចមានសិទ្ធិចាប់ផ្តើមធ្វើមុនគេ។ សូមជម្រាបជូនថា ជំហានទី១នេះមានដំណើរប្រព្រឹត្តទៅដូចប្រភេទបោះដោះដែរ ប៉ុន្តែ

[1] - ផ្លែរបស់ដើមវល្លិ៍អង្គញ់មានដើមធំរឹងផ្លែធំវែងៗ។ ក្នុងផ្លែមួយមានគ្រាប់ច្រើន។ គ្រាប់វាធំរាងមូលសំប៉ែតសម្រាប់យកមកលេងល្បែងបោះអង្គញ់។ សូមមើលបន្ថែមវចនានុក្រមសម្តេចសង្ឃរាជជួនណាតទំព័រ ១៥៧៣។

[2] - ជាឈ្មោះ ដែលអ្នករៀបរៀងអត្ថបទ ធ្លាប់ដឹងតាមចាស់ទុំក្នុងភូមិ និងធ្លាប់បានចូលរួមលេងកាល ពីក្មេងក្នុងភូមិរបស់ខ្លួន ភូមិស្រះកែវ និង ភូមិជិតខាង ក្នុងឃុំរាំងចាស់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ។

ខុសគ្នាត្រង់ថាគេមិនដោះផ្តាច់តែម្តងបន្ទាប់ពីបោះត្រូវកើយដាំ[3]ទាំងអស់ទេ ផ្ទុយទៅវិញគេត្រូវធ្វើឆ្លងទៅជំហានទី២ ហើយបន្តរហូតដល់ជំហានទីប្រាំបីទើបអាចដោះបាន។ ដូច្នេះក្រុមទាំងពីរត្រូវប្រើពេលវេលាច្រើនហើយមានលក្ខណៈស្វិតស្វាញមុននឹងឈានទៅដណ្តើមបានជោគជ័យចុងក្រោយ។

## ១.២. ជំហានទី២៖ ស៊ីគោល

*ក្រុមដែលបោះត្រូវកើយដាំទាំងអស់ក្នុងជំហានទី១ អាចបន្តទៅជំហានទី២ឬត្រូវរង់ចាំការអនុវត្តរបស់ក្រុមម្ខាងទៀតសិនក៏បាន។ ប៉ុន្តែ បន្ទាប់ពីក្រុមនោះបោះអស់កើយហើយទោះបីត្រូវឬមិនត្រូវអស់ក្តីក៏ក្រុមបោះត្រូវមុនដែលរង់ចាំអាចបន្តសកម្មភាពទៅជំហានទី២បាន។ សូមបញ្ជាក់ថា ក្នុងជំហានស៊ីគោលនេះអ្នកលេងម្ខាងៗ ត្រូវយកកើយបោះមកដាក់លើចុងភ្លៅស្តាំជិតក្បាលជង្គង់បត់ ហើយបាញ់គ្រាប់អង្គញ់ដោយចង្អុលដៃស្តាំពីទីបោះឆ្ពោះទៅរកកើយដាំ (ដាំបី ឬ ដាំប្រាំ)។ ការបាញ់នេះត្រូវគិតលៃឱ្យមានគម្លាតល្មមស្រួលបាញ់បន្តឱ្យត្រូវកើយដាំទាំងអស់ (កៀកពេកច្រើនបាញ់ខុសព្រោះបាញ់ពីលើក្បាលជង្គង់)។ ក្នុងករណីបាញ់មិនត្រូវកើយដាំទាំងអស់ទេ ត្រូវផ្អាកសកម្មភាពទុកលទ្ធភាពឱ្យក្រុមម្ខាងទៀតធ្វើបន្ត។ ផ្ទុយទៅវិញ បើបាញ់ត្រូវបានទាំងអស់ក្រុមនោះអាចបន្តសកម្មភាពរបស់ខ្លួនដោយស្វ័យប្រវត្តិទៅជំហានទី៣។*

## ១.៣. ជំហានទី៣៖ស៊ីប៉ារ៉េត

*ក្នុងជំហាននេះ ក្រុមអនុវត្តត្រូវយកម្រាមដៃទាំងប្រាំចាប់គ្រវាសកើយដោយផ្ទាល់ដីឱ្យកើយរត់ទៅជិតល្មមនឹងកើយដាំ។ ប៉ុន្តែ ក្នុងការគ្រវាសត្រូវប្រយ័ត្នកុំឱ្យម្រាមដៃចាប់កើយឡើងកំពស់ពេក ព្រោះអាចចូលទៅក្នុងករណីគ្រវាសកើយបែប «កញ្ចប់ប្រហុក» ដែលក្រុមម្ខាងទៀតមិនទទួលយកបានដូចដែលបានកំណត់ក្នុងវិធានល្បែង។ ក្នុងករណីពិសេសបើគ្រវាសទៅត្រូវកើយដាំ*

[3]- គេអាចដាំកើយចំនួន៣ ឬកើយចំនួន៥ តាមចំណង់ចំណូលចិត្តអ្នកលេងដែលបានស្រុះស្រួលគ្នាមុនពេលអនុវត្តល្បែង។ សូមមើលរបៀបដាំក្នុងទំព័រ៩ និងទំព័រ១០។

ណាមួយចាត់ទុកថាត្រូវកើយដាំមួយរួចជាស្រេចគេមិនចាំបាច់បាញ់ឱ្យត្រូវម្ដងទៀតទេ។ បើប្រទាំបាញ់ត្រូវម្ដងទៀតគេហៅថា «ម៉ាយ» ត្រូវផ្អាកសកម្មភាព។ ម្យ៉ាងទៀត បើគ្រវាសទៅកើយនោះរត់ទៅកៀកនឹងកើយដាំក្នុងគម្លាតមួយចំអាមគេហៅថា «ណាប់»។ ដូច្នេះ ត្រូវអនុវត្ត «បកណាប់» ឯរបៀបបកណាប់ គឺអ្នកលេងដែលធ្វើឱ្យណាប់នោះត្រូវឈរត្រង់ខ្លួនជើងស្ដាំដាក់ប្របនឹងកើយដាំក្អែកមិនសម្ទឹងចុះហើយយកកើយដែលណាប់ទៅដាក់ក្បែរគុម្ពត្រចៀករួចទម្លាក់ឱ្យត្រូវកើយដាំ។ បើទម្លាក់ត្រូវទើបអាចបន្តសកម្មភាពបាញ់ឱ្យត្រូវកើយដាំទាំងអស់បាន។ ជាថែជន្យអាក្រក់បើទម្លាក់កើយពីគុម្ពត្រចៀកមកខុសកើយដាំបានន័យថាសកម្មភាពត្រូវផ្អាកត្រឹមនេះទុកឱ្យក្រុមម្ខាងទៀត បន្តធ្វើតាមជំហានរបស់គេ។ ដូច្នេះ ហើយសមាជិកក្រុមលេងទាំងអស់ត្រូវមានអាកប្បកិរិយាប្រុងប្រយ័ត្នជាប់ជាប្រចាំកុំឱ្យថ្វោះធ្វោយ ដើម្បីជានាដោគជ័យដល់ក្រុមរបស់ខ្លួន។

### ១.៤.ជំហានទី៤៖ ត្រកងឆា

គេអនុវត្តជំហាននេះ ដោយធ្វើឱ្យកើយបោះមានចលនាវិលទៅមុខឆ្ពោះទៅជិតល្មមកើយដាំ ប៉ុន្តែលៃយ៉ាងណាកុំឱ្យហួសកើយដាំជាមេដំបូល។ បើហួសមេដំបូលគេហៅថា ឡើង[4] មិនអាចបន្តសកម្មភាពបាន ហើយតួនាទីអនុវត្តត្រូវបានទៅក្រុមម្ខាងទៀត។ គួរកត់សម្គាល់ថាត្រកងឆាក៏គេបាញ់កើយបោះផ្ទាល់ដីដូចជំហានស៊ីប៉ារ៉េតដែរ។

### ១.៥. ជំហានទី៥៖ ត្រកងខ្ទប់

ក្នុងជំហាននេះមានសភាពខុសប្លែកពីត្រកងឆាបន្តិច ដោយអ្នកលេងបោះកើយឱ្យមានចលនាទៅមុខហើយរត់តាមពីក្រោយឱ្យកើយ ដែលវិលនោះរត់ទៅកៀកល្មមនឹងកើយដាំទើបយកដៃខ្ទប់ឱ្យឈប់វិល។ ក្នុងករណី ខុសឆ្គងគឺកុំឱ្យកើយឈប់

[4] «ឡើង» មានន័យថាខុស ពីវិធានដែលបានកំណត់ត្រូវផ្អាកសកម្មភាពមិនឱ្យធ្វើបន្តហើយលើកក្រោយត្រឡប់សាមកធ្វើ ក្នុងជំហានដដែលវិញ។

វិល (កើយងាប់) ទើបយកដៃទៅខ្ទប់។ បើមានហេតុការណ៍យ៉ាងនេះគេហៅថា « ឡើង» ដូចគ្នា។ ធ្វើអស់កើយហើយទើបអនុវត្តការបាញ់នឹងម្រាមដៃផ្ទាល់ដីឱ្យត្រូវកើយដាំទាំងអស់។ គួររំលឹកឡើងវិញថា ទាំងស៊ីគោល ស៊ីប៉ារ៉ែត ត្រកងឆាត្រកងខ្ទប់ គេត្រូវប្រយ័ត្នកុំឱ្យកើយបាញ់ខ្ទាតទៅត្រូវកើយដាំមួយហើយមួយទៀតផ្ទួនគ្នា។ កាលបើមានករណីបែបនេះកើតឡើងគេហៅថា «រះ ម៉ាយ» មិនអាចធ្វើសកម្មភាពទៅជំហានមួយទៀតបានទេត្រូវទុកលទ្ធភាពឱ្យក្រុមម្ខាងទៀតធ្វើជំហានរបស់គេបន្តទៀត។

## ១.៦. ជំហានទី៦៖ លោតកន្ទែក

លោតកន្ទែកឬលោតកន្ទែកមានន័យថា អ្នកលេងម្នាក់ដែលពូកែលោតក្នុងចំណោមអ្នកឯទៀត ត្រូវបានអនុញ្ញាតឱ្យរត់ពីចម្ងាយហើយជាន់ឱ្យត្រូវកើយបោះ ដែលគេពង្រាយលើខ្សែទីរួចលោតឱ្យទៅកៀកនឹងកើយដាំ បន្ទាប់មកគេនាំគ្នាគូសយកជាខ្សែទីត្រង់កន្លែងដែលលោតទៅនោះ ដើម្បីធ្វើសកម្មភាព។ គេអនុវត្តសកម្មភាពដោយយកកើយបោះដាក់លើខ្នងជើងស្ដាំ ឈានជើងឆ្វេងយកកម្លាំងហើយរលាស់គ្រវែងកើយដែលនៅលើខ្នងជើងស្ដាំនោះឱ្យទៅត្រូវកើយដាំណាមួយរួចធ្វើបន្តដដែលឱ្យត្រូវអស់កើយដាំ ប៉ុន្តែ មិនឱ្យត្រូវកើយដាំមួយពីរដង។ ក្នុងករណីចៃដន្យបើកើយលើខ្នងជើងស្ដាំរបូតធ្លាក់កណ្ដាលផ្លូវគេហៅថា «ប៉ាក់កលៀនអណ្ដាត»។ បើមានយ៉ាងនេះអ្នកលេងត្រូវដាក់កើយដែលជ្រុះលើខ្នងជើងស្ដាំដដែល ងើយក្បាលឡើងលើលៀនអណ្ដាតឈានជើងឆ្វេងមួយជំហានយកកម្លាំងរួចរលាស់គ្រវែងកើយលើខ្នងជើងឱ្យទៅត្រូវកើយដាំណាមួយ ទើបក្រុមម្ខាងទៀតយល់ព្រមឱ្យបន្តសកម្មភាពទៅបាន។ បើមិនត្រូវទេមិនអាចមានសិទ្ធិបន្តសកម្មភាពទៅមុខទៀតបានទេទុកឱកាសឱ្យក្រុមម្ខាងទៀតអនុវត្តជំហានរបស់គេវិញម្ដង។

## ១.៧. ជំហានទី៧៖ ចាក់អន្ទង់

ជំហានចាក់អន្ទង់ប្រព្រឹត្តទៅដោយតៀតកើយបោះមួយនឹងមេជើងរួចលោតជើងមួយពីទីបោះទៅដល់កើយដាំហើយត្រូវចាក់លោតបង្វិលខ្លួនជុំវិញកើយដាំមួយជុំរួចញល់កើយដាំមួយឲ្យរលំដោយមិនឱ្យ

កើយគៀតនឹងមេជើងនោះប៉ះដីរួចបន្តសកម្មភាពតាមចលនាដូចមុនទៅកើយដាំទីពីរ ទីបី រហូតទាល់តែរលំអស់ទើបចាក់ត្រឡប់ទៅទីបោះវិញ។ គេអាចឃើញមានរបៀបចាក់អន្ទង់មួយបែបទៀតដែលពិបាកជាងមុន ពោលគឺ គេគៀតកើយបោះនឹងមេជើងដូចគ្នា ហើយលោតជើងមួយពីទីបោះទៅញល់កើយដាំមួយឱ្យរលំ ហើយចាក់ត្រឡប់មកទីវិញ រួចចាក់ត្រឡប់ពីទីបោះទៅញល់កើយដាំមួយទៀតឱ្យដួលរលំ រួចចាក់ត្រឡប់មកទីបោះវិញ ដោយមិនឱ្យជើងគៀតអង្គញ់ប៉ះដី ធ្វើសាចុះសាឡើងរហូតទាល់តែរលំកើយដាំទាំងអស់ទើបឈប់។ សូមបញ្ជាក់ថាក្រុមម្ខាងទៀតដែលរង់ចាំធ្វើមិនទៅស្ងៀមទេពួកគេដាំកើយឡើងវិញនិងពិនិត្យមើលសកម្មភាពរបស់ក្រុមកំពុងធ្វើជាប់ជានិច្ចក្រែងក្រុមនោះធ្វើប្រឡំខុសគ្នានឹងវិធានល្បែងដែលបានស្រុះស្រួលគ្នាកន្លងមក ដើម្បីក្រុមគេមានលទ្ធភាពបានធ្វើជំហានបន្តអាស្រ័យដោយការខុសគ្នានោះ។

## ១.៨. ជំហានទី៨៖ បោះដោះ

បោះដោះជាជំហានចុងបញ្ចប់នៃល្បែងបោះអង្គញ់ប្រភេទទីពីរ។ ក្រុមដែលមកដល់ជំហាននេះមុនគេត្រូវបោះឱ្យត្រូវកើយដាំទាំងអស់។ បោះត្រូវអស់ហើយគប្បីរង់ចាំក្រុមមួយទៀតធ្វើរហូតដល់ជំហាននេះដូចគ្នា។ ប៉ុន្តែក៏មានករណីពិសេសខ្លះរបស់ក្រុមម្ខាងទៀត ជួនកាលធ្វើមកដល់ជំហានចុងក្រោយតែបោះមិនត្រូវអស់ឬមួយក៏ធ្វើមិនទាន់ដល់ជំហាននេះផងតែបែជន្យមានកំហុសឆ្គងក្នុងវិធាន។ ក្រុមដែលបោះត្រូវអស់មុនគេនោះមានសិទ្ធិដោះក្រុមម្ខាងទៀតដោយស្វ័យប្រវត្តិតែម្តង។ ចំពោះរបៀបដោះវិញ គេដោះដោយយកអង្គញ់មួយទៅដាក់ផ្ទាប់ពីលើឆ្អឹងក្បាលជង្គង់ហើយយកកើយមួយទៀតដំពីលើតាមចំនួនដែលបានកំណត់គ្នាមុនពេលលេង។ ឬមួយក៏យកអង្គញ់ មួយដាក់ផ្តេកមួយទៀតដាក់បញ្ឈរលើគ្នាហើយយកម្រាមដៃទប់កុំឱ្យកើយដល់គ្នារួច ដំលើក្បាលជង្គង់។ ពេលដោះទៅឮសំឡេង «ផ្ទក់!ផ្ទក់!» តាមចំនួនដែលបានកំណត់។ បើដោះគេលើសសាមុី

ខ្លួនដែលឱ្យគេដោះអាចដោះអ្នកនោះវិញបាន ហើយបរិយាកាសក៏កាន់តែសប្បាយរីករាយជាមួយគ្នាពិសេសរវាងយុវជនយុវនារី។ របៀបដោះម្យ៉ាងទៀតគឺគេប្រើបំពង់ឬស្សីដែលគេពុះសាប់ ជាចម្រៀកស្តើងៗដល់គល់បំពង់ដោះទៅមានបញ្ចេញសំឡេង«ផ្លូង!ផ្លូង!» តែពុំសូវឈឺទេ។ គេហៅរបៀបដោះទាំងពីរថារបៀបដោះបែប«បាយត្រជាក់»។ ឯរបៀបដោះចុងក្រោយគឺដោះបែប«បាយក្ដៅ» ដោយយកអង្គញ់សម្រាប់បោះមកគប់ផ្ទាល់លើឆ្អឹងក្បាលជង្គង់អ្នកចាញ់។ គួរកត់សម្គាល់ថាមុនពេលដោះអ្នកឈ្នះតែងសួរទៅអ្នកចាញ់ថាឱ្យគេដោះតាមបែបបាយក្ដៅឬបាយត្រជាក់? បើសាម៉ីខ្លួនឆ្លើយថា«បាយត្រជាក់»គឺគេដោះតាមបែបពីរខាងដើម។ ប៉ុន្តែបើឆ្លើយថា«បាយក្ដៅ»គឺគេដោះតាមបែបចុងក្រោយដែលឈឺផងហើយដាំក្បាលជង្គង់ផង។ ចំពោះរបៀបដោះចុងក្រោយនេះចាស់ៗក្នុងភូមិហាមជាបណ្ដាំបមាំទាំណាស់ព្រោះនាំឱ្យហើមក្បាលជង្គង់ខានសប្បាយពេលចូលឆ្នាំ។ ប៉ុន្តែទោះបីជាយ៉ាងនេះក្ដីក៏ក្រុមយុវវ័យ នៅតែចង់ធ្វើតាមរបៀបចុងក្រោយនេះ ពីព្រោះគេមានបំណងចង់កសាងអនុស្សាវរីយ៍ជាមនោសញ្ចេតនាជ្រាលជ្រៅជាមួយគ្នាក្នុងពេលសង្ក្រាន្តឆ្នាំថ្មីដោយអាការៈខ្នក់ខ្នាញ់ផងនិងចាប់ចិត្តស្រឡាញ់គ្នាផង។

## ២. វិធាននៃល្បែងបោះអង្គញ់

ជាទូទៅល្បែងនីមួយៗតែងមានវិធាន(Rules) ដើម្បីជានាឱ្យដំណើរប្រព្រឹត្តទៅរបស់ល្បែងមានភាពរលូនគ្មានឧបសគ្គ។ ដោយឡែកល្បែងបោះអង្គញ់ក៏មានវិធានរបស់ខ្លួនដែរ ដើម្បីជានានូវសណ្ដាប់ធ្នាប់របៀបរៀបរយក៏ដូចជាការសម្រេចគោលដៅគឺឈ្នះលើគូប្រកួត។ ជាក់ស្តែងវិធានទាំងនោះរួមមានៈ

- ត្រូវមានមនុស្សពីរក្រុមជាចាំបាច់
- ត្រូវមានគើយបោះនិងគើយដាំ
- ត្រូវមានកំណត់គើយដាំ : ដាំបីឬដាំប្រាំឬដាំរបៀបណាទៀត?
- មិនឱ្យយកអង្គុញពីក្រៅឬគើយដាំមកបន្ទំបោះ
- គើយដាំមួយមិនអាចបោះត្រូវពីរដង

- កុំឱ្យមានករណី «រះម៉ាយ»
- កុំឱ្យមានករណី «កញ្ចប់ប្រហុក»
- បើមានណាប់ត្រូវបកណាប់ទើបឱ្យបន្តសកម្មភាព
- កើយវិលក្នុងត្រកងធាមិនឱ្យចលនាទៅមុខហួសមេដំបូល
- កើយឈប់វិលក្នុងត្រកងខ្ទប់ចាត់ទុកថាង៉ាប់ មិនឱ្យយកដៃខ្ទប់
- បើមានករណី «ឡើង» មិនអាចបន្តទៅជំហានថ្មីបាន
- អស់កើយបោះហើយមិនត្រូវកើយដាំអស់មិនអាចបន្តជំហានថ្មី
- ក្រុមចាញ់ឱ្យក្រុមឈ្នះដោះតាមចំនួនកំណត់
- បោះត្រូវកើយដាំមួយហើយកើយបោះត្រូវអាចយកទៅបោះម្តងទៀតបាន
- ដោះលើសចំនួនអ្នកចាញ់អាចដោះវិញបាន
- កើយតៀ្បតនឹងមេដើងកុំឱ្យជ្រុះឬប៉ះដី
- គោរពទីបោះឱ្យបានត្រឹមត្រូវ
- កើយជ្រុះពីខ្នងជើងត្រូវអនុវត្តបាក់កលៀនអណ្តាត
- មិនបង្កជម្លោះក្នុងពេលលេង

### ៣. សារៈប្រយោជន៍នៃល្បែងបោះអង្គញ់

ល្បែងប្រជាប្រិយនីមួយៗដែលចាស់បុរាណបានខិតខំបង្កើតឡើងអាចចាត់ទុកថាមានប្រយោជន៍សម្រាប់សង្គមជាតិ។ ដោយឡែក ចំពោះល្បែងបោះអង្គញ់បើពិចារណាឱ្យបានដិតដល់ទៅឃើញថាល្បែងនេះមានសារៈប្រយោជន៍ដូចខាងក្រោម៖

- រួមចំណែកជួយអភិរក្សដើមវល្លិ៍អង្គញ់ឱ្យនៅស្ថិតស្ថេរគង់វង្សជាមួយនឹងល្បែងអង្គញ់
- ជួយអ្នកស្រុកឱ្យបានចំណូលពីការលក់ផ្លែវល្លិអង្គញ់
- បង្កើនសុខភាពដល់យុវវ័យព្រោះគេបានប្រើថាមពលច្រើនតាំងពីជំហានទី១ រហូតដល់ទី៨
- បង្កើនភាពឈ្លាសវៃនិងប៉ិនប្រសប់

- មានជំនាញតម្រង់ដោយប្រើភ្នែកដៃនិងជង្គើមចេញចូល
- មានជំនាញប៉ាន់ស្មានដោយប្រើភ្នែកនិងកម្លាំងដៃដើម្បីបោះឬបាញ់ឱ្យត្រូវចំគោលដៅឬចំណុចដៅ
- បង្កើនស្មារតីភ្ញាក់រលឹកក្នុងការគោរពវិធាន។ គោរពវិធានបានល្អនាំមកនូវជោគជ័យ។ បំពានវិធាននាំមកនូវបរាជ័យ
- បង្កើននូវស្មារតីប្រុងប្រយ័ត្ននិងមានអំណត់ព្យាយាមក្នុងពេលលេងដើម្បីបានទៅដល់ជំហានចុងបញ្ចប់
- បង្កើននូវស្មារតីអភិបាលកិច្ចដោយជំរុញទឹកចិត្តអ្នកលេងក្នុងក្រុមនិងត្រួតពិនិត្យជាប់ជាប្រចាំចំពោះដំណើរប្រព្រឹត្តទៅនៃល្បែងកុំឱ្យមានសភាពខុសធម្មតា
- ស្គាល់ពីតួនាទីនិងសិទ្ធិអំណាចរបស់ក្រុមនីមួយៗ
- បណ្តុះនូវមនោសញ្ចេតនាយោគយល់គ្នាស្រឡាញ់រាប់អានគ្នារវាងភូមិមួយទៅភូមិមួយ
- បង្កើតនូវឥរិយាបថស្មោះត្រង់នឹងគ្នាមិនបន្ទៃបន្ទំគ្នា
- រួមចំណែកទ្រទ្រង់នូវវប្បធម៌របស់ជាតិមិនឱ្យបាត់បង់។

## សេចក្តីសន្និដ្ឋាន

ទោះបីជាវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាក្នុងសង្គមទំនើបកំពុងទទួលនូវការរីកចម្រើនដ៏គំហុកស្ទើរតែរត់តាមមិនទាន់យ៉ាងណាក្តីក៏យើងជាខ្មែរគួរគប្បីថែរក្សាល្បែងមួយនេះឱ្យស្ថិតក្នុងសន្តានចិត្តរបស់យុវវ័យតទៅមុខទៀតដោយហេតុផលថាល្បែងបោះអង្គញ់ជាតំណាងឱ្យវប្បធម៌រូបីមួយរបស់ជាតិ។ ដូច្នេះអំណឹះតទៅដើម្បីកុំឱ្យបុរាណចេះតែបាត់បង់ទៅដោយឆាប់រហ័សពេកជាមួយនឹងការរត់តាមទំនើបដោយមិនសមហេតុផលព្រមជាមួយនឹងការនិយមទំនើបដោយគ្មានមូលដ្ឋានរក្សាអត្តសញ្ញាណជាតិច្បាស់លាស់យើងជាខ្មែរគួរនាំគ្នាគិតពិចារណាយ៉ាងណាបញ្ចូលបុរាណទៅក្នុងទំនើបដើម្បីឱ្យបុរាណដ៏សមហេតុផលរបស់យើងអាចមានលទ្ធភាពរស់រានមានជីវិត

*ទៅបានជាមួយនឹងសង្គមទំនើបព្រោះយើង ទស្សនវិជ្ជាដ៏មានតម្លៃរបស់ជាតិរួចមក ទាំងអស់គ្នាសុទ្ធតែទទួលនូវការអប់រំពី ហើយនោះគឺៈ*

***«នាងកាន់ទំនើបកុំចោលបុរាណរក្សាលំអានដំណែលជាតិយើង»។***

***«វប្បធម៌រលត់ជាតិរលាយវប្បធម៌ពណ្ណរាយជាតិថ្កើងថ្កាន» យ៉ាងនេះឯង។***




**ប្រើប្រាស់របៀបដាំទាំងពីរសម្រាប់ច្នោះដោះនិងច្នោះឆ្លង**




**ប្រើប្រាស់របៀបដាំទាំងបួនសម្រាប់ច្នោះដោះ**

# ការប្រតិបត្តិជំនឿអ្នកតាក្នុងសង្គមខ្មែរ

បណ្ឌិត **ហែម ឡាច**
មន្ត្រីនាយកដ្ឋាននីតិសាស្ត្រ វិទ្យាស្ថានមនុសាស្ត្រ
និងវិទ្យាសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា

ជំនឿលើអ្នកតានេះមានប្រវត្តិតាំងពីយូរយារណាស់មកហើយ តាំងពីប្រទេសយើងពុំទាន់បានបង្កើតរដ្ឋទៅទៀត ពោលគឺមុនពេលមានវត្តមានព្រះថោង នាងនាគ ឬហ៊ុនទៀន លីវយី ពោលគឺមុនមានឥទ្ធិពលឥណ្ឌានិងចិនចូលមកក្នុងទឹកដីកម្ពុជា។ អ្នកតាមាននៅពាសពេញគ្រប់ទីកន្លែងតាមជំនឿរបស់ម្ចាស់ស្រុក។ ប្រភពអ្នកតាទាំងអស់នោះមានលក្ខណៈខុសៗគ្នា។ អ្នកតាខ្លះមានប្រភពដើមមកពីតួអង្គប្រវត្តិសាស្ត្រ ខ្លះទៀតមានប្រភពពីបុគ្គលដែលមានមហិទ្ធិឫទ្ធិកាលពីអ្នកនោះនៅមានអាយុជីវិត។

លោកបណ្ឌិត អាង ជូលាង អ្នកជំនាញខាងទេវនិយមនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈបានបញ្ជាក់ថា អ្នកតាមាននៅគ្រប់ទីកន្លែងក្នុងទឹកដីកម្ពុជា ហើយបង្កប់នូវអបីជំនឿដល់ប្រជាជនកម្ពុជា ចាប់ពីទីក្រុងដល់ជនបទ។ អ្នកតាមិនគ្រាន់តែជាវិញ្ញាណមានលក្ខណៈសាមញ្ញប៉ុណ្ណោះទេ ប៉ុន្តែក៏ជាកម្លាំងឬថាមពលពិសេសដែលអាចជួយខាងស្មារតីដល់មនុស្សក្នុងសហគមន៍ថែមទៀត។ អ្នកតា ឬលោកយាយត្រូវបានសន្មតថ្នាក់ពីថ្ម ឈើ ដីឥដ្ឋ និងវត្ថុផ្សេងៗទៀតដាក់នៅលើទីទួលខ្ពស់ មានប្រក់ស្លឹកស័ង្កសីឬប្រក់ក្បឿងតាមលទ្ធភាពអ្នកភូមិនិយមចូលចិត្ត។ ចម្លាក់នៃរូបកាយអ្នកតានេះគេផ្សារភ្ជាប់ជាមួយបុព្វបុរសឬបុគ្គលដែលខ្លាំងពូកែ ចេះជួយការពារភូមិស្រុកឱ្យបានក្សេមក្សាន្ត និងអាចជ្រើសរើសយកឈ្មោះបុគ្គលនោះជាឈ្មោះទីកន្លែង ដូចជាភូមិ ឃុំ ស្រុក ខេត្ត។ ដូច្នេះ គេត្រូវជាប់ថ្នាក់រូបអ្នកតានេះស្របគ្នាជាមួយសម្ភារៈនិងរូបកាយបុគ្គល ឬវីរបុរសដែលបានស្លាប់ទៅហើយ ហើយគេក៏សន្មតថា អ្នកទាំងនោះស្លាប់តែរូបកាយ តែព្រលឹងរបស់គាត់នៅតែតាមថែទាំកូនចៅក្នុងភូមិស្រុកបន្តទៀត។ ក្រៅពីការជឿលើព្រលឹងជីដូន ជីតា នេះប្រជាជនខ្មែរក៏នៅតែគោរព និង ឱ្យតម្លៃទៅដល់បរិស្ថានជុំវិញខ្លួនមានដូចជាព្រៃព្រឹក្សាទេសភាពធម្មជាតិ ភ្នំ ទន្លេ បឹងបួ ផែនដី។ល។ ដោយគេសន្មតថា ជាវត្ថុមានជីវិតមានសក្តានុពល និងអំណាច ហើយចេះការពារមនុស្សផ្តល់ប្រយោជន៍ដល់មនុស្សក្នុងសហ

គមន៍។ ក្នុងការគោរពនិងជឿគុណនេះគេសន្មតថា វត្ថុទាំងអស់នោះជាអ្នកតាហើយតែងតែបន់ស្រន់បួងសួងដាក់សំណែនសុំសេចក្តីសុខពីអ្នកតានោះ។

លោកព្រឹទ្ធាចារ្យ ជិត ជន សាស្ត្រាចារ្យនៃក្រសួងធម្មការនិងសាសនាបានប្រាប់ថា គាត់ចេះបាលីដាក់ស្នេហ៍អ្នកតាធ្លាប់ជួយមនុស្សបានច្រើនគ្នា។ អ្នកតានេះបានធ្វើឱ្យមនុស្សចុកពោះ ឈឺក្បាលទោះបីយកទៅព្យាបាលនៅមន្ទីរពេទ្យក៏មិនជាដែរ តែសំខាន់ចេះដាក់ស្នេហ៍អង្វរករ កំណត់ម៉ោងសន្យាដាក់សំណែនជូនទើបជាហើយ បើពន្យារពេលបណ្តែតបណ្តោយមិនអើពើអាចបណ្តាលឱ្យអ្នកជំងឺស្លាប់បាន។ ម្តាយមីងរបស់លោកម្នាក់បានស្លាប់ដោយអ្នកតាកាច់ព្រោះមិនព្រមជឿនិងដាក់សំណែនឱ្យអ្នកតា។

## **១-ដើមកំណើតអ្នកតា**

អ្នកតាប្រហែលជាមានដើមកំណើតនៅប្រទេសចិន មុនប្រទេសណាៗទាំងអស់។ ជនជាតិចិនម្នាក់បានទិទានរឿងអំពីប្រវត្តិអ្នកតាប្រាប់លោក ព្រាប ឌិប ជាគ្រូបង្រៀនម្នាក់នៅខេត្តសៀមរាប។ រឿងនោះមានតំណាលថាៈ

ក្នុងសម័យព្រេងនាយមានបុរសជាអ្នកទីទ័លក្រពីរនាក់ គឺឪពុក និងកូនប្រុសពេញកំលោះ អាស្រ័យនៅក្នុងភូមិនិគមដ៏តូចមួយតាំងនៅដាច់ស្រយាលពីពជជាទី។ នៅនាវស្សានរដូវ បុរសឪពុកមានជំងឺយ៉ាងធ្ងន់ធ្ងរក៏ទទួលអនិច្ចកម្មទៅ ទុកកូននៅកំព្រាតែម្នាក់ឯង។ កូននោះគិតថា អញមិនគួរយកខ្មោចឪពុក ទៅបញ្ចុះជិតម៉ុងអ្នកមានធនធានទេត្រូវតែយកទៅបញ្ចុះឱ្យឆ្ងាយពីគេ ព្រោះខ្លួនជាអ្នកទ័លក្រ។ លុះគិតហើយបុរសជាកូនបានយកសពឪពុកទៅបញ្ចុះក្បែរជើងភ្នំមួយឆ្ងាយ។ លុះបញ្ចុះរួចហើយ ក៏លាខ្មោចឪពុកវិលមកប្រកបអាជីវកម្មតាមធម្មតាវិញ។ ដោយសេចក្តីអាល័យឪពុកខ្លាំងពេក បុរសកំសត់មិនអាចបំភ្លេចចោលម៉ុងឪពុកបានក៏តែងយកនំចំណីទៅសែនជូនជាញឹកញាប់។ គាប់ជួនថ្ងៃមួយមានភ្លៀងបង្អុរចុះជាប់មិនដាច់គ្រាប់សោះ ចៅកំសត់ក៏ស៊ូទ្រាំអត់បាយអត់ទឹកដេកនៅជិតម៉ុងឪពុក មិនព្រមត្រឡប់ទៅលំនៅវិញ។

ក្នុងរាត្រីដ៏ស្ងប់ស្ងាត់នោះ ពេលដែលចៅកំសត់កំពុងនិទ្រាលក់ស្កប់ស្កល់ព្រលឹងខ្មោចឪពុកបានមកពន្យល់សប្តិ

• ទស្សនាវដ្តី សេដ្ឋកិច្ចខ្មែរៈ អត្តសញ្ញាណវប្បធម៌ខ្មែរ ចូលរួមអភិវឌ្ឍសហគមន៍សេដ្ឋកិច្ច លេខទី៤០ ខែមិថុនា។ ២០១៩ ទំព័រ៦០

និយាយនឹងកូនថា នែកូន! កូនឪពុក! ម្ដេចក៏កូននៅតែស៊ូប្ដូរនឹងឪពុកដែលចែកឋានទៅហើយ? តើសព្វថ្ងៃនេះ កូនមានគោលបំណងយ៉ាងណាខ្លះ? ព្រលឹងកូនក៏ឆ្លើយទៅវិញថាកូនគ្មានប្រាថ្នាអ្វីទេលោកឪពុក។ លុះព្រលឹងឪពុកសួរបញ្ជាក់បីបួនលើកទើបព្រលឹងកូនឆ្លើយតបទៅវិញថា ក្នុងជាតិនេះ កូនប្រាថ្នាចង់តែឱ្យបានធំជាងគេទាំងអស់សូម្បីតែស្ដេចឱ្យតែឃើញត្រូវតែសំពះរូបកូន។ព្រលឹងខ្មោចឪពុកបានប្រាប់ទៅព្រលឹងកូនវិញថា បំណងកូនឯងនេះនឹងបានសម្រេចពិត។ ថ្ងៃស្អែកនេះ កូនត្រូវក្រោកពីព្រលឹម ដើរចេញពីទីនេះទៅតាមផ្លូវខាងជើងភ្នំកាលណាឃើញភ្នំបីជាប់គ្នារដឹក កូនត្រូវខំត្រាច់ឱ្យហួសទៅទៀតនោះ កូននឹងឃើញផ្លូវលំមួយ ហើយនៅដើមផ្លូវនោះ មានឈើបីដើមធំៗហើយខ្ពស់ៗ ផុតឈើដទៃទៀត។ នៅក្រោមព្រឹក្សានោះមានថ្មមួយផ្ទាំងខ្ពស់ ភ្លឺរលោង ស្ថិតនៅខាងមុខថ្មទាំងពួង មានវល្លិដុះព័ទ្ធដូចក្បាច់រចនា។ នោះ គឺជាសិលាពិសិដ្ឋសម្រាប់អ្នកមានបុណ្យ កាលបើបានទៅដល់ហើយ ចូរកូនឡើងអង្គុយលើថ្មនោះទៅ។ ចូរកូនធ្វើតាមបណ្ដាំឪពុកនេះកុំខាន ឪពុកលាកូនសិនហើយ។

លុះព្រឹកឡើងបុរសកំសត់ភ្ញាក់ពីដំណេកមានអាការញ័រអស់អង្គប្រាណជឿស៊ប់ក្នុងការយល់សប្ដិនោះ ប៉ុន្តែមិនទាន់យល់ការណ៍អាថ៌កំបាំងនៃសុបិននោះនៅឡើយទេ ក៏សំពះលាម៉ុងខ្មោចឪពុកដើរចេញទៅដោយសង្ឃឹមថា បើបានសម្រេចដូចបំណងមែន នឹងវិលត្រលប់មកធ្វើកិច្ចការតាមធម្មតាវិញ។

បុរសកំសត់ខំស្រូតកាត់ព្រៃលេចវាលផុតវាលចូលព្រៃអស់វេលា៧យប់៧ថ្ងៃទើបបានឃើញឈើធំខ្ពស់ៗនិងថ្មពិសិដ្ឋទំនងដូចពាក្យខ្មោចឪពុកបានផ្ដាំមែនក៏ឡើងទៅអង្គុយលើថ្មនោះតាមបណ្ដាំឪពុក។ ខណៈនោះរាងកាយបុរសកំលោះក៏ប្រែក្លាយមួយរំពេចទៅជាសិលា រឹងកក្រោះគ្មានវិញ្ញាណ។

ចាប់តាំងពីពេលនោះមក អ្នកតាកំលោះតែងបានទទួលលាភសក្ការៈនិងវន្ទនាការពីជនានុជនគ្រប់ជាន់ថ្នាក់មែន។ ការសែនព្រេនបន់ស្រន់ក៏មានចាប់តាំងពីពេលនោះរហូតមក ឯអ្នកតាសោតក៏ទើបតែនឹងមានរូបមួយប៉ុណ្ណោះ។ តាមពិតដើមឡើយអ្នកតាកំលោះនេះ មិនមែនមានបំណងធ្វើជាអ្នកតាថ្មទេ គឺគាត់ប្រាថ្នាចង់បានមហេសក្ខភាព និងឥស្សរភាព។

ថ្ងៃក្រោយមកគហបតីនៅជនបទនោះ បានរៀបចំជាក្បួនយ៉ាងឱឡារិក និងនាំកូនស្រីទៅកាន់ត្រកូលខាងប្ដី ដើម្បីរៀបអពាហ៍ពិពាហ៍ ក៏បានធ្វើដំណើរតាមផ្លូវ

នោះ ដោយពុំបានដឹងថាមានអ្នកតា។ លុះមកដល់មុខអ្នកតាកំលោះៗ បានឃើញរូបនាងស្រីនោះ មានសេចក្តីប្រតិព័ទ្ធស្នេហា ក៏ឆក់យកមកដាក់លើថ្មមួយដុំជិតខ្លួន នាងក្រមុំក៏បានប្រែកាយ ក្លាយខ្លួនជាថ្មដែរ រកផ្លូវកែមិនបានដោយមហិទ្ធិឫទ្ធិរបស់អ្នកតាកំលោះ។

ចំណែកគហបតីជាឪពុក ក៏បន់ស្រន់អ្នកតាអស់ពេលដ៏យូរដើម្បីឱ្យកូនមានរូបរាងជាមនុស្សវិញតែជាការឥតប្រយោជន៍សោះ។ គហបតីមានសេចក្តីក្តៅក្រហាយ ព្រមជាមួយនឹងទុក្ខសោកជាខ្លាំងរកអ្វីប្រៀបពុំបានឡើយ គាត់ក៏តាំងចិត្តចងពៀរនឹងអ្នកតានោះវិញ។ តមកគហបតីធ្លាក់ខ្លួនមានជំងឺយ៉ាងធ្ងន់ដោយរោគក្អកធ្លាក់ឈាម ហើយពេទ្យហ្មមិនអាចមើលជាឡើយ។ មុននឹងធ្វើមរណកាលទៅគាត់បានផ្តាំប្រពន្ធថា កាលណាគាត់ស្លាប់ទៅត្រូវយកធ្យូង៤ដុំដាក់ក្នុងក្តារមឈូសគ្រប់ជ្រុងទាំង៤ឱ្យគាត់កុំខាន។ គាត់មានបំណងនឹងយកទៅដុតទីកន្លែងអ្នកតាឱ្យឆេះគ្រប់ទាំង៤ទិស សងគំនុំចិត្តរបស់គាត់វិញ។ ប្រពន្ធក៏ទទួលធ្វើតាមបណ្តាំប្តីទាំងអស់។

ថ្ងៃងពីអ្នកតាកំលោះ កាលបើបានដឹងរឿងថា ខ្មោចគហបតីបម្រុងនឹងដុតខ្ទមដូច្នេះ ក៏និម្មិតខ្លួនជាមនុស្សចាស់ម្នាក់ទៅនិយាយពន្យល់ប្រពន្ធគហបតីថា លោកស្រី! លោកស្រីមិនត្រូវចេះតែធ្វើតាមបណ្តាំប្តីនាំឱ្យខុសទំនៀមទម្លាប់យ៉ាងនេះសោះ មិនដែលមាននរណាយកធ្យូងទៅដាក់ក្នុងមឈូសដាក់សពប្តីដូចលោកស្រីទេ។

ដោយសារពាក្យណែនាំនេះ ស្រីមេម៉ាយក៏ព្រមបន្ថយដកយកធ្យូងបីដុំចេញ ទុកឱ្យនៅសល់តែមួយដុំ។ រីឯខ្មោចគហបតី ក៏បានយកធ្យូងមួយដុំនោះ ទៅដុតខ្ទមអ្នកតាមួយជ្រុងឆេះហុយទ្រលោមដូចបំណង។ ព្រោះហេតុនេះហើយទើបជនជាតិចិនតែងតំណាលប្រាប់កូនចៅរបស់គេថា ខ្ទមអ្នកតាចិនតែងស្រុតមួយជ្រុងជាដរាប ទោះបីស្ថាបនាដោយអ្វីក៏ដោយ គឺដោយសារតែខ្មោចគហបតីនោះដុត។

ពេលចូលរូបអ្នកតាចិនតែងជិះកៀវ។ កៀវនេះជាតំណាងដុំថ្មដែលគាត់ឡើងទៅអង្គុយ ហើយក្លាយរូបរាងទៅជាអ្នកតាថ្ម។ ទោះបីមានការប្រញាប់យ៉ាងណាក្តី អ្នកតាចិនតែងប្រាប់អ្នកដែលមករកមើលជតារាសីថា ចាំទៅសួរអ្នកតាធំសិន គឺប្រហែលជាចាំទៅសួរខ្មោចឪពុកហើយមើលទៅព្រោះឪពុកគាត់បានឱ្យឥស្សរភាពនេះមកគាត់។

ជនជាតិចិនកាន់ទំនៀមមួយនេះរហូតមកដល់សព្វថ្ងៃ គឺមុនរៀបមង្គលការ

កូនប្រុស ស្រី សាមីខ្លួនត្រូវទៅប៉ាយអ្នកតាជាមុនសិន ដើម្បីថ្លែងសេចក្តីគោរពចំពោះអ្នកតា។ ចិនគ្រប់ឋានៈតែងកោតខ្លាច គោរពអ្នកតា មានចិននៅត្រង់ណាមានអ្នកតានៅត្រង់នោះ។ ម្យ៉ាងវិញទៀត អ្នកតានេះហើយដែលជាសរណៈមួយយ៉ាងខ្ពង់ខ្ពស់របស់ជនជាតិចិន[2]។

## ២-ទីតាំង សណ្ឋាននិងឈ្មោះអ្នកតា

*អ្នកតាដែលល្បីល្បាញនៅក្នុងប្រទេសកម្ពុជាភាគច្រើនមានទីតាំងនៅក្នុងភូមិ ដើមឈើធំៗ ព្រៃភ្នំ ទីទួល ដោយគេសង់ខ្ទមមានរបៀបជាផ្ទះរបស់មនុស្សមានទំហំធំ តូច ទៅតាមភាពស័ក្តិសិទ្ធិរបស់អ្នកតា។ ខ្មែរយើងមានជំនឿថា អ្នកតាមានសត្វផ្សេងៗជាបរិវារដូចជាក្រពើ ខ្លា ពស់ ជាដើម។*

*នៅស្រុកខ្មែរយើងមានរូបភាពអ្នកតាច្រើនសណ្ឋានដូចជា៖ ដីដំបូកខ្ពស់ៗ ដុំថ្មមួយដុំដែលគ្មានឆ្លាក់ ឬឆ្លាក់ដោយខ្វីខ្វា រូបសំណាកទេវៈបុរាណក្នុងព្រហ្មញ្ញសាសនា ឫសឈើមានលក្ខណៈ ក្រវេមក្រវាមស្អុគស្អាញ វត្ថុមានទ្រង់ទ្រាយចម្លែកៗ ឬវត្ថុដែលគេរើសបានយកមកសន្មត។*

*ក្រៅពីទីស្នាក់អាស្រ័យដែលជាលំនៅឋាន ដូចជាខ្ទម ដើមឈើ ដំបូកឬដុំថ្ម អ្នកតាក៏នៅមានឈ្មោះដូចមនុស្សលោកដែរ។ ឈ្មោះអ្នកតាត្រូវបានមនុស្សជំនាន់ក្រោយៗ ហៅតៗគ្នារាប់ស.វ.មកហើយ គឺហៅតាមឈ្មោះដើមឈើដែលមានអត្ថិភាពរបស់អ្នកតានៅទីណានោះ ជួនកាលហៅតាមឈ្មោះរបស់បុព្វបុរសដែលមានគុណបំណាច់ មានឥទ្ធិពល មានសមត្ថភាពធ្វើជាអ្នកដឹកនាំដ៏ល្អ ចេះយល់ទុក្ខធុរៈ ចេះជួយយកអាសា និងណែនាំទូន្មាន បង្ហាញផ្លូវល្អឱ្យអ្នកស្រុកអ្នកភូមិដើរតាមក្នុងន័យស្វែងរកសេចក្តីសុខឱ្យសហគមន៍។ ឈ្មោះអ្នកតាក៏អាចជាឈ្មោះព្រះចៅអធិការវត្តឈ្មោះអាចារ្យ ឈ្មោះគ្រូហ្មមើលជំងឺ ឈ្មោះមេទ័ព ដូចជាអ្នកតាឃ្លាំងមឿង អ្នកតាដំបងគ្រញូង លោកតាឪ។ល។ ក្រៅពីអ្នកតាជាបុរស ក៏មានអ្នកតាជាស្ត្រីដែរ ដែលគេនិយមហៅថា អ្នកដូន ឬលោកយាយ ដូចជាដូនពេញ ដូនកែវ យាយម៉ៅ យាយទេព យាយយ៉ាត ជាដើម។ គួរគត់សម្គាល់ថា ឈ្មោះអ្នកតាទាំងប៉ុន្មានដែលធ្លាប់ដឹងធ្លាប់ហៅជាយូរមកហើយនេះ មិនដែលប្តូរឈ្មោះទេគឺឈ្មោះដើមយ៉ាងណា តែងនៅរក្សាឈ្មោះនោះដដែលរាប់ពាន់តំណមមកហើយ។ ត្រង់នេះសបញ្ជាក់ឱ្យឃើញថា ព្រលឹងអ្នកតា ឈ្មោះអ្នកតាទាំង*

[2]ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ៖ *ប្រជុំរឿងព្រេងខ្មែរភាគ៨* ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យឆ្នាំ ២០០១. ទំព័រទី៦៤-៦៨

ប៉ុន្មានគឺមានចរិតអមតៈ អចិន្ត្រៃយ៍ មិនចេះស្លាប់ មិនផ្លាស់ប្តូរ មិនមានអ្នកជំនួស។

ជំនឿលើអ្នកតា អ្នកដូនឬព្រលឹងនិយមនេះមានមកតាំងពីយូរយារណាស់មកហើយៗមិនងាយនឹងផ្លាស់ប្តូរនោះទេ។ នៅស្ទើរគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា មានខ្ទមអ្នកតាសម្រាប់ប្រជាជនគោរពបូជា។ ប្រជាជនខ្មែរមិនអាចរស់នៅដោយគ្មានប្រពៃណីទំនៀមទម្លាប់និងជំនឿជូនតាបានឡើយ។

## ៣-អ្នកតា អ្នកដូនល្បីល្បាញ

នៅប្រទេសកម្ពុជាយើងមានអ្នកតា អ្នកដូនល្បីល្បាញជាច្រើនដូចជា៖

### ៣.១-អ្នកតាដងកើ

មានទីតាំងនៅក្បែរដំណាក់ផៃ មុខព្រះបរមរាជវាំង។ បានជាគេឱ្យឈ្មោះថា អ្នកតាដងកើ ព្រោះអ្នកតានេះជ្រើសរើសទីលំនៅនៅដងទង់ក្បែររាជដំណាក់ផៃ។ ដងទង់នេះសម្រាប់បង្ហូតទង់ជាតិនៅពេលដែលព្រះមហាក្សត្រមិនគង់នៅក្នុងប្រទេស។ នេះជាទម្លាប់ដែលបានអនុវត្តតាំងពីអតីតកាលតរៀងមក។

នៅពេលក្រោយមក ព្រលឹងរបស់អ្នកតា លែងនៅនឹងដងទង់ទៀតហើយ ប៉ុន្តែដោយមានកូនវិហារ យ៉ាងស្អាតមួយត្រូវបានកសាងឡើងនៅខាងជើងដងកើ ជិតព្រះដំណាក់ផៃ ព្រលឹងអ្នកតាក៏ផ្លាស់មកនៅក្នុងទីតាំងនៃកូនវិហារថ្មីនេះវិញ ដោយមានរូបតំណាងសាងអំពីឥដ្ឋ ស៊ីម៉ងត៍ ហើយត្រូវបាន មហាជនបំពាក់គ្រឿងស្បង់ អង្សរ៉ែក កម្រងផ្កាផ្សេងៗ ទៅតាមជំនឿ និងសទ្ធាជ្រះថ្លារៀងៗខ្លួន។ នៅរៀងរាល់ថ្ងៃសីល នៅទីស្នាក់ការរបស់អ្នកតាដងកើ មានសភាពឱឡារិក អ៊ូអរជាងថ្ងៃធម្មតា ព្រោះមាន មហាជនស្រីប្រុសដែលជំពាក់បំណន់ ឬជាអ្នកមានជំនឿ ដែលឮល្បីតពីគេថាអ្នកតានេះស័ក្តិសិទ្ធិណាស់ បើបែរបន់ចង់បានអ្វីនឹងបានសម្រេចដូចបំណង ក៏បាក់ក្លូកមកធ្វើពិធីបន់ស្រន់ក្នុងបំណង ចង់ឱ្យក្តីប្រាថ្នារបស់ខ្លួនបានសម្រេចដូចគេមុនៗ។ ដូច្នេះ គេសង្កេតឃើញមានទិដ្ឋភាពអ៊ូអរលាយឡំដោយសំឡេងពិណពាទ្យ ព្រមទាំងក្លិនធូបក្រអូបឈ្ងុយឈ្ងប់ ហើយថែមទាំងមានផ្សែងហុយទ្រុបទៅលើអាកាសផង។ អ្នកលាបំណន់ និងអ្នកបន់ស្រន់ ដើរប្រជ្រៀតគ្នា ខ្លះកាន់ផ្កា ទៀនធូប ផ្លែដូងខ្ចី ចេក និងវត្ថុផ្សេងៗទៀតដែលជាតង្វាយចំពោះអ្នកតា។

[3] មៀច ប៉ុណ្ណ៖ ប្រពៃណីនិងទំនៀមទម្លាប់ខ្មែរ ភាគ ៤ ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ២០១២ ទំព័រទី១១។

យើងហ៊ានត្រឹមតែសន្និដ្ឋានថា អ្នកតាដងកើនេះ អាចជាព្រលឹងព្រះមហាក្សត្រអង្គណាមួយ ឬវីរជនខ្មែរណាមួយ ដែលមានហឫទ័យស្រឡាញ់ជាតិសាសន៍ខ្មែរ ហើយចង់នៅតាមថែរក្សាអភិបាលការពារប្រជាជាតិខ្មែរឱ្យគង់វង្ស និងរីកចម្រើនរុងរឿង។ ចំណែកប្រជាជាតិខ្មែរនៅតែគោរពស្រឡាញ់ព្រះមហាក្សត្រ ឬវីរជននោះ ដោយទឹកចិត្តគោរពភក្តី ហើយនៅតែមានជំនឿជឿជាក់ទៅលើដួងព្រលឹងរបស់បុព្វបុរសរបស់ខ្លួន ថានឹងជួយដោះទុក្ខធុរ និងបំពេញសេចក្តីត្រូវការរបស់ខ្លួន ដូចកាលដែលលោកមានជីវិតរស់នៅដូច្នោះដែរ។

យើងខ្ញុំសង្កេតឃើញថា អ្នកតាដងកើនេះស័ក្តិសិទ្ធិណាស់។ រៀងរាល់ថ្ងៃ ជាពិសេសថ្ងៃសីលមានប្រជាជាច្រើនកុះករទៅបន់ស្រន់ ឬលាបំណន់ចំពោះមុខអ្នកតាអង្គនេះដោយពេលខ្លះមានទាំងថ្វាយភ្លេងពិណពាទ្យទៀតផង។

**៣.២-លោកតាស្រុះភ្នំដោះក្រមុំ**

ភ្នំដោះក្រមុំ ស្ថិតនៅក្នុងក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី។ នៅលើភ្នំនេះមានអាគារអាស្រមជាទីសក្ការបូជាមួយខ្នងដែលសាងសង់ឡើងក្នុងរចនាបថអាគារលំនៅឋានរបស់ជនជាតិព្នងនៅតំបន់នោះ។ នៅក្នុងអាស្រមនោះមានរូបសំណាកមួយដែលមានមនុស្សម្នា នៅតំបន់នោះគោរពបូជា។ ហើយរូបសំណាកនោះមាននាមថា "លោកតាស្រុះ"។

ប្រវត្តិរឿងរ៉ាវដែលបណ្តាលឱ្យកើតមានឡើងនូវអាគារនិងរូបសំណាកលោកតាស្រុះនេះគឺមានរឿងព្រេងមួយតំណាលថា: មានយុវជនម្នាក់ឈ្មោះស្រុះរស់នៅក្នុងភូមិអូរទ្រូ តែងតែធ្វើដំណើរជាញឹកញាប់ទៅលេងបងប្អូនភូមិត្រពាំងអំបិលហើយបានឃើញយុវតីម្នាក់ឈ្មោះផ្ទំមានរូបសម្បត្តិស្រស់ស្អាតលើសនារីៗនៅក្នុងភូមិនោះ។ បន្ទាប់មកយុវជនស្រុះក៏ជាប់ចិត្តស្រលាញ់យុវតីផ្ទំ ហើយមានទំនាក់ទំនងជាមួយនាងរហូតដល់បានស្គាល់ចិត្តថ្លើមគ្នា។

យុវជនស្រុះបានសុំឪពុកម្តាយចូលដណ្តឹងយុវតីផ្ទំដើម្បីរៀបការ។ ឪពុកម្តាយនាងផ្ទំយល់ព្រមតែពុំទាន់កំណត់ពេលវេលា ព្រោះមង្គលការអាចកំណត់ទៅបានលុះណាតែខាងកូនកំលោះ អាចរកបណ្ណាការសម្រាប់ជូនទៅខាងកូនក្រមុំសព្វគ្រប់សិនដូចជា ក្របី គោ ជ្រូក ពាងសម្រាប់ដាក់ស្រា ព្រមទាំងគ្រឿងអលង្ការជាដើម។

[4] http: www. kampucheathmey.com/kpt 16 June, 2015

ក្នុងពេលដែលគ្រួសារស្រុះរកជំនូនបានហើយ ខាងគ្រួសារនាងផ្ទំ ដែលកំពុងត្រៀមលក្ខណៈទទួលកូនកំលោះនោះក៏ជួនត្រូវចំពេលប្រមូលផលស្រូវដែរ។ បញ្ហារៀបការត្រូវបានពន្យារពេលសិន ព្រោះជនជាតិព្នងមានជំនឿថាអ្វីៗសុទ្ធតែមានព្រលឹង។ ផលស្រូវដែលប្រមូលបានត្រូវយកមកដាក់ក្នុងជង្រុកហើយបើមិនទាន់បានសែននោះទេ គឺមិនអាចឱ្យយកទៅបុកបរិភោគ ឬប្រើប្រាស់ក្នុងពិធីមង្គលការបានឡើយព្រោះនឹងធ្វើឱ្យមានគ្រោះចង្រៃដល់គូស្រករថ្មី។ ដូច្នេះ គេត្រូវរៀបពិធីសែនព្រលឹងស្រូវជាមុនសិន។

ថ្ងៃនេះគ្រួសារយុវតីផ្ទំបានរៀបចំសែនព្រលឹងស្រូវ ដើម្បីអំពាវនាវហៅព្រលឹងស្រូវដែលវង្វេងបាត់នៅក្នុងព្រៃដោយត្រូវសត្វស៊ីបំផ្លាញ ឬដោយអ្នកថែរក្សាព្រៃភ្នំជ្រោះជ្រលងដងអូរចាប់ឃាត់ទុក។ ក្នុងពេលជាមួយគ្នានោះឪពុកម្ដាយយុវតីផ្ទំធ្ងល់យ៉ាងខ្លាំង ព្រោះយុវតីផ្ទំបានទៅដងទឹកយូរពេកមិនឃើញ ត្រឡប់មកវិញ។ គេក៏បានស្រែកប្រកូកហៅនាងគ្រប់ទិសទី ហើយដើរទៅដល់អណ្ដូងទឹក ប៉ុន្តែឃើញតែកាផា និងឃ្លោកសម្រាប់ដងទឹក។

ដំណឹងនេះបានធ្វើឱ្យយុវជនស្រុះព្រួយចិត្តយ៉ាងខ្លាំង។ គេនៅតែបន្តព្យាយាមដើររកយុវតីផ្ទំ ជានិច្ច។ ថ្ងៃមួយយុវជនស្រុះត្រូវទៅកាប់ឫស្សីនៅក្បែរភ្នំពីរ គឺភ្នំមួយមានព្រលឹងលោកយាយដីហូវ ថែរក្សានិងភ្នំមួយទៀតមានព្រលឹងលោកយាយដីហ្គរ ថែរក្សា។ ពេលលោកយាយទាំងពីរឃើញយុវជនស្រុះ ជញ្ជូនឫស្សីមកដាក់ក្បែរអណ្ដូងទឹក លោកយាយទាំងពីរក៏បានប្រាប់យុវតីផ្ទំឱ្យមកជួបគូដណ្ដឹង។ ខណៈនោះយុវជនស្រុះភ្ញាក់ផ្អើលយ៉ាងខ្លាំង។

យុវតីផ្ទំបានរៀបរាប់សេចក្ដីនឹករលឹករបស់ខ្លួនចំពោះយុវជនស្រុះ និងដំណើរជីវិតរបស់នាងក្នុងពេលបាត់ខ្លួន។ នាងបានបញ្ជាក់ថាលោកយាយទាំងពីរបានឃាត់នាង ឱ្យនាងថែរក្សាទឹកដីម្ដុំអស់នេះ។ នាងក៏បបួលយុវជនស្រុះឱ្យមករស់នៅជាមួយនាងដើម្បីកសាងសុភមង្គលជាមួយគ្នា។ យុវជនស្រុះក៏ យល់ព្រមតាមការស្នើសុំរបស់យុវតីផ្ទំ។ បន្ទាប់ពីការបាត់ខ្លួនរបស់យុវតីផ្ទំ ហេតុការណ៍បាត់ខ្លួនរបស់ស្រុះបានធ្វើឱ្យមានការជ្រួលច្របល់ពេញភូមិ ដូច្នេះគេនាំគ្នាប្រារព្ធពិធីបន់ស្រន់។ ក្រោយការបន់ស្រន់គេមិនឃើញមានការបាត់ខ្លួនអ្នកដទៃទៀតឡើយ។ ចូលដល់រដូវធ្វើចម្ការ ឪពុកម្ដាយយុវជនស្រុះបានទៅធ្វើចម្ការនៅឯភ្នំដីហូវ និងភ្នំដីហ្គរហើយបានជួបស្រុះ និងផ្ទំ។ អ្នកទាំងពីរបានរៀបរាប់ថាខ្លួនត្រូវនៅជួយថែរក្សាភូមិស្រុកម្ដុំនេះ សូមកុំឱ្យពុកម៉ែបងប្អូនទាំង

អស់គ្នាពិបាកចិត្តអី បើមានទុក្ខសូមអ្នកទាំងអស់ធ្វើពិធីសែនព្រេនរំលឹកដល់ម្ចាស់ទឹក ម្ចាស់ដី និងបារមីភ្នំទៅ នឹងបានសេចក្តីសុខហើយ។ ម៉្យាងទៀតលោកយាយទាំងពីរបានផ្តាំថា ចាប់ពីថ្ងៃនេះទៅសូមឱ្យអ្នកស្រុកនាំគ្នាហៅភ្នំនេះថា "ភ្នំស្រុះផ្ទុំ" វិញ។

ភ្នំដោះក្រមុំស្ថិតនៅក្នុងក្រុងសែនមនោរម្យដែលជាទីរួមខេត្តមណ្ឌលគិរី ដោយជម្រាលភ្នំខាងត្បូងទល់នឹងព្រលានយន្តហោះ។ ភ្នំនេះគ្របដណ្តប់ទៅដោយវាលស្មៅពីចង្កេះភ្នំរហូតទៅដល់កំពូលភ្នំ។ ទិដ្ឋភាពភ្នំដោះក្រមុំមានលក្ខណៈស្រដៀងទៅនឹងភ្នំជាច្រើនទៀត ដែលមាននៅក្នុងក្រុងសែនមនោរម្យ និងស្រុកដទៃទៀតនៃខេត្តមណ្ឌលគីរី។ ប្រជាជនទាំងខាងបងប្អូនជនជាតិដើមភាគតិច(ខ្មែរលើ)ក៏ដូចជាបងប្អូនខ្មែរទូទៅដែលរស់នៅក្នុងខេត្តមណ្ឌលគិរីបានចាត់ទុកភ្នំដោះក្រមុំជាកន្លែងសក្ការបូជាមួយ។

ទន្ទឹមនឹងនេះដែរ គេបានចាត់ទុកភ្នំដោះក្រមុំជាមជ្ឈមណ្ឌលវប្បធម៌របស់ខេត្តមណ្ឌលគិរី ដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជាទៀតផង។ ឯទឹកដីខេត្តនេះតាំងពីសម័យអាណានិគមបារាំងរហូតដល់ឆ្នាំ ១៩៦១ត្រូវបានគេស្គាល់ថាជាតំបន់ខ្ពង់លើនៃស្រុកមួយក្នុងខេត្តក្រចេះ។

ភ្នំដោះក្រមុំគឺហៅតាមការប្រសិទ្ធនាមរបស់មន្ត្រីរាជរដ្ឋាភិបាលម្នាក់ ដែលតែងតែជិះយន្តហោះទៅបំពេញបេសកកម្មរៀបចំដែនដីតំបន់នោះកាលពីទសវត្សរ៍ឆ្នាំ១៩៥០ និងដើមទសវត្សរ៍ឆ្នាំ ១៩៦០ ដើម្បីបង្កើតខេត្តថ្មីមួយទៀតគឺខេត្តមណ្ឌលគិរី។ នៅពេលយន្តហោះបន្ទាបចុះ លោកតែងចាប់អារម្មណ៍ចំពោះស្ថានភាពភ្នំជាប់គ្នាទាំងពីរនេះដោយនិយាយជជែកគ្នាលេង។ ដូច្នេះហើយ ការប្រសិទ្ធនាមថា "ភ្នំដោះក្រមុំ" នោះ គឺយោងទៅតាមលក្ខណៈរូបរាងភ្នំដែលមានសភាពដូចសុដន់នារីក្រមុំព្រហ្មចារីកំពុងសម្រាកផ្ងារ។ ឈ្មោះនេះបានជ្រួតជ្រាបដល់បងប្អូនជនជាតិព្នង និងបងប្អូនខ្មែរដែលរស់នៅក្នុងខេត្តនេះតាំងពីពេលនោះរហូតមកដល់បច្ចុប្បន្ន[5]។

យើងខ្ញុំសង្កេតឃើញថា ក្រៅពីរមណីយដ្ឋានទឹកជ្រោះធម្មជាតិប៊ូស្រា ប្រជាជនជាច្រើននៅក្នុង ខេត្តមណ្ឌលគិរី ជាពិសេសភ្ញៀវទេសចរដែលមកលេងកម្សាន្តនៅខេត្តនេះតែងឡើងភ្នំដោះក្រមុំ ដើម្បីគោរពបូជាចំពោះលោកតាស្រុះ។

[5] ហ៊ឺ ចិន្តាះ បដិមាសាស្ត្រនៅកម្ពុជា សិក្ខាសាលានៅរាជបណ្ឌិត្យសភាកម្ពុជា ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២។

## ៣៣.លោកយាយម៉ៅជ្រោះពេជ្រនិល

រឿងរបស់យាយម៉ៅ គេពុំទាន់មានឯកសារណាមួយដាក់លាក់ជាប្រវត្តិសាស្ត្រទេ ប៉ុន្តែរឿងនេះត្រូវបានគេនិយាយតៗគ្នាពីមាត់មួយទៅមាត់មួយទាក់ទងនឹងប្រវត្តិយាយម៉ៅ តាំងពីសម័យបុរាណកាលមករហូតដល់សព្វថ្ងៃនេះ។

យោងតាមរឿងព្រេងដែលត្រូវបានតំណាលតៗគ្នា ពីអតីតកាលមកនេះបានកើតឡើង តាំងពីមុនសម័យអាណានិគមបារាំង។ លោកយាយម៉ៅ គឺជាស្ត្រីដ៏ស្អាតផូរផង់ហើយបានរៀបការជាមួយនឹងមេទ័ពម្នាក់។ ក្រោយពេលដែលស្វាមីរបស់គាត់ធ្វើមរណកាលក្នុងសង្គ្រាមរវាងកម្ពុជានិងថៃ គាត់ក៏បានដឹកនាំទ័ពឡើងប្រឆាំងតបវិញ។ ពេលនោះ លោកយាយក៏បានក្លាយជាវីរនារីដ៏ល្បីល្បាញរបស់ជនជាតិខ្មែរ។ រឿងតំណាលមួយទៀតថា ស្វាមីរបស់ដូនម៉ៅជាមេទ័ព បានចេញទៅធ្វើសង្គ្រាមតាមផ្លូវសមុទ្រ ដោយសារតែនឹកស្វាមី ខ្លាំងពេកដូនម៉ៅនោះក៏ទៅតាមរកហើយក៏បានមកដួលស្លាប់នៅខេត្តកោះកុងក្លាយជាអ្នកដូន។

ដោយឡែក មានរឿងនិទានមួយទៀតដំណាថា កាលពីសម័យមុនមានមេកន្ទ្រាញម្នាក់ឈ្មោះដុច ត្រួតត្រាកុលសម្ព័ន្ធជនជាតិព័រនៅស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ដែលពីមុនហៅថាព្រៃខ្វាដំរី។ តាដុចមានឫទ្ធិអំណាចខ្លាំងពូកែណាស់ ជាមនុស្សធ្មឹងដែក ស្បែកស្លាន់ ហើយកាលនោះមានយុវតីម្នាក់ជនជាតិព័រឈ្មោះនាងម៉ៅមានរូបឆោមល្អល្អះ ត្រូវបានមេកន្ទ្រាញយកធ្វើជាភរិយា។ ក្រោយយាយម៉ៅនិងតាដុចស្លាប់ បានបន្សល់ទុកទ្រព្យសម្បត្តិជាច្រើន ដោយហេតុថា ពួកគាត់គ្មានកូនបន្តពូជពង្សចិត្តរបស់ពួកគាត់នៅមិនដាច់អាល័យ ក៏ចាប់ជាតិជាអ្នកតាអ្នកដូន នៅចាំយាមថែរក្សាទឹកដីនោះតែម្តង។ បន្ទាប់មក មេកន្ទ្រាញ ដែលឡើងកាន់តំណែងក្រោយៗ ក៏នៅតែគោរពកោតខ្លាចតាដុចយាយម៉ៅ ដូចកាលនៅរស់ ថែមទាំងយកដុំថ្ម២ដុំធំៗដាក់ទន្ទឹមគ្នា ធ្វើរោងប្រក់ស្បូវគ្រង់ផ្ទះតាយាយ ដោយឧបកិច្ចសុំឱ្យពួកគាត់តាមថែរក្សាជនជាតិព័រ កុំឱ្យមានជំងឺតម្កាត់អ្វីឡើយ។ គ្រាមួយ ដូនម៉ៅ បានចូលសណ្ឋិតក្នុងរូបស្នងម្នាក់ហើយប្រាប់អ្នកស្រុកថា គាត់មានភារកិច្ចតាមថែរក្សាមនុស្សលោក មិនត្រឹមតែតំបន់ភ្នំក្រវាញនេះទេ ខេត្តផ្សេងៗទៀតរួមមានខេត្តកំពង់ស្ពឺខេត្តកោះកុង ក្រុងកំពង់សោម ពិសេសកូនចៅដែលធ្វើដំណើរតាមសមុទ្រ ក៏លោកយាយតាមមើលថែរក្សាដែរ។

ដោយសារតែហេតុនេះ ទើបអ្នកជំនាន់ក្រោយបានរៀបចំការសែនព្រេនជូនលោកយាយម៉ៅ និងលោកតាដុចរឿង

រាល់ឆ្នាំនៅអំឡុងខែមិថុនា។ អ្នកមានជំនឿតែងនាំគ្នាទៅវត្តឬក៏ទីសក្ការៈនានាដើម្បីគោរពបូជា។ គេនាំយកសំណែនដូចជាក្បាលជ្រូក មាន់ស្ងោរ និងគ្រឿងសក្ការៈមាន ដូចជា ស្លាធម៌ ដូងទុំ ផ្កាភ្ញីនិងបាយសីតាមទំនៀមទម្លាប់របស់ប្រជាជនខ្មែរ ទៅសែនលោកយាយ លោកតារហូតមកដល់សព្វថ្ងៃ។

តាមរយៈស្នាដៃនិពន្ធរបស់លោកសេក សុផាត និងលោកស្ដើង ធូរ កាលពីរវាងឆ្នាំ១៨៦៦អ្នកដូនម៉ៅនេះកាចណាស់ គឺបើអ្នកណាធ្វើដំណើរកាត់តាមផ្លូវជ្រោះភ្នំពេជ្រនិល ហើយមិនបានបង្អង់ឈប់ដើម្បីសុំសេចក្ដីសុខសប្បាយទេ ឬប្រព្រឹត្តចោរកម្មផ្សេងៗ អ្នកដូននឹងធ្វើជាហេតុផ្សេងៗ មានជំងឺតម្កាត់ឬមើលផ្លូវដែលត្រូវធ្វើដំណើរមិនឃើញដែលអាចបណ្ដាលឱ្យបើកខុសផ្លូវមានគ្រោះថ្នាក់ដល់ជីវិត។ មួយវិញទៀត បើអ្នកណាមានគំនុំហើយមានប្រាថ្នានឹងព្យាបាទអ្នកដទៃ ហើយទៅធ្វើការបន់សុំឱ្យអ្នកដូនជួយទៅបង្ក្រាបគូសត្រូវរបស់ខ្លួនដោយសន្យាថា បើបានសម្រេចដូចការបន់ នឹងថ្វាយវត្ថុអ្វីមួយនោះ អ្នកដូនក៏ទៅកាច់ ធ្វើតាមបំណងអ្នកដែលបន់នោះក៏មាន។ ដោយហេតុតែកាចសាហាវយ៉ាងនេះ ទើបបារាំងសែស (ក្នុងសម័យអាណានិគមបារាំងរវាងឆ្នាំ១៩០០ ប្លាយ) បានទៅបាញ់ទីសក្ការៈអ្នកដូននោះម្ដង។ តាំងពីពេលនោះមក អ្នកដូននេះ ក៏ថយអានុភាពបន្តិចៗ លុះអំឡុងឆ្នាំ១៩៤០ ជំនាន់ជប៉ុនចូលស្រុក បានកេណ្ឌប្រជាពលរដ្ឋចំណុះខេត្តកំពតឱ្យទៅជីកលេណដ្ឋាន នៅត្រង់ថ្នល់បត់ភ្នំទ្វារកំពតនោះ ហើយពលករទាំងនោះ បានទៅធ្វើម៉ុំបរិវេណទីសក្ការៈដូនម៉ៅឱ្យស្មោកគ្រោកមានបន្ទោរបង់លាមកពាសវាលពាសកាល គាត់មានការខឹងសម្បា អ្នកទាំងនោះជាខ្លាំង ទើបដូនម៉ៅ ក៏ធ្វើឱ្យមានជំងឺស្លាប់អស់ជាច្រើននាក់។ អ្នកខ្លះទៀតមានជំងឺឈឺតាំងពីកន្លែងកាប់ដីរហូតដល់ផ្ទះក៏ស្លាប់ ស្លាប់រង្គាលចោលប្រពន្ធ កូនឱ្យនៅមេម៉ាយគរគោក រហូតទាល់តែបាននាមថាមេម៉ាយជំនាន់ជប៉ុនកេណ្ឌ។ ដោយឃើញហេតុការស្ដែងយ៉ាងនេះ បានជាអ្នកស្រុកទាំងខ្មែរ ទាំងចិន យួន ចាម ជ្វា បាក់បបខ្លបខ្លាចបារមីយាយម៉ៅ។ ម្នាក់ៗ កាលបើមានការត្រូវធ្វើដំណើរទៅដល់កន្លែងនោះ គេមានការប្រុងប្រយ័ត្ន មានវត្ថុកំដរដៃសម្រាប់ថ្វាយអ្នកដូនម៉ៅពុំដែលខានឡើយ[6]។

[6] *https : www. twitter.com/share* 17July, 2014

## ៣.៤-អ្នកតានៅភ្នំឈើកាច់

តាមអ្នកប្រវត្តសាស្ត្រខ្លះ តំបន់ភូមិសាស្ត្រភ្នំឈើកាច់ស្រុកបាភ្នំ គឺជាអតីតរាជធានីខ្មែរ ដែលមានឈ្មោះថាវ្យាធបុរៈឬទីក្រុងទាក់ដំរី។ ប៉ុន្តែតាមមតិរបស់អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រខ្លះទៀតថា ក្រុងវ្យាធបុរៈនេះទីតាំងនៅអង្គរបូរី ក្នុងខេត្តតាកែវវិញ។ ពិធីឡើងអ្នកតានៅបាភ្នំនេះ ជារៀងរាល់ឆ្នាំតែងមានសភាពឱឡារិកអធិកអធមខ្លាំងណាស់។ គេឃើញមន្ត្រីធំៗនៃក្រសួងវប្បធម៌ មន្ត្រីសំខាន់ក្នុងព្រៃវែង អ្នកសិល្បករ អ្នកកាសែត ទូរទស្សន៍បានចូលរួមក្នុងពិធីដែលប្រព្រឹត្តទៅក្នុងរយៈពេលបីថ្ងៃ ហើយដែលមហាជននៅតំបន់ជិតខាងតែងតែទៅចូលរួមស្ទើររៀងរាល់ឆ្នាំ។ មានការរៀបចំរណ្ដាប់ តង្វាយ និង គ្រឿងសក្ការៈបូជាចំពោះអ្នកតា ការប្រគុំភ្លេងល្បីៗខាងតន្ត្រីបុរាណសម្រាប់បញ្ចូលរូប ជួនកាលក៏តម្រូវឱ្យមានវង់ភ្លេងពិណពាទ្យជាចាំបាច់ផងដែរ។

នេះបញ្ជាក់ថា ប្រជាជននៅទីនេះមានការគោរពអ្នកតាខ្លាំងណាស់ ហើយមិនត្រឹមតែប៉ុណ្ណោះ
គេថែមទាំងរៀបចំពិធីឡើងអ្នកតាមិនដែលខកខានឡើយ។

## ៣.៥-អ្នកតាឃ្លាំងមឿង

នៅក្នុងខេត្តពោធិ៍សាត់ មានអ្នកតាធំមួយដ៏ល្បីល្បាញ ដែលមានលំដាប់ថ្នាក់ក្រមិតជាតិផងដែរ។ តាមព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនាសតវត្សរ៍ទី១៦ ក្នុងរជ្ជកាលព្រះបាទចន្ទរាជា មានវីរជនស្នេហាជាតិម្នាក់ឈ្មោះ តាពេជស្ម័គ្រចិត្តបម្រើព្រះចន្ទរាជាក្នុងនាមជាមេទ័ព។ ក្នុងការតស៊ូប្រយុទ្ធដ៏ខ្លាំងក្លាជាមួយទ័ពជេដ្ឋាធិរាជនៅបន្ទាយខេត្តពោធិ៍សាត់លោកតាពេជឃើញសេនាទាហានស្លាប់ច្រើនពេក ដោយទ័ពខាងថៅហ្វាកៅ មានទាហានច្រើនលើសលុបនោះ តាពេជ ក៏ទូលសុំព្រះអង្គចន្ទរាជាទៅកេណ្ឌទ័ពខ្មោចមកជួយច្បាំង។ នៅក្នុងពេលធ្វើហោមពិធីដ៏ឱឡារិកនោះ លោកតាពេជក៏លោតចុះទៅក្នុងរណ្ដៅហើយក៏បានស្លាប់បាត់បង់ជីវិតដោយសារមុតនឹងចុងដាវ លំពែង ដែលដាំច្រូងច្រាង នៅក្នុងរណ្ដៅនោះទៅ។ បន្ទាប់ពីនោះមក នៅថ្ងៃពេញបូណ៌មីខែពិសាខ ធាកប្រយុទ្ធដ៏ធំសម្បើមអស្ចារ្យក៏ប្រព្រឹត្តឡើង រវាងទ័ពព្រះចន្ទរាជា និងទ័ពស្ដេចកន។ ក្នុងយប់ងងឹតនោះ ស្រាប់តែគេបានឮសន្ធឹកគ្គងគ្គាំងគ្រាំគ្រេងដូចមេឃរលំភ្នំរលើងធ្វើឱ្យពួកទ័ពដែលចោមរោមព័ទ្ធបន្ទាយត្រូវបាក់បែករត់ខ្ចាត់ខ្ចាយស្លាប់អស់ពលរេហ៍ជាច្រើនឥតគណនា។ ជ័យជម្នះដ៏កក្រើកទឹកកក្រើកដីនេះ ត្រូវបានភាគីខាងចន្ទរាជាសន្មតថា បានមកដោយសារមានទ័ពខ្មោច បិសាចដែលលោកតាពេជ

បានទៅកេណ្ឌាមកជួយ។ គេលុបរណ្ដៅត្រង់កន្លែងដែលចៅពញាមឿងស្លាប់ ហើយក្រោយមកព្រលឹងអ្នកតាឃ្លាំងមឿងក៏បានមកសណ្ឋិតនៅគ្រប់គ្រង់រណ្ដៅនោះ។ ពីជំនាន់មួយទៅជំនាន់មួយ គេនាំគ្នាប្រារព្ធធ្វើពីធីឡើងអ្នកតាដ៏អធិកអធមគគ្រឹកគគ្រេង ដើម្បីរលឹកគុណូបការរបស់ពញាមឿងនៅខែពិសាខ ជារៀងរាល់ឆ្នាំ។

ចំពោះប្រវត្តិរឿងរ៉ាវទាក់ទងនឹងអ្នកតាឃ្លាំងមឿងនេះមានដូចតទៅ៖

ក្នុងអតីតកាលកន្លងទៅ ក្នុងរាជព្រះចន្ទរាជា ស្ដេចគង់នៅបន្ទាយលង្វែកគ.ស.១៥០២។ កាលជាន់នោះ ស្រុកខ្មែរជាស្រុកចំណុះសៀមនៅឡើយ តែងនាំសួយសារអាករឡើងទៅស្រុកសៀម។ ព្រះចៅសៀមចាត់ព្រះរាជបុត្រមួយអង្គ មាននាមមិនប្រាកដ ឱ្យមកនៅស្រុកខ្មែរដើម្បីមើលការខុសត្រូវ ធ្វើជាអ្នកត្រួតត្រាខាងពន្ធអាករគ្រប់យ៉ាង ក្រែងស្ដេចស្រុកខ្មែរ មានចិត្តមិនត្រង់ បំបាត់សួយសារអាករយកទៅមិនអស់ ឬមួយក្រែងស្ដេចខ្មែរមានគំនិតក្បត់មានចិត្តមិនត្រង់ នឹងរាជការ ដោយប្រការណាមួយទើបប្រើព្រះរាជបុត្រពេញព្រះហឫទ័យមកនៅដើម្បីជំនួសព្រះនេត្រព្រះអង្គ។ ចំណែកព្រះរាជបុត្រមានចិញ្ចឹមសត្វឆ្មាតមួយ ឆ្មាតនោះមានមារយាទ ចេះដឹងប្រហែលមនុស្សជាសត្វខុសពីសត្វដទៃធម្មតា ចេះស្រឡាញ់ម្ចាស់ប្រើនាំសារទៅមករវាងស្រុកខ្មែរនឹងស្រុកសៀមបានដោយស្វាត់។

ថ្ងៃមួយ ព្រះចន្ទរាជានឹកព្រួយព្រះទ័យថា ព្រះចៅលោកមិនទុកព្រះហឫទ័យនឹងយើងហើយ បានជាលោកចាត់ព្រះរាជបុត្រឱ្យមើលការផ្ទាល់ ណាមួយព្រះរាជបុត្រនោះមានការរំលោភបៀតបៀន មិនមានសេចក្ដីកោតក្រែង បង្គាប់ឱ្យនាំសួយឡើងនគរខ្ជួនហួសហេតុ។ ទ្រង់តូចព្រះហឫទ័យយ៉ាងខ្លាំង អត់ទ្រាំពុំបាន ក៏បង្គាប់ពួកពេជ្ឈឃាដឱ្យចាប់រាជបុត្រស្ដេចសៀមយកទៅសម្លាប់ចោលក្នុងព្រៃក្នុងពេលយប់។ ចំណែកសត្វឆ្មាត លុះព្រឹកឡើងមិនឃើញព្រះរាជបុត្រជាម្ចាស់របស់វា ហើរចុះហើរឡើងរកឃើញខ្មោចនៅក្នុងព្រៃ ឆ្មាតឃើញព្រះទម្រង់ វាស្គាល់ច្បាស់ជាម្ចាស់វាក៏ចឹកពាំព្រះទម្រង់ទៅស្រុកសៀមថ្វាយព្រះបិតា។ ព្រះចៅទតឃើញព្រះទម្រង់ទ្រង់យល់ថា ព្រះរាជបុត្ររបស់ព្រះអង្គដល់ទិវង្គតហើយ រឿងនេះពិតជាស្ដេចស្រុកខ្មែរសម្លាប់។ ទ្រង់ក្រោធខ្លាំងណាស់កោះប្រជុំពួកសេនាបតីមួយរំពេច មានព្រះបន្ទូលប្រាប់តាមរឿង រួចបង្គាប់ឱ្យលើកកងទ័ពមកសងសឹកស្ដេចស្រុកខ្មែរវិញ ហើយមានព្រះបន្ទូលថា ត្រូវតែសម្លាប់ព្រះចន្ទរាជា ព្រមទាំងញាតិ សាច់

សាលោហិត ទាំងពួកសេនាបតី ហើយរឹបជាន់យកទ្រព្យសម្បត្តិ និងកៀរពួកបណ្ដារាស្ត្រ មកស្រុកសៀមកុំឱ្យសល់។ ពួកកងទ័ពក៏ចេញមក។ មកដល់បន្ទាយលង្វែកចូលឡោមព័ទ្ធចាប់ព្រះចន្ទរាជាសម្លាប់ព្រមទាំងព្រះញាតិ។ ចំណែកព្រះម្នាងប៉ែនជាស្នំ ក៏កៀសខ្លួនរួចអំពីគ្រោះថ្នាក់ជាមួយនឹងសេនាបតី មឿង ព្រមទាំងភរិយា និងបុត្រ៤នាក់ទៀត។ ពួកកងទ័ពសៀមកៀរមនុស្សអំពីស្រុកខ្មែរដោយទាំងព្រះម្នាងប៉ែនទៅជាមួយផងទាំងព្រះរាជទ្រព្យមានវិញ្ញាណឥតវិញ្ញាណ។ ចំណែកមេដំរីសមួយមានកូននៅក្នុងពោះឈ្មោះជំទាវប៉ាលប៉ៃ ដែលជាព្រះទីនាំងដ៏ប្រសើរក៏ត្រូវកងទ័ពសៀមកៀរយកទៅដែរ។ ពួកសៀមជាន់នោះ មានសេចក្ដីព្យាបាទ ធ្វើបាបខ្មែរអស្ចារ្យណាស់ ចាប់មនុស្សដោតស្មឹកត្រចៀក ដឹកយកទៅដូចជាសត្វជាតុស្រីណាមានកូនខ្ចី ចាប់ប្រកការុងឱ្យដំរីជាន់ វៀរលែងតែមានកូននៅក្នុងពោះ។ លុះទៅដល់ស្រុកសៀមនាំសេចក្ដីទៅថ្វាយព្រះចៅដោយសព្វគ្រប់។ ដោយសេចក្ដីសង់សឹកបានសម្រេចដូចប្រាថ្នា ព្រះចៅទ្រង់បង្គាប់ឱ្យយកពួកខ្មែរទាំងអស់ទៅនៅមួយក្រុមជិតក្រុង ហើយសន្មត់ឱ្យឈ្មោះថាក្រុមខ្មែរអ្នកគ្រួ។

ព្រះម្នាងប៉ែន ហាក់ជាស្រីមានបុព្វវាសនា ទុកណាជានាងទទួលគ្រោះថ្នាក់ដោយសៀមកៀរយកទៅយ៉ាងនឹងក៏ដោយនាងគង់នៅជាស្រីប្លែកអំពីស្រីផ្សេងៗទៀត។ ដោយអំណាចកូន ដែលនៅក្នុងគភ៌ជាកូនមានឥទ្ធិឫទ្ធិ មានបុណ្យក៏បណ្ដាលឱ្យអ្នកផងជិតខាងមានចិត្តទោរទន់ រាប់អានស្រឡាញ់ ជួយឧបត្ថម្ភ ជួយយកអាសានាងគ្រប់យ៉ាង។ លុះនាងមានគភ៌គ្រប់ខែដប់ក៏ប្រសូតបុត្រមកដោយសុខសប្បាយ អ្នកជិតខាងទាំងប្រុសទាំងស្រី ជួយថែទាំផ្ដល់ទឹកក្ដៅទឹកត្រជាក់ អ្នកណាក៏មកមិនមានខាន ដោយអំណាចគុណបុណ្យតេជៈបារមីនៃទារកនោះ។ លុះប្រសូតបាន៣ថ្ងៃ ពួកក្រុមញាតិមិត្តមូលមាត់គ្នាឱ្យឈ្មោះកូននោះថា ឧទេន។

ចំណែកមេដំរីដែលជាព្រះទីនាំងក៏កើតកូនក្នុងថ្ងៃតំណាលទារកនោះដែរ តែមេដំរីនោះ ផ្ដាច់ខ្សែទន្ទឹងទៅកើតកូននៅក្នុងព្រៃឆ្ងាយ លាក់មិនឱ្យអ្នកណាមួយដឹងឡើយ ដរាបដល់៣ថ្ងៃ ទើបនាំកូនមកកាន់ទីកន្លែងដើមវិញ។ កូនដំរីនោះមានពណ៌សម្បុរ ព្រមទាំងមានរូបរាងល្អប្លែក អំពីដំរីធម្មតា អ្នករក្សាដំរីនាំដំណឹងទៅក្រាបទូលព្រះចៅគ្រប់សព្វព្រះចៅពេញព្រះហឫទ័យណាស់ ។

តំណាលពីកុមារឧទេន លុះបានអាយុប្រាំឆ្នាំ ដឹងសេចក្ដីខុសត្រូវខ្លះ នឹកភ្នករកបិតាសួរម្ដាយថាឪពុកខ្ញុំទៅណាពុំដែលឃើញក្មេងគេឯទៀតមានម្ដាយ ឪពុកខ្ញុំមិនឃើញមានឪពុកដូចគេ។ ម្ដាយកាលបើឮកូនសួរដូច្នោះ នាងណែនក្នុងទ្រូង អួលអាក់ខ្ទោចផ្សារនិយាយប្រាប់កូនមិនរួច ក៏និយាយបន្ទែបន្ទប់រឿងវៀសទៅកុំឱ្យកូនសួរទៀតពីព្រោះខ្លាចក្រែងរឿងនោះមិនជិតដឹងទូទៅនឹងដល់នូវសេចក្ដីអន្តរាយនៃជីវិត។ កូនចេះតែសួរញយៗ នាងក៏និយាយបង្វែះពង្វាងមិនឱ្យសួរបាន ដរាបដល់កូននោះអាយុ១២ឆ្នាំ។ ថ្ងៃមួយនាងនឹកថា កូននេះខានប្រាប់ពុំបាន ក៏នាំកូនទៅកាន់ទីស្ងាត់តែពីរនាក់ តំណាលរឿងរ៉ាវតាំងពីដើមដល់ចុង កូនស្ដាប់បានយល់សេចក្ដីសព្វគ្រប់ ប្រាប់ម្ដាយឱ្យអត់ទ្រាំសិនចុះកូននឹងគិតរកមធ្យោបាយណាមួយដើម្បីនឹងវិលទៅនគរវិញ ។ ចំណែកកុមារឧទេនចាប់ផ្ដើមតាំងពីថ្ងៃដែលបានស្ដាប់ពាក្យម្ដាយមក ក៏ខំស្វែងរៀនសូត្រវិជ្ជាគ្រប់យ៉ាងមានអក្សរជាដើម ឧទេន ជាកុមារឆ្លាតវៀងវៃ អង់អាចប្លែកអំពីកុមារធម្មតា។

ថ្ងៃមួយ កុមារឧទេនចូលទៅសេពគប់នឹងពួកហ្មដំរី សុំខ្លួនជាអ្នកបម្រើបោសប្រាសពេងដំរី ដើម្បីរៀនវិជ្ជាខាងហ្មដំរីឱ្យស្ទាត់ ថ្ងៃមួយព្រះចៅស្ដេចយាងមកទតពេងដំរី ឃើញកុមារនោះ ជួយធ្វើនេះធ្វើនោះ ដោយយកចិត្តទុកដាក់រហ័សរហួនរាងវៃ មានព្រះបន្ទូលសួរថា ក្មេងនេះមកពីណា ហ្មដំរីក្រាបទូលតាមដំណើតដោយសព្វគ្រប់ ទ្រង់ពេញព្រះហឫទ័យមានព្រះបន្ទូលប្រាប់ថា ចូរមើលក្មេងនេះផង។ ចាប់ផ្ដើមពីថ្ងៃនោះមកកុមារខំយកចិត្តទុកដាក់ធ្វើការដោយហ្មត់ចត់ បោសប្រមូលអាចម៍ដំរី ដុតបំពក់ជាជី ដើម្បីយកទៅដាំស្ពៃស្ពៃក៏មានគុម្ពធំប្លែក ចម្លែកអំពីស្ពៃអ្នកស្រុកធម្មតា។ លុះស្ពៃនោះធំល្មមដក កុមារឧទេនដកយកទៅលាងយ៉ាងស្អាត រែកយកទៅថ្វាយព្រះចៅ ទ្រង់ទតឃើញមានព្រះបន្ទូលថា  នែ! កុមារឯងបានស្ពៃនេះមកពីណា ប្លែកពីស្ពៃធម្មតា។ កុមារក្រាបទូលតាមដំណើរសព្វគ្រប់ ព្រះចៅទ្រង់ប្រទានរង្វាន់ និងមុខងារជាអ្នកត្រួតត្រាភ្នាក់ងារខាងដំរី។

ដំរីជាកូនមេដំរីឈ្មោះដំទាវប៉ាលប៉ៃ ដែលជាទីនាំងដ៏ប្រសើររបស់ព្រះចៅ ក៏ស្រាប់តែចុះប្រេង មានកិរិយាខុសប្រក្រតី កាចសាហាវមិនព្រមស្ដាប់បង្គាប់ព្រិចហ្មស្ទាប់ មិនមានអ្នកណាមួយអាចដឹកបាន ថែមទាំងធ្វើបាបអ្នកស្រុក បោចពោចផ្ទះសម្បែងផ្អើលជ្រួលច្របល់រត់ខ្ចាត់ខ្ចាយចោលទីលំនៅរៀងៗខ្លួន។ ពួកអ្នកគង្វាលដំរីនាំសេចក្ដីទៅទូលព្រះចៅ។

ទ្រង់ចាត់ការឱ្យស៊ើបសួររកអ្នកណាដែលអង់អាច ក្លាហាន ហ៊ានទៅចាប់ដំរីនោះបាន។ ពេលនោះកុមារឧទេនឆ្លើយថាខ្ញុំហ៊ានទទួលការចាប់ដំរីនោះឱ្យបានទើបទ្រង់ប្រគល់ការទៅកុមារឧទេនចាត់ការយ៉ាងណាឱ្យតែចាប់បានព្រះទីនាំងនោះ។ ឧទេនបង្គាប់ឱ្យប្រមូលដំរី៥០០មកដើម្បីនឹងរើសយកដំរីណាគួរយកមកធ្វើផ្ទាក់បាន ទើបរើសយកមេដំរីសឈ្មោះជំទាវប៉ាល់ប៉ែ។ ពេលចេញទៅចាប់ កុមារឧទេនបង្គាប់ឱ្យរៀបពិធីបួងសួងសែនព្រេនអឹកធឹក។ អ្នកស្រុកផ្អើលមកមើលគឹកកង ពាសពេញមីរដេរដាស។ លុះសែនព្រេនរួចកុមារឧទេនបង្គាប់ឱ្យយកចេក៣ស្និតអំពៅ៣បាច់ ពេលទៅដល់ ព្រះទីនាំងស្ទុះមករកហាក់ដូចជាប្រុងនឹងព្រិចតែបែរទៅជាក្រាបថ្វាយបង្គំវិញ ដោយអំណាចតេជៈបុណ្យបារមីនៃឧទេន។ និយាយទូន្មានប្រដៅ ថា ទីនាំងឯង តាំងពីថ្ងៃនេះទៅលះបង់មារយាទអាក្រក់ចេញទៅ ត្រូវធ្វើឱ្យស្លូតល្អដូចពីដើមឱ្យចេកនិងអំពៅស៊ីរួច និយាយថាឯងទៅតាមយើងថាតែប៉ុណ្ណោះស្រាប់តែដំរីដើរតាមទៅដោយស្រួលឥតបាច់ចាប់ចងអ្វីឡើយហាក់ដូចជាហ្មចាស់យូរមកហើយ។

ចាប់ផ្ដើមតាំងពីថ្ងៃដែលទៅយកព្រះទីនាំងមក ព្រះចៅទ្រង់ប្រទានរង្វាន់ឱ្យឧទេន និងប្រទានងារថា ជ័យអស្ចារ្យ ជាសេនាខាងទ័ពដំរីនិងខាងទាក់ដំរីព្រៃ។ ពួកអ្នករាជការទទួលស្គាល់ ខ្លាចអំណាចឧទេនថាជាអ្នកមោះមុតស្ទាត់ជំនាញខាងហ្វឹកដំរីសូម្បីតែពេលចេញទៅទាក់ដំរីព្រៃម្ដងៗមិនចាំមានគ្នាច្រើនប៉ុន្មាន ក៏ទៅទាក់បានដែរ ហាក់ដូចជាហៅមកបាន ព្រះចៅទ្រង់ពេញនិងទុកព្រះហឫទ័យលើជ័យអស្ចារ្យប្រហែលគ្នានឹងព្រះរាជបុត្ររបស់ព្រះអង្គ។

លុះដល់អាយុ១៦ឆ្នាំ ជ័យអស្ចារ្យក្នុកទឹកដល់បំណងដើម ក៏រំពឹងគិតរកឧបាយណាមួយនឹងដោះខ្លួនចេញអំពីកណ្ដាប់ដៃសៀម ហើយទៅនៅស្រុកខ្មែរសោយរាជ្យស្នងព្រះបិតានិងនាំយកមនុស្សអំពីស្រុកសៀមទៅស្រុកខ្មែរវិញព្រមទាំងទ្រព្យសម្បត្តិមានវិញ្ញាណឥតវិញ្ញាណទៅឱ្យអស់អំពីស្រុកសៀមឱ្យបានសម្រេចដូចសេចក្ដីបំណង។

ជ័យអស្ចារ្យដើរនយោបាយចាត់មនុស្ស១៥នាក់ ដែលជាមនុស្សទុកចិត្តស្និទ្ធស្នាល ដូចបងប្អូនបង្កើតធ្វើជាលនិងឈើជើងដំរីឱ្យយកជាលច្រកអាចម៍ដំរីញាត់ឱ្យណែន ទុកឱ្យស្ងួតចាក់រាយតាមស្ទឹង ឬផ្លូវ យកឈើជើងដំរីដើរសង្កត់ជាស្នាមដានដូចជាដំរីដើរមែនៗ ដើម្បីឱ្យអ្នកស្រុកឃើញ ហើយបាននាំព័ត៌មាននោះក្រាបទូលព្រះចៅៗនឹងទ្រង់ចាត់ឱ្យសេនា

ជ័យអស្ចារ្យខ្លួនទៅតាមទាក់មិនខាន ម្យ៉ាងទៀតដើម្បីឱ្យពលដែលព្រះចៅចាត់ឱ្យទៅជាមួយ ជឿជាក់ក្នុងចិត្តថា ជាដានដំរីពិតមែន។

ចំណោកអ្នកស្រុកលុះឃើញដានជើងដំរីនិងអាចម៍ធំៗអណ្តែតតាមទឹកមកដូច្នោះក៏នាំសេចក្តីនោះទៅក្រាបទូលព្រះចៅៗ ទ្រង់ប្រើជ័យអស្ចារ្យឱ្យទៅតាមទាក់ដំរីព្រៃដែលមានដានជើងធំនោះៗ ជ័យអស្ចារ្យក្រាបទូលថា សូមព្រះមេត្តាប្រោសបើទ្រង់សព្វព្រះទ័យចង់បានដំរីធំបែបនោះលុះត្រាតែមានគ្នាច្រើន និងដំរីធ្នាក់ក៏ច្រើន ហើយឱ្យមនុស្សដែលទៅជាមួយទូលព្រះបង្គំទាំងប៉ុន្មាន ស្តាប់បង្គាប់ទូលបង្គំ ទើបធ្វើការនោះបាន ពេលចេញទៅសូមព្រះអង្គមេត្តាអនុញ្ញាតឱ្យធ្វើពិធីបួងសួងផង ឱ្យមានជោគជ័យ។ ព្រះចៅទ្រង់អនុញ្ញាតគ្រប់សំណូមពរប្រគល់ការនោះឱ្យជ័យអស្ចារ្យតាមត្រូវការធ្វើបែបណាៗស្រេចនៅលើជ័យអស្ចារ្យចុះ។ លុះរៀបធ្វើពិធីរួច ព្រះចៅប្រទានព្រះខ័នសឹកឱ្យអំណាចពេញ បើឈ្មោះណាមិនស្តាប់បង្គាប់អាចសម្លាប់បាន។ លុះចេញទៅបានចំនួន១៥ថ្ងៃដល់ពាក់កណ្តាលផ្លូវមកស្រុកខ្មែរ ជ័យអស្ចារ្យធ្វើសារទៅក្រាបទូលព្រះចៅវិញថា សូមទ្រង់មេត្តាប្រោស ទូលបង្គំជាខ្ញុំតាមទាក់ដំរីធំនោះកាន់តែឃើញដានកៀកហើយ តែអស់ស្បៀង សូមព្រះអង្គមេត្តាប្រោសព្រះរាជទានបញ្ជូនមកឱ្យឆាប់ ដើម្បីនឹងធ្វើការឱ្យបានសម្រេចដូចបំណង។ ព្រះចៅទ្រង់ព្រះរាជទានតាមសេចក្តីសុំដោយរួសរាន់ ដោយបំណងចង់បានដំរីនោះពេក ភ្លេចគិតអំពីការបង់ខាតព្រះរាជទ្រព្យឬសង្ស័យដោយហេតុណាមួយឡើយ។

ជ័យអស្ចារ្យលុះបានទទួលស្បៀងអំពីព្រះចៅក៏បន្តដំណើរទៅទៀតចំនួន៥ថ្ងៃក្រោយមកក៏បានដល់ស្រុកបាត់ដំបង ដែលជាដីខ្មែរ មានអ្នកស្រុកជិតឆ្ងាយគ្រប់តំបន់រត់មកចុះចូលថ្វាយខ្លួនជាពលសេនាព្រមទាំងសេនាចាស់ម្នាក់ធ្លាប់បម្រើព្រះវរបិតាឈ្មោះ មឿង និងកូនប្រុស៤នាក់បានចូលមក ថ្វាយខ្លួនដែរ ក៏មានមនុស្សច្រើនល្មមតទល់នឹងព្រះចៅសៀម។ ជ័យអស្ចារ្យក៏សរសេរសំបុត្រចងនឹងដំរីប្រើឱ្យទៅអញ្ជើញម្តាយមកស្រុកខ្មែរ រួចចងកូនដំទាវប៉ាលប៉ៃឱ្យទៅទទួលម្តាយ។ មេដំរីទៅដល់ទឹកន្ទ្វេងម្តាយ ពេលពាក់កណ្តាលអាធ្រាត្រ មេដំរីវាទម្ទាក់បំពង់៣ដង ម្តាយភ្ញាក់នឹកស្មានថាកូន ត្រឡប់មកវិញ ក៏អុជភ្លើងបំភ្លឺមើល តែមិនឃើញកូនឃើញតែសំបុត្រ មើលដឹងសេចក្តីសព្វគ្រប់ រៀបដំណើរឡើងជិះមេដំរីយ៉ាងប្រញាប់ខំស្រូតឱ្យជួបនឹងកូននៅស្រុកបាត់ដំបង។ ទើប

ជ័យអស្ចារ្យប្រកាសខ្លួនឱ្យអ្នកស្រុកដឹងច្បាស់ថា ខ្លួននឹងហើយជាព្រះរាជបុត្ររបស់ព្រះចន្ទរាជា គង់នៅបន្ទាយលង្វែកឥឡូវនេះវិលមកគ្រងរាជ ស្នងព្រះបិតា។ រឿងនេះមិនបាត់ស្ងាត់ ជ្រាបដល់ព្រះចៅសៀម ទ្រង់ព្រះពិរោធយ៉ាងខ្លាំងពន់ពេកនឹកតូចចិត្តព្រះទ័យក្រៃលែង ទ្រង់ប្រជុំពួកសេនាយោធាមកប្រាប់ថា ជ័យអស្ចារ្យប្រើឧបាយកលបោកបញ្ឆោតយកព្រះខ័នសឹកព្រមទាំងទ្រព្យមានវិញ្ញាណឥតវិញ្ញាណរត់ទៅស្រុកខ្មែរ ហេតុនេះត្រូវលើកទ័ពទៅតាមដណ្ដើមយកមកវិញឱ្យបាន ហើយចាប់ជ័យអស្ចារ្យ សម្លាប់ឱ្យផុតពូជព្រះចន្ទរាជាព្រមទាំងពួករាជការទាំងប៉ុន្មានកុំឱ្យសល់។

ជ័យអស្ចារ្យបានដំណឹងច្បាស់ថាព្រះចៅលើកទ័ពមកតាមដូច្នោះ ទ្រង់ជំនុំនឹងសេនាបតីថា ឥឡូវពលសេនាយើងនិងគ្រឿងអាវុធយុទ្ធភ័ណ្ឌរបស់យើងពុំបរិបូណ៌ តើអ្នករាល់គ្នាគិតរកឧបាយកលបែបណា ឱ្យមានជ័យជម្នះ ពេលនេះសេនាទាំងអស់មិនមានអ្នកណាមួយហ៊ានឆ្លើយទទួលជានាអះអាងសោះ មានតែសេនាមឿង ឆ្លើយជានាអះអាងថា ហ៊ានតទល់នឹងទ័ពសៀម ដោយឧបាយមួយដ៏ចំឡែកគឺហ៊ានប្តូរជីវិតដើម្បីនឹងទៅកែនពលខ្មោចធ្វើជាទ័ពច្បាំងនឹងពលសៀម។ ទើបបង្គាប់ឱ្យជីករណ្ដៅទំហំ៤ម៉ែត្រ៤ជ្រុង ជម្រៅ៤ម៉ែត្រ រួចឱ្យដាក់គ្រឿងសាស្ត្រាវុធក្នុងរណ្ដៅនោះដើម្បីនឹងលោតឱ្យជង់ស្លាប់ក្នុងរណ្ដៅតែមុនពេលលោតសម្លាប់ខ្លួនសេនាមឿង បង្គាប់ឱ្យពួកពលរដ្ឋទាំងអស់មកស្ដាប់ពាក្យឱវាទលោកប្រកាសថា សូមឱ្យអស់លោកខំប្រឹងយកចិត្តទុកដាក់ក្នុងរឿងចម្បាំងពេលនេះ ដើម្បីរំដោះដែនដីខ្មែរឱ្យបានរួចអំពីកណ្ដាប់ដៃនៃបច្ចាមិត្ត។ ចំណែកខ្ញុំៗជានាខាងទ័ពខ្មោច សូមអស់លោកសង្ឃឹមទុកចុះ បើខ្ញុំស្លាប់ទៅបាន៧ថ្ងៃឮសូរសន្ទឹកហ៊ោកញ្ជ្រៀវបីដូចជាសំឡេងផ្គរលាន់នោះ យើងនឹងមានជ័យជម្នះហើយ។ លុះផ្ដាំរួចលោតចុះក្នុងរណ្ដៅព្រឹប ប្រពន្ធឃើញប្ដីលោតដូច្នោះ ក៏លោតទៅជាមួយនឹងប្ដី ព្រមទាំងកូនប្រុស២នាក់ស្លាប់ជាមួយគ្នាដល់ថ្ងៃជាគម្រប់៧លាន់ឮសូរសន្ទឹកដូចកាលផ្ដាំមែន។

ទ័ពសៀមចូលដល់បាត់ដំបង ឆ្លងចូលមកដល់អូរមួយ សព្វថ្ងៃគេហៅថា អូរស្វាយដូនកែវ ជួបគ្នានឹងទ័ពជ័យអស្ចារ្យទ័ពខ្មោចចេញទៅមុនសម្ដែងឫទ្ធិ ធ្វើឱ្យពលសៀមវិលមុខ ចុកពោះ ចុកក្អួតដួលស្រួសៗ ទ័ពព្រះជ័យអស្ចារ្យចូលទៅកាប់សម្លាប់អស់ពួកកងទ័ពសៀម ទប់ទល់មិនបាន ថយទៅដល់បាត់ដំបង ធ្វើសារទៅក្រាបទូលព្រះចៅសៀមតាមដំណើរសព្វ

គ្រប់ ព្រះចៅទ្រង់ជ្រាបឱ្យទ័ពថយត្រឡប់ទៅស្រុកសៀមវិញ។

ចំណែកពួកកងទ័ពព្រះជ័យអស្ចារ្យ ក៏បាននាំគ្នាមកកាន់កាប់បន្ទាយវិញ។ សព្វថ្ងៃនេះ គេហៅថាបន្ទាយជ័យ។ ចាប់តាំងពីពេលនោះមក ព្រះជ័យអស្ចារ្យបានទទួលរាជាភិសេកសោយរាជ្យ និងទទួលនាមជាព្រះជ័យចេស្តា ព្រះចៅក្រុងកម្ពុជាធិបតី គង់នៅបន្ទាយជ័យ។ លុះព្រះអង្គបានឡើងសោយរាជ្យសម្បត្តិសុខសាន្តហើយ ទ្រង់នឹកឃើញដល់គុណូបការៈសេនាមឿង ដែលស៊ូប្តូរជីវិតចំពោះព្រះអង្គនិងចំពោះទឹកដីខ្មែរ ទ្រង់ក៏ចាត់ឱ្យធ្វើបុណ្យឧទ្ទិសដល់ដួងវិញ្ញាណក្ខន្ធរបស់សេនាមឿងយ៉ាងឱឡារិកអស្ចារ្យ ជាប់ជាទំនៀមរហូតមក។ សព្វថ្ងៃនេះ គេហៅថាធ្វើបុណ្យឡើងអ្នកតាឃ្លាំងមឿងទៅវិញ។

ការគោរពបូជាចំពោះអ្នកតាឃ្លាំមឿងគឺជាកតញ្ញូតាធម៌មួយដែលកុលបុត្រខ្មែរគ្រប់រូបត្រូវបំពេញចំពោះបុព្វបុរសស្នេហាជាតិដែលហ៊ានលះបង់ជីវិតរបស់ខ្លួនដើម្បីជាតិមាតុភូមិ។ នេះជាគំរូវីរភាពមួយដ៏ល្អសម្រាប់កូនខ្មែរជំនាន់ក្រោយ។

### ៣.៦-អ្នកតាដំបងគ្រញូង

សព្វថ្ងៃនេះ និមិត្តសញ្ញារបស់ខេត្តបាត់ដំបងគឺរូបលោកតាដំបងគ្រញូង។ ប្រវត្តិរឿងដែលជាប់ទាក់ទងនឹងលោកតាដំបងគ្រញូងនេះមានដូចតទៅ៖

នាយញូងមានដើមកំណើត នៅស្រុកសួនមង្ឃុត មានឪពុកឈ្មោះ សួន ម្តាយឈ្មោះ សែន។ មុននឹងនាយញូងមកទំពោះម្តាយ បុរសជាឪពុកបានសុបិនឃើញព្រះកាល យកដាវមួយមកប្រគល់ឱ្យ។ តាមសុបិននេះលោកគ្រូចៅអធិការវត្តភ្នំ បានទស្សន៍ទាយថា ប្តីប្រពន្ធនេះនឹងបានកូនប្រុសហើយកូនប្រុសនេះនឹងបានឡើងសោយរាជ្យ តែមិនមានអាយុវែងទេ។ នៅពេលដែលនាងសែនមានផ្ទៃពោះ នាងចង់បរិភោគប្រមាត់ដី។ នាយសួនជាប្តីតែងតែទៅបេះកាត់យកមកចម្អិនធ្វើអាហារឱ្យប្រពន្ធបរិភោគតាមចំណង់ជាប្រក្រតី។ គ្រប់ថ្ងៃខែ ពេលវេលាកាលណា គឺនៅថ្ងៃទី៦កើត ខែពិសាខ ឆ្នាំថោះ ព. ស. ១១៥៤ នាងសែនសម្រាលបានកូនប្រុសម្នាក់ ដូចហោរាទស្សន៍ទាយមែន។ ទារកនោះមានសម្បុរខ្មៅស្រអែមស្វាយដែលជាហេតុនាំឱ្យម្តាយឪពុកដាក់ឈ្មោះហៅថា ញូង។

លុះចូលដល់វ័យល្មមនឹងសិក្សា បានកុមារញូងត្រូវបានឪពុកម្តាយយកទៅឱ្យរៀនសូត្រជាមួយលោកគ្រូចៅអធិការវត្តភ្នំ។ ស្ទេះសេចក្តីប៉ុណ្ណឹងចុះ នឹងនិយាយអំពីព្រះបាទចក្រព័ត្របន្តិចសិន។ កាលដែលព្រះបាទស័ង្ខចក្រ ឬស្តេចគំលង់ ព្រះ

មហាក្សត្រខ្មែរទី១៥ ចូលទីវង្គតទៅព្រះរាជបុត្ររបស់ព្រះអង្គព្រះនាមចក្រព័ត្របានឡើងសោយរាជសម្បត្តិគ្រប់គ្រងប្រទេសកម្ពុជាបន្តពីព្រះបិតាក្នុងព្រះជន្ម ២១វស្សា។ ពិធីអភិសេកព្រះចក្រព័ត្រជាព្រះមហាក្សត្របានប្រារព្ធយ៉ាងឱឡារិកនៅថ្ងៃទី៣កើត ខែចេត្រ ឆ្នាំវក ព.ស. ១៥១៦។ ព្រះអង្គជាស្តេចខ្មែរទី១៦ ហើយមានព្រះរាជបរមនាមថា ព្រះបាទសម្តេចព្រះចក្រពត្រាធិរាជមរមបពិត្រ។ ព្រះអង្គគង់នៅព្រះបរមរាជវាំងមហានគរដដែល។ ព្រះបាទចក្រព័ត្រ មានព្រះរាជបុត្រពីរព្រះអង្គ។ បុត្រច្បង ព្រះនាមបទុមកុមារប្រសូតនៅឆ្នាំវក និងព្រះរាជបុត្របន្ទាប់ព្រះនាមសិរីកុមារ ប្រសូតនៅឆ្នាំរកា។ ជាមួយគ្នានេះអ្នកម្នាងកែវ ត្រូវជាមហេសីម្នាក់ទៀតរបស់ស្តេចចក្រព័ត្រ ក៏មានគភ៌ដែរ គឺនៅក្នុងឆ្នាំជូតព.ស.១៥៤៤។ សម័យមួយព្រះរាជាបានចេញបញ្ជាឱ្យនាម៉ឺនសព្វមុខ មន្ត្រីកេណ្ឌប្រជានុរាស្ត្រគ្រប់ខេត្តខណ្ឌឱ្យមកកាប់ឈើជញ្ជូនថ្មសាងសង់ព្រះបរមរាជវាំង និងបាចទឹកសម្អាតស្រះអូរប្រឡាយតូចធំក្នុងព្រះនគរ។ ក្នុងចំណោមប្រជាជនកំណែនទាំងនោះគេឃើញមានបុរសម្នាក់មាឌមាំ រាងធំ សម្បុរខ្មៅ ឈ្មោះនាយញូង។ នាយញូងត្រូវចៅហ្វាយខេត្តចាត់ឱ្យធ្វើជាមេរយពួកកំណែនហើយត្រូវបានបញ្ជូនទៅបំពេញការងារនៅឯមហានគរ។ ក្រុមរបស់នាយគ្រញូងត្រូវគេបង្គាប់ឱ្យទៅកាប់ឈើ និងជញ្ជូនថ្មនៅជើងភ្នំដងរែក។ ក្រុមកំណែនខ្លះទៀតក៏មានទៅធ្វើការឯភ្នំគូលែនដែរ។ ព្រឹត្តិការណ៍កំណែននេះ បានធ្វើឱ្យប្រជាជនខ្មែរទាំងប្រុស ទាំងស្រីខឹងសម្បាក្តៅក្រហាយគ្រប់ៗគ្នា។ គឺដោយសារខ្លាចអំណាចស្តេច ខ្លាចទទួលទោសពៃរ៍ ម៉្លោះហើយម្នាក់ៗចេះតែខាំមាត់សង្កត់ចិត្តញគោរពធ្វើតាមតែបញ្ជាទៅ។

ថ្ងៃមួយនាយញូង ត្រូវដល់វេននៅចាំដំរំ ហើយមានភារកិច្ចដាំស្ងចម្អិនម្ហូបអាហារសម្រាប់សមាជិកក្រុមកំណែនឯទៀត ដែលទៅបំពេញភារកិច្ច។ វេលាដាំបាយឆ្អិនកាលណា នាយញូងរកអ្វីមិនបានមកជ្រួយបាយ ក៏ងាកឆ្វេងស្តាំ ស្រាប់តែក្រឡេកឃើញមែកដើមរកាខ្មៅ។ នាយញូងក៏ឈោងចាប់យកមែកដើមរកាខ្មៅនេះមកជ្រួយបាយ។ រំពេចភ្លាមនោះ បាយដែលមានពណ៌សស្គុះ ក៏ប្រែក្លាយជាខ្មៅវិញ។ ដោយក្តីហេវហត់ និងឃ្លានផងនាយញូងក៏បរិភោគ បាយពណ៌ខ្មៅនោះទាល់តែអស់ពីខ្ទះ។ បន្ទាប់មកនាយញូងក៏ចាប់ផ្តើមដាំបាយថ្មីសម្រាប់សមាជិកកំណែនឯទៀត។ តែម្តងនេះដល់ពេលនាយញូងរកមែកដើមរកាខ្មៅនោះ មកជ្រួយបាយ

ស្រាប់តែមែកឈើនោះបាត់ស្រមោល រកមិនឃើញ។ មែកដើមរកាខ្មៅ ដែលបាននោះ គេមិនដឹងឡើយថា ជាអន្តរាគមន៍របស់ទេវតា ឬខ្មោចអារក្សយកមកដាក់ហើយលាក់បំបាំងវិញ ឬយ៉ាងណានោះទេ ប៉ុន្តែបើតាមពង្សាវតារវត្តទឹកវិល ក្នុងស្រុកស្អាង ខេត្តកណ្ដាលបានសរសេរកត់ត្រាទុកមកថា ដោយគុណបុណ្យបារមីនាយញូងនឹងត្រូវបានធ្វើជាស្ដេច ទើបបានជាទេវតាមមកដាក់បណ្ដុះឱ្យមានដើមរកាខ្មៅដុះនៅចំកណ្ដាលកន្លែងដែលពួកកំណែនរបស់នាយញូង ត្រូវមកបោះជំរំតាំងទីយ៉ាងដូច្នេះ។ គ្រាន់តែបរិភោគបាយនោះឆ្អែត នាយញូងក៏ចាប់ផ្ដើមមានកម្លាំងខ្លាំងក្លា កើតឡើងប្រើស។ ជាលំដាប់ដោយមិនដឹងខ្លួន។ គឺនៅពេលដែលនាយញូងចាប់ទាញពត់មែកដើមឈើទាលយកមកដាក់ព្យួរសង្ក្រែកបាយទើបនាយដឹងថា មានកម្លាំងខ្លាំងអស្ចារ្យស្មើនឹងដំរីសារប្រាំពីរ។ នាយញូងអាចពត់កាច់និងដកដើមឈើទាលបានយ៉ាងងាយស្រួលមិនបាច់ខំ។ ក្រុមកំណែនទាំងអស់កាលបើឃើញមហិទ្ធិឫទ្ធិបារមីនាយញូងសមាជិកកំណែនទាំងនោះក៏នាំគ្នាបាក់បបខ្វបខ្វាច កោតស្ញប់ស្ញែង គោរពបូជាទុកជាអ្នកមានបុណ្យ។ ម្នាក់ៗយល់នឹងជឿថា នាយញូងជាតួអង្គព្រះបាទធម្មិកដែលយាងចុះមកចាប់កំណើតជាមនុស្សលោក ដើម្បីស្រោចស្រង់និងលើកស្ទួយតម្កើងព្រះពុទ្ធសាសនា។ ប្រជាជនកំណែនទាំងនោះនាំគ្នាសុំចុះចូលបម្រើនាយញូង ហើយសុំតែងតាំងឱ្យឡើងធ្វើជាស្ដេច។

នៅពេលដែលនាយញូងកំពុងតែមានកម្លាំងកើនមហិមាដូចដំរីសារប្រាំពីរ ស្រាប់តែមានដំបងមួយបានលេចចេញមកធ្វើជាអាវុធ។ គឺដំបងឈើគ្រញូងមានប្រវែងប្រាំហត្ថមួយចង្អាម។ នាយញូងចាប់យកដំបងនោះមកគ្រវី វិលញាប់ស្មេដូចកងចក្រ ហើយនាយក៏អាចហក់លោតបានដល់កម្ពស់ទៅ១៥ហត្ថផងដែរ។ មនុស្សម្នាទាំងឡាយដែលបានឃើញឫទ្ធិបេស្ដារបស់នាយញូងខ្លាំងអស្ចារ្យដូច្នេះ ក៏បានដាក់ឈ្មោះឱ្យថា ដំបងគ្រញូង ជាប់ជារៀងដរាបរហូតមក។ ដឹងច្បាស់ថាខ្លួនមានកម្លាំងខ្លាំងក្លាពូកែ លើសអស់មនុស្សធម្មតា ហើយមានឫទ្ធិបុណ្យអំណាច នាយញូងក៏ចាប់ផ្ដើមបែកគំនិតចង់សោយរាជ្យធ្វើជាស្ដេចដូចដែលក្រុមជនកំណែនទាំងអស់ឱ្យឈប់កាប់ឈើ សម្រាប់យកទៅសង់ព្រះរាជវាំងស្ដេច។ ក្រុមកំណែនទាំងអស់ត្រូវនាំគ្នាកាប់ឈើធ្វើជាដំបងព្រនង់វិញនិងនាំគ្នាកាន់អាវុធមានកាំបិត ដាវលំពែងពូថៅ ព្រួញ ធ្នូ ស្នា ហើយនាំគ្នារៀបចំហ៊ឹកហ៊ឺនជាកងទ័ពដើម្បីចេញដំណើរ ទៅ

ព័ទ្ធវាយរាំងប្រហារស្តេចព្រះបាទចក្រព័ត្រ។ ប្រជាជនទាំងអស់បានស្មោះស្ម័គ្រនាំគ្នាមូលមីរដើរតាមដំបងគ្រញូង។ ដូច្នេះគេអាចរួចពីកំណែន លែងនឿយហត់កាប់ឈើជញ្ជូនថ្មបម្រើស្តេចទៀត។

ពង្សាវតារវត្តទឹកវិលប្រាប់ថា ដំបងគ្រញូងលើកទ័ព១០ម៉ឺននាក់ទៅឡោមព័ទ្ធព្រះមហានគរ។ ព្រះមហាក្សត្រព្រះនាមចក្រព័ត្រគ្រានោះដែលកំពុងមានជំងឺរោគាព្យាធិយ៉ាងទម្ងន់ ព្រះអង្គបានចែកទ័ពជាពីរផ្នែកឱ្យចេញទៅទប់ទល់នឹងដំបងគ្រញូង។ ទ័ពផ្នែកទីមួយត្រូវចេញទៅក្រៅទីក្រុងវាយប្រយុទ្ធប្រឈមមុខផ្ទាល់នឹងសត្រូវ។ ឯទ័ពផ្នែកទីពីរត្រូវនៅប្រចាំការពារព្រះរាជធានី។ ការប៉ះទង្គិចរាំងជល់គ្នារវាងទ័ពទាំងពីរមានសភាពខ្លាំងក្លាគួរឱ្យរន្ធត់។ ទាហានពលសេនាទាំងសងខាងស្លាប់ និងរបួសច្រើនមីរដេរដាស។ ប៉ុន្តែមិនយូរប៉ុន្មានទ័ពរបស់គ្រញូងក៏ចាប់ផ្តើមមានប្រៀបជាង ហើយក៏យកបានជោគជ័យ កំទេចទ័ពទីមួយរបស់ស្តេច ព្រះចក្រព័ត្រ។ ដំបងគ្រញូងវាយសម្រុក រុលរុកតទៅមុខទៀត រហូតដល់ទៅព័ទ្ធជុំជិតព្រះនគរ។ ខាងព្រះមហាក្សត្រ នៅសល់តែទ័ពទុកសម្រាប់ការពារទីក្រុងតែប៉ុណ្ណោះ។ ទោះបីជាដូច្នេះក៏ដោយ ក៏ទ័ពរបស់ដំបងគ្រញូងនៅតែពុំអាចវាយដណ្តើមយករាជធានីបានដែរ។ កងទ័ពដំបងគ្រញូងឡោមព័ទ្ធព្រះមហានគរអស់រយៈពេល២ខែ ហើយនៅតែមិនទាន់បានជ័យជម្នះផ្តាច់ព្រ័ត្រទៀត។ ក្នុងឱកាសនោះ ដំបងគ្រញូងចាត់ពលសេនាគ្រប់រូបឱ្យប្រដាប់ដាប់នឹងខ្លួននូវចន្ទុះ និងជ័រឈើ។ លុះយប់ជ្រៅកាលណា ដំបងគ្រញូងក៏បញ្ជាឱ្យពលរេហ៍ទាំងអស់វាយប្រហារសន្ធប់យ៉ាងគគ្រឹកគគ្រេង ដាក់ជណ្តើរលោតផ្លោះឡើងកំពែងមហានគរ យ៉ាងរហ័សរហួន ហើយចាក់ស្រោចស្រព និងដុតជ័រឈើបោះចូលទៅលើផ្ទះសម្បែងក្នុងបរិវេណក្រុង។ មិនយូរប៉ុន្មានកងទ័ពព្រៃរបស់ដំបងគ្រញូងក៏វាយកំទេចទ្វារមហានគរបានដោយជោគជ័យ ហើយក៏រត់សម្រុកចូលវាយលុក រុករុល ប្រហារកាប់ចាក់យ៉ាងសាហាវឥតត្រាប្រណី ទៅលើកងទ័ពព្រះរាជានិងប្រជាពលរដ្ឋស្លូតត្រង់ ទាំងប្រុសស្រីទាំងចាស់ទាំងក្មេង។ ក្នុងគ្រានោះព្រះមហាក្សត្រព្រះចក្រព័ត្រ ដែលកំពុងដែលមានជំងឺយ៉ាងធ្ងន់ធ្ងរ ផ្ទំនៅឮព្រះទែនកាលបើឮសូរស្នូរ អាវុធប៉ះទង្គិចគ្នា ឃើញភ្លើងកំពុងតែឆាបឆេះព្រះបរមរាជវាំង ឮសូរសំឡេងស្រែកហ៊ោរកញ្ជ្រៀវអឺងកងលាយឡំដោយការយំយែក ស្រែកឈឺចុកចាប់ព្រះអង្គខំប្រឹងងើបឈរ ដកព្រះខ័នដើម្បីចេញទៅតស៊ូ។ តែព្រះអង្គត្រូវដួល

ធ្លាក់មកលើព្រះក្រឡាបន្ទំវិញ ហើយសុគតក្នុងគ្រានោះទៅ។

ពង្សាវតារសម្ដេចវាំងជួន បានសរសេរថា ព្រះបាទចក្រព័ត្រព្រះមហាក្សត្រខ្មែរទី១៦ បានសុគតនៅក្នុងឆ្នាំជូតក្នុងព្រះជន្ម៤៩វស្សា។ ព្រះអង្គសោយរាជ្យបាន២៩ឆ្នាំ។ ពង្សាវតារវត្តទឹកវិលបានបញ្ជាក់ថា ដំបងគ្រញូងកាលបើបានជ័យជម្នះត្រួតត្រានគរហើយ បានរៀបចំធ្វើបុណ្យបូជាព្រះសពព្រះបាទចក្រព័ត្រ ហើយយកព្រះអដ្ឋិធាតុព្រះអង្គទៅបញ្ចុះនៅភ្នំក្រោម។

ថ្ងៃ១០កើត ខែពិសាខ ឆ្នាំឆ្លូវ ព. ស . ១៥៤៥ ដំបងគ្រញូងកូនរាស្ត្រសាមញ្ញដែលមានពង្សចេញពីស្រទាប់ប្រជាជនកសិករបានទទួលអភិសេក ឡើងសោយរាជ្យសម្បត្តិគ្រប់គ្រងប្រទេសកម្ពុជា។ ដំបងគ្រញូងក្លាយជាស្ដេចទី១៧បន្ទាប់ពីព្រះបាទចក្រព័ត្រ ហើយបានដាក់ឈ្មោះថ្មីជាព្រះមហាក្សត្រថា ព្រះបាទគោតមអមរទេវរាជ។

គ្រាន់តែបានទទួលជ័យជម្នះឡើងកាន់អំណាច និងសោយរាជ្យភ្លាម ស្ដេចដំបងគ្រញូងមិនទុកឱ្យរាជវង្សានុវង្សព្រះមហាក្សត្រមុនបានសុខឡើយ។ ព្រះអង្គចេញបញ្ជាទៅគ្រប់មន្ត្រីពលសេនាទៅតាមភូមិស្រុកតំបន់នានាក្នុងព្រះរាជាអាណាចក្រឱ្យដើរស្រាវជ្រាវឆែកឆេររកចាប់ចងឃុំឃាំងសមាជិកក្រុមព្រះញាតិវង្សទាំងអស់ហើយយកទៅសម្លាប់ចោលដោយដុតក្នុងភ្លើងទាំងរស់។

ថ្វេងពីព្រះបទុមកុមារ បុត្រច្បងព្រះបាទចក្រព័ត្រ ដែលទើបតែមានអាយុ១៣វស្សាភ័យភិតឥតឧបមា ហើយបានគេចលួចរត់រួចផុតពីកណ្ដាប់ដៃពួកស្ដេចដំបងគ្រញូង។ ព្រះអង្គបានទៅសាងផ្នួសជាងសង្ឃក្នុងព្រៃភ្នំក្រំថ្មចាប់តាំងពីថ្ងៃនោះមក។ គេបានដឹងថាព្រះអង្គមិនដែលទាក់ទងឬនិមន្តចេញចូលកាត់តាមស្រុកភូមិអ្នកស្រុកឡើយ ហើយគេបានដឹងទៀតថាព្រះអង្គព្រមទាំងបានរៀនចេះចាំគ្រប់សិល្បសាស្ត្រ វេទមន្តវិជ្ជាការខ្លាំងពូកែអស្ចារ្យ។

ចំណែកឯព្រះរាជបុត្រទី២ គឺព្រះសិរីកុមារ ដែលទើបតែមានព្រះជន្ម៥ព្រះវស្សារួមជាមួយនឹងមេដោះ ខំរត់ពួនគេចវេសវាងយករួចខ្លួនដែរ តែរត់មិនផុតត្រូវក្រុមសេនាដំបងគ្រញូងចាប់បាន។ ព្រះសិរីកុមារត្រូវពលសេនាទាំងនោះចាប់គ្រវាត់បោះចូលទៅក្នុងភ្នក់ភ្លើងដើម្បីឱ្យស្លាប់។ នាកាលនោះ ពេលល្ងាចព្រលប់យប់បន្តិចហេតុតែសំណាងបុណ្យបារមីមកជួយទាន់ ស្រាប់តែពលទាហានមួយក្រុមមកដល់មើលឃើញប្រទះនឹងក្មេក ក៏

កើតមានចិត្តសង្វេគអាណិតអាសូរនាំគ្នាអូសទាញព្រះសិរីកុមារចេញពីភ្លើងយកមកលាក់ទុកក្នុងគម្ពោតផ្តៅក្រែក ហើយក៏នាំគ្នារត់បាត់ទៅ។ ព្រះអង្គមិនសុគតទេ គ្រាន់តែត្រូវភ្លើងឆាបឆេះរលេះរលួយមានដំបៅ ស្នាកស្នាម ពាសពេញរាងកាយតែប៉ុណ្ណោះ។

បន្ទាប់មកថៃជន្យអ្វី មានព្រះសង្ឃមួយក្រុមនិមន្តកាត់មកតាមនោះបានយល់ឃើញព្រះសិរីកុមារស្ថិតក្នុងសភាពដ៏សែនខ្លោចផ្សារដូច្នេះ ព្រះសង្ឃទាំងអស់អង្គមានចិត្តមេត្តាករុណា សង្គ្រោះជួយរើសយកទៅចិញ្ចឹមបីបាច់ថែរក្សា។ អស់កាលយូរបន្តិចមក ដំបៅព្រះរាជកុមារក៏បានជាសះស្បើយតែដៃជើងរបស់ព្រះអង្គត្រូវឡើងក្រញឹងក្រញង់រួញជាប់គ្នា រកដើរមិនកើត។ ដើម្បីនឹងធ្វើចលនាទៅមុខថយក្រោយទៅឆ្វេងទៅស្តាំងព្រះអង្គខំប្រឹងរំកិលដោយគូទ។ ហេតុដូច្នេះហើយបានជាអ្នកផងទាំងពួងដាក់ឈ្មោះឱ្យថា ព្រហ្មកិល។ អ្នកខ្លះទៀតនិយមហៅពញាក្រែក ព្រោះព្រះសង្ឃបានរើសយកចេញពីគម្ពោតផ្តៅក្រែក។ ឥឡូវយើងនឹងអធិប្បាយនិយាយអំពីស្តេចដំបងគ្រញូងក្សត្រខ្មែរទី១៧វិញ ព្រះអង្គសោយរាជ្យបាន៧ឆ្នាំ៧ខែហើយ។ ថ្ងៃមួយព្រះអង្គបានកោះហៅ ព្រះរាជហោរាមកទស្សន៍ទាយមើលជោគជតារាសីរបស់ព្រះអង្គ។ ព្រះអង្គចង់ដឹងថា តើមានអ្នកមានបុណ្យណាមួយអាចមកដណ្តើមរាជ្យពីព្រះអង្គឬទេ។ ហោរាបានវាយលេខអត្ថៈ គន់គូរបូកសងគុណចែកចុះឡើងមើលទៅឃើញថា ព្រះអង្គដំបងគ្រញូងសោយរាជ្យសម្បត្តិប្រទេសកម្ពុជាបានតែ៧ឆ្នាំ ៧ខែនិង៧ថ្ងៃប៉ុណ្ណោះ។ ដូច្នេះ៧ថ្ងៃទៀត ព្រះអង្គនឹងត្រូវអស់បុណ្យ។ ពេលនោះនឹងមានអ្នកមានបុណ្យចេញមកដណ្តើមយករាជ្យសម្បត្តិជាក់ជាមិនខាន។

ឮសូរហោរាទស្សន៍ទាយដូច្នេះ ស្តេចដំបងគ្រញូងនឹកគិតថាបើអ្នកមានបុណ្យ នោះចេញមកមែន យើងនឹងយកដំបងគ្រញូងរបស់យើងគប់វាឱ្យបែកខ្ទេចម៉ត់តែម្តង។ បើយើងវាយកម្ទេចយកជ័យជម្នះមិនបានទេ នោះយើងនឹងសូមចុះចាញ់ហើយយើងនឹងលើករាជបល្ល័ង្កថ្វាយភ្លាមដើម្បីជៀសវាងកុំឱ្យកើយមានសង្គ្រាមកាប់សម្លាប់បង្ហូរឈាមគ្នា។ ដូច្នេះប្រទេសជាតិខ្មែរក៏មិនរងទុក្ខវេទនាព្រាត់ប្រាស់ មិនមានកម្មពៀរវេរាដោយសារតែរូបយើងដែរ។ ឯរូបយើងសោត ក៏គ្មានជាប់ជំពាក់កម្មពៀរនឹងបណ្តាជនខ្មែរ ហើយយើងក៏គ្មានអ្នកណាអាចដាក់កំហុស ផ្តន្ទាទោសជេរប្រទេសផ្តាសា តកូនតចៅរៀងរហូតទៅដែរ។

ដំណឹងទស្សន៍ទាយបានលេចឮ ជ្រួតជ្រាបទៅដល់ប្រជានុរាស្ត្រគ្រប់ទិសទី។ ថ្ងៃទី៧មកដល់កាលណាមនុស្សម្នាអ្នកស្រុកភូមិ ពីគ្រប់តំបន់ជិតឆ្ងាយ នាំគ្នាមកមហានគរជួបជុំ កុះករ កកកុញទ្រហឹងអឺងកង រង់ចាំមើលអ្នកមានបុណ្យ។ ពញាក្រែក ឬព្រហ្មកិល ចង់ទៅទីក្រុងដែរ ហើយក៏បានសុំសេចក្តីអនុញ្ញាតពីព្រះសង្ឃដើម្បីទៅមើលអ្នកមានបុណ្យនឹងគេដែរ។ កាលនោះ នាយខំប្រឹងរំកិលចៃវគាស់លើដីអូសគូទធ្វើដំណើរ យ៉ាងសែនត្រដាបត្រដួសតាមផ្លូវផ្លោះទៅកាន់មហានគរដោយមានជំនឿ និងសង្ឃឹមថា បើមានអ្នកមានបុណ្យចេញមកមែន អ្នកដែលមានជំងឺ មានរោគាព្យាធិ មនុស្សខ្វាក់ មនុស្សខ្វិន មុខតែនឹងជាសះស្បើយ មើលឃើញដើររួចដូចដើមជាមិនខាន។

កាលបើបានឃើញអ្នកមានបុណ្យជិះសេះមកដល់ដូចហោរាទស្សន៍ទាយ ប្រជាពលរដ្ឋដែលនាំគ្នាចាំមើលកកកុញក្នុងមហានគរ បាននាំគ្នាស្រែកហ៊ោរកញ្ជ្រៀវ ទ្រហឹងអឹងកងរត់ពពាក់ពពូនតាមមើលព្រឹត្តិការណ៍។ ចំណែកស្តេចដំបងគ្រញូងដែលរង់ចាំអ្នកមានបុណ្យជាយូរណាស់មកហើយ កាលបើបានឃើញដាក់ស្តែងនឹងភ្នែកកើតមានក្តីមួហ្មងក្តៅក្រហាយខឹងសម្បាជាខ្លាំង ចាប់ទាញដំបងគ្រញូង មកគប់ចោលតម្រង់ទៅពញាក្រែកឬព្រហ្មកិល ដើម្បីប្រហារជីវិតឱ្យក្សិណក្ស័យតែម្តង។ ប៉ុន្តែដំបងរបស់ស្តេចដំបងគ្រញូងបែរជាអស់ឫទ្ធិ មិនបានប៉ះចំអ្នកមានបុណ្យទេ ហើយក៏ធ្លាក់បាត់ទៅ។ កន្លែងដែលដំបងធ្លាក់ក៏ក្លាយជាអូរដែលមានឈ្មោះថាអូរដំបង។ ហើយតំបន់នោះក៏មានឈ្មោះថា បាត់ដំបង។

ឃើញហេតុភេទដ៏អស្ចារ្យដូច្នោះ ប្រជានុរាស្ត្រខ្មែរគ្រប់រូប ព្រមទាំងសេនានាហ្មឺនសព្វមុខមន្ត្រីក៏នាំគ្នាក្រាបថ្វាយបង្គំសំពះទទួលព្រហ្មកិល។ ឯស្តេចដំបងគ្រញូងវិញដែលយល់ដឹងថាខ្លួនអស់បុណបារមី អស់សមត្ថភាព ក៏សុខចិត្តដាក់ខ្លួនក្រាបថ្វាយបង្គំ ពញាក្រែក ឬព្រហ្មកិលសុំចំណុះចុះចាញ់ហើយលើករាជសម្បត្តិប្រគល់ថ្វាយក្នុងពេលជាមួយគ្នានោះទៅហោង។

អតីតស្តេចដំបងគ្រញូង បានសម្រេចចិត្តធ្វើដូចអ្វីដែលបានគិតទុកនោះមែន គឺធ្វើដំណើរគ្មានទិសដៅ ចាកចេញពីព្រះនគរក្នុងខែភទ្របទឆ្នាំវក។ ដំបងគ្រញូងបានទៅដល់ស្រុកលាវ។ កាលនោះនគរចម្ប៉ាសាក់ ត្រូវហ្វូងដំរីចេញមកយាយីរាតត្បាត ធ្វើឱ្យប្រជានុរាស្ត្ររងទុក្ខវេទនា និងវិនាសហិនហោចអស់ជាច្រើន។ ស្តេចដំបងគ្រញូង បានចេញទៅជួយយក

អាសារស្ដេចលាវ កំចាត់អស់ហ្វូងដំរី។ ដូច្នេះហើយ ដើម្បីតបស្នងសងគុណផង ហើយជាពិសេស ដោយភ័យព្រួយបារម្ភខ្លាចកម្លាំងអំណាច តេជៈបារមីផងទើបបានជាស្ដេចស្រុកលាវ ព្រះស៊ីសុច្ចណាគុណហ៊ុត លើកកូនក្រមុំព្រះនាមសយបុប្ផាឱ្យទៅដំបងគ្រញូងធ្វើជាភរិយា។ តែស្ដេចលាវនឹកគិតក្នុងខ្លួនម្នាក់ឯងថា ដំបងគ្រញូងនេះ ខ្លាំងពូកែណាស់ ហើយនឹងអាចក្បត់ដណ្ដើមរាជ្យពីយើងជាមិនខាន។ ដូច្នេះ ត្រូវតែធ្វើដូចម្ដេចដើម្បីកំចាត់ឱ្យបានមុនជាដាច់ខាត។ ស្ដេចលាវក៏អង្វរកូនស្រីឱ្យប្រើល្បិចកិច្ចកលស៊ើបសួរប្ដីថា តើធ្វើដូចម្ដេចទើបគេអាចសម្លាប់បាន ហើយបើចង់សម្លាប់វិញ តើគេប្រើមធ្យោបាយដូចម្ដេចដែរ។ កាលណាបានដឹងគ្រប់សេចក្ដីហើយនាងត្រូវមកប្រាប់បិតាវិញជាបន្ទាន់។

លុះទៅដោយការលួងលោមរបស់ប្រពន្ធដំបងគ្រញូងរៀបរាប់អស់នូវរឿងអាថ៌កំបាំងដែលមានជាប់ទាក់ទងទៅនឹងអាយុជីវិតរបស់ខ្លួន។ នាងសយបុប្ផា ក៏យកដំណឹងនោះទៅប្រាប់បិតាតាមដំណើររឿង។ បានដឹងដូចបំណងស្ដេចលាវមិនបង្អន់យូរឡើយក៏ចាត់ចែងរៀបចំឱ្យធ្វើគ្រឿងយន្ដដាក់ក្នុងបន្ទប់សម្រាប់សម្លាប់ដំបងគ្រញូង។ ថ្ងៃមួយនៅពេលដែលដើរចូលទៅក្នុងបន្ទប់ដំបងគ្រញូងដើរទៅទាក់ជើងនឹងខ្សែជាហេតុធ្វើឱ្យគន្លឹះគ្រឿងយន្ដបាញ់ស្នចំចូលក្នុងទ្រូងគូថ ដែលជាកន្ទែងដួងកែវជីវិត។ ដំបងគ្រញូងមិនបានស្លាប់ភ្លាមនោះទេ។ ពេលនោះដំបងគ្រញូងយល់ច្បាស់ណាស់អំពីបុព្វហេតុដែល បណ្ដាលឱ្យអស់ជីវិត។ គាត់បានពោលថា មិនគួរណាយើងមកបរាជ័យចាញ់បោកគេដោយសារតែសម្ផស្សរបស់ស្ត្រីសោះ ហើយគាត់បានផ្ដែផ្ដាំទៀតថា៖

-មិនត្រូវដេកលង់លក់ទេ នៅពេលណាដែលយើងត្រូវខ្យល់បោកបក់ បបោសអង្អែល។

-កាលណាចូលដំណេក មិនត្រូវនិយាយរឿងអាថ៌កំបាំងប្រាប់ប្រពន្ធទេ។

-មិនត្រូវទុកចិត្តស្រីណា  ដែលនៅក្រៅគ្រួសារឡើយ។

-កាលណាឃ្លានគេត្រូវយកអង្ករមកលាងដណ្ដាំបាយឱ្យឆ្អិនសិនសឹមបរិភោគជាក្រោយ។

ដោយមានរបួសជាទម្ងន់ដំបងគ្រញូងក៏ចាកចេញពីស្រុកលាវ ហើយត្រឡប់ទៅស្លាប់នៅឯស្រុកកំណើតរបស់ខ្លួនវិញ គឺនៅស្រុកសួនមង្ឃុត នេះបើតាមពង្សាវតារវត្តទឹកវិល។ ពង្សាវតារដដែលបានបញ្ជាក់បន្តទៀតថា ព្រះនាងសយបុប្ផា ដែលពោរពេញទៅដោយវិប្បដិសារីបានធ្វើដំណើរទៅតាមស្វាមី ហើយបម្រើ

កំដរ ប្រណិប័តន៍ រហូតដល់ថ្ងៃស្លាប់។ ព្រះនាងបានរៀបចំធ្វើពិធីបូជាសពតាមទំនៀមទម្លាប់ ប្រពៃណី ហើយបានយកអដ្ឋិធាតុទៅតម្កល់ទុកក្នុងចេតិយមួយក្នុងស្រុកចម្ប៉ាសាក់។

ចំណែក ពញាក្រែកឬព្រហ្មកិល វិញ ព្រះអង្គបានទទួលរាជាភិសេក នៅថ្ងៃ ១កើត ខែមិគសិរ ឆ្នាំរកា ព. ស. ១៩៩២។ ព្រះអង្គបានទទួលព្រះបរមនាមថា ព្រះបាទសម្តេចសន្ធពអម្រែក ព្រះបរមព្រហ្មកិលអង្គម្ចាស់ នេះបើតាមពង្សាវតាររបស់ព្រះអង្គម្ចាស់នព្វរតន៍។ តែបើតាមពង្សាវតារ វត្តកោកកាក ថា ពញាក្រែកឬព្រហ្មកិល ព្រះអង្គមានព្រះបរមនាមថា ព្រះបាទសន្ធពអម្រិន្ទ។

ការប្រកាន់យកសច្ចធម៌របស់លោកតាដំបងគ្រញូង ទឹកចិត្តអង់អាចក្លាហាននិងបណ្តាំប្រកបដោយគតិបណ្ឌិត ធ្វើឱ្យយើងចងចាំជារឿងរហូត។

**៣.៧-អ្នកតាក្រហមក**

អ្នកតាក្រហមកបិតនៅភូមិមហារាជសព្វថ្ងៃគេហៅថាភូមិឈើទាលសង្កាត់បឹងត្រាញ់ ស្រុកសំរោង ខេត្តតាកែវ។ អ្នកតានេះ មានខ្ទមធ្វើដោយឈើប្រក់ស្លឹកជញ្ជាំងក្តារ។ អ្នកស្រុកទើបនឹងសង់អាស្រមថ្មីមួយទៀតដោយស៊ីម៉ងត៍នៅទន្ទឹមគ្នានឹងខ្ទមចាស់ពីមុន។ នៅខាងក្រោយអាស្រម មានដំបូក ហើយមានដើមឈើដុះស៊ុបទ្រុប តាំងនៅលើដីទួលមួយខ្ពស់ដែលអ្នកស្រុកនេះនិយមហៅថា **លោកតាភូមិ**។ លោកតាម្នាក់និយាយថា អ្នកតានេះមិនដឹងជាមានពីកាលណាទេ គាត់កើតឡើងដឹងក្តីកាលណា ក៏ឃើញអ្នកតានេះតែម្តង ប្រហែលជាកើតមានពីត្រឹមសម័យដែលមនុស្សមកតាំងនៅលើភូមិមហារាជនេះ។ អ្នកតានេះមានឥទ្ធិពលលើអ្នកស្រុកភូមិនេះណាស់ ចេះជួយថែរក្សាសេចក្តីសុខ និងជួយស្វែងរកយុត្តិធម៌ឱ្យអ្នកស្រុក ភូមិទៀតផង។ សម័យដើម កាលបើមានរឿងរ៉ាវផ្សេងៗកើតឡើងរវាងអ្នកភូមិ ឬមានការឈ្លោះទាស់ទែងគ្នាជាដើម គេតែងទៅប្តឹង ស្បថចំពោះមុខអ្នកតានោះរាប់រៀបតាមដំណើររឿងរៀងៗខ្លួន ហើយមានសូត្រពាក្យស្បថប្រាំជានទៀតផង គូវិវាទទាំងពីរក៏សុខចិត្តរៀងៗខ្លួនជាការស្រេច មិនបាច់ប្តឹងផ្តល់ដល់រដ្ឋការមុខក្រសួងទៀតទេ។ ពាក្យសម្បថនេះ ឃើញថាស័ក្តិសិទ្ធិមែន។ បើអ្នកណាប្រព្រឹត្តពុំសុចរិតទៀងត្រង់ទេ អ្នកនោះមុខជាអន្តរាយរហូតដល់ស្លាប់យ៉ាងទាន់ហន់ក៏សឹងមាន។

ម្យ៉ាងទៀត អ្នកតានេះស្អប់ណាស់មនុស្សណាពាក់មួក ជិះដំរី និងស្ត្រីមានផ្ទៃពោះ ដើរកាត់មុខមិនបានទេ នឹងបណ្តាលឱ្យរលូតកូន បើអ្នកមានបុណ្យស័ក្តិនឹងធ្លាក់

បុណ្យស័ក្តិ ។ អ្នកស្រុកខ្លាចហើយមិនហ៊ានប្រព្រឹត្តបំពានចំពោះរឿងនេះទេ ។

អ្នកស្រុកតំណាលតៗមកថា ប្រមាណជា៤០ ឬ៥០ឆ្នាំកន្លងទៅហើយ មានតាចាស់ម្នាក់ឈ្មោះង៉ែត ប្រពន្ធឈ្មោះលឿង ផ្ទះគាត់នៅចម្ងាយប្រមាណ៤០០ម ពីទិសអាគ្នេយ៍នៃអាស្រមអ្នកតានោះ។ តាង៉ែតជាអ្នករកស៊ីធ្វើទឹកត្នោត។ គាត់បានធ្វើទឹកត្នោតមួយដើមក្បែរខ្ទមអ្នកតានេះឯង។ ពេលដែលឡើងគាបត្នោតនោះម្តងៗ តាង៉ែតបេះតែជ្រលួសមាត់ក ដោយគាបទៅវាបាក់ ឬក្រឡាប់ផ្កាត្នោតពីឃ្នាប។ អ្នកតានេះខឹង ក៏ច្រានតាង៉ែតទម្លាក់ពីចុងត្នោតមកដី ហើយទៅចូលរូបអ្នកស្រុកម្នាក់ឱ្យនិយាយថា លោកតាមិនឱ្យតាង៉ែតធ្វើត្នោតទៀតទេឱ្យរកស៊ីអ្វីដទៃទៀតទៅកុំដើរគាបផ្កាគេទៀតគេឈឺណាស់។ គ្រោះជាតាង៉ែតមិនស្លាប់ក្នុងពេលនោះដែរ។ តែលុះគាត់បានស្រាកស្រាន្តជាចាកជំងឺ មានកម្លាំងស្រួលបួលឡើងវិញ គាត់ក៏ចាប់ធ្វើរបរត្នោតទៀត គាត់ធ្វើដើមដដែលហ្នឹង។ ពេលនោះអ្នកតាក្រហមកដែលគេហៅថាអ្នកតាភូមិនោះលែងច្រានតាង៉ែតទម្លាក់ដូចមុនទៀតហើយ អ្នកតាខឹងខ្លាំងណាស់ដោយប្រដៅតាង៉ែតមិនស្តាប់ ក៏ចាប់តាង៉ែតយកទៅដាក់ច្រវាក់ភ្ជាប់នឹងសសរខ្ទមអ្នកតា អស់ពេលមួយយប់មួយថ្ងៃ។ ប្រពន្ធកូនបាត់តាង៉ែតដើររកមិនឃើញសោះ រកចុះរកឡើងក៏បានឃើញតាង៉ែត នៅខ្ទមអ្នកតា។ ពេលនោះតាង៉ែតឃើញប្រពន្ធដើរចូលទៅ គាត់ក៏ស្រែកប្រាប់មកថា អញទៅមិនរួចទេអញជាប់ច្រវាក់ជើងហើយ!។ ឮដូច្នោះ ប្រពន្ធកូនក៏ខំទាញគាត់ចេញពីខ្ទមអ្នកតា តែគ្មានកម្រើកសោះ ទាញយ៉ាងណាក៏មិនរួច គេឃើញជើងគាត់ទាំងពីរព័ទ្ធជាប់នឹងសសរខ្ទម ហើយឮសូរច្រវាក់ច្រាវៗនៅក្បែរគាត់នោះដែរ។ ប្រពន្ធកូនខំទាញទាល់ចំណោះ នៅតែមិនរួចក៏តាំងបែរបន់ចុះញ៉ម សុំឱ្យអ្នកតាលែងតាង៉ែតនោះមកវិញ។ អ្នកតាក៏លែងតាង៉ែតឱ្យមកជួបជុំប្រពន្ធកូនវិញដូចធម្មតា។ តាំងពីពេលនោះមក អ្នកស្រុកភូមិក៏នាំគ្នាជឿស៊ប់ចំពោះអ្នកតានោះឥតងាករេ គេតែងបន់គ្រប់ៗគ្នា ក្នុងពេលណាដែលមានទុក្ខព្រួយ ឬបាត់របស់ទ្រព្យផ្សេងៗ ឬក៏ចង់បានជ័យជម្នះក្នុងការលេងល្បែងស៊ីសងជាដើម។ គោលបំណងនៃការបន់នេះច្រើនតែបានសម្រេចដូចបំណងរៀងៗរហូតមក។ ឯរបៀបតង្វាយគេច្រើនថ្វាយស្វាធម៌ដៃ១គូ ស្វាធម៌ដូង១គូ មាន់ស្ងោរ១ មាន់រស់ ឬមាន់ផ្អាក់ នំ ចេក ប្រាក់ ទង់ ទៅតាមការដែលគេបានបន់។

ពិធីឡើងអ្នកតាក្រហមក ឬអ្នកតាភូមិនេះ គេកំណត់ធ្វើនៅថ្ងៃ១៣កើត ខែ

ពិសាខរៀងរាល់ឆ្នាំ។ អ្នកស្រុកមហារាជ (ភូមិឈើទាល)រៀបចំធ្វើពិធីនេះរៀងរាល់ឆ្នាំ។ ឆ្នាំខ្លះគេធ្វើបង្ហា រួចនិមន្តព្រះសង្ឃចម្រើនព្រះបរិត្ត រួចទេសនា។ ព្រឹកឡើងនិមន្តព្រះសង្ឃដារឆាន់ដល់ពេលល្ងាចទើបគេចាប់ធ្វើពិធីបញ្ចាន់រូប។ ប៉ុន្តែមានឆ្នាំខ្លះ គេធ្វើបញ្ចាន់រូបតែម្តង មិនមាននិមន្តព្រះសង្ឃឆាន់ទេ។ អ្នកតានោះ មានរូបសម្មឹងជាភេទប្រុស សម្រាប់ចូលមកនិយាយកិច្ចការប្រាប់កូនចៅ។ តារូបសម្មឹងនោះមានអាយុប្រមាណ៥០ឆ្នាំ គឺអ្នកតាក្រហមកចូលជាន់តែម្តង ឥតមានអ្នកណារើសទេ។ ប៉ុន្តែតមកខាងក្រោយ រូបនោះក៏កាន់តែចាស់ ចូលជាន់លែងកើត អ្នកស្រុកក៏រើសរករូបថ្មីទៀត ដោយគេបួងសួងថា បើអ្នកតាស្រឡាញ់អ្នកណាសូមឱ្យចូលរូបអ្នកនោះចុះ ព្រោះរូបមុនចាស់ណាស់ហើយ។ គេបួងសួងរួចហើយ ក៏ចាប់លេងភ្លេងខ្មែរឱ្យអ្នកតារើសរូបចូលទៅ។ សព្វថ្ងៃនេះចូលរូបតាម្នាក់ឈ្មោះតាអន ដែលជារូបថ្មីអាយុ៥០ឆ្នាំប្លាយដែរ ទើបនឹងចូលធ្វើសម្មឹងក្នុងឆ្នាំ១៩៦៦។ មុននេះគាត់នៅភូមិខ្នារុង សង្កាត់បឹងត្រាញ់ ស្រុកសំរោងខេត្តតាកែវ។

### ៣.៨-លោកយាយពេញភ្នំដូនពេញ

រាជពង្សាវតារខ្លះបាននិទានពីប្រវត្តិសាស្ត្រនៃក្រុងភ្នំពេញ ដោយមានសេចក្តីសម្រួលដូចតទៅ៖

ក្នុងកាលដែលកន្លងយូរទៅហើយមានស្ត្រីមេម៉ាយម្នាក់ជាអ្នកមានទ្រព្យស្តុកស្តម្ភដែលអ្នកផងហៅថា ដូនពេញ។ ផ្ទះគាត់តាំងនៅលើទួលខ្ពស់មួយនៅលើត្រើយខាងលិចនៃទន្លេប្រាបឈាម គឺទន្លេចតុមុខសព្វថ្ងៃនេះ។

នាសម័យថ្ងៃមួយ ក្នុងរដូវវស្សាមានទឹកជំនន់នៅប្រទេសលាវយ៉ាងធំបណ្តាលឱ្យបាក់ច្រាំងរលំដើមគគីរជាច្រើនហើយអណ្តែតបណ្តោយទឹកតាមទន្លេមេគង្គរហូតមកដល់ទន្លេប្រាបឈាម។ ក្នុងចំណោមនោះ មានដើមគគីរធំមួយ បានអណ្តែតមកទើនៅត្រង់មាត់កំពង់របស់ដូនពេញ។ គាត់ក៏បានបបួលញាតិមិត្តជិតខាងជិះទូកទៅចងដើមគគីរនោះហើយនាំយកមកលើគោក។ កាលបើអ្នកទាំងនោះរើសំរាមនៅគល់គគីរ ស្រាប់តែឃើញព្រះពុទ្ធរូបបួនព្រះអង្គ និងរូបបដិមាថ្ម មានលក្ខណៈជាព្រាហ្មណ៍ នៅក្នុងប្រហោងឈើនោះ។ ពួកអ្នកស្រុកបានដង្ហែរូបបដិមាទាំងនោះ យកទៅតំកល់ទុកនៅផ្ទះដូនពេញ ហើយគាត់បានឱ្យគេជញ្ជូនដី ពូនដំបូកធំខាងល្វៀសានផ្ទះ និងឱ្យគេយកឈើ

គគីរនោះសង់ព្រះវិហារតូចមួយនៅលើកំពូលភ្នំនោះ ហើយបានយកព្រះពុទ្ធរូបទៅតំកល់នៅក្នុងព្រះវិហារនោះនៅក្នុងឆ្នាំជូត ឆស័ក ព.ស.១៩១៦ គ.ស. ១៣៧២។ តមកទៀត ដូនពេញបានឱ្យគេសង់ខ្ទមមួយខាងទិសឦសាន ព្រះវិហារ រួចយកបដិមាថ្មទៅតំកល់ទុកទីនោះ ហើយបានសន្មតថា អ្នកតាព្រះចៅ តរៀងមក។ សព្វថ្ងៃនេះគេហៅថា លោកតាព្រះចៅ។ ពិធីបុណ្យសម្ពោធក៏ត្រូវបានប្រារព្ធធ្វើឡើងដើម្បីសម្ពោធពុទ្ធសេនាសនៈយ៉ាងអធិកអធម។ ដោយអាស្រ័យហេតុនេះ ភ្នំនោះក៏មានឈ្មោះហៅថា ភ្នំដូនពេញ ហើយដែលយូរៗទៅក្លាយនៅត្រឹមតែ ភ្នំពេញ ដូចយើងហៅសព្វថ្ងៃនេះ។

ពុំមានប្រភពផ្សេងទៀតសម្រាប់ធ្វើការស្រាវជ្រាវអំពីប្រវត្តិនៃទីក្រុងភ្នំពេញក្រៅអំពីឈ្មោះលោកយាយពេញនេះទេ។ ថ្មីៗនេះ សាលារាជធានីភ្នំពេញបានសង់រូបសំណាកលោកយាយពេញដើម្បីទុកជាអនុស្សាវរីយ៍ សម្រាប់អ្នកជំនាន់ក្រោយបានយល់ដឹង។

តាមការសិក្សាស្រាវជ្រាវរបស់បណ្ឌិតសភាចារ្យ ឡុង សៀម អតីតប្រធានវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា បានឱ្យដឹងថា លោកមិនទាន់ឯកភាពឬយល់ស្របទៅនឹងប្រវត្តិរឿងព្រេងរបស់ខ្មែរថាភ្នំពេញកើតឡើងតាមឈ្មោះដូនជីម្នាក់ឈ្មោះពេញនេះទេ។ លោកបណ្ឌិតបន្តថា បើតាមទីតាំងភូមិសាស្ត្ររបស់ទីក្រុង ធ្វើឱ្យលោកយល់ថា ពាក្យថាភ្នំពេញនេះ អាចកើតមកពីពាក្យភ្នំបឹង ឬភ្នំដែលព័ទ្ធជុំវិញទៅដោយបឹង។ លោកបណ្ឌិតសាស្ត្រាចារ្យបញ្ជាក់ថា កត្តាភូមិសាស្ត្រ ទើបអាចធ្វើឱ្យយើងវិនិច្ឆ័យបានដូចជានៅភ្នំពេញនេះ មានសង្កាត់ជាច្រើនប្រើពាក្យបឹង និងអូរ ដូចជាបឹងទំពុន បឹងព្រលឹត បឹងកេងកង បឹងរាំង បឹងត្របែក អូរឫស្សី អូរឡាំពិច អូរបែកក្អមជាដើម។ លោកថា កត្តាទាំងនេះ អ្នកសិក្សា គួរតែបន្តសិក្សាបន្តទៀត មិនគួរបញ្ចប់តែត្រឹមនេះទេ។លោកបន្តថា លោកទទួលស្គាល់ថា រឿងព្រេងវាគ្រាន់តែជារឿងព្រេងទេ តែកត្តាវិទ្យាសាស្ត្រ គឺជាកត្តាផ្សេង។ លោកក៏បានអះអាងការពារហេតុផលរបស់លោកទៀតថា ការដែលលោកអះអាងបែបនេះគឺសំអាងទៅលើការប្រែប្រួលនៃភាសាខ្មែរដែលកាលពីដើមខ្មែរនិយាយពាក្យធីជំនួសស៊ី។ តែក្រោយមកក្លាយជាពាក្យឈីដែលពាក្យនេះនៅមានប្រើនៅតំបន់មួយចំនួននៃខេត្តតាកែវនិងកំពត។ ហើយក្រោយមកពាក្យឈីនេះ ក៏ក្លាយទៅជាស៊ីតែម្តង។

ឯពាក្យថាភ្នំពេញនេះ ប្រហែលមកពីពាក្យភ្នំបឹងឬភ្នំដែលព័ទ្ធជុំវិញទៅដោយបឹង(បឹងកេងកង បឹងកក់ បឹងទំពុន បឹងត្របែក។ល។) លុះក្រោយមក ពាក្យបឹងនេះ អាចក្លាយទៅជាពេញទៅវិញ។ ការលើកឡើងរបស់លោកបណ្ឌិតសាស្ត្រាចារ្យពិតជាអាចទទួលយកបានតាមលក្ខណៈវិទ្យាសាស្ត្រ និងភូមិសាស្ត្រ ដែលនិស្សិត ឬអ្នកប្រាជ្ញខ្មែរ គួរតែស្រាវជ្រាវបន្តទៀត។

## ៤-ពិធីកម្មចំពោះអ្នកតា

ក្រៅពីពិធីសុំអភ័យពីអ្នកតានៅពេលដែលមនុស្សខ្លះ បានប្រព្រឹត្តអំពើមិនគប្បីចំពោះអ្នកតានោះនៅមានពិធីបួងសួង បន់ស្រន់សុំទឹកភ្លៀង ពិធីបួងសួងបន់ស្រន់សុំសេចក្ដីសុខសប្បាយពិធីឡើងអ្នកតាតាមរដូវកាលនិងតាមទម្លាប់តាមតំបន់។ ក្នុងពិធីនីមួយៗវត្ថុជាតង្វាយដែលពុំអាចខ្វះបាននោះមានដូចជា ពែសំណែនជាម្ហូបអាហារ ផ្លែឈើភេសជ្ជៈ(ស្រាទឹកតែ) ជួនកាលមានមាន់ឆ្អាងក្បាលជ្រូក មាន់ស្ងោរ។ ឯគ្រឿងតង្វាយក្រៅពីម្ហូបចំណី មានពែជមចារ ស្លាធម៌ លាជ ទៀនធូប ផ្កា ជាដើម។ លោកតាក៏មាមនាទីបញ្ចៀសទុក្ខភ័យប្រជាករក្នុងភូមិ ឃុំ ស្រុក ឬតំបន់នៅពេលដែលមានជំងឺរាតត្បាត ដូចជាអាសន្នរោគ អុតធំចូលមកបង្កការស្លាប់រង្គាលនៅតាមទីតាំងភូមិសាស្ត្រដែលគាត់ទទួលខុសត្រូវផងដែរ។ ការធ្វើពិធីកម្មជាប្រពៃចំពោះអ្នកតាសុទ្ធតែធ្វើឡើងដោយមានរូបសំណឹងជាអន្តរការី ធ្វើជាអ្នកនាំសារជាការបែរបន់ជាសំណូមពរពីប្រជាករមនុស្សលោកចង់បានអ្វីចង់ឱ្យអ្នកតាសម្រេចបំណងអ្វីខ្លះដល់ខ្លួនក៏ដូចជាអ្នកនាំពាក្យពីលោកតាពាក់ព័ន្ធនឹងពាក្យទូន្មានពីការអនុគ្រោះការផ្ដល់ផ្សេងៗនិងពីបម្រាមដែលលោកតាបានដាក់កំណត់ដល់មនុស្សលោក។ យើងក៏មិនត្រូវភ្លេចដែរ អំពីសេចក្ដីត្រូវការរបស់លោកតាក្នុងកិច្ចសុំយាងសុំនិមន្ត និងការកម្សាន្តសប្បាយរបស់លោកតា គឺក្រុមភ្លេងដែលជាធម្មតាមានអ្នកផ្លុំប៉ីពកឬប៉ីអអ្នកកូតទ្រខ្មែរខ្សែបីអ្នកដេញចាប៉ី អ្នកវាយស្គរពីរឬបីនាក់។ ជួនកាលអ្នកតាក៏ត្រូវការអ្នកភ្លេងពិណពាទ្យផងដែរ ដែលរួមមានអ្នកវាយគងវង់តូចនិងរនាតអ្នកផ្លុំស្រឡៃអ្នកវាយស្គរធំស្គរសំភោ។ នៅពេលចូលរូបអ្នកតាច្រើនតែជួតក្បាលដោយក្រមាពណ៌ក្រហម។ ជួនកាលអ្នកតាពាក់អាវបំពង់ដៃខ្លីពណ៌សស្លៀកសំពត់ហូល កាន់ដាវគ្រវីរាំតាមចង្វាក់ភ្លេង[7]។

ដោយផ្អែកទៅតាមភូមិសាស្ត្រតំបន់នីមួយៗ ពិធីបុណ្យប្រចាំឆ្នាំដែលគេ

---

[7] មៀច ប៉ុណ្ណះ ប្រពៃណីនិងទំនៀមទម្លាប់ខ្មែរ ភាគ

៦ ដ.ឯ.ម. ទំព័រទី៥-៦។

នាំគ្នាហៅថា "បុណ្យឡើងអ្នកតា" ច្រើនធ្វើឡើងនៅក្រោយរដូវចម្រូតគឺក្នុងរវាងខែមករាឬកុម្ភៈ។ បុណ្យឡើងអ្នកតានេះប្រជាជនយើងតែងប្រារព្ធធ្វើឡើងជារៀងរាល់ឆ្នាំ ទោះបីជាគេធ្វើទ្រង់ទ្រាយធំតូចក៏ដោយ។ ការឡើងអ្នកតាបានក្លាយទៅជាពិធីបុណ្យប្រពៃណីសម្រាប់ប្រជាជនខ្មែរស្ទើរទាំងអស់គ្នាទៅហើយ។

## ៥-អ្នកតាឆ្លុះបញ្ចាំងតាមរយៈអក្សរសិល្ប៍

មិនថាតែក្នុងជីវភាពសង្គមទេ សូម្បីតែអក្សរសិល្ប៍ប្រជាប្រិយមួយចំនួនក៏បានលើកយកបញ្ហាអ្នកតាមកបង្ហាញតាមរយៈរូបភាពអច្ឆរិយៈដោយលើកសរសើរពីគុណធម៌និងគតិយុតិធម៌របស់អ្នកតាដែរ។ ម្យ៉ាងវិញទៀត វាបានបង្ហាញពីតថភាពធម្មជាតិនៅពេលដែលការយល់ដឹងនិងបញ្ញាញាណរបស់មនុស្សនៅមានកម្រិតទាបមិនទាន់អាចពន្យល់បាតុភូតធម្មជាតិបានទើបបានជាគេច្នៃប្រឌិតបង្កើតជាបញ្ហាអច្ឆរិយៈតាមគំនិតស្រមើស្រមៃរវើរវាយ។

តាមរយៈរឿងអ្នកតាទឹក អ្នកតាភ្នំដែលជាទេវកថាអស្ចារ្យដែលបុព្វបុរសយើងបានបង្កើតឡើង យើងបានដឹងថាប្រជាជនខ្មែរមានជំនឿយ៉ាងខ្លាំងទៅលើអ្នកតា ព្រោះនៅពេលគាត់ជួបប្រទះទឹកជំនន់ពួកគាត់យល់ដោយស្មាន ឬដោយស្រមៃថា ប្រាកដជាមានអ្នកតាណាមួយបង្កើតព្រឹត្តការណ៍នេះឡើង ហើយពួកគាត់ក៏ធ្វើការបន់ស្រន់។

ក្រោយមក ទោះបីជាវិទ្យាសាស្ត្រអាចទន់សុំអ្នកតាជាម្ចាស់។ ដូចគ្នាដែរ បើអ្នកស្រុកប្រកបរបរនេសាទតាមបឹងបួរទន្លេ ស្ទឹង ឬធ្វើដំណើរតាមផ្លូវទឹក ក៏គេតែងតែបន់ស្រន់សុំឱ្យអ្នកតាទឹកជួយពួកគេដែរ។

ម្យ៉ាងវិញទៀត តាមរយៈរឿងអ្នកតាឃ្លាំងមឿងបានដកស្រង់ពីប្រវត្តិសាស្ត្រក្នុងសម័យគស១៥០២ នារជ្ជកាលព្រះបាទចន្ទរាជាសោយរាជ្យនៅក្រុងលង្វែកដែលកាលនោះប្រទេសខ្មែរស្ថិតនៅក្រោមចំណុះប្រទេសសៀម។ រឿងនេះបានឆ្លុះបញ្ចាំងពីវីរភាពរបស់តាមឿងដើម្បីរំដោះជាតិឱ្យផុតពីការឈ្លានពានរបស់សៀម។ តាមឿងសុខចិត្តបូជាជីវិតដោយលោតចូលក្នុងរណ្តៅដែលពោរពេញដោយចម្រូងដាវ និងលំពែងឱ្យមុតស្លាប់ក្នុងបំណងលើកទឹកចិត្ត ស្មារតីទ័ពខ្មែរឱ្យមានភាពនឹងនរឡើងវិញ ក្រោយពីចាញ់ដៃទ័ពសៀម (ទៅកេណ្ឌទ័ពខ្មោចឱ្យជួយច្បាំង) នៅពេលប្រមូលស្មារតីប្រយុទ្ធតាមឱវាទនិងបណ្តាំរបស់តាមឿងរួច

ហើយ កងទ័ពខ្មែរបានវាយកម្ចាត់កងទ័ពបច្ចាមិត្រឱ្យបាក់ទ័ព ខ្ចាត់ខ្ចាយអស់ពីមាតុភូមិ។ ក្នុងន័យកតញ្ញូតាធម៌ព្រះរាជានិងប្រជារាស្ត្រខ្មែរទាំងអស់បានធ្វើបុណ្យបញ្ជូនកុសល រំលឹកគុណដល់តាមឿងដែលបានធ្វើពលិកម្មដើម្បីជាតិយ៉ាងឱឡារិក អធិកអធម ជារៀងរាល់ឆ្នាំឥតមានខានឡើយ។ ក្រោយមកគេនាំគ្នាសន្មតថា ព្រលឹងមានគុណរបស់តាមឿងឱ្យទៅជាអ្នកតាតាមផ្នត់គំនិតរបស់ប្រជាជនខ្មែរ។ អ្នកតាឃ្លាំងមឿងមានឥទ្ធិពលខ្លាំងណាស់ក្នុងខេត្តពោធិ៍សាត់ ក៏ដូចជានៅទូទាំងប្រទេសតាមទំហំនយោបាយប្រវត្តិសាស្ត្រ។

ក្នុងរឿងមាយាស្ត្រីដែលជាអក្សរសិល្ប៍ប្រជាប្រិយ ក៏មានជាប់ទាក់ទងនឹងអ្នកតានេះដែរ។ អ្នកនិពន្ធចង់អប់រំប្រជាជនខ្មែរទាំងអស់ អំពីបញ្ហាផិតក្បត់របស់ស្ត្រីចំពោះស្វាមី។ ក្នុងសាច់រឿង នៅពេលដែលប្រពន្ធមានសាហាយ នាងក៏យកគ្រឿងសំណែនទៅបន់ស្រន់អ្នកតាភូមិឱ្យកាច់បំបាក់កប្តីដើម្បីខ្លួនមានឱកាសយកសាហាយធ្វើជាប្តីវិញ។ តែតួនាទីរបស់អ្នកតានៅពេលនោះគ្រាន់តែជាដុំថ្មមួយដុំគ្មានឫទ្ធិអំណាចអ្វីទាំងអស់ដោយមិនអាចជួយសម្រេចបំណងរបស់ស្ត្រីនោះឡើយ។ ចំណែកបុរសជាប្តីនៅពួនពីក្រោយរូបសំណាក ឆ្លើយទារសំណែនតាមតែអំពើចិត្ត។

តាមរយៈរឿងនេះយើងអាចនិយាយបានថា ប្រជាជនខ្មែរអស់ជំនឿលើអ្នកតា ឬមានន័យថាអ្នកតាជួយតែមនុស្សល្អ មិនជួយមនុស្សអាក្រក់ដែលប្រព្រឹត្តមិនត្រឹមត្រូវខុសប្រពៃណីជាតិរបស់ខ្លួនបានឡើយ។

រឿងមាយាស្ត្រីចង់បញ្ជាំងពីការជឿហួសហេតុពេកទៅលើអ្នកតា គឺអ្នកនិពន្ធចង់ដាស់តឿនមិនឱ្យប្រជាជនជឿងប់ពេកស្អីក៏ជឿស្អីក៏ទៅពឹងអ្នកតានាំឱ្យបាត់បង់ការតស៊ូជម្នះបញ្ហាស្មុគស្មាញរបស់មនុស្ស។

## ៦-ការប្រតិបត្តិជំនឿអ្នកតានៅក្នុងជីវភាពរស់នៅ

អ្នកស្រាវជ្រាវបញ្ហានេះមួយចំនួនយល់ថា នៅក្នុងពិធីបុណ្យតាំងតុ គេប្រមូលអ្នកតាទាំងអស់នៅក្នុងដែនដីកម្ពុជាទាំងមូល ឱ្យមកនៅជុំវិញស្តេចផែនដី ព្រោះស្តេចជាម្ចាស់ផែនដីទាំងមូល ឯអ្នកតាជាម្ចាស់ផែនដីតាមតំបន់។

តំបន់ដែលមានភូមិ ស្រុកច្រើន ពួកអ្នកតាក៏មានច្រើនដែរ។ គេរៀបធៀបលំដាប់ថ្នាក់អ្នកតាទៅតាមបងប្អូនក្នុងគ្រួសារមួយ គឺបងបង្អស់មានសិទ្ធិ និងតួនាទីធំជាងគេ និងមានឋានៈបន្តបន្ទាប់ ដូចជាអ្នកតាស្តេច អ្នកតាខេត្ត អ្នកតាស្រុក អ្នកតា

ភូមិ។ល។ អ្នកតាដែលការពារភូមិត្រូវបានការគោរពបូជាពីសំណាក់អ្នកភូមិទាំងមូល។ បំណងដែលភ្ជាប់អ្នកតាជាមួយអ្នកភូមិ គឺបញ្ជាក់ឡើងតាមការគោរពបូជាច្រើនបែបច្រើនយ៉ាងដែលគេចាត់ចែងឡើងតាមរដូវនិងតាមការបន់ស្រន់សម្រាប់ព្រឹត្តិការណ៍ពិសេស ឬដោយឡែក។

បុណ្យឡើងអ្នកតាច្រើនធ្វើឡើងនៅក្រោយរដូវចម្រូត ដើមខែមាឃ(មករា-កុម្ភៈ)។ ការឡើងអ្នកតាក្លាយជាបុណ្យប្រពៃណីសម្រាប់ប្រជាជនខ្មែរគ្រប់តំបន់។

បញ្ហាអ្នកតានៅក្នុងសង្គមខ្មែរបានចាក់ឫសយ៉ាងជ្រៅតាំងពីបុរាណកាលមក ហើយត្រូវបានប្រជា ជនខ្មែរ ទទួលស្គាល់ឥទ្ធិពលស្ទើរតែក្លាយទៅជាច្បាប់ទៅហើយ បើទោះបីជាបញ្ហានេះមានលក្ខណៈអរូបិយក៏ដោយ។ អ្នកតាជះឥទ្ធិពលយ៉ាងខ្លាំងទៅលើជីវភាពរស់នៅរបស់ប្រជាជនខ្មែរ។ អ្នកតាគឺជាម្ចាស់ទឹក ម្ចាស់ដី ម្ចាស់ព្រៃព្រឹក្សា។ មុននឹងដាំដំណាំ កសិករត្រូវបួងសួងសុំទឹកភ្លៀងនិងសុំម្ចាស់ដីដាំដុះ។ ជាពិសេសអ្នកដាំដំណាំត្រូវពឹងលើអ្នកតាថែរក្សាឱ្យអ្នកតាជួយការពារកុំឱ្យសត្វល្អិតបំផ្លាញ។

មនុស្សដែលមានជំនឿលើអ្នកតាត្រូវបានទទួលការអប់រំតាមបែបអាថ៌កំបាំង ដោយម្នាក់ៗសុទ្ធតែយល់ថាការព្រឹត្តអ្វីៗសព្វបែបយ៉ាងគេចមិនផុតពីភ្នែកអ្នកតាឡើយ។ដូច្នេះគេត្រូវធ្វើអំពើល្អ ចេះស្គាល់កំហុសខ្លួនឯង ហ៊ានសារភាពចំពោះមុខអ្នកតា ចេះនិយាយការពិត និយាយត្រង់មិនបោកប្រាស់គ្នា យកសម្បថជាសម្អាង។

នៅពេលមានមនុស្ស ឬសត្វឈឺ គេទៅបន់ស្រន់ឱ្យអ្នកតាជួយ។ ទោះជាការជួយរបស់អ្នកតាមិនមានប្រសិទ្ធភាពជាក់លាក់ក៏ដោយក៏ជំនឿនេះបានជួយលើផ្នែកផ្លូវចិត្តមនុស្សឱ្យមានសង្ឃឹមអាចធូរស្រាលមួយកម្រិតដែរ។

រហូតមកដល់ពេលបច្ចុប្បន្ន ប្រជាជនខ្មែរភាគច្រើននៅតែមានជំនឿលើអ្នកតានៅតែបន់ស្រន់ទោះជាវិទ្យាសាស្ត្ររីកចម្រើនហើយក៏ដោយ ដូចពាក្យទំនឹមមួយឃ្លាថា "**អាគមផ្សំអាយ៉ូស**"។

បើមានអ្នកស្រុកផ្សេងដើរកាត់ភូមិ ឬដែនដីដែលអ្នកតាគ្រប់គ្រង គេត្រូវធ្វើគារវកិច្ចសម្តែងការគួរសមឱនលំទោនគោរពសិទ្ធិអ្នកតាដែលគ្រប់គ្រង ដោយគ្រាន់តែថ្វាយអ្វីធ្វើជានិមិត្តរូប ដូចជា កាច់មែកឈើដោតធ្វើជាធូបទៀន ស្លឹកឈើធ្វើជាស្លាធម៌ ឬ គ្រាន់តែប្រើសម្ដីឧបកិច្ចក៏បានដែរ។ នៅពេលចូលកាន់តំណែងថ្មី ចៅហ្វាយខេត្ត ស្រុកថ្មី ត្រូវរៀបចំពិធីគោរពដល់អ្នកតាម្ចាស់ស្រុកម្ចាស់ដីដើម្បីឱ្យពួកគាត់ទទួលស្គាល់ដឹងឮនិងជួយថែ

រក្សា។ ពេលរៀបចំពីធីនេះអ្នកកាន់ដំណែងថ្មីត្រូវធ្វើគារវកិច្ចដល់អ្នកតាម្ចាស់ស្រុក ដោយស្បថសច្ចាថានឹងខិតខំបំពេញភារកិច្ចដើម្បីសេចក្ដីសុខរបស់ប្រជរាស្ត្រ សូមការសណ្ដោសប្រណីពីអ្នកតា និងឱ្យអ្នកតាជួយបំភ្លឺផ្លូវពួកគេផង[8]។

នៅត្រង់ចំណុចនេះយើងអាចសន្និដ្ឋានបាន ថាជំនឿបែបព្រលឹងនិយម នៅតែរស់រវើកក្នុងសតិអារម្មណ៍ ខ្មែរតំណទៅមុខគ្មាននរណាអាចអះអាងបានថា ជំនឿនេះអាចសាបរលាបអស់ទៅនៅឆ្នាំណា ស.វ.ទីប៉ុន្មានឡើយ។ យើងគ្រាន់តែដឹងថា ជំនឿសាសនា ទំនៀមទម្លាប់នេះ ធ្លាក់មុតជ្រៅណាស់ទៅក្នុងខួរក្បាលខ្មែរ[9]។

អ្នកតា អ្នកដូនដូចបានរៀបរាប់មកខាងលើនេះសុទ្ធតែជាអ្នកតា អ្នកដូនល្បីល្បាញ ប៉ុន្តែនៅមានអ្នកតា អ្នកដូនល្បីល្បាញជាច្រើនទៀតដែលយើងពុំអាចរៀបរាប់អស់។ បើយើងធ្វើដំណើរតាមទីជនបទយើងនឹងឃើញខ្ទមអ្នកតានៅពាសពេញប្រទេស។

បញ្ហាជំនឿទៅលើអ្នកតារបស់មនុស្សខ្មែរកើតមានតាំងពីយូរយារណាស់មកហើយ ហើយវាបានក្លាយទៅជាទម្លាប់របស់ខ្មែរយើងទៀតផង។ នៅពេលដែលវិទ្យាសាស្ត្រមិនទាន់រីកចម្រើន ខ្មែរបុរាណបានយកបញ្ហាអ្នកតាទៅអនុវត្តក្នុងជីវភាពរស់នៅបានយ៉ាងល្អប្រសើរ គឺបុព្វបុរសបានធ្វើឱ្យអ្នកតាមានតួនាទីយ៉ាងសំខាន់សម្រាប់ទ្រទ្រង់ស្ថានភាពពូជសាសន៍ខ្មែរឱ្យមានស្ថិរភាព និងបង្រួបបង្រួមជាតិខ្មែរឱ្យមានសង្គមនិងជាតិត្រឹមត្រូវ។

ដូច្នេះ យើងត្រូវថែរក្សាទុកបន្តទៀតនូវចំណុចណាមានប្រយោជន៍ត្រូវចម្លងទុកជាកស្តុតាងនូវមរតកល្អដែលយើងមានគឺតម្លៃវប្បធម៌ អរិយធម៌បុរាណរបស់ជាតិយើងឬជាប្រវត្តិសាស្ត្រសម្រាប់ទុកឱ្យមនុស្សខ្មែរជំនាន់ក្រោយបានដឹងអំពីជំនឿទំនៀមទម្លាប់ប្រពៃណីដើមរបស់ខ្លួន។ ម៉្យាងទៀត យើងក៏ត្រូវរកមធ្យោបាយកម្ចាត់ចោលជាបណ្ដើរៗចំណុចណាចាស់គម្រិលហួសហេតុពេកឬវាឆ្ងាយចាកពីការពិតពេកដែលធ្វើឱ្យអសកម្មក្នុងការអភិវឌ្ឍជាតិ។

---

[8] សាកលវិទ្យាល័យបៀលប្រាយះ ***ខេមរសិក្សា*** ឯកសារប្រើប្រាស់ផ្ទៃក្នុង ឆ្នាំ២០០៥ ទំព័រទី៨១-៨២។

[9] មៀច ប៉ុណ្ណះ ប្រពៃណីនិងទំនៀមទម្លាប់ខ្មែរ ភាគ ២ ដ.ឯ.ម. ទំព័រទី៩។

# គន្ថនិទ្ទេស


1. ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ៖ *ប្រជុំរឿងព្រេងខ្មែរភាគ៨* ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ២០០១។
2. ជួន ណាត៖ *វចនានុក្រមខ្មែរ* ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ គ.ស.១៩៦៧។
3. ទស្សនាវដ្ដី សេដ្ឋកិច្ចខ្មែរ ៖ *អត្តសញ្ញាណវប្បធម៌ខ្មែរចូលរួមអភិវឌ្ឍសហគមន៍សេដ្ឋកិច្ច* លេខទី៤០ ខែមិថុនា ២០១៥ ។
4. មៀច ប៉ុណ្ណ ៖ *ប្រពៃណីនិងទំនៀមទម្លាប់ខ្មែរ ភាគ៤* ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ២០១២ ។
5. សាកលវិទ្យាល័យបៀលប្រាយ៖ *ខេមរសិក្សា* ឯកសារប្រើប្រាស់ផ្ទៃក្នុង ឆ្នាំ២០០៥
6. ហ៊ឺ ចិន្តា ៖ *បដិមាសាស្ត្រនៅកម្ពុជា* សិក្ខាសាលានៅរាជបណ្ឌិត្យសភាកម្ពុជា ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២។
7. http: www. kampucheathmey.com/kpt 16 June, 2015
8. *https : www. twitter.com/share* 17July, 2014

# ស្វែងយល់ពីល្បែងបាយខុំ

## ( Understanding on Baykhom Game )

*ដោយ ៖ ឯកឧត្តមបណ្ឌិត* **អ៊ុំ ប៉ុម**

*ជំនួយការរាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្ដីផ្ដើម

*បាយខុំជាប្រភេទល្បែងមួយក្នុងចំណោមប្រភេទល្បែងប្រជាប្រិយខ្មែរ* (khmer popular game) *ដែលយើងធ្លាប់បានដឹងនិងចូលរួមលេងជាទម្លាប់ហូរហែមក ហើយដូចជា ល្បែងបោះអង្គុញ ល្បែងចោលឈូង លាក់កន្សែង ទាញព្រ័ត្រ គ្របមាន់ ជាដើម។ គេច្រើនលេងល្បែងបាយខុំនៅពេលសង្ក្រាន្តឆ្នាំថ្មី*[1] *ឬពេលសម្រាកពីការងារ ប៉ុន្តែគ្រាន់តែមិនលេងជាក្រុមដូចល្បែងដទៃទៀតពោលគឺលេងម្នាក់ទល់នឹងម្នាក់ ដូចល្បែងអុកចត្រង្គដែរ។ សូមបញ្ជាក់ជូនប្រិយមិត្តអ្នកអានបានជ្រាបថា អត្ថបទនេះគ្រាន់តែជាការពិពណ៌នារៀបរាប់ពីល្បែងបាយខុំទៅតាមអ្វីដែលធ្លាប់បានត្រងត្រាប់ពីចាស់ទុំក្នុងនាមពួកគាត់ជាអ្នកបញ្ជូនបន្ត ក៏ដូចជាការចូលរួមលេងល្បែងជាមួយមិត្តភក្តិ និងក្រុមគ្រួសារដោយផ្ទាល់កាលពីនៅយុវវ័យតែប៉ុណ្ណោះ ហើយមកដល់ពេលនេះបេះតែនឹកគិតចង់ឱ្យល្បែងមួយនេះបន្តរស់រានមានជីវិតតទៅទៀតជាមួយនឹងវប្បធម៌របស់ជាតិ។ ដូច្នេះ នៅក្នុងការពិពណ៌នាជាបន្តបន្ទាប់ទៅនេះ ប្រិយមិត្តអ្នកអាននឹងបានឃើញពីអ្វីដែលជាមធ្យោបាយប្រើប្រាស់របស់ល្បែង របៀបលេងជាក់ស្តែង វិធានជាគោលទាំងឡាយ ភាសាប្រើប្រាស់ក្នុងល្បែង ក៏ដូចជាសារប្រយោជន៍មួយចំនួនរបស់ល្បែងបាយខុំផ្សារភ្ជាប់ទៅនឹងជីវិតរស់នៅរបស់ប្រជាជនខ្មែរយើង។*

---

[1] *វចនានុក្រមសម្ដេចសង្ឃរាជជួនណាតភាគ១,២ បោះពុម្ពគ្រាទី៥ ឆ្នាំ ១៩៦៨ ទំព័រ ៥៨៩។*

## ១.មធ្យោបាយប្រើប្រាស់

ល្បែងបាយខុំទាមទារឱ្យមានជាចាំបាច់ នូវបន្ទះឈើក្រាស់ឈូសស្អាតមួយរាងជាពងក្រពើមានទម្ងន់ធូន់ល្មមងាយស្រួលលើកទុកដាក់និងមានរន្ធមូលៗចំនួនដប់មានទំហំមាត់រន្ធនិងជម្រៅប្រហែលមួយចង្អុលដៃ។ នៅខាងចុងម្ខាងៗមានរន្ធពីរព្រមទាំងមានរន្ធចំនួន៨ទៀតនៅទល់មុខគ្នាម្ខាងបួនៗ។ បន្ទាប់មកត្រូវមានកូនចំនួនសែសិបពីរសម្រាប់ដើរ[2] អាចជាសំបកខ្យងគ្រាប់ផ្លែរលួស ឬគ្រាប់ផ្លែស្វាតព្រមទាំងមានស្មុគពីរធ្វើពីស្លឹកត្នោតសម្រាប់ដាក់កូនដែលទទួលបានពីការដើរ។

## ២.អំពីរបៀបលេង

ជាធម្មតាល្បែងនីមួយៗតែងមានរបៀបលេងផ្សេងៗពីគ្នា។ ដោយឡែកចំពោះល្បែងបាយខុំ ក៏មានរបៀបលេងផ្ទាល់របស់ខ្លួនដែរ។ មុននឹងចាប់ផ្តើមលេងភាគីទាំងពីរត្រូវជួយគ្នារៀបចំដាក់កូនក្នុងរន្ធទាំងដប់ : រន្ធចុងដើមដាក់កូនដប់(ម្ខាងៗកូនប្រាំ)និងកូនសាមសិបពីរទៀតដាក់ក្នុងរន្ធទាំងប្រាំបីនៅទល់មុខគ្នា(មួយរន្ធៗចំនួនបួន)។ បន្ទាប់មកភាគីទាំងពីរចាប់ផ្តើមប៉ាវជាមួយគ្នាដើម្បីប្រកាសឱ្យដឹងពីអាទិភាពនៃភាគីត្រូវដើរមុនបន្ទាប់ពីប៉ាវឈ្នះគេ។ សូមឆ្លៀតឱកាសនេះបញ្ជាក់ជូនបន្តិចពីរបៀបប៉ាវដាក់ស្តែង។ ដំណើរការប៉ាវប្រព្រឹត្តទៅដោយភាគី ម្ខាងៗយកដៃស្តាំលាក់ក្រោយខ្នងហើយបន្ទឺវាចាថា «ប៉ាវស៊ីងស៊ុង» ដោយចេញដៃជាសញ្ញាព្រមៗគ្នាមកខាងមុខដូចជាចេញម្រាមចង្អុលដៃមួយ ចេញម្រាមដៃលាតទាំងប្រាំ ឬម្រាមដៃក្តាប់ទាំងប្រាំជាដើម។ ជាក់ស្តែងបើភាគីម្ខាងចេញចង្អុលដៃមួយ ម្ខាងទៀតចេញម្រាមដៃលាត(លាតបាតដៃ)គឺ អ្នកចេញម្រាម ចង្អុលដៃមួយជាអ្នកឈ្នះ។ បើម្ខាងចេញម្រាមចង្អុលដៃមួយ ម្ខាងទៀតចេញម្រាមដៃក្តាប់ អ្នកចេញម្រាមដៃក្តាប់ជាអ្នកឈ្នះ។ បើម្ខាងចេញម្រាមដៃលាត ម្ខាងទៀតចេញម្រាមដៃក្តាប់ គឺអ្នកចេញម្រាមដៃលាតជាអ្នកឈ្នះ។ បើចេញម្រាមដៃមកដូចគ្នា គេហៅថា «ចារ៉» ត្រូវអនុវត្តម្តងទៀត។ ភាគីឈ្នះជាអ្នកចាប់ផ្តើមដើរមុនដោយដើរទៅស្តាំ ឬទៅឆ្វេងក៏បាន ហើយចាប់រន្ធណាក៏បាន ប៉ុន្តែអ្នករៀបរៀងអត្ត

[2] ដ.។

បទនឹងជម្រាបជូនដោយលម្អិតបន្ថែមពីរបៀបដើរដែលបានចំណោញឬខាតកូនរបស់ភាគីទាំងពីរក្នុងចំណុចទី២ ស្តីពីក្បួនដើរដាក់ស្តែង។សូមត្រឡប់មករៀបរាប់ពីរបៀបលេងជាបន្តទៅទៀត។ បើចាប់យករន្ធណាមួយដើរហើយដើរទៅអស់កូនត្រឹមណាត្រូវចាប់កូនក្នុងរន្ធបន្ទាប់ដើរទៅទៀត។ ដើរទាល់តែអស់កូនហើយឃើញមានរន្ធមួយទទេនៅពីមុខទើបអាចស៊ីបានរន្ធបន្ទាប់ដោយយកដៃកេះរន្ធទទេហើយស៊ីកូនក្នុងរន្ធបន្ទាប់នោះ។ បើមានរន្ធទទេទៀតត្រូវយកដៃកេះរន្ធទទេនោះហើយស៊ីរន្ធមានកូនបន្តទៀត។ សូមបញ្ជាក់ថាតាមវិធានកំណត់ក្នុងពេលដើររន្ធ មួយអាចដាក់បានតែកូនមួយប៉ុណ្ណោះ។ រីឯចំនួនកូនដែលត្រូវស៊ីវិញអាចមានតាំងពីមួយរហូតដល់ម្ភៃក៏មានក្នុងករណី ដើរញៀក[3]ដោយចាប់យករន្ធពិសេសណាមួយ។ ក្នុងសភាពបែ ជន្យដោយមិនបានគិតឱ្យស្រួលបួលដើរទៅស្រាប់តែអស់កូនហើយរន្ធបន្ទាប់មានទំនេរដល់ទៅពីររន្ធបានន័យថាដើរឃ្លាំងមិនអាចបន្តសកម្មភាពទៀតបានទេត្រូវទុកអាទិភាពឱ្យភាគីម្ខាងទៀតដើរម្តង។ ប៉ុន្តែក្នុងល្បែងបាយខុំមានការខុសប្លែកពីល្បែងបោះអង្គញ់បន្តិចនៅត្រង់ថាភាគីទាំងពីរ ដើរម្តងម្នាក់ មិនមែនរង់ចាំទាល់តែភាគីមួយធ្វើ «ឡើង» ទើបភាគីមួយទៀតបន្តសកម្មភាពរបស់ខ្លួននោះឡើយ។ ម្យ៉ាងទៀតបន្ទាប់ពីលេងលើកទីមួយទៅអាចមានភាគីណាមួយខ្វះកូនដាក់មិនគ្រប់។ បើមានករណីបែបនេះកើតឡើងភាគីនោះត្រូវទុករន្ធឱ្យនៅទំនេរ។ បើភាគីម្ខាងដើរប្រទ្បំដាក់កូនក្នុងរន្ធទទេភាគីម្ខាងទៀតអាចយកដៃខ្ទប់រន្ធនោះហើយយកកូនមកទុកជារបស់ខ្លួន។ ម្យ៉ាងទៀតបើលេងទៅម្ខាងៗនៅសល់កូនមួយឬពីរពុំអាចដើរបានគេត្រូវបញ្ឈប់ការដើរត្រឹមប៉ុណ្ណោះហើយចែកកូនគ្នា កូននៅខាងណា ខាងនោះទទួលយក។ រួចហើយដើរបន្តសកម្មភាពដាក់កូនក្នុងរន្ធសាជាថ្មី។ គួរកត់សម្គាល់ថាក្នុងការរៀបចំកូនដាក់ក្នុងរន្ធបើមានភាគីណាមួយសល់កូនមួយឬពីរ ឬក៏អត់សោះគ្មានកូនដាក់ក្នុងរន្ធតែម្តង គេសន្មតហៅថា «ដាច់ស្រុក» បានន័យថាភាគីនោះចាញ់គេ ហើយបើប្រៀប

[3] ដើរញៀកគឺគេចាប់យករន្ធមួយ ហើយដាក់កូក្នុង  រន្ធស្តាំនិងរន្ធឆ្វេង ហើយដើរបន្តទៅឆ្វេង។ បើដាក់កូនក្នុងរន្ធឆ្វេងមុន ហើយត្រូវដាក់កូនក្នុងរន្ធស្តាំមួយទៀតរួចដើរបន្តមកស្តាំ។

ជៀបមកការរកស៊ីវិញ មានន័យថាខាតលិច លង់តែម្ដង។ ដូច្នេះភាគីដែលឈ្នះអាចឱ្យភាគីចាញ់ផ្ដុំរន្ធ។ គេឱ្យភាគីចាញ់ដាក់កូនក្នុងរន្ធណាមួយហើយផ្ដុំកូននោះឱ្យប៉ើងឡើងដល់មាត់រន្ធ ទើបភាគីឈ្នះគេសុខចិត្ត។ គេអាចឱ្យផ្ដុំរន្ធប៉ុន្មានក៏បាន អាស្រ័យលើការសន្យាគ្នាមុនពេលចាប់ផ្ដើមលេងល្បែង។

## ៣.ភាសាប្រើប្រាស់ក្នុងល្បែងបាយខ្ញុំ

ភាសាហៅទៅលើរន្ធឬក្នុងដំណើរការដើរមានភាពខុសប្លែកគ្នា។ ដាក់ស្ដែងចំពោះរន្ធចុងដើមក្ដារគេហៅថារន្ធក្បាលដីមឿង។ ភាគីនីមួយៗមានរន្ធក្បាលដីមឿងមួយម្នាក់នៅខាងស្ដាំដៃរបស់ខ្លួន។ ចំណែករន្ធទាំងប្រាំបីដែលនៅចន្លោះរន្ធក្បាលដីមឿងគេហៅថារន្ធបរិវារ[4]។ សំបកខ្ចៅដូងឬគ្រាប់រុក្ខជាតិស្រាលៗដែលយកមកដាក់ក្នុងរន្ធទាំងដប់ហៅថា«កូន»។ សកម្មភាពដែលភាគីម្ខាងៗធ្វើសាចុះសាឡើងគេហៅថា «ដើរ»។ ចំពោះកូនវិញមានពីរប្រភេទគឺកូនក្បាលដីមឿង(កូនប្រាំ)និងកូនបរិវារឬកូនក្នុងរន្ធបរិវារទាំងប្រាំបី(កូនបួនៗ)។ កូនដែលបានមកពីការដើរមានឈ្មោះថា «កូនស៊ី»។ ចំពោះរន្ធវិញ រន្ធទំនេរគ្មានកូនក្នុងពេលកំពុងលេងគេហៅថា «រន្ធកេះ»។ រន្ធកេះអាចមានពីរឬបីក៏មាន។ បើដើរមកដល់រន្ធមានសភាពបែបនេះគេត្រូវពោលពាក្យថា «កេះស៊ី»។ បើដើរទៅហើយប្រទះឃើញកូនតែមួយក្នុងរន្ធគេហៅថា «កូនលើកទុក»។ គេអាចលើកទុកកូនក្នុងរន្ធបន្ទាប់ទោះបីជារន្ធបន្ទាប់នោះមានឬមិនមានកូនក្ដី។ គេអាចឃើញមានករណីលើកទុកហើយកេះស៊ីឬលើកទុកហើយចាប់កូនក្នុងរន្ធដើរបន្តទៅមុខទៀតក៏មាន។ រន្ធដែលទទេខ្វះកូនដាក់តាំងពីដើមទីគេឱ្យឈ្មោះថា «រន្ធស្អុយ»។ អាចមានរន្ធស្អុយពីមួយទៅបីឬបួនក៏មាន។ បើមានករណីបែបនេះកើតឡើងគេហៅថា «ដាច់ស្រុក» ដែលជាសក្ខីភាពនៃការត្រៀមចាញ់របស់ភាគីម្ខាងទៀត ដោយជៀសមិនផុត ព្រោះថាបើខ្វះកូនហើយគេមិនអាចដើរងាយស្រួលបានទេចង់ឬមិនចង់ភាគីដែលមានកូនគ្រប់គ្រាន់គេអាចស៊ីបន្ថែមទៀតក៏មានហើយកូនរបស់គេចេះតែកើនឡើងៗវិស័យដូចការរកស៊ីដែលវិវត្តទៅមុខដូចឡើងកាំជ

[4]- សូមមើលវចនានុក្រមសម្ដេចសង្ឃរាជជួនណាតទំព័រ ៥៨៩ដូចមុន។

ណ្តើរៗ ឯកូនរបស់ភាគីម្ខាងទៀតចេះតែហោចទៅៗរហូតដល់ទៅគ្មានកូនដាក់ក្នុងរន្ធសោះតែម្តង។ នោះហើយដែលគេហៅថាដំណាក់កាលចាញ់ជាស្ថាពរព្រោះភាគីម្ខាងទៀតគេស៊ីផ្តាច់ស្រុកអស់តែម្តង។ ដល់ពេលនេះភាគីដែលឈ្នះគេបង្គាប់ភាគីចាញ់យកកូនមួយទៅដាក់ក្នុងរន្ធហើយផ្ទុំកូននោះឱ្យប៉ើងឡើងមកលើមាត់រន្ធ។ នោះហើយដែលគេហៅថាដំណាក់កាល «ផ្ទុំរន្ធ»។ បន្ទាប់ពីនោះគេអាចបន្តលេងទៀតក៏បានអាស្រ័យលើការសម្រេចចិត្តរបស់ភាគីចាញ់ថាចង់ស្តារស្ថានការណ៍ឬមួយយ៉ាងណាតែប៉ុណ្ណោះ។

## ៤.អំពីក្បួនដើរដាក់ស្តែង

ចំពោះក្បួនដើរដាក់ស្តែងអ្នករៀបរៀងនឹងលើកយកមកបង្ហាញជូនតែនៅពេលចាប់ផ្តើមដើរដំបូងរបស់ភាគីនីមួយៗបន្ទាប់ពីប៉ាវឈ្នះតែប៉ុណ្ណោះ ដើម្បីបានទុកជាក្បួនច្បាប់តទៅ។

៤.១. ក្បួនដើរសម្រាប់ភាគីទី១ ដែលប៉ាវឈ្នះ

ដើម្បីងាយស្រួលយល់សូមតាងភាគីទី១ ជាភាគី «x» រន្ធក្បាលដីមៀងជាx5,រន្ធបរិវារទី១ ជា x1,រន្ធបរិវារទី ២ជាx2 ,រន្ធបរិវារទី ៣ជា x3 , រន្ធបរិវារទី៤ ជា x4។

បើសិនជាភាគីទី១ «x» ប៉ាវឈ្នះ គេអាចចាប់យករន្ធណាដើរក៏បាន ប៉ុន្តែត្រូវគិតថាចាប់រន្ធណាស៊ីបានកូនច្រើនជាង។ សូមសាកល្បងបង្ហាញជូនដាក់ស្តែងដោយផ្អែកលើរូបភាពនៅទំព័រ៩។

បើចាប់យករន្ធX1 ហើយដើរមកស្តាំនឹងស៊ីបានកូន៥។ ផ្ទុយទៅវិញបើចាប់យករន្ធ x1 ដដែល ហើយដើរទៅឆ្វេង លើក្បាលដីមៀងអ្នកម្ខាងទៀតនឹងស៊ីបានកូន៦។

-x1 ដើរមកស្តាំស៊ីបានកូន៥

-x1 ដើរទៅឆ្វេងស៊ីបានកូន៦

x1 ត្រូវដើរទៅឆ្វេងស៊ីបានកូន៦ លើសដើរមកស្តាំ១

បើចាប់យករន្ធX2 ហើយដើរមកស្តាំនឹងស៊ីបានកូន៥។ បើដើរទៅឆ្វេងនឹងស៊ីបានកូន៥ ដែរ។

-X2 ដើរមកស្តាំ : ៥

- X2 ដើរទៅឆ្វេង : ៥

X2 ដើរមកស្តាំ ឬដើរទៅឆ្វេងនឹងស៊ី

បានកូន៥ដូចគ្នា

បើចាប់យករន្ធ X3 ហើយដើរមកស្តាំ នឹងស៊ីបានកូន៥។ បើដើរទៅឆ្វេងក៏នឹងស៊ីបានកូន៥ដូចគ្នា :

-X3 : ដើរមកស្តាំ : ៥

-X3 : ដើរទៅឆ្វេង : ៥

X3 ទាំងដើរមកស្តាំ ឬដើរទៅឆ្វេង នឹងស៊ីបានកូន៥ដូចគ្នា

ដូច្នេះចាប់យករន្ធ X2 និង X3 ស៊ីបាន

កូន

៥ដូចគ្នា

| X2 = X3 = ៥ (ស្តាំឬឆ្វេង) |
|---|

បើចាប់យករន្ធ X4 ហើយដើរមកស្តាំ នឹងស៊ីបានកូន៦។ បើដើរទៅឆ្វេងនឹងស៊ីបានកូន៥

-X4 : ដើរមកស្តាំ : ៦

-X4 : ដើរទៅឆ្វេង : ៥

ដើរមកស្តាំនឹងស៊ីបានកូន៦ លើសទៅឆ្វេង១

| X4 (ស្តាំ) > X4 (ឆ្វេង) ឬ៦ > ៥ |
|---|

បើចាប់យករន្ធ X5 (រន្ធក្បាលដីមឿង) ហើយដើរទៅស្តាំនឹងស៊ីបានកូន៧។ បើដើរត្រឡប់មកឆ្វេងវិញក៏នឹងស៊ីបានកូន៧ ដែរ។

-X5 ដើរទៅស្តាំ : ៧

-X5 ដើរមកឆ្វេង : ៧

ដើរទៅស្តាំឬដើរមកឆ្វេងនឹងស៊ីបានកូន៧ ដូចគ្នា

| X5(ស្តាំ) = X5(ឆ្វេង) = ៧ |
|---|

| ដូច្នេះ សម្រាប់ភាគីទី១ (X) បើប៉ាវឈ្នះគប្បីចាប់យករន្ធ X5 ហើយដើរទៅឆ្វេងឬមកស្តាំក៏បាន នឹងស៊ីបានកូន៧ ដូចគ្នា លើសពីចាប់យករន្ធដទៃហើយដើរមកស្តាំ ឬ ទៅឆ្វេង។ |
|---|

៤.២.ក្បួនដើរដាក់ស្តែងសម្រាប់ភាគីទី២ :

ដើម្បីងាយស្រួលយល់ សូមតាងភាគីទី២ ជាភាគីY, រន្ធក្បាលដីមឿងជាY5, រន្ធបរិវារទី១ ជាY1, បរិវារទី២ ជាY2, បរិវារទី ៣ ជាY3, បរិវារទី៤ ជាY4។

បើសិនភាគីទី២(Y)ប៉ាវឈ្នះវិញនោះ ភាគីសាម៉ីអាចចាប់យករន្ធណាដើរក៏បាន ប៉ុន្តែ

ត្រូវគិតថាចាប់យករន្ធណាស៊ីបានកូនច្រើនជាង។ សូមសាកល្បងបង្ហាញជូនដាក់ស្តែង (សូមផ្ទៀងផ្ទាត់តាមរូបភាពនៅទំព័រទី៩):

-បើចាប់យករន្ធ Y1 ហើយដើរទៅស្តាំដៃនឹងស៊ីបានកូន៥។ បើដើរមកឆ្វេងនឹងស៊ីបានកូន៦

-Y1 : ដើរទៅស្តាំ : ៥

-Y1 : ដើរមកឆ្វេង : ៦

Y1 ដើរមកឆ្វេងស៊ីបានកូន៦ លើសដើរទៅស្តាំ១

| Y1(ឆ្វេង) > Y1(ស្តាំ) ឬ ៦ > ៥ |
|---|

បើចាប់យករន្ធ Y2 ហើយដើរទៅស្តាំនឹងស៊ីបានកូន៥ បើដើរមកឆ្វេងនឹងស៊ីបានកូន៥ដូចគ្នា

-Y2 : ដើរទៅស្តាំ : ៥

-Y2 : ដើរមកឆ្វេង : ៥

Y2 ដើរទៅស្តាំ ឬដើរមកឆ្វេងនឹងស៊ីបានកូន៥

| ដូច្នេះសម្រាប់ភាគីទី២ (Y) បើប៉ារឈ្នះគេគួរចាប់យករន្ធY5 ហើយដើរទៅស្តាំនឹងស៊ីបានកូនច្រើនជាងដើរមកឆ្វេង ល្អជាងចាប់យករន្ធដទៃទៀត។ |
|---|

បើចាប់យករន្ធ Y3 ហើយដើរទៅស្តាំនឹងស៊ីបានកូន៥។បើដើរមកឆ្វេងនឹងស៊ីបានកូន៥ដែរ។

-Y3 : ដើរទៅស្តាំ : ៥

-Y3 : ដើរមកឆ្វេង : ៥

Y3 ដើរទៅស្តាំ ឬដើរមកឆ្វេងនឹងស៊ីបានកូន៥

| Y3(ស្តាំ) = Y3(ឆ្វេង) = ៥ |
|---|

បើចាប់យករន្ធY4 ហើយដើរទៅស្តាំនឹងស៊ីបានកូន៦។ បើដើរមកឆ្វេងនឹងស៊ីបានកូន៥។

-Y4 : ដើរទៅស្តាំ : ៦

-Y4 : ដើរមកឆ្វេង : ៥

Y4 ដើរទៅស្តាំ ស៊ីបានកូនលើសដើរមកឆ្វេង១

| Y4(ស្តាំ) > Y4(ឆ្វេង) ឬ ៦ > ៥ |
|---|

| Y2(ស្តាំ) = Y2(ឆ្វេង) = ៥ |
|---|

បើចាប់យករន្ធY5 (រន្ធក្បាលជីមឿង) ហើយដើរទៅស្តាំនឹងស៊ីបានកូន៧ បើដើរមកឆ្វេងនឹងស៊ីបានកូន៥ប៉ុណ្ណោះ។

-Y5 ដើរទៅស្តាំ : ៧

-Y5 ដើរមកឆ្វេង : ៥

| |
|---|
| Y5(ស្តាំ) > Y5(ឆ្វេង) ឬ ៧>៥ |

Y5 ដើរទៅស្តាំស៊ីបានកូន៧លើសដើរមកឆ្វេង២

-ជាការសន្និដ្ឋានរួមបើគេប្រៀបធៀបមក ភាគី X ដែលប៉ាវឈ្នះដូចគ្នា ឃើញថាចំនួនកូនស៊ីបាន៧ ដូចគ្នា ប៉ុន្តែខុសគ្នាត្រង់ទិសដើរប៉ុណ្ណោះ ពោលគឺភាគី Y ត្រូវដើរទៅស្តាំតែមួយគត់ទើបស៊ីបានកូន៧ដូចភាគី X។

៤.៣. អំពីក្បួនដើរញែក

តាមពិតទៅក្បួនដើរញែកត្រូវបានគេហាមមិនឱ្យយកមកប្រើប្រាស់ក្នុងល្បែងបាយខ្ញុំនេះទេប៉ុន្តែប្រិយមិត្តអ្នកអានច្បាស់ជានឹងមានមន្ទិលសង្ស័យក្នុងចិត្តថាហេតុអ្វីបានជាក្នុងវិធានល្បែងគេហាមមិនឱ្យប្រើ? តើដើរញែកជះឥទ្ធិពលអ្វីដល់គូភាគីទាំងពីរ ហើយក្បួនដែលញែកនោះមានរបៀបដើរយ៉ាងដូចម្តេចខ្លះ ហើយយករន្ធណាធ្វើជារន្ធពិសេស?

-ជារួមដើរញែក គឺជារបៀបដើរសម្រាប់ផ្តួលគូប្រកួតឱ្យចុះចាញ់ដោយឆាប់រហ័សព្រោះដើរញែកអាចចាប់យករន្ធពិសេសដែលដើរទៅស៊ីបានកូនច្រើនរហូតដល់ទៅម្តៃពោលគឺប្រហាក់ប្រហែលនឹងពាក់កណ្តាលនៃចំនួនកូនសរុបដែលត្រូវប្រើប្រាស់ទាំងសែសិបពីរ។ ដើរញែកគឺគេចាប់យកកូនក្នុងរន្ធពិសេសណាមួយដែលបានកំណត់ទុកថាស៊ីច្រើនជាងគេ។គេដាក់កូនទៅក្នុងរន្ធបន្ទាប់ខាងមុខរួចត្រឡប់មកដាក់កូនក្នុងរន្ធខាងក្រោយ ហើយបន្តដើរជាធម្មតា។ ឧទាហរណ៍ : បើភាគីទី១ តាងដោយ(X)ចង់ដើរញែកគឺគេកំណត់យករន្ធX3 ដើម្បីដើរដោយ ដាក់កូនមួយទៅរន្ធឆ្វេង ហើយដាក់កូនមួយទៀតទៅរន្ធស្តាំហើយដើរបន្តមកស្តាំ។ ជាលទ្ធផលគឺគេទទួលបានកូនចំនួនម្តៃ។ បើភាគីទាំងទី២តាងដោយ(Y)ត្រូវដើរមុនហើយចង់ដើរញែក។ គឺគេចាប់យករន្ធ Y2 ដោយដាក់កូនមួយនៅរន្ធឆ្វេងកូនមួយទៀតនៅរន្ធស្តាំ ហើយដើរបន្តមកស្តាំ។ ជាលទ្ធផលគឺគេអាចស៊ីបានកូន១៥ពោល គឺជិតពាក់កណ្តាលនៃកូនទាំងសែសិបពីរ។ ហេតុដូច្នេះបានជាក្នុងវិធានគេហាមមិនឱ្យភាគីណាមួយលេងដើរញែក ប៉ុន្តែ ដើរញែកក៏មានចែង

ច្បាស់ក្នុងក្បួនដើររបស់បាយខ្ញុំដូចទើបនឹងបានរៀបរាប់រួចមកហើយនេះ។

ដូច្នេះជាការសន្និដ្ឋានបើភាគីXប៉ាវឈ្នះចង់ដើរញែកត្រូវចាប់យករន្ធx3 ញែកទៅឆ្វេងរួចមកស្ដាំ ហើយដើរបន្តមកស្ដាំ ទើបស៊ីបានកូនម៉្ដៃ។

បើភាគ Y ប៉ាវឈ្នះចង់ដើរញែកត្រូវចាប់យករន្ធY2ញែកទៅឆ្វេងរួចញែកមកស្ដាំ ហើយដើរបន្តមកស្ដាំទើបស៊ីបានកូនចំនួនដប់ប្រាំលើសខ្វះគ្នាចំនួន៥។

## ៥. វិធានល្បែងបាយខ្ញុំ

មិនថាល្បែងណាជាល្បែងណាទេឱ្យតែមានឈ្មោះថាល្បែងតែងតែមានវិធានជាប់មកជាមួយដើម្បីជានាសណ្ដាប់ធ្នាប់របៀបរៀបរយឬក៏ជានានូវយុត្តិធម៌ឱ្យភាគីម្ខាងៗ។ ចំពោះល្បែង បាយខ្ញុំ គេឃើញមានវិធានក្នុងការលេងមានជាអាទិ៍:

ភាគីណាឈ្នះត្រូវដើរមុន

ហាមមិនឱ្យដើរញែក

រន្ធក្បាលដីមឿងត្រូវដាក់កូនប្រាំរន្ធបរិវារត្រូវដាក់កូនបួន

ពេលដើររន្ធមួយអាចដាក់បានកូនតែមួយគត់មិនអាចដើររំលងឬផ្លោះរន្ធមានរន្ធចន្លោះ(រន្ធទទេ) ទើបអាចស៊ីរន្ធបន្ទាប់បានអាចស៊ីបានច្រើនរន្ធ កាលបើមានរន្ធចន្លោះ(ជារន្ធទទេ)ពេលដើរបើអស់កូនត្រូវចាប់យករន្ធបន្ទាប់ដើរបន្តមិនឱ្យដាក់កូនក្នុងរន្ធស្អុយ បើជ្រុលដាក់ មិនអាចយកវិញបានទេ បើដើរទៅអស់កូនហើយនៅរន្ធបន្ទាប់មានរន្ធពីរទំនេរមិនអាចបន្តសកម្មភាពបានទេ ភាគីមួយដើរចប់ភាគីមួយទៀតអាចដើរបាន

សល់កូនមួយ ឬពីរ ត្រូវបញ្ឈប់ការដើរ ហើយចែកកូនគ្នា (កូននៅខាងណាខាងនោះទទួល)ចាញ់ គេត្រូវផ្ទុំរន្ធ ហើយផ្ទុំឱ្យកូនប៉ើងដល់មាត់រន្ធគោរពវិធានឱ្យបានម៉ឺងម៉ាត់ជៀសវាងការរំលោភបំពាន

## ៦. សារប្រយោជន៍របស់ល្បែងបាយខ្ញុំ

ល្បែងបាយខ្ញុំបានផ្ដល់នូវសារប្រយោជន៍ មួយចំនួនចំពោះបុគ្គលម្នាក់ៗជាក់ស្ដែង:

បាយខ្ញុំបណ្ដុះនូវស្មារតីឆ្លាតវាងវៃចំពោះបុគ្គលចេះល្បិចដើរបានចំណេញនិងយកឈ្នះលើគូប្រកួតកាត់បន្ថយភាពតានតឹង

បន្ទាប់ពីធ្វើការហាត់នឿយទទួលបន្តនូវវប្បធម៌ដែលមានមកហើយឱ្យរស់រានមានជីវិតពីជំនាន់មួយទៅជំនាន់មួយ។

## សេចក្តីសន្និដ្ឋាន

ថ្វីត្បិតតែមិនមានសកម្មភាពមមាញឹក ឬបរិយាកាសខ្មៀវខ្វារ ដូចល្បែងបោះអង្គញ់ក្តី ក៏ល្បែងបាយខុំអាចរក្សាបាននូវរូបភាពទំនាក់ទំនងជាមិត្តភាពឬទំនាក់ទំនងសង្គមដ៏ជិតស្និទ្ធមួយក្នុងចំណោមមិត្តភក្តិក៏ដូចជាសមាជិកគ្រួសារដែលចាត់ទុកជាផែនគ្រឹះដ៏រឹងមាំសម្រាប់សង្គមជាតិ។ ទន្ទឹមនឹងនេះបើគេគិតពិចារណាទៅលើការដើរវិញល្បែងបាយខុំក៏អាចឆ្លុះបញ្ចាំងឱ្យឃើញពីស្មារតីចេះគិតគូរប្រមាណទុកបានត្រឹមត្រូវលើការខាតបង់ឬចំណេញដែលជាទស្សនវិជ្ជាមូលដ្ឋាននៃវឌ្ឍនភាពក្នុងមុខរបរចិញ្ចឹមជីវិតប្រចាំថ្ងៃរបស់ប្រជាជនខ្មែរគ្រប់រូបរូប។




*ក្តារបាយខ្ញុំ និងទិសនៃការដើរ

X1, x2, x3, x4, : វន្ទបរិវាររបស់ភាគី X

X5 : វន្ទក្បាលជីមឿងរបស់ភាគី X

Y1, y2, y3, y4, : វន្ទបរិវាររបស់ភាគី Y

Y5 : វន្ទក្បាលជីមឿងរបស់ភាគី Y

# ស្វែងយល់ពីម្ហូបខ្មែរ៖ សម្លរម្ជូរខ្ទូរក្តាម[1]

Understanding on Khmer food "Khuor Kdam Food"

*ដោយ៖ ឯកឧត្តមបណ្ឌិត* **អ៊ុំ ប៉ុម**

*ជំនួយការរាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*ម្ហូបអាហារជាធាតុមួយក្នុងចំណោមធាតុទាំងឡាយនៃប្រភេទទាំងប្រាំបួនរបស់វប្បធម៌មានតួនាទីទ្រទ្រង់ការរស់រានមានជីវិតរបស់មនុស្សក៏ដូចជាជាតិសាសន៍ទាំងអស់នៅលើសកលលោកយើងនេះ។ មនុស្សម្នាក់ៗចេះធ្វើម្ហូបតគ្នាពីជំនាន់មួយទៅជំនាន់មួយដោយសាររៀនពីម្តាយផ្ទាល់ឬមួយក៏ចេះដោយការរៀនសូត្រពីសាលាតាមរយៈកម្មវិធីសិក្សាវិជ្ជាមេផ្ទះ*(Art ménager)*ដែលក្នុងនោះមានរៀនលម្អិតពីវិជ្ជាធ្វើម្ហូប។ ទាក់ទងនឹងម្ហូបអាហារនេះដែរបើគេពិចារណាទៅតាមសីលធម៌របស់នរវិទ្យាមុខវិជ្ជានេះបានអប់រំប្រែកបដោយគុណធម៌យ៉ាងនេះថាគ្មានម្ហូបអាហាររបស់ជាតិសាសន៍ណាមួយដែលអន់ថយឬថ្កុំថ្កើងជាងជាតិសាសន៍ណាមួយផ្សេងទៀតនោះឡើយ មានន័យថាជាតិសាសន៍នីមួយៗត្រូវដាក់កាយដាក់ចិត្តសិក្សាស្វែងយល់ពីគ្នាក្នុងរសជាតិម្ហូបអាហារគ្នាទៅវិញទៅមកដោយក្តីសោមនស្សរីករាយគោរពស្រឡាញ់វប្បធម៌ម្ហូបផងគ្នាឲ្យតម្លៃខ្ពស់ដោយមិនរើសអើង ឬបង្កជាជម្លោះរាលដាលធំព្រោះតែរឿងម្ហូបអាហារហូបចុកខុសគ្នានោះឡើយ។ ដោយឡែកផ្សារភ្ជាប់ទៅនឹងបញ្ហាម្ហូបនេះដែរក្នុងឋានៈជាជាតិសាសន៍មួយនៅលើសាកលលោកខ្មែរយើងក៏មានម្ហូបអាហារសម្រាប់សម្គាល់អត្តសញ្ញាណជាតិសាសន៍របស់ខ្លួនដែរ ហើយដែលក្នុងឱកាសនេះខ្ញុំសូម*

---

[1] *ពាក្យ"ខ្ទូ" នៅទីនេះសរសេរគ្មាន"រ" ទេ។*

លើកយកនូវសម្លដ៏សាមញ្ញមួយមុខដែលគេនិយមហូបចុកនៅឯជនបទស្រែចម្ការរបស់យើងបច្ចុប្បន្ននោះគឺ "សម្លខ្វក្ដាម" យកមកបង្ហាញជូន។ តើសម្លមួយប្រភេទនេះមានវិធីធ្វើនិងគ្រឿងផ្សំអ្វីខ្លះ? ហេតុអ្វីបានជាគេដាក់ឈ្មោះថាសម្លម្ជូរខ្វក្ដាម? សូមអញ្ជើញតាមដាននិងភ្លក្សរសជាតិក្នុងអារម្មណ៍ជាមួយនឹងរូបខ្ញុំជាអ្នករៀបរៀងអត្ថបទនេះដូចតទៅ៖

សំណួរសួរថាហេតុអ្វីបានជាគេដាក់ឈ្មោះថាសម្លម្ជូរ "ខ្វក្ដាម" យ៉ាងដូច្នេះ? តើគេយកខ្វក្ដាមពិតប្រាកដមកធ្វើសម្លនេះឬមួយយ៉ាងណា? ប៉ុន្តែមកទាស់ត្រង់គេសរសេរពាក្យ ខ្វ គ្មាន"រ" ខាងចុង។ តាមពិតទៅសម្ល "ខ្វក្ដាម" ជាឈ្មោះសម្លដែលគេផ្សំឡើងជាសំខាន់ពីសាច់ក្ដាមដោយគេយកក្ដាមមកបកស្នូកនិងសន្ទះទ្រូងចេញលាងទឹកឱ្យស្អាតរួចហើយបុកឱ្យល្អិតលាយជាមួយទឹក ហើយពូតយកទឹកសាច់ក្ដាម[2] នោះមកស្ល‌ផ្សេងផ្សំនិងគ្រឿងផ្សំដទៃទៀតឲ្យកើតចេញជាសម្លបរិភោគប្រកបដោយរសជាតិនិងពេញនិយមរបស់ខ្មែរយើងតែប៉ុណ្ណោះ។ យើងក៏អាចចោទសួរជាបន្តទៀតថាតើសម្លនេះមានគ្រឿងផ្សំប៉ុន្មានមុខ? ហើយមានវិធីធ្វើយ៉ាងណាដែរ?

[2] សូមមើលបន្ថែមវចនានុក្រមសម្ដេចសង្ឃរាជជួនណាត បោះពុម្ពគ្រាទី៥ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យឆ្នាំ ១៩៦៨ ទំព័រ១០០។

## ១. គ្រឿងផ្សំ ( Ingredients )

គ្រឿងផ្សំរបស់សម្លនេះមាន១២មុខជាក់ស្ដែងមាន÷

- ក្ដាមពេញចំណាស់ស្រស់ៗពី១០ទៅ១៥ក្ដាម(ញីក៏បានឈ្មោលក៏បានឬយកចម្រុះគ្នា) លើកលែងតែក្ដាមសកឬកូនក្ដាមតូចៗចេញ។ គួរកត់សម្គាល់ថាក្ដាមដែលមានរសជាតិបំផុតគឺនៅខែកត្តិកធ្លាក់ខ្យល់ពីជើង ពេលស្រូវហាលផ្កាចេញស្រុះឬទុំមួយៗព្រោះពេលនោះក្ដាមមានខ្លាញ់ច្រើនដោយសារសម្បូរចំណីអាហារចិញ្ចឹមជីវិត។

-កំពឹសស្រស់ៗមួយដៃ(ប្រហែលមួយខាំ)

- ផ្លែល្ពៅស្រកាក្ដាម[3]ប្រភេទសំបករលោងមួយផ្លុង។ បានជាយកល្ពៅប្រភេទនេះព្រោះវាមានសាច់ស្អិតហើយល្អតល្អ។ បើគ្មាន

[3] ស្រកាក្ដាមមានន័យថាពេញចំណាស់។

ផ្លែល្ពៅទេគេអាចយកមើមដំឡូងផ្អាមកជំនួសក៏បាន ប៉ុន្តែបើឱ្យត្រូវហើយចាប់គ្នាល្អ មានតែផ្លែល្ពៅនិងត្រួយល្ពៅ[4]ប៉ុណ្ណោះ។

- ត្រួយល្ពៅ (បេះដៃវាចោល) ហើយនិងផ្កាល្ពៅនោបឬរីកមួយបាច់។

- ក្តាតហួប (ជាងប្រផេះមិនមែនក្តាតហោព) ពី៣ ទៅ៤ ជាង

- ផ្លែអំពិលស្រកាក្តាមមួយចង្កោមឬផ្លែក្រសាំងពេញចំណាស់ក៏បាន បើគ្មានអំពិល

- ប្រហុកសាច់ត្រីកំភ្លាញមួយកូនដុំ

- ផ្លែល្ហុងខ្ចីតូចល្មមមួយផ្លែ

- ម្ទេសប្លោកទុំឬស្រគាលមួយផ្លែ

- ម្អមស្រស់ពី២ ទៅ ៣ ដើម (ម្អមមានផ្កាឬមិនទាន់ផ្កាក៏បាន)

- អំបិលម៉ត់មួយស្លាបព្រា

- ស្ករត្នោត(ស្ករក្រហម) មួយស្លាបព្រា

**២.វិធីធ្វើ** ( Method )

យកក្តាមស្រស់ៗ (ទើបងាប់ក្តាមៗ) មកបកស្នូកនិងសន្ទះទ្រូងចេញហើយលាងទឹកឱ្យស្អាតដាក់លើកញ្ច្រែងឱ្យស្រស់ទឹក។ យកស្នូកក្តាមដែលបកហើយមកគ្ដិះយកខ្លាញ់ពណ៌លឿងដាក់ក្នុងស្នូកស្អាតណាមួយដោយឡែក (ធ្វើដោយប្រយ័ត្នប្រយែងបំផុតកុំឱ្យដោយអ្វីក្រៅពីខ្លាញ់)ឬដាក់ក្នុងកូនចានគោមក៏បានហើយកូរឹកឱ្យសព្វជាមួយអំបិល (ប៉ាន់អំបិលឱ្យល្មមកុំឱ្យប្រៃពេកបាត់រសជាតិ)។ គេអាចយកសំបកខ្លាញ់ក្តាមនោះមកអាំងឱ្យឆ្អិនល្អទុកហូបបន្តិចៗជាមួយសម្លឬយកទៅចាក់លាយក្នុងសម្លពេលកំពុងស្ងូក៏បានដើម្បីយកពណ៌ស្រស់របស់សម្ល ហើយអាចទាក់ទាញឱ្យចង់ហូបសម្លនោះផង។ បន្ទាប់មកគេយកក្តាមដែលលាងសម្រស់ទឹករួចមកបុកឱ្យម៉ត់ល្មមហើយពូតឬច្រោះយកទឹកក្តាមដោយកុំឱ្យដោយកាកមកដាក់ក្នុងចានមួយដោយឡែកទុកមួយអន្ទើ។ បន្ទាប់មកទៀត យកល្ពៅមួយកូនជ្រុងនោះមកចិតសំបក ហើយគាស់សាច់ល្ពៅនឹងកាំបិតឱ្យទៅជាដុំៗតូចល្មម ហើយត្រាំទឹកឱ្យអស់ជ័រ។ រួច

[4]បើគេយកត្រួយល្ពៅទៅដាក់ក្នុងទ្រូតាមវាលស្រែក្តាមចូលស៊ីត្រួយល្ពៅឡើងណែនទ្រូតែម្តង។

ហើយយកផ្កាល្ពៅមកហែកជាចំណែកៗដោយបកយកបណ្តូលចេញ។ បន្ទាប់មកទៀតយកត្រួយល្ពៅមកបេះដៃចោល កាត់ជាកង់ៗខ្លីល្មមរួចពុះជាពីរហើយលាងទឹកឲ្យជ្រះជ័រ រួចសំដិលលើកញ្ច្រែងឲ្យស្រស់ទឹក។ យកម្អមស្រស់មកហាន់ជាកង់ៗខ្លីល្មម។ យកម្ទេសប្លោកមកកាត់ទងចោលហើយពុះជាពីរយកបណ្តូលនិងគ្រាប់ចេញ (ការពារកុំឱ្យហឹរ) លាងទឹកឱ្យស្អាតហាន់ជាចំណិតត្រសក់ឆ្មារៗ ទុកបង់ក្នុងសម្ង។ បន្ទាប់មកយកផាងក្តាតមកបកសំបកចេញចិតជាចំណិតត្រសក់រួចត្រាំជាមួយទឹកអំបិលប្រៃឡូមៗ ហើយច្របាច់ឱ្យសព្វ(ដើម្បីការពារកុំឲ្យរមាស់កពេលបរិភោគ) រួចលាងទឹកចេញឲ្យជ្រះទឹកអំបិល។ ចំពោះផ្ទៃអំពិលវិញអាចទុកឱ្យនៅជាចង្កោមដូចដើមឬកាត់ជាក្ដួរៗ ក៏បានរួចលាទឹកឱ្យស្អាត។ យកប្រហុកសាច់ត្រីកំភ្លាញមកចិញ្ច្រាំឱ្យល្អិតទុកក្នុងចានមួយដោយឡែកសម្រាប់ទុកជ្រុំចូលក្នុងឆ្នាំងសម្ល។ យកឆ្នាំងសម្លដាក់ទឹកឲ្យល្មមហើយដាំឱ្យពុះលោតកូនក្រាញ់[5]រួចបង់អំបិលនិងស្ករចូលភ្លក្សមើលឱ្យសមល្មមកុំឲ្យប្រៃពេកផ្អែមពេក។ បន្ទាប់មកយកចង្កោមផ្ទៃអំពិលទៅដាក់ស្ងោរក្នុងឆ្នាំងទឹកពុះនោះលៃឲ្យឆ្អិនល្មម ហើយស្រង់យកមកដាក់ក្នុងចានទុកជ្រុំយកទឹកដាក់ចូលក្នុងឆ្នាំងសម្ល។ ដួសទឹកពុះមួយវែកមកដាក់ក្នុងចានប្រហុកជ្រុំឲ្យសព្វហើយច្រោះនឹងកន្ត្រងដាក់ចូលទៅក្នុងឆ្នាំងសម្លដែលមានទឹកកំពុងពុះស្រាប់ រួចដួសកករខ្លាញ់ប្រហុកអណ្តែតលើទឹកកំពុងពុះនោះចេញ (បើសិនជាមាន) រួចហើយទើបយកទឹកម្ជូរអំពិលដែលជ្រុំទុករួចស្រេចចាក់ចូលទៅក្នុងឆ្នាំងទៀតហើយត្រូវរង់ចាំទឹកឲ្យពុះកញ្ជ្រោលដូចមុន។ ក្រោយមកទើបយកទឹកសាច់ក្តាមចាក់ចូលក្នុងឆ្នាំងទឹកពុះនោះ រួចបន្ទល្ពៅនិងត្រួល្ពៅតាមក្រោយ។ រម្ងាស់ឲ្យផុយល្មម ទើបបង់ល្ហុងនិងក្តាតចូល។គួរចងចាំថាល្ហុងនិងក្តាត គប្បីកុំឲ្យផុយពេកតែរក្សាសភាព"ច្រុបៗ"ទើបឆ្ងាញ់។ រង់ចាំឱ្យទឹកពុះបន្តិចទើបគេយកកំពឹសមកបង់ចូល។ បន្ទាប់មកយកខ្លាញ់ក្តាមដែលបម្រុងទុកមកបង់បន្ថែមហើយកូរឲ្យសព្វ។

[5] លោតកូនក្រាញ់មានន័យថា ទឹកពុះខ្ជោលៗ ដូចកូនត្រីក្រាញ់លោតឡើងពីទឹកហើយននាលខ្លួនទៅរកទីដែលវាចង់ទៅពេលកំពុងភ្លៀង។

គួរចង់ចាំថាល្ហុង់និងក្តាត គប្បីកុំឲ្យផុយពេកតែរក្សាសភាព "ច្រុបៗ" ទើបឆ្ងាញ់។ រង់ចាំឱ្យទឹកពុះបន្តិចទើបគេយកកំពឹសមកបង់ចូល។ បន្ទាប់មកយកខ្ទាញ់ក្តាមដែលបម្រុងទុកមកបង់បន្ថែមហើយកូរឲ្យសព្វ។ ជាសម្រេចចុងក្រោយយកម្ទេសហ្វាក និង ម្អមបង់ចូលក្នុងឆ្នាំងភ្លក្សមើលឲ្យដឹងជូរប្រៃល្មមទើបដាក់ឆ្នាំងសម្លចុះពីចង្ក្រានហើយរៀបចំបរិភោគ។ ក្នុងពេលជាមួយគ្នានោះដែរ បើគេសង្កេតមើលទៅក្នុងឆ្នាំងសម្លគេនឹងឃើញទឹកសាច់ក្តាមអណ្តែតឡើងខ្ចូលខ្ទាញ់ពេញឆ្នាំងសម្លលាយឡំជាមួយខ្ទាញ់ក្តាមពណ៌លឿងទុំស្រស់អណ្តែតត្រៀបត្រាពាសពេញឆ្នាំង ហើយធុំក្លិនម្អមឡើងឈ្ងុយគួរឱ្យស្រក់ទឹកមាត់នឹកចង់ភ្លក្សរសជាតិមុនគេមុនឯងជួបជុំគ្នា។

**កំណត់សម្គាល់៖** សូមបញ្ជាក់បន្ថែមថាសម្លខ្ជូក្តាមស្រូបយកម្ជូរណាស់ បង់ម្ជូរល្មមៗមិនផាយជូរទេមកពីសាច់ក្តាមនិងកំពឹសបង្កឡើង។ ជួនកាលជូរល្មមហើយទុកតែបន្តិចបាត់ជូរទៅវិញក៏មាន។ ប៉ុន្តែត្រូវប្រុងប្រយ័ត្នកុំថែមម្ជូរឲ្យលើសជ្រុលហួសនាំឲ្យជូរជ្រេញបាត់រសជាតិសម្ល។ ក្រៅពីនោះ គេអាចថែមត្រីបីបួនកង់ (ត្រីរ៉ស់ឬត្រីកេះ) ចូលទៅក្នុងសម្លក៏ដូចជាបន្ថែមគ្រាប់សណ្តែកដីស្ងោរមួយចំនួនតាមចំណង់ចំណូលចិត្តរបស់អ្នកបរិភោគបានដែរមិនជាទាស់ខុសអ្វីឡើយ។

## សេចក្តីសន្និដ្ឋាន

សរុបសេចក្តីមក សម្ល "ខ្ជូក្តាម" ជាម្ហូបអាហារមួយបែបដែលជាផ្នែកមួយនៃវប្បធម៌រូបីរបស់ខ្មែរយើងព្រមទាំងជាមុខម្ហូបដែលយើងគប្បីរួមគ្នាថែរក្សាកុំឱ្យបាត់បង់ទៅដោយងាយៗពេកដែរ។ នាពេលបច្ចុប្បន្នក្នុងកាលៈទេសៈដែលពិភពលោកកំពុងយកចិត្តទុកដាក់ទៅលើវិស័យទេសចរណ៍យើងក៏អាចយកសម្លនេះទៅបញ្ចូលក្នុងកម្មវិធីសិក្សាវិជ្ជាធ្វើម្ហូបនៅតាមគ្រឹះស្ថានសាធារណៈក៏ដូចជាឯកជននានា ថែមទាំងអាចយកទៅប្រើប្រាស់ធ្វើជាមធ្យោបាយផ្សព្វផ្សាយឲ្យទេសចរដែលមកទស្សនាកម្សាន្តស្រុកយើងពិសាសាកល្បងមើលផងដែរ។ ជាថែ

ជនទ្បល្អ បើគេភ្លក្សរសជាតិសម្លយើងទៅឆ្ងាញ់ដូចយើងដែរយើងក៏រីតតែមានឈ្មោះបោះសំឡេងកាន់តែឆ្ងាយពីព្រោះថាក្នុងសភាពធម្មជាតិជាមនុស្សមិនថាជាតិសាសន៍ណាជាជាតិសាសន៍ណាទេឱ្យតែមានម្ហូបឆ្ងាញ់ សម្លឆ្ងាញ់ត្រូវមាត់ គេតែងតែប្រាប់តៗគ្នានឹងបបួលគ្នាត្រាច់ចរស្វែងរកដោយមិនគិតពីទីជិតទីឆ្ងាយ ឬចំណាយលុយកាក់ច្រើននោះឡើយ។



*រូបភាពសម្លខ្ទឹមក្ដាម* (*ប្រភព៖* YouTube Channel *មេផ្ទះ*, Housewife)

# ជំនឿបែបជីវចលនិយមក្នុងសង្គមខ្មែរ

*ដោយៈ បណ្ឌិត* **ហែម ឡាច**
*មន្ត្រីនាយកដ្ឋាននីតិសាស្ត្រ*
*វិទ្យាស្ថានមនុសាស្ត្រនិងវិទ្យាសង្គម*
*នៃរាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*មនុស្សក្នុងលោកយើងនេះតែងតែមានជំនឿលើអ្វីៗជាច្រើនតាមការយល់ឃើញរបស់ពួកគេ។ ជនជាតិខ្លះមានជំនឿលើកធម្មជាតិដូចជា បឹងបួ ទន្លេ ព្រៃភ្នំ ដើមឈើធំៗ ឬអព្ភូតហេតុផ្សេងៗដែលជារឿង អច្ឆរិយៈៗ ពួកគេនាំគ្នាគោរពបន់ស្រន់ដោយជឿជាក់ថា កម្លាំងអភិធម្មជាតិទាំងនោះនឹងនាំមកនូវសុភមង្គល ឬ សេចក្តីសុខចម្រើនដល់ក្រុមគ្រួសារសហគមន៍និងប្រទេសជាតិរបស់គេ។*

*ម៉្យាងទៀត ជនជាតិខ្មែរក៏មានជំនឿផ្សេងៗដែលមានលក្ខណៈដូចគ្នា និងខុសគ្នាខ្លះៗទៅនឹងជំនឿរបស់ជាតិសាសន៍ដទៃ។ មុនការមកដល់នៃហិណ្ឌូសាសនា និងព្រះពុទ្ធសាសនាជនជាតិខ្មែរមានជំនឿលើព្រលឹងដូនតា គោរពព្រៃព្រឹក្សា អ្នកតា អ្នកដូន ដើមឈើ។ល។ បុព្វបុរសយើងហៅជំនឿទាំងនេះថាជាជំនឿបែបជីវចលនិយម។*

## ១-ជំនឿអំពីការស្លលោហធាតុ

*ការរៀបចំពីធីថ្វាយដល់វត្ថុស័ក្តិសិទ្ធិនេះ អ្នកស្លលោហធាតុទាំងអស់គេមានជំនឿមុតមាំណាស់ហើយគេតែងតែប្រារព្ធធ្វើជានិច្ចមិនដែលខានឡើយ។ គេបានពោលថា ប្រសិនបើមិនបានរៀបចំគេអាចនឹងស្លលោហធាតុដោយមិនបានផល។*

*តាមរបាយការណ៍ជាក់ស្តែងរបស់លោក អ៊ឹម ធិល និងប្អូនលោកឈ្មោះ អ៊ឹម ធន ជាអ្នកស្លលោហធាតុដ៏ចំណានក្នុងការ ផលិតឧបករណ៍តន្ត្រីគង់នៅសាកលវិទ្យាល័យភូមិវិចិត្រសិល្បៈ បានផ្តល់ព័ត៌មានថាៈ*

*ក្នុងឆ្នាំ១៩៧៦ គឺសម័យខ្មែរក្រហម ប៉ុល ពត នោះ លោកទាំងពីរត្រូវបានគេជម្លៀសឱ្យទៅនៅភូមិដួងញ៉ាញ់ ជាប់ព្រំប្រទល់ថៃ ក្នុងខេត្តបាត់ដំបង។ ប្រជារាស្ត្រនៅភូមិនោះ ត្រូវបានគេប្រមូលរឹបអូសយកអស់ទ្រព្យសម្បត្តិទៅដាក់រួមសូម្បីតែស្វាបព្រាហូបបាយក៏ត្រូវបានយកមកដាក់រួមដែរ។ បញ្ហាដាក់រួមនេះមិនសូវមាននរណាយកចិត្តទុកដាក់ថែរក្សាទេ*

ម៉្លោះ ហើយស្លាបព្រាក៏បាត់បន្តបន្ទាប់រហូតដល់មានកង្វះ ម្នាក់ៗតែងស្ទុះដណ្តើមគ្នាប្រញាយជានិច្ចនៅរាល់ពេលហូបបាយម្តងៗ។ មានអ្នកខ្លះពេលដណ្តើមគេមិនបានយកស្លឹកឈើកែវដួសសម្លហុត ខ្លះខ្និលដណ្តើម រើសយកសង្កសីមកចៀរកាត់ឱ្យមានទម្រង់ជាស្លាបព្រា។ ដោយឃើញការលំបាកនេះ ថ្ងៃមួយបន្ទាប់ពីហូបបាយនៅរោងរួមហើយ លោកទាំងពីរបានពិគ្រោះគ្នាពីនាក់បងប្អូន គិតរកមធ្យាបាយស្លដែកដើម្បីផលិតស្លាបព្រា ដោយរើសយកស្លាព្រា២ទៅធ្វើគំរូចាក់ពុម្ព។ ក្នុងពេលឃើញលោកទាំងពីរយកស្លាបព្រាចេញពីរោងបាយរួមគណៈសហករណ៍ជាកម្មាភិបាលគ្រប់គ្រងនៅភូមិនោះ ដែលបានឈរពីក្រោយខ្នងលួចស្តាប់យូរហើយនោះ បានគំរាម និងបង្គាប់ឱ្យលោកស្លចាក់ពុម្ពជាផាលនង្គ័លសម្រាប់ធ្វើស្រែផង។ លោកក៏យល់ស្របតាមហើយស្នើរសុំសំភារៈដើម្បីរៀបចំចង្រ្កានដំណើរការផលិត។ ការស្លដែកជាធម្មតាដែលលោកបានស្លកន្លងមកមានរយៈពេលមួយម៉ោងប៉ុណ្ណោះអាចរលាយចាក់ពុម្ពបាន។ តែនៅពេលនោះលោកស្លរហូតដល់មួយសប្តាហ៍ទៅហើយ ក៏នៅតែមិនទាន់រលាយអាចចាក់ពុម្ពបាន។ កម្មាភិបាលខ្មែរក្រហមទាំងនោះបានពោលថា នេះជាឧបាយកលខ្មាំង មានបំណងចង់បំផ្លាញបដិវត្តន៍ហើយ...! ។ លោកទាំងពីរឮដូច្នោះមានការភ័យរន្ធត់ណាស់ លោកយល់ច្បាស់ថា ពួកគេនិងយកលោកទៅសម្លាប់ចោលហើយ។ ថ្ងៃទី៧នោះដែរលោកហាក់ចាប់ភ្លឹកមានអារម្មណ៍ នឹកឃើញបួងសួងអង្វរដល់គុណបុណ្យវត្ថុស័ក្តិសិទ្ធិទាំងអស់ សូមជួយលោកផង។ ក្នុងរាត្រីថ្ងៃដដែលនោះ លោកក៏បានសុបិនឃើញឪពុករបស់លោកមានមាឌធំខ្ពស់ កម្ពស់ប្រហែល៦ម៉ែត្រ មកឈរជង្រ្គើងយកជើងជាន់ចង្ក្រានស្លលោហធាតុនោះៗ ស្អែកឡើងលោកទៅទាំងព្រលឹមជម្រាបពីដំណើររឿងកន្លងមកដល់ចាស់ទុំដែលត្រូវជាឪពុកម្តាយរបស់កម្មាភិបាលក្នុងភូមិនោះ និងអង្វរសុំទៀនធូបដែលគាត់មានអំណាចអាចលួចរក្សាទុកសម្រាប់ប្រើការចំពោះជំនឿរបស់គាត់។ គាត់ក៏អាណិតជួយរៀបចំតាមលទ្ធភាព ដោយប្រមូលទាំងកន្ទុយទៀនធូបដែលនៅសល់ យកស្លឹកត្របែកជំនួសស្លឹកម្លូ ដើម្បីធ្វើស្លាធម៌រកចាប់កណ្តុរប្រែងតាមវាលស្រែយកមកខ្វៃអាំងឧបកិច្ចជាជ្រូក...។ បន្ទាប់ពីរៀបចំឧទ្ទិសរួច លោកក៏ចាប់ពិនិត្យដែកដែលកំពុងស្ល ឃើញថារលាយអាចចាក់ពុម្ពចេញជាលទ្ធផលបានតាមប្រាថ្នាមែន។

នៅពេលកំពុងចាក់ពុម្ពចេញជាលទ្ធផលនោះ គណៈសហករណ៍បានមកទាន់ដោយបានឃើញទាំងរណ្តាប់ដែលលោកបានរៀបចំសែនព្រេនទៀត។ គេក៏មិនអាចចាប់ទោសបានព្រោះវាជាការជាក់ស្តែង។ ប៉ុន្តែគេបានសំណូមពរឱ្យយកស្លាធម៌ បាយ សី ដើង

ធូបចេញឱ្យអស់ គឺគេបង្គាប់ឱ្យយកទៅកប់ក្នុងដីដើម្បីឱ្យបាត់ពីភ្នែកពួកយោធា ព្រោះខ្លាចក្រែងគេមិនយោគយល់។ ពួកទាំងអស់នោះសុទ្ធតែជាពួកដាច់ខាតមហាអស្ចារ្យ មហាលោតផ្លោះ ហាមមិនឱ្យនរណាម្នាក់មានជំនឿអរូបិយដាច់ខាត។

តាំងពីថ្ងៃនោះមកការរៀបចំពិធីសម្រាប់មួយឆ្នាំម្ដង ក្នុងការស្ដូលោហធាតុ ចាស់ទុំក្នុងភូមិនោះតែងជួយឧបត្ថម្ភរៀបចំឱ្យដំណើរការរហូតដល់របប ប៉ុល ពត ត្រូវរលំ[1]។

## ២-ជំនឿក្នុងរឿងទាក់ដំរី

គ្រូដែលជួយទាក់ដំរីជាគ្រូអរូបកាន់លើគ្រូដែលចេះរបៀនមន្តអាគមស្និលសម្រាប់ប្រសិទ្ធីដំរី និងអ្នកទាក់ មុនពេលចេញទៅទាក់ដំរី។ មន្តអាគមស្និល អាចធ្វើឱ្យមនុស្សមានកម្លាំងខ្លាំងលុបមាឌលើសប្រក្រតី។ ពេលគេខឹងគេអាចខាំត្បាលបុកគ្រឿងគ្រវែងទៅបានឆ្ងាយ ឬអាចខាំចានកែវស៊ីបាន។ ក្នុងឆ្នាំ ១៩៨១-៨២ យើងខ្ញុំធ្លាប់បានឃើញផ្ទាល់កូនលោក យឹម សាំង ឈ្មោះ យឹម សេន ខាំកែវទំពាស៊ីបាន។

តាមការអធិប្បាយរបស់លោក យឹម សាំង ជាគ្រូបុរាណ កាន់ឧបករណ៍ ផ្ទុំនៅសាកលវិទ្យាល័យ ភូមិន្ទវិចិត្រសិល្បៈ បានមានប្រសាសន៍ដូចតទៅ ៖

ជនជាតិខ្មែរលើ ព័រ រស់នៅក្នុងខេត្តពោធិ៍សាត់ ច្រើនមានជំនាញយ៉ាងចំណានក្នុងការទាក់ដំរី ព្រោះខេត្តនេះសំបូរទៅដោយដំរី។ លោកមានបងធម៌ជាជនជាតិខ្មែរដើម ព័រ បានប្រទះភាពជាក់ស្តែង នូវឧប្បត្តិហេតុមួយគឺ៖

មានប្រពន្ធអ្នកទាក់ដំរីម្នាក់បានទទួលទានដំណេកក្រោមហ៊ឹងតំកល់គ្រឿងសក្ការបូជាសម្រាប់គ្រូស្និល ដែលបានដាក់ជន្ទាប់ក្រមួនស្វលាយជាមួយប្រេងដូង។ នៅពេលក្តៅ ក្រមួនបានរលាយហូរប្រេងដូងស្រក់លើក្បាល ស្រាប់តែនាងករិយាស្ទុះងើបប្រកបដោយកម្លាំងដូចដំរីសាររត់ចូលព្រៃ។ នាងនោះ ចេះដើរជើងបួនផ្ងារពោះឡើងទៅលើដើរតាមហ្វុងខ្លា ដោយដោះសម្លៀកបំពាក់ចេញអស់ ហើយលែងចេះនិយាយទៀត។

អ្នកស្រុកបានដឹងនាំគ្នារត់ទៅព្រៃដើម្បីហៅប្តីឱ្យមករៀបចំបួងសួងសុំខមាទោសគ្រូ។ ប៉ុន្តែហួសរយៈពេល៧ថ្ងៃ មិនអាចកែប្រែឱ្យមកសភាពដើមវិញបាន។ តែអ្នកស្រុកនៅតែនាំគ្នាព័ទ្ធចាប់ហើយចងទុក ក្រែងមានសង្ឃឹមអាចព្យាបាលបានដូចដើម។ បន្ទាប់មកអ្នកនោះឈឺលែងដឹងខ្លួន រហូតដល់បាត់បង់ជីវិត។ នេះជាព័ត៌មានដែលយើងបានដឹងតាមរយៈអ្នកទាក់ដំរីនិងចាស់ទុំ[2]។

[1] កែវ ណារុំ៖ ***តន្ត្រីនិងជីវិតខ្មែរ*** ភ្នំពេញ ការផ្សាយរបស់បណ្ណាល័យ ធពណ្ណរង្សី ឆ្នាំ២០១១ ទំព័រទី២៨៨។

[2] -ដ- ទំព័រទី២៨៩។

## ៣-ជំនឿលើអារក្ស

តើអ្វីជាអារក្សនោះ? អារក្សជាទម្រង់មួយនៃលទ្ធិព្រលឹងនិយម ដែលមានការខុសប្លែកបន្តិចពីអ្នកតា។ នៅពេលដែលអ្នកតាជាតំណាងព្រលឹងបុព្វជន ដូនតា មេកុលសម្ព័ន្ធ អ្នកដឹកនាំប្រចាំភូមិ ឃុំ ស្រុក ខេត្ត តំបន់ ប្រចាំទីឋានភូមិ ស្រែចម្ការ ព្រៃព្រឹក្សា បឹង ស្ទឹង ទន្លេ សមុទ្រនោះ អារក្ស គឺជាព្រលឹងតំណាងគ្រួសារខ្មែរ។ ព្រលឹងអារក្សនេះចែកជាពីរសាខា ដែលខ្មែរមានពាក្យពិសេសមួយហៅថា«ជំបួរ»។ ជំបួរនេះក្លាយមកពីពាក្យ«ជួរ» ពោលគឺជំបួរខាងឪពុក និងជំបួរខាងម្ដាយ។ ជំបួរម្ខាងៗមានឈ្មោះខ្មោចតិច ឬ ច្រើនខុសគ្នាទៅតាមការកំណត់របស់គ្រួសារនីមួយៗ ដែលមានប្រវត្តិយូរអង្វែងរាប់រយពាន់ម៉ឺនឆ្នាំមកហើយ។ ឈ្មោះព្រលឹងអារក្សនេះមានប្រុសមានស្រីដូចឈ្មោះអ្នកតាដែរ។ តើឈ្មោះព្រលឹងអារក្សប្រុស និង អារក្សស្រី ដែលមានប្រចាំគ្រួសារខ្មែរនីមួយៗនេះជាឈ្មោះរបស់អ្នកណា? អ្នកនោះមាននាទីជាអ្វី?។ ប្រហាក់ប្រហែលនឹងឈ្មោះអ្នកតាដែរ ឈ្មោះព្រលឹងអារក្សគឺជាឈ្មោះរបស់បុព្វជនដែលជាប់សាច់ញាតិជាឪពុកម្ដាយ ជីដូន ជីតា ជាគ្រូហ្មព្យាបាលជំងឺជាមេបាជាមេទ័ព ជាអ្នកសិល្ប៍ មានឈ្មោះល្បីនៅក្នុងពេលស្លាប់ទៅព្រលឹងរបស់គាត់មិនដាច់ចិត្តទៅចាប់កំណើតនៅភពថ្មីឡើយ គឺនៅរារែកហិចហើរអណ្ដែតត្រសែតទៅមកតែនៅទីក្បែរៗកូនចៅរួចក៏ប្រាប់ដំណឹងដល់កូនចៅតាមរយៈការពន្យល់សប្ដិ។ តាមរបៀបនេះ កូនចៅក្នុងត្រកូលក៏កត់ចំណាំ ចាំទុក រួចហើយប្រជាដំណឹងតៗឱ្យបានដឹងគ្រប់គ្នាក្នុងត្រកូល គ្រួសារ។ ជួនកាលទៀត ការផ្ដល់ដំណឹងអំពី វត្តមាននៃព្រលឹងដូនតាមកក្នុងជួរជំបួរ ក៏អាចធ្វើបានដែរតាមរយៈការចូលរូប ប្រសិនបើនៅក្នុងវង្សត្រកូលគ្រួសារនេះមានរូបជាតំណាងព្រលឹងខ្មោចរួចហើយ។ ប្រការដែលមិនគួរភ្លេចជម្រាបនោះគឺគ្រប់គ្រួសារវង្សត្រកូល គ្រប់ជួរជំបួរខ្មែរទាំងអស់សុទ្ធតែមានរូប។ វាជាអន្តរការីឈរនៅចន្លោះពិភពខ្មោចនិងមនុស្ស។ សម្រាប់សម្រួលការទាក់ទងបំណងប្រាថ្នា ឬសេចក្ដីត្រូវការខាងសេវាយ៉ាងណាៗ ពីពិភពមួយទៅពិភពមួយទៀត។ រូបអារក្សតំណាងជួរជំបួរទាំងនោះជាធម្មតា ពោលគឺសមាជិកជួរជំបួរតែងគោរពស្រឡាញ់កោត ខ្លាចរូប ដោយគេចាត់ទុករូបដូចជាជនពិសេសមានតេជៈបារមីអាចផ្ដល់សេចក្ដីសុខ អាចជួយយកអាសាគេរាល់ពេលមានភ័យវង្សត្រកូលគ្រួសារ។ ជនប្រភេទនេះមានមនោសញ្ចេតនាស្រឡាញ់ជាប់ចិត្តនឹងកូនចៅ។

អាសន្ន។ រូបអារក្សនៅក្នុងជំបូរនីមួយៗតែងតែផ្លាស់ប្តូរថ្មី កាលណារូបចាស់ស្លាប់ ឬក៏ចាស់ជរាទ្រុឌទ្រោមកម្លាំង។ អ្នកដែលត្រូវមកជំនួសរូបចាស់គឺមនុស្សស្ថិតក្នុងជួរជំបូរតែមួយជាមនុស្សមានវ័យក្មេង មានឋាមពលកម្លាំងខ្លាំងក្លា ហើយត្រូវជាមនុស្សដែលមានលក្ខណៈសម្បត្តិសម្រាប់ធ្វើជារូបអារក្ស។ គេអាចនិយាយបានថា ជាមនុស្សដែលទទួលបានការជ្រើសរើសពីព្រលឹងខ្មោចទាំងឡាយប្រចាំជំបូរ។

គប្បីជ្រាបផងដែរថា ទោះបីអ្នកនោះមិនចង់ក៏ពុំអាចគេចបាន។ ផ្ទុយទៅវិញ បើជនណាមួយចង់ធ្វើរូបដោយពុំមានការជ្រើសរើសក៏មិនអាចសម្រេចបំណងគេបានដែរ។

## ៤-ជំនឿលើម្រេញគង្វាល

បញ្ហាពាក់ព័ន្ធទៅនឹងជំនឿម្រេញគង្វាលគឺ ខ្មែរចាត់ទុកថាជាប្រភេទខ្មោច ក្មេងៗមួយប្រភេទជាអ្នកថែរក្សាផ្ទះសម្បែង ទ្រព្យសម្បត្តិ សត្វពាហនៈ។ នៅតាមស្រុក ភូមិ មិនថា នៅទីក្រុងឬនៅតាមខេត្តទេ យើងតែងតែឃើញវត្ថុមានខ្នមមួយធ្វើអំពីឈើឬឫស្សី ឬកញ្ច្រែងចងព្យួរជាសង្រែក ឬដើមឫស្សីច្រៀកដាក់កងរាងជាជីវឡាវ ដោយមានព្យួរបំពង់ដាក់ទឹកចំនួន៤ ហើយនៅលើរាន មានដាក់របស់សំណែនមានព្យួរសម្លៀកបំពាក់(កូនខោអាវ)ពណ៌ក្រហម៤សម្រាប់ និងរបស់ក្មេងលេងដូចជាកូនឃ្លី កូនបាល់ ...នៅមុខផ្ទះរបស់ប្រជាជនខ្មែរសឹងតែគ្រប់ផ្ទះ នោះគឺជាលំនៅស្ថានរបស់ម្រេញគង្វាល។ ហើយជានិច្ចកាលម្ចាស់ផ្ទះ សែនព្រេនចំណីដូចជា ស្ករគ្រាប់និងទឹកជាដើមដោយមានជំនឿថា ម្រេញគង្វាលនឹងផ្តល់ចំពោះគេនូវសេចក្តីសុខ សេចក្តីចម្រើនឱ្យមុខរបររកស៊ីរបស់គេបានរីកចម្រើនលូតលាស់ជាពុំខាន។ តាមការសង្កេតរបស់យើងឃើញថា ប្រជាជនខ្មែរគោរពបូជាម្រេញគង្វាលសឹងតែគ្រប់ផ្ទះទាំងអស់។ នៅតាមទីសាធារណៈ និងកន្លែងលក់ដូរមួយចំនួនក៏គេរៀបចំសំណែនសម្រាប់ម្រេញគង្វាលដែរ។



ម្រេញគង្វាល(ប្រភព: https://www.google.com )

## ៥-ជំនឿលើជំនាងផ្ទះឬម្ចាស់ផ្ទះ

ជំនឿលើជំនាងផ្ទះ គឺជាទំនៀមទម្លាប់មួយដែលមានជាប់ជាប្រពៃណីខ្មែរយើងតាំងពីយូរយារមកហើយ។ ដូនតាយើងជឿថា ជំនាងផ្ទះជាទេវតាថែរក្សា និងគ្រប់គ្រងសំណាង់ ហើយដែលប្រហែលជាស្ទាកស្ទាមគ្រប់គ្រងតាមបែបមាតាធិបតេយ្យ។ ម្ល៉ោះហើយជនជាតិខ្មែរជឿថា ផ្ទះនីមួយៗសុទ្ធសឹងតែមានជំនាងផ្ទះនៅតាមថែរក្សាជានិច្ចកាល។ ប្រជាជនខ្មែរជឿថា ផ្ទះថ្មីដែលទើបនឹងសាងសង់រួច គឺមានទេវតាផ្ទះមកតាមថែរក្សា។ ជំនាងផ្ទះមិនគ្រាន់តែជួយរក្សាការពារកំណប់ទ្រព្យ មាសប្រាក់មិនឱ្យបាត់បង់ប៉ុណ្ណោះទេ ថែមទាំងទប់ទល់ការពារនឹងខ្មោច ព្រាយ បិសាចមិនឱ្យមកបៀតបៀនម្ចាស់ផ្ទះទៀតផង។ ជំនាងផ្ទះស្លៀកពាក់ស្អាតបាត មានរូបរាងប្រៀបដូចទេវតា ប្រកបដោយសីលធម៌ខ្ពង់ខ្ពស់។ ទោះបីម្ចាស់ផ្ទះត្រូវបង្ខំចិត្តចាកចេញពីផ្ទះដោយប្រការណាមួយក៏ដោយ ក៏ប៉ុន្តែជំនាងផ្ទះមិនបោះបង់ផ្ទះនេះទេ ហើយរង់ចាំនៅបន្តថែរក្សាផ្ទះរហូតដល់ពេលមានម្ចាស់ផ្ទះថ្មីមករួមរស់ជាមួយតទៅទៀត។

## ៦-ជំនឿលើព្រះភូមិ

នៅតាមផ្ទះប្រជាជនខ្មែរយើង ជាពិសេសអ្នកស្រុកភ្នំ និងអ្នកស្រុកស្រែចម្ការតែងតែមានរានអាសនៈមួយស្ថិតក្នុងបរិវេណទីធ្លាខាងមុខផ្ទះ ឬនៅក្បែរផ្ទះ។ នោះគឺជាទីកន្លែងរស់នៅរបស់ព្រះភូមិ ដែលប្រជាជនខ្មែរមានជំនឿថាជាទេវតាថែរក្សា និងគ្រប់គ្រងដីធ្លីការពារភូមិស្រុក ផ្ទះសម្បែង ប្រឆាំងនឹងសត្រូវ ឈ្លាន ពាន មានខ្មោច ព្រាយ បិសាចជាដើម។ ជំនាងផ្ទះនិងព្រះភូមិ ប្រៀបបាននឹងអភិបាលនគរូបនីយកម្មនិងសំណាង់។ ព្រះភូមិត្រូវបានប្រជារាស្ត្រខ្មែរគោរពជឿ និងឱ្យតម្លៃយ៉ាងខ្ពស់ ជាអ្នកមានបារមីខ្លាំងក្លាក្នុងការបីបាច់ថែរក្សាលំនៅស្ថានអ្នកភូមិ។ ព្រះភូមិ មានឥទ្ធិពលខ្លាំងក្លាក្នុងសង្គមខ្មែរ ដែលប្រជាជនខ្មែរគោរពកោតខ្លាចយ៉ាងជ្រាលជ្រៅ។ ដូច្នេះហើយបានជាភ្ញៀវដែលចូលផ្ទះនីមួយៗ ត្រូវអុជធូបទៀន ស្នើសុំការអនុញ្ញាតពីព្រះភូមិ។ ក្មេងទើបនឹងកើត គូស្វាមីទើបនឹងរៀបការហើយចូលទៅរស់នៅក្នុងផ្ទះ គេត្រូវសែនព្រេន អុជធូប ទៀនជម្រាបដល់ព្រះភូមិ ជំនាងផ្ទះ ដើម្បីសុំបើកផ្លូវ សុំការអនុញ្ញាតរស់នៅក្នុងផ្ទះឱ្យបានសេចក្តីសុខ សេចក្តីចម្រើន។

### ៦.១-មន្តព្រះភូមិ

យើងសូមថ្វាយបង្គំ សូមសរសើរព្រះធរណី ដែលជាអ្នកទទួលបន្ទុកនូវមនុស្ស សត្វរុក្ខជាតិ និងទឹកដីជាដើម ជាអ្នកអាចអត់នូវក្តីដែលត្រូវ គេបៀតបៀនគ្រប់បែបយ៉ាង មានត្រូវការកាប់ដីជាដើម។ បពិត្រព្រះធរណី ហើយដោយអំណាច ដែលយើងខ្ញុំសូត្រស្តុតិ

*សរសើរសព្វថ្ងៃនេះសូមក្តីក្តៅក្រហាយ នូវ កំសួលពិស កុំបីមានឡើយ។*

### ៦.២-គាថាបូជាព្រះភូមិ

*ទើបអស់យើងខ្ញុំ ហត្ថប្រណម្យ បង្គំវន្ទា*
*អញ្ជើញព្រះភូមិ ឧត្តមរាជា អ្នកតែងជានា*
*ព្រះធរណីឋាន ។*

*បពិត្រអ្នកកើយ កុំនៅកន្តើយ ខ្ញុំសូមស្មោះស្មាន*
*សូមអស់លោកយាង យាត្រាហោះប្តាន មកដល់ទីឋាន*
*គេហានេះនៃ ។*

*យើងខ្ញុំរៀបចំ ប្រពៃណីសក្តិសម អាហារចំណី*
*អស់គ្រឿងក្រយា សារពើស្រេចស្រាប់ គ្រប់គ្រឿងវណ្ណាប់*
*អញ្ជើញសេពសោយ។*

*មុនលោកយាត្រា ចរចេញលីលា សូមប្រសិទ្ធី*
*ពរជ័យដល់អ្នក គ្រប់អស់អង្គប្រាណ បានសុខក្សេមក្សាន្ត*
*និរន្តរ៍តទៅ។*

*សូមឱ្យរោគភ័យ គ្រោះកាចចង្រៃ វិនាសសូន្យសុង*
*កុំមកបៀតបៀន ចេញអស់ពីប្រាណ ដូចពាក្យអធិដ្ឋាន*
*នាគ្រានេះហោង[៣]។*

---

[៣] ឱុច សុនះ ***សីលធម៌ ជំនឿនិងទំនៀមទម្លាប់ខ្មែរបូរាណ*** ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ២០០៥ ទំព័រទី២២៣។

## ៧-ជំនឿលើត្រណម

ខ្មែរសម័យដើមមានជំនឿលើត្រណមជាច្រើន។ ត្រណមពេលរៀមង្គលការ ដើរព្រៃសែនប្រចាំភូមិ ត្រណមក្នុងការនិយាយស្តី។ល។ អ្នកស្រុកស្រែចម្ការ និងអ្នកស្រុកភ្នំ ជាពិសេសជនជាតិខ្មែរដើម គេកាន់ត្រណមហ្មត់ចត់ណាស់។ កាលបើប្តីចេញឆ្ងាយ ប្រពន្ធនៅផ្ទះ មិនត្រូវដេរវាយកូនចៅ សិតសក់យំស្រែកយកវែកបាយ វែកសម្ភោះមាត់ផ្នាំង ឬគងមាត់ផ្នាំងឡើយ។ បើមិនគោរពតាម ត្រណមទាំងនេះទេ នោះប្តីនឹងត្រូវទទួលគ្រោះថ្នាក់គ្រោះអកុសលដោយប្រការផ្សេងៗ។

### ៧.១-ត្រណមសម្រាប់អ្នកមានគភ៌

តាមជំនឿខ្មែរបុរាណដើម្បីរក្សាគភ៌ឱ្យបានគង់វង្សល្អនិងឆ្លងទន្លេបានរហ័សស្ត្រីដែលមានផ្ទៃពោះ ត្រូវកាន់ត្រណមជាច្រើន ដូចជា៖

-កុំបរិភោគអាហារមានជាតិហឹរ នាំឱ្យក្រហល់ក្រហាយដល់កូនក្នុងផ្ទៃ

-កុំស្លៀកពាក់រឹតតឹងពេក នាំឱ្យចង្អៀតចង្អល់ដល់កូន

-កុំឈោងយករបស់ដែលស្ថិតនៅខ្ពស់ ផុតដៃ នាំឱ្យរបូតទងសុកពីមាត់កូន

-កុំបរិភោគបបរ នាំឱ្យកូនកើតមកមិនស្អាត

-កុំដេកថ្ងៃ កុំផ្ញឹតទឹកយប់ នាំឱ្យកូនថ្លោសពិបាកកើត

-កុំអង្គុយមាត់ទ្វារ ឬមាត់ជណ្តើរ ខ្លាចកូនកើតមិនរួច

-កុំទៅសួរសុខទុក្ខអ្នកដែលកើតកូនពិបាក ខ្លាចពិបាកកើតកូន

-កុំដេកដំអក់ ត្រូវរហ័សរហួនក្រោកមុនប្តី នាំឱ្យកើតកូនបានស្រួល

បើមានសូរ្យគ្រាសឬចន្ទ្រគ្រាស ត្រូវយកអកកំបោរមកដាក់លើពោះ ដើម្បីជួយសង្កត់ទារកនៅក្នុងផ្ទៃកុំឱ្យភ័យ ឬភ្ញាក់ផ្អើលនឹងមហិទ្ធិឫទ្ធិរាហូ បើមិនបានធ្វើបែបនេះទេ កូនកើតមកនឹងទៅជាលីលើ មិនគ្រប់ដប់។ល។ក្រោយពេលឆ្លងទន្លេរួចហើយ ស្ត្រីជាម្តាយតម្រូវឱ្យអាំងភ្លើងចំនួនបីថ្ងៃ ឬមួយសប្តាហ៍ ដោយមានអាចារ្យសូត្រមន្តអាគមព័ទ្ធសីមា ដាក់បន្ទាស្អិត ជុំវិញបរិវេណគ្រែអាំងភ្លើងផងដែរ។ បុព្វបុរសខ្មែរជឿថា ប្រសិនបើបុគ្គលណាធ្វើខុសត្រណមនេះ នោះខ្សែសីមានឹងត្រូវដាច់ ហើយបណ្តាលឱ្យមានគ្រោះថ្នាក់ ដូចជា មានព្រាយបិសាចមកយាយីដែលខ្មែរតែងហៅថា ព្រាយក្រឡាភ្លើង។ ព្រាយនេះជាខ្មោចស្ត្រីដែលស្លាប់តាយហោងទាំងម្តាយទាំងកូនពេលឆ្លងទន្លេ។ ព្រាយក្រឡាភ្លើង អាចសម្តែងរូបជាដុំភ្លើងឬប្រែក្រឡាជាភ្លើង ហើយតែងមកយាយី រំខានស្ត្រីមានកូនដែលកំពុងអាំងភ្លើង ឱ្យមានអារម្មណ៍ ក្តៅក្រហល់ក្រហាយ អន្ទះអន្ទែងឬប្រកាច់ជាដើម។ ក្រៅពីនេះ មានត្រណមចំពោះអ្នកអាំងភ្លើងមិនឱ្យក្រោកពីដំណេក និយាយឆ្លើយឆ្លងជា

មួយញាតិមិត្តដែលមកសាកសួរនោះទេ ប៉ុន្តែអាចនិយាយទាក់ទងជាមួយអ្នកបៃភ្លើងបាន។

### ៧.២-ត្រណម៩ប្រការសម្រាប់អ្នកចម្បាំងសម័យបុរាណ

មនុស្សនៅសម័យបុរាណតែងស្វែងរកហាត់រៀនវិជ្ជាសិល្ប៍មន្តអាគមគាថាផ្សេងៗ ដើម្បីការពារខ្លួនពីសត្រូវ ជាពិសេសអ្នកចម្បាំងតែម្តង ដែលប្រើតែកាំបិត ពូថៅ លំពែង ។ល។ ពួកគេក៏ត្រូវមានត្រណមជាច្រើនដែលត្រូវតម បើមិនដូច្នោះទេនឹងធ្វើឱ្យមន្តអាគមរបស់គេសាបរលាប។ ត្រណមទាំងនោះមាន៖

-កុំឱ្យអ្នកដទៃវាយក្បាល៖ អ្នកចម្បាំងសម័យបុរាណចូលចិត្តបញ្ចុះមន្តអាគមនៅត្រង់ក្បាលដើម្បីឱ្យខ្លួនក្លាយជាមនុស្សខ្លាំងពូកែ។ បុរសនាសម័យនោះចាត់ទុកក្បាលមានតម្លៃស្មើនឹងជីវិតដោយ មិនព្រមឱ្យអ្នកណាម្នាក់មកបះឬវាយក្បាលឡើយ។ បើធ្វើដូច្នេះមន្តអាគមនឹងសាបរលាប លើកលែងតែអ្នកដែលគេត្រូវគោរពដូចជាឪពុកម្តាយនិងចៅហ្វាយនាយទើបអនុញ្ញាតឱ្យប៉ះក្បាលបាន។

-ហាមអង្គុយលើខ្នើយ៖ អ្នកដែលមានមន្តអាគមមិនត្រូវយកខ្នើយមកទ្រាប់អង្គុយជាដាច់ខាតព្រោះវាធ្វើឱ្យមន្តអាគមគាថាដែលបានរៀនមកទាំងប៉ុន្មានត្រូវសាបរលាប។ ខ្នើយគឺជាវត្ថុទុកសម្រាប់សំពះព្រះមុនចូលដំណេក។ ដូច្នេះបើយកវាមកអង្គុយលើគឺស្មើនឹងមើលងាយគ្រូបាធ្យាយ ធ្វើឱ្យវិជ្ជាដែលរៀនមកទាំងប៉ុន្មានត្រូវរលាយអស់។

-ហាមបោសសំរាមនៅពេលយប់៖ មនុស្សនៅសម័យដើមជឿជាក់ថា មនុស្សល្អមានខ្មោចតាមថែរក្សា តែប្រសិនបើងើបឡើងមកសម្អាតផ្ទះនៅពាក់កណ្តាលយប់ ធ្វើឱ្យខ្មោចបិសាចឈប់ថែរក្សា។

-មិននិយាយនៅពេលយប់៖ ទោះបីជាមានសំឡេងរំខានយ៉ាងណាក៏ដោយក៏មនុស្សប្រុសសម័យមុនមិនព្រមនិយាយនៅពេលពាក់កណ្តាលយប់ព្រោះពេលនោះគឺជាពេល ដែលខ្មោចបិសាចចូលចិត្តសាកល្បងវិជ្ជនិងបញ្ចេញអប័នមិនល្អ។ ប្រសិនបើហើបមាត់និយាយ មន្តអាគមនោះនឹងចូលខ្លួន ដែលគេនិយមហៅថាត្រូវអំពើគេនោះឯង។

-ហាមកាត់ក្រចកនៅពេលយប់៖ ក្រចកសរសៃសក់ជារបស់ផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗ ដូច្នេះទើបពួកគេមិនហ៊ានកាត់ក្រចកនៅពេលយប់ឡើយព្រោះខ្លាចមានអ្នកដទៃយកបំណែកក្រចកនោះទៅធ្វើមន្តអាគមនិងធ្វើអំពើអាក្រក់ដល់ខ្លួន។

-មិនទទួលទានត្រឡាច ឃ្លោក នននោង និងត្រីគ្មានស្រកា៖ការចាក់សាក់លើខ្លួនប្រាណ នៅសម័យបុរាណមិនដូចការសាក់នៅសម័យបច្ចុប្បន្ន ដែលគ្រាន់តែជាការសាក់លម្អតែប៉ុណ្ណោះនោះទេ។ការចាក់សាក់នៅសម័យបុរាណ គឺជាការបញ្ចុះមន្តអាគមការពារខ្លួនពីសត្រូវឬការពារផ្លូវងងឹតផ្សេងៗ។ បន្ទាប់ពីសាក់រួចអ្នកចម្បាំងទាំងអស់ត្រូវតមទទួលទាន

ត្រឡាច ននោង ឃ្លោក ឬ ត្រីគ្មានស្រកា បើមិនដូច្នេះទេមន្តអាគមនឹងសាបរលាបអស់។

-ហាមជេរម្តាយរបស់សត្រូវ៖ ដើម្បីឱ្យមនុស្សផងទាំងពួងមានការពេញចិត្តចំពោះខ្លួន មនុស្សប្រុសសម័យមុនតែងរកគ្រូដើម្បីបញ្ចុះមន្តអាគមស្នេហ៍ដែលគេនិយមហៅថា សារិកាលិនថោង។ ប៉ុន្តែមន្តអាគមនេះនឹងសាបរលាបទៅវិញប្រសិនបើអ្នកនោះជេរម្តាយរបស់គូសត្រូវ ព្រោះមាតាគឺជាអ្នកមានគុណរបស់មនុស្សប្រុស។

-ហាមដើរកន្ទងសៀវភៅ៖ មនុស្សសម័យបុរាណចាត់ទុកថាសៀវភៅជាគ្រូទី២។ ដូច្នេះត្រូវចេះថែរក្សាឱ្យបានស្អាតល្អមានរបៀប មិនត្រូវបោះលេងឬដើរជាន់លើសៀវភៅឡើយ។ ប្រសិនបើនរណាម្នាក់ហ៊ានដើរជាន់ឬដើរកន្ទងលើសៀវភៅនោះ គេជឿថារៀនមិនចេះនិងអាប់បញ្ញា។

-ហាមឆ្លើយតបសំឡេងប្លែកៗ៖ មនុស្សសម័យដើមតែងហាមកូនចៅមិនឱ្យឆ្លើយតបឡើយនៅពេលដែលឮសំឡេង ប្លែកៗដូចជាសំឡេងសត្វឬមនុស្សហៅចំឈ្មោះ ពិសេសគឺនៅពេលយប់តែម្តង ឬ បើមុននឹងឆ្លើយតបគេត្រូវបើកទ្វារមើលឱ្យច្បាស់សិន បើមិនដូច្នេះទេអាចត្រូវវិញ្ញាណអាក្រក់ ឬអំពើអាបធ្មប់ចូលសណ្ឋិតក្នុងខ្លួន ភ្លាមៗ[៥]។

អ្នករស់នៅតំបន់ភ្នំ មានត្រណមមិនឱ្យអង្គុយសំយុងជើងនៅមាត់ទ្វារឬមាត់ជណ្តើរ មិនឱ្យស៊ីបាយ ក្នុងឆ្នាំង មិនឱ្យកាច់អុសនឹងក្បាលជង្គង់ ឬកាច់នឹងជើងទេ តែឱ្យកាច់នៅលើក្បាល។ ពួកគេមានជំនឿថា បើកាលណាគេធ្វើខុសនឹងត្រណមនេះ នឹងមានសត្វសាហាវចូលមកខាំដល់ជណ្តើរផ្ទះតែម្តង។ អ្នករៀនរបៀន អ្នកពាក់ខ្សែបង្កេះគេតម្រូវឱ្យកាន់ត្រណមជាច្រើនដូចជា: មិនឱ្យមុជក្រោមស្នូខោអាវមិនឱ្យញ៉ាំសាច់ឆ្កែ ផ្លែស្ពឺ សម្ល ឃ្លោកស្រឡាញ់ប្រពន្ធគេ។ល។

## ៨-ជំនឿលើអាប

ក្នុងសង្គមខ្មែរ នរណាក៏ដឹងដែរថា អាបគឺជាមនុស្សស្រី ដែលគេជឿថាបានរៀនសិល្ប៍មន្តស្នេហ៍ ឬស្នេហ៍មុខ។ ដោយឥទ្ធិពលនៃមន្តស្នេហ៍នេះហើយ ទើបស្ត្រីនោះមានឫទ្ធិអំណាចគួរឱ្យព្រឺព្រួចណាស់ ដោយព្រលឹងរបស់គាត់អាចមកសណ្ឋិតក្នុងខ្លួនរបស់មនុស្សដទៃ ពេលដែលមានការថ្នាំងថ្នាក់ម្តងៗ ធ្វើឱ្យគេចុកពោះរហូតដល់បាត់បង់ជីវិតក៏សឹងមាន។

ជាទូទៅគេកត់សម្គាល់ថា នៅពេលវេលាយប់ ព្រលឹងអាបដែលប្រថាប់ក្នុងខ្លួន

[៥] ទស្សនាវដ្តី សេដ្ឋកិច្ចខ្មែរ៖ *អត្តសញ្ញាណវប្បធម៌ខ្មែរចូលរួមអភិវឌ្ឍសហគមន៍សេដ្ឋកិច្ច* លេខទី៤០ ខែ មិថុនា ២០១៥ ទំព័រ៦៣។

មនុស្សចេញទៅរកស៊ីហើយក្នុងខណៈនោះ ក្បាលត្រូវដកចេញពីដងខ្លួន ហោះហើររកស៊ីគ្រឿងចំណីដូចជាគំនរឈាម ឬកូនក្អាត់កង្កែប ហ៊ីងជាដើម។ តាមជម្មតា ដងខ្លួនអាបចេញពីខ្លួនហើយមានពណ៌ខៀវភ្លឺជាងអំពិលអំពែក។ មុនថ្ងៃរះបន្តិចឬព្រឹកព្រលឹមទើបក្បាលអាបវិលចូលក្នុងដងខ្លួនវិញ។

អាបជាសភាវៈអាក្រក់ហើយគ្រូអាបត្រូវប្រើមន្តអាគម ស្រាស់បន្ទាជុំវិញគំនរឈាម ដើម្បីការពារកុំឱ្យអាបមកបៀតបៀន។ បើខ្លួនអាបស្លាប់ មនុស្សជាប់អំពើក៏អាចស្លាប់ដែរ។ ដូច្នេះគេសម្លាប់អាបក្នុងន័យឧបកិច្ចទៅវិញ។ គេដេញអាបចេញពីខ្លួនតាមរយៈសំដីអ្នកជំងឺ គ្រូអាបទុកឱ្យគេមានជីវិតរស់នៅ។ ការជឿលើធ្មប់អាបក៏មាននៅក្នុងប្រទេសមួយចំនួនទៀតដែរ ដូចជានៅប្រទេសម៉ាឡេស៊ី ឡាវ ថៃ ជាពិសេសនៅប្រទេសដែលមានសហគមន៍ខ្មែររស់នៅ។ វាជាចរន្តវប្បធម៌ដ៏ចំណាស់ប្រកបដោយលក្ខណៈជីវចលនិយម។

ដោយសារភាពឯកភាពនៃជំនឿប្រពៃណីដែលឆ្លុះបញ្ចាំងតាមរយៈអក្សរសាស្ត្ររបស់អ្នកស្រុក យើងអាចបញ្ជាក់ថា ជំនឿលើអាបធ្មប់ដែលបានប្រសូតចេញពីខឿនវប្បធម៌ អរិយធម៌ខ្មែរ-មននាសម័យប្រវត្តិសាស្ត្រ នៅតែរក្សាឫទ្ធានុភាពរបស់ខ្លួនដដែល ជាពិសេសនៅតំបន់ជនបទ ដែលរហូតមកដល់ពេលបច្ចុប្បន្ននេះ អ្នកស្រុកនៅតែជឿ នៅតែភ័យខ្លាចអាប។

សូមរំលឹកផងដែរថា សព្វថ្ងៃនេះ ជំនឿលើអាប ត្រូវបានបន្តក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ទោះបីជាយើងស្ថិតនៅក្នុងសម័យទំនើបដែលជាសម័យមានវិទ្យាសាស្ត្រដ៏ជឿនលឿន និងសម្បូរបែបក៏ដោយ ហើយនេះជាអ្វីមួយដែលត្រូវគូសបញ្ជាក់តាមរយៈខ្សែភាពយន្តមួយចំនួនដែលគេបញ្ចាំងនៅក្នុងរាជធានីភ្នំពេញយើង[5]។

## ៩-ជំនឿលើប្រេត អសុរកាយ

នៅក្នុងបុណ្យភ្ជុំបិណ្ឌដែលប្រារព្ធជារៀងរាល់ឆ្នាំ ក្នុងវត្តអារាមនានា ពុទ្ធបរិស័ទខ្មែររមែងយក ចង្ហាន់ទៅប្រគេនព្រះសង្ឃនៅពេលព្រឹក ឬថ្ងៃត្រង់ ដើម្បីបង្សុកូលឧទ្ទិសបុណ្យជូនទៅដល់ញាតិទាំង៧ សន្តាន ដែលបានចែកឋានទៅ។ ភ្ជុំបិណ្ឌនេះមានរយៈពេល១៥ថ្ងៃ ដោយចាប់ផ្តើមពីថ្ងៃ១រោចទៅដល់ថ្ងៃ១៥ រោច ខែភទ្របទ។

សូមជម្រាបថា នៅក្នុងមួយឆ្នាំមានតែរយៈកាលនេះទេ ដែលយមរាជដោះលែងពួកប្រេតម្តង ដើម្បីទទួលនូវចំណីអាហារ។ សាសនិកខ្លះមានការភ័យខ្លាចថាញាតិសន្តានរបស់ខ្លួនដែលស្លាប់ទៅ បានក្លាយទៅជាប្រេតដោយអំពើបាបកម្មគ្រប់ប្រភេទ ដែលបានធ្វើពីជាតិមុន។ ពួកគេក៏យកអាហារនំចំណីទៅវត្តដើម្បី

---

[5] មីសែល ត្រាណេ៖ ***មូលដ្ឋានគ្រឹះអរិយធម៌ខ្មែរភាគ២*** ភ្នំពេញ ការផ្សាយរបស់គ្រឹះស្ថានបោះពុម្ពខ្មែរ ឆ្នាំ២០១៤ ទំព័រទី៣២០។

ឱ្យព្រះសង្ឃឧទ្ទិសមគ្គផលដល់ពួកប្រេតអាសុរកាយទាំងនោះ។ តាមទំនៀមទម្លាប់ប្រពៃណីរបស់ប្រជាជនខ្មែរគេក្រោកឡើងនៅម៉ោង៤ជិតភ្លឺ ដាំបាយដំណើបលាយជាមួយល្ង ហើយពូតជាដុំៗដាក់ក្នុងចានដោយដាក់ទឹកជាមួយផងរួចហើយកាន់តាមខ្លួនយកទៅវត្ត។ បន្ទាប់មកពួកគេម្នាក់ៗ ក៏យកបាយដំណើប ផ្លែឈើដូចជា ក្រូច ចេក មៀន និងនំនែកជាដើម និងដោតធូបផង ដើម្បីឧទ្ទិសឱ្យខ្មោចដូនតាមកទទួលសំណែនទាំងនោះ។

សូមជម្រាបថា តាំងពីបុរាណកាលមករហូតដល់សម័យក្រោយៗមកទៀត ហើយសូម្បីតែនៅសម័យទំនើបនេះក្ដី ក៏ពុទ្ធសាស និកខ្មែរនៅតែជឿលើបុណ្យបាបកម្មពៀរវេរា។ ពួកប្រេតទាំងនោះសុទ្ធសឹងតែមានមុខគឺជាមនុស្សដូចគេដូចឯង ក៏ប៉ុន្តែ ដោយសារតែអំពើអាក្រក់កាចសាហាវ អធម៌ ដែលខ្លួនបានសាងទើបពេលទទួលមរណកាលទៅបានក្លាយជាប្រេតអសុរកាយ។

តាមចាស់ៗបុរាណ គេចែកប្រេតទាំងនោះជា១២ពួក ដោយប្រេតនីមួយៗមានឈ្មោះខុសៗគ្នា យោងតាមជំនឿ និងការរៀបរាប់តំណាលតៗមក។ ការតាំងឈ្មោះប្រេតទាំងនោះ គឺអាស្រ័យលើអំពើបាបកម្មដែលខ្លួនបានសាងពីមុន។ ម៉្យាងវិញទៀត ប្រេតខ្លះក៏មាន រូបសញ្ញាផ្ទាល់ខ្លួនដែរ។

-ប្រេតទី១ឈ្មោះវន្តាសាៈ ប្រេតនេះមានភ្នែកក្រលួង មានមុខក្រញូវ ជុះរោមច្រើនស្រមូវ មាត់វៀចកំប៉ូវខ្នងកោងកំពូរ សក់រួញក្រញង់ ដោះប៉ោងកំប៉េង ខ្លួនធំក្លិនខ្ទរ ដៃជើងក្រញង់ ធ្មេញជុះខុសជួរ មានរូបរាងខ្ពស់ចង្រ្កោងស្គមដូចកុកគ្រោង ដំបៅពេញកាយរាប់រយលានឆ្នាំ មិនដែលស្គាល់បាយ ស៊ីតែកំហាកដែលស្ដោះចេញពីទឹកមាត់គេ។ ប្រេតទាំនេះមកពីមិនបានធ្វើបុណ្យដោយចិត្តជ្រះថ្លា ស្ដោះទឹកមាត់ដាក់អាហារឱ្យអ្នកដែលមានសីលខ្ពស់។

-ប្រេតទី២ឈ្មោះ កុណបាៈ មានពោះធ្លាក់ត្រយោក មុខខ្ទីកំប៉ុក ភ្នែកប៉ុនត្រឡោកចង្កាយាស្ដោក ធ្មេញធំប៉ុនដប សក់វែងអូសដីច្រមុះខោចខ្ទី កស្ដួចដូចដប ក្បាលធំជាងខ្លួនមិនសមប្រកប ធំក្លិនស្អុយអសោច ស៊ីតែសពខ្មោច។ ប្រេតនេះអត់បាយរាប់កោដិឆ្នាំ ស៊ីតែខ្ទុះឈាមនៃសាកសពខ្មោចឥតបានប្រយោជន៍ទេ បើស៊ីណាស់កាន់តែឃ្លានណាស់ ព្រោះផលកម្មចាស់បានសាងឡើង។

-ប្រេតទី៣ឈ្មោះ គូថៈ មានភ្នែកទទឹងមាត់ខើចសំពេញ ជុះរោមជិត ឈឺច្រុះត្រង់ភ្លើងកខ្ទីដូចហ៊ឹង។ ក្បាលធំក្រមាង សក់ជុះខាងៗ កណ្ដាលរលីង ត្រចៀកកំបិត ពោះធំកំភ្លឹង រូបរាងស្គមរីង ស៊ីតែលាមក ក្លិនស្អុយខ្មោះៗ សាច់ស្រែងកក្រោះ ដៃជើងធំស្ទក់ ខំដើរស្កាត់រកគំនរលាមកមកធ្វើជាចំណី។ ប្រេតនេះ គឺរស់នៅរបៀបនេះរាប់រយកោដិឆ្នាំ រស់ដោយកម្ម គឺ

-ប្រេតទី៦ឈ្មោះកណ្ឌជិះ មានរូបរាងធំខ្ពស់ពេញចិត្ត ដៃជើងធំៗ ខ្លួនធំដូចយក្ស សាច់សពញាក់ពពាលឡង់ចាង កវែង ក្បាលផ្អៀង ភ្នែកស្រលៀង ច្រមុះធំខ្ទី ពោមស្រមាម ដៃជើងក្រញាង ធ្មេញពីរសំញេញ បបូរមាត់ស្លេះ យារធ្លាក់សំយែះ ពោះប៉ោងក្រអាញ ធំវែងដូចភ្នំ សាច់ស្បែកស្គោតសាញ ដៅសែស្រមាញ។ ប្រេតនេះច្រើនរស់នៅ ក្នុងព្រៃជ្រៅ ដាច់ពីគេឯង ហើយស្រេកឃ្លានអាហារ ព្រោះស៊ីមិនបានស្រេកទឹកខ្លាំងណាស់ ឃើញបឹងស្រះ ស្ទុះទៅរក ប៉ុន្តែប្រែក្លាយទៅជាក្រួសថ្មទៅវិញ។

-ប្រេតទី៧ឈ្មោះ និជ្ឈាះ មានរូបរាងកាយគ្រាំគ្រាគ្មានពេលស្បើយទេ ប្រេតនេះ គឺមានកម្មក្រាស់ណាស់បើមានចំណីគឺពុំអាចស៊ីបានទេ គឺមាត់ដុះកន្ទុយ។ ចំពោះរូបរាងវិញ គឺរូបរាងអាក្រក់ ពោះប៉ោងកំប៉ិត ផ្ចិតទុលលៀនស្កុយ ច្រមុះកញ្ចត ភ្នែកដូចទីទុយ ដុះពោមច្រើន មាត់ស្អុយខ្ទរខ្ទោះ សាច់ខ្មៅក្រងឹត រាងខ្ពស់ស្គមស្វិត ដៃជើងកគ្រោះ ម្រាមដៃដុះចង្កា។ ត្រចៀកបាក់ធ្លាក់យារដាបដល់ស្មា សក់វែងប្រះស្មា អាក្រក់ពេកក្រៃ។ ប្រេតនេះច្រើនរស់នៅក្នុងព្រៃជ្រៅ ឆ្ងាយដាច់ពីគេ ឬនៅលើកោះតែម្នាក់ឯង ព្រោះខ្លាចចង្រៃ ប្រព្រឹត្តតក់ម៉ក់ពេលឃើញសាមណៈឬស្មូនយាចកប្រើពាក្យអាក្រក់ជេរស្តីឱ្យលោក និយាយពាក្យចាក់ចោទឡុកឡឺយបញ្ចោតអ្នកមានសីលឱ្យអាប់កិត្តិយស។

ពៀរវេរាពីជាតិមុន ជាជនពាលអត់មានសទ្ធា កោងកាចអប្រិយ។

-ប្រេតទី៨ឈ្មោះ អគ្គិជាលះ មានភ្លើងឆេះរោលរាលពេញខ្លួនប្រាណ ភ្នែកហើមលានភ្លើងឆេះ រន្ធមាត់ មានដំបៅខ្លាំងស្រែកយំគគ្រុក សាច់ស្បែកឡើងរលួយ ភ្លើងឆេះទាំងនេះ គឺឆេះទាំងយប់ទាំងថ្ងៃ។ ពួកប្រេតនេះ គឺចង្រៃ ព្រោះមានកម្មសាងមកពីជាតិមុន គឺជាមនុស្សប៉ោឡៃ លលេងនឹងព្រះសង្ឃបញ្ចោតលេងសប្បាយ។ ប្រេតនេះច្រើនតែរស់នៅដងព្រៃជ្រៅញកបព្វតា ក្បែរមាត់សមុទ្រលើដុំសិលា ស្រេកឃ្លានអាហារ ស្រេកទឹកពុំអាចផឹកចំណីបាន។

-ប្រេតទី៩ឈ្មោះសុចិះ មុខមាត់ស្រួចដូចម្ជុល ក្បាលធំត្រមែង រន្ធមាត់ប៉ុនរន្ធក្តិតម្ជុល ដៃជើងធំបែក រាងរលទុលមុល ធំប៉ុនភ្នំ ភ្នែកលៀនក្រឡោត ក្រចកដៃសោតស្រែងស៊ីសុះដុំដុះវែងក្រាលចោតដូចដើងភ្នំ សក់ក្បាល ពុកមាត់ចង្កាដុះដូចព្រឹក្សា។ ពួកប្រេតនេះច្រើនរស់នៅបព្វតាព្រៃជ្រៅភ្នំកិជ្ឈកូដ ហើយ ប្រេតនេះស្រេកឃ្លានអាហារ ចាក់ទឹកមិនចូល ញាត់បាយមិនទៅ ចេះតែរស់នៅ ដោយផលកម្មដែលខ្លួនបានសាង។ កាលពីជាតិមុន មិនបានធ្វើបុណ្យ មានទ្រព្យច្រើន តែកំណាញ់មិនដាក់ទានឱ្យអ្នកក្រខ្សត់ សូម្បីតែមាតាបិតាក៏មិនឱ្យលោកពិសាគ្រប់ដែរ។

-ប្រេតទី៨ឈ្មោះសព្វង្គៈ មានដំបៅពេញរាងកាយ ក្នុងសាច់សុទ្ធតែពង់រុយ មានខ្ទុះពាសពេញប្រាណក្លិនស្អុយគគ្រុក ភ្នែកធំលៀន ច្រមុះធំវែង ពោះធ្លាក់ទ្រយុក ស្រែកថ្ងូររងទុក្ខ ដោយមានសេចក្តីស្រេកឃ្លាន ខំយកដៃខ្វារពាសពេញប្រាណ ក្រចកវែង មុតខេះរហែកសាច់បាន គឺសាច់ខ្លួនឯងយកមកស៊ីជាអាហារ។ ប៉ុន្តែ បើស៊ីណាស់រឹតតែឃ្លាន ព្រោះវាមានកម្មក្រាស់ណាស់។ នៅក្នុងព្រៃជ្រៅ លើកោះក៏មានច្រើនណាស់ គរគោករាប់ម៉ឺនសែនលាន កាលពីជាតិមុនអត់បានធ្វើបុណ្យមានចិត្តអាក្រក់ ប្រេតនេះច្រើនរស់នៅ ឫស្សាប្រកែកជាមួយម៉ែឪ ព្រមទាំងវាយគាត់ ប្រើពាក្យប្រមាថជីដូនជីតា ញាតិសន្តាន បំភ្លេចគុណគេ បែរជាឱ្យទោសគេទៅវិញ។

-ប្រេតទី៩ឈ្មោះបព្វង្គៈ មានដៃខ្វីជើងខ្វី ខ្លួនវែងជង្រក់ ធំខ្ពស់ដូចភ្នំក្បាលតូច កខ្វី សាច់រឹងដូចដំរី ចំពោះខ្លួនប្រាណវិញ គឺមានភ្លើងឆេះរងំ ឆេះទាំងយប់ឆេះទាំងថ្ងៃ ដូចភ្លើងឆេះភ្នំ ស្រេកឃ្លាន អាហាររាប់កោដិឆ្នាំឃ្លានអត់មានស្រាករឹតតែមិនស្លាប់ ព្រោះបានធ្វើបានកម្មច្រើន និងទ្រាំរស់នៅនេះរាប់រយឆ្នាំទៀត លុះអស់កម្មពៀរ។ ប្រេតនេះច្រើនរស់នៅក្នុងព្រៃជ្រៅ នាហេមពាន្តភ្នំកិជ្ឈកូដ កាលពីជាតិដែលសោយសុខ គឺក្លាយខ្លួនទៅជាទេវបុត្រកំលោះរូបល្អឥតខ្ចោះ នៅក្នុងឋានសួគ៌ ស្រីទេពអប្សរចោមរោមសុំស្នេហ៍។ ដល់ពេលមុនគឺជាមនុស្សទុរជនមានចិត្តរឹងរូស ចង់គំនុំឈ្លោះប្រកែក និងតាមព្យាបាទគេឯងអត់មានកោតក្រែងអំពើអាក្រក់ដែលខ្លួនបានសាង។

-ប្រេតទី១០ឈ្មោះអជគរៈ មានក្បាលច្រើនប្រភេទដូចជា ពស់ថ្លាន់ សត្វខ្លា ជាឆ្មា គោក្របី។ ប្រេតនេះចម្លែកមានរូបរាងប្លែកខុសប្រក្រតី ខ្លួនជាពស់ថ្លាន់ធំ វៀនលើដីធំ លើដំរីធំវែង ដូចភ្នំ។ ភ្លើងឆេះព័ទ្ធទាំងយប់ទាំងថ្ងៃ ស្រេកឃ្លានអាហារគ្រប់ពេលវេលា ចេះតែថ្ងូរស្រែកទុក្ខខ្លាំងពេកក្រៃ។ ប្រេតនេះរស់នៅក្នុងព្រៃជ្រៅ ឬបព្វតាក្បែរសមុទ្រ លើដុំសិលា។ ប្រេតនេះពីជាតិមុនមិនបានធ្វើបុណ្យ ប៉ោឡែមិនខ្លាចឪម៉ែជីដូនជីតា ដេរអ្នកមានគុណថាឆ្កែថាឆ្មា ព្រះសង្ឃក៏មិនខ្លាចប្រើពាក្យប្រមាថទៅទៀត ទើបធ្វើឱ្យប្រេតនេះឯង មានភ្លើងគ្រប់ពេលវេលាបែបនេះ។

-ប្រេតទី១១ ឈ្មោះវេមានិកៈ មានរូបធំទ្រមឹង រាងជាត់ក្រអាញ ដុះរោមជិតឈឹង ពោះប៉ោងត្រដ់ក្លឹងសម្បើមអស្ចារ្យ ប៉ុន្តែសុខទុក្ខស្មោះគ្មានតាមធម្មតា ដៃកាន់អាវុធចិត្តកាចក្លៀវក្លា។ ប្រេតនេះគេហៅថា មរាជ ទៅកាប់សត្វរកឈាមប្រឡាក់ព្រាច ពីព្រឹកដល់ល្ងាច អត់បាយអត់ទឹកវាយស្លរចម្លើយកាត់ទោសគ្រប់នរកត្រួតត្រាទាំងអស់។ ពេលសោយទុក្ខ កើតជាប្រេតចង្រៃរងទុក្ខវេទនាទាំងយប់ទាំងថ្ងៃ ប្រេតនេះកាលពីជាតិមុនជាមនុស្សស៊ិយប្រព្រឹត្តិលីលាបានធ្វើទានខ្វះ ធ្វើ

តាមទម្លាប់ គឺបុណ្យក៏ធ្វើ បាបក៏ធ្វើ ក្នុងន័យប្រមាថ ដូច្នេះហើយទើបរងផលកម្មសងទាំងពីរបែបនេះ។

-ប្រេតទី១២ឈ្មោះមហិទ្ធកៈ៖ រូបល្អពេញទី ជាស្តេចនៃប្រេត អ្នកមានឫទ្ធីល្អអត់មានពីរស្មើរូបទេព្តាមានគ្រឿងស្លៀកពាក់ស្រស់ស្អាតពេកក្រៃ ទាល់តែស្រេកអាហារអ្វីៗត្រេកអរលើសលន់ ខំស្ទុះទៅចាប់ភ្លើងឆេះពេកពន់បើមិនដូច្នេះទេឃើញហើយខំស្ទុះចាប់កើបស្រវាបានដាក់ក្នុងមាត់ លេបទៅកាលណាស្រាប់តែក្លាយទៅជាដុំដែកក្រហមឆ្អាល ឆេះឆាបក្នុងមាត់ស្រេកឃ្លានណាស់ ព្រោះមានកម្មច្រើន ក្លិនស្អុយអស្ចារ្យ ល្អតែរូបកាយ។ ប្រេតនៅខាងក្រៅតែប៉ុណ្ណោះ[6]។

នេះកាលពីជាតិមុនបួសក្នុងសាសនាប្រមាថសុះសាយ បួសមិនប្រព្រឹត្តិវិន័យ បួសធាន់តែបាយ ប្រព្រឹត្តអាក្រក់ ធ្វើមិច្ឆាចារ ឆបោកគ្រហស្ថ បូន់លាភសាសនាវិន័យសិក្ខាប្រតិបត្តិ។

ជាអវសាន សូមជម្រាបផងដែរថា ការតំណាងប្រេតអសុរកាយទាំងនោះ ក្រោមរូបភាពជាមនុស្ស ឬក៏ជាសត្វដែលមានលក្ខណៈផ្សំត្រូវបានអ្នកស្រាវជ្រាវចាត់ទុកថាជាការស្តែងចេញពីផ្លូវក្នុងទឹកចិត្ត ឬអារម្មណ៍របស់មនុស្សដែលជួនកាលល្អ ជួនកាលអាក្រក់តែប៉ុណ្ណោះ។ ការតំណាងខ្មោចបិសាចទាំងនោះ គឺគ្មានអ្វីក្រៅពីអារម្មណ៍អាក្រក់ឬល្អដ៏ជ្រាលជ្រៅដែលបង្កប់ក្នុងចិត្តរបស់មនុស្សដែលស្តែងចេញ។

---

6 មីសែល ត្រាណេះ *មូលដ្ឋានគ្រឹះអរិយធម៌ខ្មែរភាគ* ជ. ឯ.ម. ទំព័រទី៣២៧



ប្រភេទប្រេតទាំង១២ពួកក្នុងជំនឿខ្មែរប្រភព៣): https://www.google.com)

## ១០-ជំនឿលើទីងមោង

ដូនតាខ្មែរមានទឹកដី និងអារ្យធម៌វ័យចំណាស់ជាងគេនៅក្នុងឧបទ្វីបឥណ្ឌូចិនហើយធ្លាប់មានឥទ្ធិពលលើប្រទេសជិតខាងមួយចំនួន។ យោងលើការសិក្សាស្រាវជ្រាវតាមរយៈប្រពៃណីទំនៀមទម្លាប់ជាទូទៅនិងជំនឿលើផ្លូវផងឹតដូចករណីជំនឿក្នុងការធ្វើទីងមោង យើងឃើញភាពឈ្លាសវៃនិងប៉ិនប្រសប់ព្រមទាំងលក្ខណៈជីវចលនិយមនៃប្រពៃណីខាងលើនេះរបស់ខេមរជន។

វាជាការពិតណាស់ វប្បធម៌ឥណ្ឌាបានហូរចូលមកប្រទេសកម្ពុជាប្រមាណជាង២០០០ឆ្នាំ មកហើយដោយបានផ្តល់នូវប្រព័ន្ធគំនិតថ្មីៗជាវិជ្ជមានក៏មែនពិត ក៏ប៉ុន្តែទន្ទឹមនឹងនេះ ប្រជាជនខ្មែរបានរក្សានូវប្រពៃណី ធ្វើទីងមោងសម្រាប់បង្ការនូវអ្វីដែលប្រកបដោយលក្ខណៈមិនអំណោយផលផងដែរ ដើម្បីយោងទៅរកសេចក្តីផូរផង់ សេចក្តីសុខសប្បាយ នៃជីវិតក្នុងសង្គមមួយដែលពឹងផ្អែកទាំងស្រុងលើកសិកម្មនិងការចិញ្ចឹមសត្វជាអត្តិភាព។

ពលរដ្ឋមានជំនឿដាក់ទីងមោងនៅមុខផ្ទះ ដើម្បីបញ្ចៀសនូវឧបទ្រពចង្រៃគ្រប់ប្រភេទ គឺ ជាប្រពៃណីដូនតាដែលមាន លក្ខណៈប្រជាប្រិយច្រើនជាងវិទ្យាសាស្ត្រ។ ជាទូទៅនៅប្រទេសកម្ពុជាសព្វថ្ងៃ ការធ្វើទីង មោងស្ថិតក្នុងចន្លោះខែធ្នូ និងមេសា នៅតាមភូមិ ស្រុកនានាព្រោះថារដូវនេះជំងឺដង្កាត់ មួយចំនួនតែងតែកើតមានឡើងជាប្រចាំដូចជាជំងឺអាសន្នរោគជាដើម។

ទន្ទឹមនឹងវត្តមានរបស់ទីងមោង យើងក៏ឃើញមានការនិយមប្រើសញ្ញាដើងក្អែក ដែលគេគូរលើក្តារជញ្ជាំងផ្ទះ ឬក៏លើបាតក្អម ដែលគេព្យួរនៅមុខផ្ទះ ដើម្បីមូលហេតុដូចគ្នាដែរ។

ដូច្នេះ ទីងមោងនិងសញ្ញាជើងក្អែក គឺគេនិយម ធ្វើឡើងសម្រាប់បន្ទាចខ្មោចបិសាចកុំឱ្យមក រំខានអុកឡុកមនុស្សក្នុងសង្គម។

អ្នកស្រែចម្ការខ្មែរធ្វើទីងមោងតៗគ្នា ហើយភាគច្រើនមានលក្ខណៈកាចសាហាវគួរ ឱ្យភ័យខ្លាច។ នៅខេត្តកណ្ដាល មានទីងមោង ខ្លះបំពាក់ដោយអាវទាហាន ហើយនៅដៃមាន កាន់កាំភ្លើងឈើ ឬផ្លាស្ទិក។ ខ្លះទៀតស្លៀកខោ អាវបែបអាមេរិកកាំងវែង ហើយមានសក់លាប ពណ៌ក្រហមដូចក្មេងស្ទាវនាសម័យទំនើប យើងនេះ។

ដូចនៅកម្ពុជាបច្ចុប្បន្ន នៅខេត្តស៊ីសា កេត និងសុរិនឯណោះវិញ យើងក៏បានប្រទះ ជួបនូវទីងមោងដែរដែលគេដាក់នៅតាមវាល ស្រែស្រូវទុំឬចម្ការពោតដើម្បីការពារសត្វចាបកុំ ឱ្យមកស៊ីដំណាំស្រូវ។ នៅទីនេះ រូបទីងមោង ត្រូវគេចាត់ទុកជាជាមនុស្សបង្ការដំណាំ ដោយ ហេតុថា នៅពេលដែលហ្វូងចាបឃើញវាពិតជា មិនហ៊ានចុះមកស៊ីស្រូវឡើយ។

សូមរំលឹកថា ពីដើមក៏ដូចសព្វថ្ងៃដែរ ចាស់ៗនៅពេលដែលស្រូវទុំរមែងតែបញ្ជាកូន ចៅឱ្យទៅដេញចាបកុំឱ្យមកស៊ីស្រូវទុំ។ ដូច្នេះ ទីងមោងត្រូវបានគេពេញនិយម ដើម្បីជំនួស មនុស្សពិតដែលចាបរមែងខ្លាច។ អ្វីដែលគួរឱ្យ ចាប់អារម្មណ៍ គឺនៅភូមិភាគឦសាននៃប្រទេស ថៃបច្ចុប្បន្ន ដែលស្ថិតលើខ្ពង់រាបនគររាជសហ គមន៍ខ្មែរ មិនស្គាល់ពាក្យទីងមោង។ បើយើង មិនប្រទ្បំទេ យើងធ្លាប់ឮគាត់ប្រើពាក្យ កន្ទោង ទៅវិញ។ ជាក់ស្ដែងអ្នកស្រុកខេត្តសុរិន្ទស៊ី សាកេត ដែលរស់នៅលើទឹកដីដូនតាខ្មែរតាំង ពីសម័យបុរេអង្គរ នៅតែប្រើពាក្យ កន្ទោងនេះ ជាបន្តទៀតរហូតដល់បច្ចុប្បន្ននេះ។

ប៉ុន្តែការធ្វើទីងមោងក៏អាចត្រូវអនុវត្ត ឡើងតាមពេលវេលាសមស្រប និងការប្រែ ប្រួលមួយចំនួនរបស់ធម្មជាតិឬស្ថានភាពសង្គម ដោយគ្មានការកំណត់ពេលទុកជាមុនផងដែរ។ រហូតមកទល់នឹងបច្ចុប្បន្ន អ្នកស្រុកនៅខេត្តព្រៃ វែង និងតាកែវ គឺនៅពេលមានមនុស្សឈឺ ឬកូន ក្មេងស្លាប់ច្រើនដោយប្រការណាមួយដែលគេ ពុំអាចដឹងមូលហេតុច្បាស់ គឺគេតែងធ្វើទីង មោងដាក់មុខផ្ទះ ឬ នៅជិតក្បៀនរបង។ គេត្រូវ រង់ចាំដល់ពេលយប់ទើបធ្វើពិធីបណ្ដេញខ្មោច បិសាចចេញពីភូមិដោយដុតភ្លើងនៅមុខកាំជ ណ្ដើរផ្ទះ។ ក្នុងខណៈដែលអណ្ដាតភ្លើងកំពុង ឆាបឆេះយ៉ាងសន្ធោរសន្ធៅ គេក៏ហ៊ោកញ្ជ្រៀវ វាយប៉ោត ទូងស្គរយ៉ាងទ្រហឹងអឺងអាប់។ មិន តែប៉ុណ្ណោះសោត អ្នកខ្លះស្រែកថា ខ្មោចទៅ ហើយថែមទៀតផង។

ការធ្វើទីងមោងសម្រាប់បន្ទាចឬបណ្ដេញ ខ្មោចបិសាចបែបនេះ គឺមានតាំងពីបុរាណ កាលម៉្លេះ ដោយកាលនោះវិស័យសុខាភិបាល មិនទាន់មានការរីកចម្រើននៅឡើយ។ ប្រជា ជនខ្មែរនៅតាមស្រុកភូមិបានទទួលនូវការគំរាម ដោយជំងឺតម្កាត់គ្រប់ប្រភេទយ៉ាងងាយស្រួល។

តែទោះជាយ៉ាងណាក៏ដោយ ក៏ប្រពៃណីនេះត្រូវបន្តរហូតដល់សព្វថ្ងៃតាមបណ្តាខេត្តមួយចំនួនដែលបង្កដោយសារការខ្វះអនាម័យ។

ទីងមោងធ្វើអំពីចំបើង មានរូបរាងជាមនុស្សពាក់អាវ ស្លៀកខោពីក្រៅ ស្ថិតក្នុងស្ថានភាពផ្កាងដៃផ្កាងជើង ដោយមុខមាត់មានលាបកំបោរសក្នុងបំណងបង្ការជំងឺតម្កាត់ ឬខ្មោចបិសាចកុំឱ្យមកធាតៅអុកឡុកអ្នកស្រុកភូមិជិតឆ្ងាយ។

ដូចនៅប្រទេសកម្ពុជាដែរ សហគមន៍ខ្មែរនៅកម្ពុជាក្រោម និងប្រទេសថៃបច្ចុប្បន្នមានទម្លាប់ធ្វើ និងនិយមទីងមោងដូចគ្នា។ ប៉ុន្តែភាពខុសប្លែកពីគ្នាគឺស្ថិតនៅត្រង់ចំណុចដែលថា នៅលើទឹកដីខ្មែរសព្វថ្ងៃ គេប្រើទីងមោងសម្រាប់យាមដំណាំ និងបង្ការខ្មោចបិសាច។ នៅតាមផ្ទះសម្បែងខ្មែរនៅប្រទេសថៃ គេច្រើនតែប្រើទីងមោង ដែលគេហៅថាចន្ទោងសម្រាប់ការពារស្រែចម្ការ ជាងដាក់នៅមុខផ្ទះ។ សញ្ញាជើងក្អែកនិងគំនូរមុខមនុស្សនៅតាមផ្ទះ ឬរបងផ្ទះគឺសម្រាប់ការពារគ្រោះចង្រៃរួមទាំងជំងឺរាតត្បាតផ្សេងៗ។ ទីងមោងខ្មែរបានឆ្លងកាត់ដំណាក់កាលវិវត្តសំខាន់ៗពីរយ៉ាង។ ក្នុងដំណាក់កាលទី១ទីងមោងគ្រាន់តែបង្ការសត្វចង្រៃនៅតាមស្រែចម្ការអ្នកស្រុកប៉ុណ្ណោះ។ ចំណែកដំណាក់កាលទី២ គេប្រើទីងមោងសម្រាប់បង្ការខ្មោចបិសាច ឬជំងឺផ្សេងៗនៅក្នុងស្រុកភូមិ[7]។



ទីងមោង(ប្រភព: http://akt-media.com)

7 មីសែល ត្រាណេះ *មូលដ្ឋានគ្រឹះអរិយធម៌ខ្មែរភាគ២* ដ.ឯ.ម. ទំព័រទី៣៥៣។

## ១១-ជំនឿលើពាក្យសម្បថ

*ការស្បថស្បែ នៅតែមានអត្ថិភាពនៅក្នុងសង្គមខ្មែរ ទាំងមជ្ឈដ្ឋានអ្នកនយោបាយ និងមជ្ឈដ្ឋានប្រជាជនសាមញ្ញ។ អ្នកសិក្សាស្រាវជ្រាវវប្បធម៌ទំនៀមទម្លាប់ខ្មែរបានបញ្ជាក់ថា ការស្បថ គឺជាវិធីសាស្ត្ររបស់មនុស្សជំនាន់មុនដែលគេប្រើដើម្បីកម្ចាចអ្នកជទៃឱ្យឆ្លើយការពិតពីព្រោះថាសម័យនោះគេខ្វះវិធីសាស្ត្រ ឬបច្ចេកទេសក្នុងការស៊ើបអង្កេត ស្រាវជ្រាវដើម្បីរកចម្លើយឱ្យត្រឹមត្រូវបាន។ ការប្រើប្រាស់ពាក្យសម្បថ ឬស្បថនៅក្នុងជំនឿខ្មែរតាំងពីសម័យបុរាណរហូតមកដល់សព្វថ្ងៃ គេឃើញនៅតែបន្តនិយមប្រើនៅឡើយ បើទោះបីបច្ចុប្បន្ននេះជាសម័យវិទ្យាសាស្ត្រទំនើបជឿនលឿនយ៉ាងណាក៏ដោយ។ ប្រការដែលនៅមានគេនិយមពាក្យសម្បថឬស្បថក្នុងសម័យនេះ ពីព្រោះគេយល់ថា គឺជាវិធីសាស្ត្រមួយដែលអាចជួយឱ្យគេបានស្ងប់រម្ងាប់ចិត្តដែលចម្រូងចម្រាស ឬក៏អាចជួយដោះស្រាយសភាពបញ្ហាទ័លច្រកណាមួយរបស់គេម្នាក់ៗ។ ការប្រើពាក្យសម្បថនោះ គឺមានច្រើនយ៉ាង ដូចជាអ្នកខ្លះគេស្បថនៅក្នុងពេលណាដែលមានរឿងវិវាទ ក្តីក្តាំនឹងគ្នា ហើយដោះស្រាយមិនចេញ ថាអ្នកណាខុសអ្នកណាត្រូវៗ រីឯអ្នកខ្លះទៀតបាននាំគ្នាប្រើពាក្យសម្បថ នៅពេលដែលគេមានគូសង្សារឬគូកំណាន់ចិត្តដើម្បីបង្ហាញពីកក្តីភាព ឬភាពស្មោះត្រង់ប្តូរផ្តាច់ជាមួយគ្នា។ ក្រៅពីគេប្រើពាក្យសម្បថនៅក្នុងរឿងវិវាទទំនាស់ដីធ្លីរបស់ពលរដ្ឋធម្មតា ក្នុងនោះពាក្យសម្បថនេះគេក៏ឃើញមន្ត្រីរាជការជាន់ខ្ពស់មួយចំនួនក៏និយមប្រើដែរ ពិសេសគឺនៅពេលដែលគេចូលកាន់តំណែង ដូចជាសមាជិកព្រឹទ្ធសភា រដ្ឋសភា សមាជិករាជរដ្ឋាភិបាល និងតុលាការ។*

*មួយវិញទៀត ចំពោះសម្បថនេះ នៅក្នុងសង្គមខ្មែរសព្វថ្ងៃនេះជួនកាលគេយកទៅប្រើប្រាស់ក្នុងផលប្រយោជន៍នយោបាយក៏មានដែរ។ តួយ៉ាងដូចជានៅក្នុងកំលុងពេលដែលគណបក្សនយោបាយនានាធ្វើយុទ្ធនាការឃោសនារកសំឡេងគាំទ្រសន្លឹកឆ្នោតរបស់គេ គេឃើញមានមន្ត្រីរបស់គណបក្សនយោបាយមួយចំនួនបានឱ្យប្រជាពលរដ្ឋនៅតាមតំបន់ខ្លះស្បថស្បែថា ឱ្យបោះឆ្នោតឱ្យគណបក្សរបស់គេជាដើម។*

*ពល់ការប្រើប្រាស់ពាក្យសម្បថទាំងអម្បាលមាណនេះ ទាំងជានយោបាយក្តី ទាំងជាក្នុងរឿងវិវាទដីធ្លីរបស់ពលរដ្ឋសាមញ្ញធម្មតាក្តី អ្នកប្រាជ្ញផ្នែកព្រះពុទ្ធសាសនាបានបញ្ជាក់អំពីរឿងនេះថា គឺជាជំនឿមួយរបស់ព្រហ្មញ្ញសាសនា ដែលប្រជាពលរដ្ឋខ្មែរបានជឿតៗគ្នាពីមួយជំនាន់ទៅមួយជំនាន់ ឬគេហៅថា ជាជំនឿអរូបិយមិនមានភាពប្រាកដប្រជាច្បាស់លាស់អាចយកជាការបាននោះទេ។*

*ទាក់ទងនឹងការប្រើប្រាស់ពាក្យសម្បថនេះ គេឃើញមិនមែនមានតែនៅក្នុងសង្គម*

ជាតិខ្មែរទេក្នុងនោះក៏មាននៅតាមបណ្តាលោក ដូចជានៅបារាំង អង់គ្លេស និងសហរដ្ឋអាមេរិកជាដើម។ ប៉ុន្តែការប្រើពាក្យសម្បថរបស់គេ ច្រើនតែប្រើនៅក្នុងពិធីធំៗ ដូចជាពេលនាយករដ្ឋមន្ត្រី ឬប្រធានាធិបតីចូលកាន់តំណែង។

អ្នកប្រាជ្ញផ្នែកព្រះពុទ្ធសាសនាបានបញ្ជាក់ប្រាប់ដែរថា នៅក្នុងព្រះពុទ្ធសាសនា ពុំបានអប់រំឱ្យមនុស្សជឿលើអ្វីដែលមិនច្បាស់លាស់មិនប្រាកដប្រជានោះទេ គឺឱ្យសិក្សាស្វែងយល់ជឿលើកម្មផល ពោលគឺ បើបុគ្គលណាមួយបានធ្វើអំពើល្អ នោះគេនឹងទទួលបានផលល្អ។ ប៉ុន្តែបើគេប្រព្រឹត្តឬធ្វើអំពើអាក្រក់ផ្ទុយពីច្បាប់ធម្មជាតិពេលនោះគឺគេនឹងទទួលផលអាក្រក់នៅថ្ងៃណាមួយជាក់ជាមិនខាន។

ប្រទេសផ្សេងៗជាច្រើនទៀតនៅក្នុងសកលលោក។

សម្បថ កើតមានក្នុងផ្នត់គំនិតខ្មែរតាំងពីយូរលង់ណាស់មកហើយ ហេតុនេះពិបាកនឹងលុបបំបាត់បានណាស់។ វិបត្តិនយោបាយក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០១៣ បាននាំឱ្យមានការចោទប្រកាន់គ្នាទៅវិញទៅមកនៅក្នុងចំណោមគណៈបក្សដែលទទួលបានអាសនៈនៅក្នុងរដ្ឋសភា។ ដើម្បីជម្រះមន្ទិលសង្ស័យ ក៏ដូចជាការបញ្ជាក់អំពីភាពស្អាតស្អំ មេដឹកនាំនយោបាយបានបបួលគ្នាស្បថនៅចំពោះមុខព្រះអង្គដងកើ និងវត្ថុស័ក្តិសិទ្ធិផ្សេងៗទៀត។ ម៉្យាងទៀតនៅក្នុងការជម្រះក្តី សាក្សីក៏បានតម្រូវឱ្យស្បថមុននឹងផ្តល់ចម្លើយជាសក្ខីកម្មដែរ។

## ១១.១-ពាក្យសម្បថប្រើនៅក្នុងតុលាការរាជធានី ខេត្ត

បពិត្រសូមធុត    ធុតក្រៃបំផុត    ដូចចិត្តបំណង
ចំពោះរឿងក្តី    កុំបីផ្លូវផ្សេង    ឱ្យអស់មនុស្សផង
រាងចាលរអា។

បើខ្ញុំវៀចវេរ    មានចិត្តបង្វែរ    ក្លែងពោលមុសា
សូមឱ្យខ្ញុំត្រូវ    នឹងពាក្យបណ្តាសារ    រងទុក្ខខ្លោចផ្សារ
អាត្មាក្សិណក្ស័យ។

ញាតិប្រាំពីរសន្តាន    បងប្អូនព្រៀងលាន    ទោះប្រុសឬស្រី
ត្រូវទទួលរង    គ្រោះកាចចង្រៃ    ទុកសោករោគភ័យ
អន្តរាយប្រាំផាន។

ថាបើខ្ញុំត្រង់    ចិត្តស្មោះផ្លូវផង់    មិនពោលក្លែងក្តី
សូមលោកប្រទាន    ឱ្យពរឱ្យជ័យ    មានសុខសួស្តី

តរៀងទៅហោង។

## ១១.២-ពាក្យសម្បថប្រើនៅសាលាឧទ្ធរណ៍

យើងខ្ញុំសូមរំលឹកនឹកដល់គុណដល់វត្ថុស័ក្តិសិទ្ធិ និងសូមរំលឹកនឹកដល់គុណនាងគង្ហីងទេពព្រះធរណី ព្រះអង្គដង្កើរ លោកយាយទេពដង្កើរ លោកយាយពេញ ទេព្តារក្សា ព្រះមហាស្វេតច្ឆត្រ លោកមេទ័ពសេះសរក្សានៅក្នុងបរមរាជវាំង ព្រះអង្គវិហារសួគ៌ ព្រះអង្គគោកធ្លក ព្រះអង្គខ្មៅ ព្រះអង្គកែវមរកត សូមអញ្ជើញ ព្រះនាងចេក ព្រះនាងចម សូមអញ្ជើញលោកតាដំបងគ្រញូង លោកតាព្រះថោ លោកតាដំបងដែកលោកតាដំបងពេជ្រ និងព្រះទសបារមីវត្ថុស័ក្តិសិទ្ធិទិសទាំងប្រាំបីមេត្តាចុះមកវិនិច្ឆ័យ ទោសតាមការសច្ចាប្រណិធានរបស់យើងខ្ញុំទាំងអស់គ្នា។ បើខ្ញុំទាំងអស់គ្នាមានចិត្តមិនស្មោះត្រង់សូមឱ្យវត្ថុស័ក្តិសិទ្ធិនៅក្នុងលោកដាក់ទោសតាមពាក្យសម្បថដូចខាងក្រោមនេះ៖

បពិត្រយើងទាំងអស់គ្នា សូមសច្ចាប្រណិធានចំពោះមុខតុលាការ និងព្រះអង្គដង្កើរ លោកយាយទេពដង្កើ លោកយាយពេញ ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រលោកមេទ័ពសេះសរក្សាក្នុងព្រះបរមរាជវាំង ព្រះអង្គវិហារសួគ៌ ព្រះអង្គគោកធ្លក ព្រះនាងចេក ព្រះនាងចម។

សូមអញ្ជើញលោកតាដំបងគ្រញូង លោកតាព្រះថោ លោកតាតំបងដែក លោកតាដំបងពេជ្រ លោកតាក្រហមក លោកតាក្បាល៨រក្សាក្បាលជ្រោយ បើយើងខ្ញុំសច្ចានេះ មិនស្មោះត្រង់ មានចិត្តវៀចវេរ សូមឱ្យព្រះអង្គដាក់ទោសតាមពាក្យសច្ចាដូចខាងក្រោមនេះ ៖

បើយើងខ្ញុំនៅផ្ទះឱ្យភ្លើងឆេះផ្ទះស្លាប់គ្រប់៥០០ជាតិ បើខ្ញុំជិះទូក កប៉ាល់សូមឱ្យលិចលង់៥០០ជាតិ បើយើងខ្ញុំទៅជាខ្មោចសូមឱ្យស៊ីខ្ទុះឈាមឬហែលនៅក្នុងខ្ទះភ្លើងគ្រប់៥០០ជាតិ បើកើតជាមនុស្សសូមឱ្យជួបតែក្រខ្វះខាតគ្រប់៥០០ជាតិ និងសូមឱ្យបារមីគ្រប់ព្រះអង្គ បរាមុខ និងវាយបំបាក់កគ្រប់៥០០ជាតិទៅ។

បើយើងខ្ញុំទាំងអស់គ្នាមានការទៀងត្រង់ សូមវត្ថុស័ក្តិសិទ្ធិគ្រប់ទិសទី និងទេព្តារក្សាទិសទាំងប្រាំបីជួយឱ្យយើងខ្ញុំទាំងអស់គ្នា ជួបតែសេចក្តីសុខគ្រប់ប្រការ បើយើងខ្ញុំស្លាប់ពីជាតិនេះ អន្ទោលទៅកើតក្នុងភពតូច ឬភពធំក្តីណា សូមបានជួបព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ហើយមានបញ្ញាស្មារតីឆ្លាតវៃ កុំឱ្យស្គាល់សេចក្តីក្រលំបាក ជំងឺតម្កាត់ជារៀងរាល់ជាតិ រហូត

បានសម្រេចព្រះនិព្វាន ជាស្ថានបរមសុខនោះ ហោង[៨]។

សរុបសេចក្តីមក ជំនឿខ្មែរដែលមានតាំងពីបុរាណកាលមកនោះបានក្លាយជាអត្តសញ្ញាណ វប្បធម៌មួយដែលកំពុងតែមានឥទ្ធិពលក្នុងពេលបច្ចុប្បន្ន។ ជំនឿទាំងនេះមានតួនាទីយ៉ាងសំខាន់ក្នុងការថែរក្សាអត្តសញ្ញាណជាតិសាសន៍ខ្មែរ។

---

[៨] ឱុប សុន៖ *សីលធម៌ ជំនឿនិងទំនៀមទម្លាប់ខ្មែរបូរាណ* ដ.ឯ.ម. ទំព័រទី២៣២

# គន្ថនិទ្ទេស


1. *កែវ ណារុំ៖ តន្ត្រីនិងជីវិតខ្មែរ ភ្នំពេញ ការផ្សាយរបស់បណ្ណាល័យ ធពណ្ណារង្សី ឆ្នាំ២០១១។*
2. *ជួន ណាត៖ វចនានុក្រមខ្មែរ ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។*
3. *ឌុច សុន៖ សីលធម៌ ជំនឿនិងទំនៀមទម្លាប់ខ្មែរបូរាណ ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ២០០៥។*
4. *ទស្សនាវដ្ដី សេដ្ឋកិច្ចខ្មែរ៖ អត្តសញ្ញាណវប្បធម៌ខ្មែរចូលរួមអភិវឌ្ឍសហគមន៍សេដ្ឋកិច្ច លេខទី៤០ ខែមិថុនា ឆ្នាំ២០១៥។*
5. *មីសែល ត្រាណេ៖ មូលដ្ឋានគ្រឹះអរិយធម៌ខ្មែរភាគ២ ភ្នំពេញ ការផ្សាយរបស់គ្រឹះស្ថានបោះពុម្ពខ្មែរ ឆ្នាំ២០១៤។*
6. http://akt-media.com)
7. https://www.google.com

# បុណ្យភ្ជុំបិណ្ឌ និង ប្រភេទប្រេតទាំង១២ពួកក្នុងជំនឿខ្មែរ

*ដោយៈ បណ្ឌិត* **ហែម ឡាច**
*មន្ត្រីនាយកដ្ឋាននីតិសាស្ត្រ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា*

*ជនជាតិខ្មែរជាអ្នកនិយមព្រះពុទ្ធសាសនាតាំងតែពីសាសនានេះមានវត្តមាននៅក្នុងសង្គមខ្មែរយើងមកម្ល៉េះ។ ពុទ្ធសាសនិកខ្មែរ តែងមានជំនឿអំពីបុណ្យ បាបកម្មផល ទាំងអតីតកាល បច្ចុប្បន្នកាល និងទៅអនាគតកាលផងដែរ។ គេជឿថា ជីវិតមិនសាបសូន្យឡើយ។ ពេលដែលមនុស្សស្លាប់ ព្រលឹងរបស់មនុស្សមិនស្លាប់ទេ។ ព្រលឹងនឹងទៅចាប់កំណើតនៅភពថ្មីទៀតដោយត្រូវទទួលកម្មផលទៅតាមអំពើដែលគេបានធ្វើក្នុងកាលដែលគេនៅរស់។*

*ដូច្នេះ ដើម្បីទទួលបាននូវផលល្អនៅអនាគត មនុស្សត្រូវធ្វើអំពើល្អ ត្រូវចូលរួមធ្វើបុណ្យទានផ្សេងៗទៅតាមសទ្ធា និងលទ្ធភាពដែលខ្លួនមាន។*

## ១-បុណ្យភ្ជុំបិណ្ឌ

*បុណ្យភ្ជុំបិណ្ឌ ជាពិធីបុណ្យមួយធំជាងគេ នៅក្នុងចំណោមពិធីបុណ្យទាំងអស់ ចំពោះអ្នកកាន់ព្រះពុទ្ធសាសនា។ ពិធីបុណ្យនេះជាប្រពៃណីមួយដែលជនជាតិខ្មែរគ្រប់រូបតែងប្រារព្ធធ្វើជារៀងរាល់ឆ្នាំមិនអាចខ្វះបាន។ ជារៀងរាល់ឆ្នាំនៅពេលដល់ថ្ងៃខែដែលត្រូវប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ បងប្អូនកូនចៅ សាច់ញាតិសន្តានទាំងអស់ ទោះនៅទីជិតឬទីឆ្ងាយតែងតែធ្វើដំណើរទៅជួបជុំគ្នា ជាពិសេសទៅជួបជុំឪពុកម្ដាយនៅស្រុកកំណើតដើម្បីរៀបចំម្ហូបអាហារ បាយសម្ល ចង្ហាន់យកទៅប្រគេនព្រះសង្ឃដែលគង់នៅវត្តអារាម។ ទាំងនេះគឺជាទម្លាប់មួយដែលជនជាតិខ្មែរយើងនិយមធ្វើតៗគ្នាពីជំនាន់មួយទៅជំនាន់មួយតាំងពីយូរលង់ណាស់មកហើយ។*

*តាមទំនៀមទម្លាប់ការធ្វើពិធីបុណ្យភ្ជុំបិណ្ឌមានរយៈពេល១៥ថ្ងៃ។ គេចាប់ផ្ដើមធ្វើតាំងពីថ្ងៃ១រោច រហូតដល់ថ្ងៃ១៥រោចខែភទ្របទ។*[1]

*ពីថ្ងៃ១រោច ដល់ថ្ងៃ១៤រោច គឺជាថ្ងៃដាក់បិណ្ឌ ឬកាន់បិណ្ឌ។ នៅក្នុងរយៈពេល១៤ថ្ងៃនៃការកាន់បិណ្ឌ ឬដាក់បិណ្ឌនេះ*

---

[1] *ត្រឹង ងា ៖ **អរិយធម៌ខ្មែរ** ការផ្សាយរបស់អ្នកនិពន្ធ គ.ស. ១៩៧៥*

ពុទ្ធបរិស័ទចំណុះជើងវត្តទាំងអស់ជាពិសេសក្រុមនីមួយៗដែលបានរៀបចំដោយលោកតាអាចារ្យ និងគណៈកម្មការវត្ត ត្រូវបែងចែកចេញជា៣ ឬ៤ក្រុមតូចៗ ដើម្បីរៀបចំធ្វើយាគូ(បបរ) ឬធ្វើកត្តាហារប្រគេនចំពោះព្រះសង្ឃ។

ពេលគេទូងស្គរចំណាំវស្សា អ្នកនៅក្នុងក្រុមវេននីមួយៗត្រូវចាប់ផ្ដើមធ្វើចង្ហាន់ ហើយយាយតាចាស់ៗក្នុងក្រុមវេនត្រូវជ្រើសរើសយកផ្ទះណាមួយដើម្បីប្រមូលនំរៀបចំបាយបិណ្ឌ បាយបត្តបូរ(បាយបិត្តបូរ)។ កាលបើរៀបចំរួចហើយ គេនាំគ្នាទៅវត្តដើម្បីស្ដាប់លោកសង្ឃសូត្រថ្វាយបង្គំធម៌សុខោ និង ធម៌បរាភវសូត្រ។

ចំណែកឯកូនចៅដែលនៅផ្ទះ ត្រូវនាំគ្នាខិតខំដុតដៃដុតជើងដាំបាយ បបរ ឬស្លតាមមុខម្ហូបនីមួយៗដោយឡែកពីគ្នា។ លុះដល់ពេលព្រឹកព្រាងអរុណោទ័យ (ពេលព្រះអាទិត្យរះឡើង) ត្រូវនាំគ្នារៀបចំខ្លួន កណ្ដៀត យួរ កាន់ ទូល រែក ចង្ហាន់ទៅវត្ត។ នៅក្នុងវត្ត លោកតាអាចារ្យត្រូវរៀបចំពិធីរាប់បាត្រនៅលើឧបដ្ឋានសាលា។ បន្ទាប់មកលោកអាចារ្យជាប្រធានត្រូវនាំពុទ្ធបរិស័ទវេរចង្ហាន់ប្រគេនព្រះសង្ឃ វេរបាយបត្តបូរ។ល។ លុះដល់ពេលព្រះសង្ឃធ្វើបត្តានុមោទនគាថាចប់ មេវេនក្រុមនីមួយៗត្រូវរៀបចំម្ហូបអាហារ នំចំណីចូលគំនាប់ជូនលោកតាអាចារ្យវត្ត ព្រមទាំងចាត់ចែងភោជនាហារទទួលភ្ញៀវដែលអញ្ជើញទៅចូលរួមបុណ្យនៅក្នុងថ្ងៃវេនរបស់ខ្លួននីមួយៗផងដែរ។

ថ្ងៃ១៥រោចគឺជាថ្ងៃភ្ជុំបិណ្ឌដោយហេតុថាថ្ងៃនេះ អ្នកស្រុកគ្រប់ភេទ គ្រប់វ័យត្រូវទៅប្រជុំគ្នានៅវត្តដើម្បីឆ្លងបុណ្យ។

បុណ្យភ្ជុំបិណ្ឌមានគោលបំណងឧទ្ទិសកុសល និងចំណីអាហារដល់ខ្មោច ។ ពាក្យបិណ្ឌមានន័យថា ដុំបាយឬពុំនូតបាយដែលគេឧទ្ទិសដល់ខ្មោច។ បាយបិណ្ឌគឺជាពំនូតបាយដំណើបលាយជាមួយខ្ទិះដូងនិងជាមួយគ្រឿងផ្សំខ្លះទៀត ទៅតាមចំណង់ចំណូលចិត្តរបស់អ្នកស្រុកនីមួយៗ។ គេតែងយកបាយបិណ្ឌដាក់ក្នុងថាសមួយដោយមានបាយបិត្តបូរដាក់ចំកណ្ដាលហើយទូលទៅវត្ត។ បាយបិត្តបូរគឺដូចជាបាយបិណ្ឌដែរគ្រាន់តែគេពូតឱ្យមានរាងជាសាជីហើយគ្របស្លឹកចេកពីលើហើយគេចោះកំពូលសម្រាប់ដោតទៀនធូបឬផ្កា។ នៅក្នុងរោងគេរៀបចំតុបតែងធ្វើជាផ្កាបិណ្ឌដែលមានរាងមូលដូចសាជី។ លើកំពូលផ្កាបិណ្ឌ គេធ្វើហង្សទ្រទៀនដែលគេពូនរាល់យប់នៅពេលកាន់បិណ្ឌ។ ផ្កាបិណ្ឌជាដង្វាយចំពោះព្រះចូឡាមណី។

ថ្ងៃ១៤រោច មុនថ្ងៃបញ្ចប់ពិធីបុណ្យ គេធ្វើនំនែកផ្សេងៗ ពិសេស នំអន្សម នំគម នំជាល តាមទម្លាប់អ្នកស្រុក ដើម្បីយកទៅប្រគេនព្រះសង្ឃ ជូនអ្នកមានគុណ ក៏ដូចជាញាតិសន្តានផងដែរ។នៅយប់ថ្ងៃដដែល នៅឯវត្តមានធ្វើពិធីបង្សុកូល ឧទ្ទិសចំពោះវិញ្ញាណក្ខន្ធក្រុមញាតិដែលបានបាត់បង់ជីវិតទៅហើយដោយមានការសូត្រធម៌ចម្រើនព្រះបរិត្ត និងសម្តែងព្រះធម៌ទេសនា។

ព្រឹកឡើងថ្ងៃ១៥រោច ខែភទ្របទ ដែលជាថ្ងៃសំខាន់ជាងគេនៃពិធីបុណ្យ អ្នកស្រុក អ្នកភូមិ ទោះបីនៅឆ្ងាយដល់ទីណាក្តី ក៏តែងវិលមកស្រុកកំណើតវិញ ដើម្បីទៅប្រជុំគ្នានៅវត្តអារាមរៀងៗខ្លួនដោយយកបង្អែមចំអាបនំចំណីទៅប្រគេនព្រះសង្ឃ ឧទ្ទិសកុសលផលបុណ្យចំពោះសាច់ញាតិ សាលោហិត ដែលចែកឋានទៅ។

ក្រៅពីពិធីនៅឯវត្ត នៅមានពិធីសែនព្រេននៅតាមគេហដ្ឋាន តាមគ្រួសារ នៅពេលយប់ ថ្ងៃបង្ហើយបុណ្យនោះផងដែរ។ នៅពេលនោះគ្រួសារទាំងមូលបានអុជទៀន ធូប ឧទ្ទិស អញ្ជើញវិញ្ញាណក្ខន្ធបុព្វបុរស ជីដូនជីតាឱ្យមកទទួលយកភោគផលដែលឧទ្ទិសទាំងនោះ។ លុះព្រឹកឡើង គេរៀបចំនំចំណីដាក់ក្នុងកូនសំពៅធ្វើពីដើមចេកបណ្តែតតាមទឹក ដើម្បីជូនដំណើរជូនតាទៅវិញ។

### *ហេតុដូចម្តេចបានជាគេនិយមធ្វើពិធីបុណ្យភ្ជុំបិណ្ឌនៅរនោចខែភទ្របទ?*

តាមពុទ្ធសាសនា មនុស្សស្លាប់ទៅតែងទទួលកម្មផល ទៅតាមអំពើដែលខ្លួនបានប្រព្រឹត្តកាលដែលខ្លួនមានជីវិតរស់នៅ។ មនុស្សចិត្តអាក្រក់ ប្រព្រឹត្តបាបកម្ម លុះស្លាប់ទៅនឹងទៅកើតជាប្រេត នៅស្ថាននរក។

តាមគម្ពីរមិលិន្ទប្បញ្ហាសម្តែងថា ប្រេតមាន៤ប្រភេទគឺ៖

-ប្រេតដែលចិញ្ចឹមជីវិតដោយខ្ទុះឈាម

-ប្រេតដែលស្រេកឃ្លានអាហារជានិច្ច

-ប្រេតដែលភ្លើងឆេះជានិច្ច

-ប្រេតដែលចិញ្ចឹមជីវិតដោយផលដែលបុគ្គលដទៃឧទ្ទិសឱ្យ។

គឺពួកប្រេតទី៤នេះហើយដែលគេតែងធ្វើបុណ្យភ្ជុំបិណ្ឌឧទ្ទិសផល ឬសែនឱ្យ។

គេនិយមជ្រើសរើសយកថ្ងៃរនោចខែភទ្របទ ព្រោះពេលនោះព្រះចន្ទពុំសូវមានពន្លឺ ឬពន្លឺកាន់តែងងឹតទៅៗពីមួយថ្ងៃទៅមួយថ្ងៃ។ គឺក្នុងឱកាសនោះហើយ ដែលយមរាជដោះលែងពួកប្រេតទាំងនោះឱ្យមកទទួលផលដែលបងប្អូនឧទ្ទិសឱ្យ។

គេតែងមានជំនឿថា ក្នុងរយៈពេល ១៥ថ្ងៃ ប្រសិនបើពួកប្រេតដើររកគ្រប់៧វត្ត ហើយ ពុំឃើញមានបងប្អូនកូនចៅណាធ្វើបុណ្យបញ្ជូនកុសលទៅឱ្យទេ ពួកប្រេតទាំងនោះនឹងអត់បាយអត់ទឹក ស្រេកឃ្លាន រងទុក្ខវេទនាក្រៃលែង ហើយពួកប្រេតទាំងនោះនឹងដេរប្រទេចផ្ដាសាមកញាតកាទាំងឡាយឱ្យវិនាសហិនហោចទ្រព្យសម្បត្តិ ព្រាត់ប្រាសម្ដាយ ឪពុក ប្ដី ប្រពន្ធ កូន ចៅ ញាតិផៅទាំង៧សន្ដានជាដើម។[2]

នៅថ្ងៃចុងក្រោយឬថ្ងៃបិទបញ្ចប់នៃពិធីបុណ្យភ្ជុំបិណ្ឌ យើងតែងសង្កេតឃើញនៅតាមវត្តអារាមជាច្រើននៃប្រទេសយើងមានរៀបចំពិធីមួយហៅថា ពិធីសែនដូនតា ឬជូនដំណើរដូនតាត្រឡប់ទៅវិញ។



អ្នកស្រុកជូនដំណើរដូនតាត្រឡប់ទៅវិញនៅថ្ងៃចុងក្រោយនៃពិធីបុណ្យភ្ជុំបិណ្ឌ(រូបភាពពីហ្វេសប៊ុកៈ ព្រះគុណម៉ែពុក)

បើតាមតម្រាចារតាមប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា បានបង្ហាញថា ពិធីបុណ្យភ្ជុំបិណ្ឌ គឺកើតមានតាំងពីបុរាណកាលមកម្ល៉េះ។[3] ប៉ុន្តែទាស់ត្រង់ថា កាលពីសម័យមុនគេមិនហៅថា បុណ្យភ្ជុំទេ ដោយនៅក្នុងពិធីនេះ គេមានបែងចែកចេញជាពីរថ្នាក់។ ថ្នាក់ដំបូង គឺគេចាប់ផ្ដើមធ្វើចាប់ពីថ្ងៃ១រោចរហូតដល់ថ្ងៃ១៤រោច ជាវារកភត្ត (ភត្តធ្វើតាមថ្ងៃ) ជាបន្តបន្ទាប់។ ចំណែកមួយថ្នាក់ទៀតគេធ្វើនៅថ្ងៃ១៥រោច ដែលគេហៅថាបុណ្យភ្ជុំ។ ពិធី

---

[2] ត្រឹង ង៉ា ៖ *អរិយធម៌ខ្មែរ* ជ.ឯ.ម.

[3] https://freshnewsasia.com/index.php/en/localnews/313879-2023-10-14-00

បុណ្យទាំងពីរថ្នាក់នេះ បច្ចុប្បន្នត្រូវបានយើងបូកបញ្ចូលគ្នា ហើយហៅកាត់ថា ពិធីបុណ្យភ្ជុំបិណ្ឌ។

កាលពីសម័យបុរាណកាល គេធ្វើពិធីបុណ្យនេះ គឺដើម្បីរៀបចំធ្វើសង្ឃភត្ត ទំនុកបម្រុងព្រះសង្ឃ ដែលគង់ចាំវស្សាក្នុងវត្តអារាមនានារយៈពេល៣ខែ ពោលគឺចាប់តាំងពីថ្ងៃចូលព្រះវស្សារហូតដល់ថ្ងៃចេញព្រះវស្សា។នៅក្នុងចំណេរកាលបុរាណបានចារថា ដោយនៅក្នុងរដូវវស្សាមានភ្លៀងធ្លាក់ជោកជាំ រលឹមពព្រិចធ្វើឱ្យមានការលំបាកដល់ព្រះសង្ឃក្នុងពេលធ្វើគោចរ(ដើរ) បិណ្ឌបាត។ ហេតុដូច្នេះទើបបណ្ដាពុទ្ធបរិស័ទនាំគ្នារៀបចំពិធីនេះ ដើម្បីផ្គត់ផ្គង់ព្រះសង្ឃប្រចាំថ្ងៃរហូតដល់ថ្ងៃចេញវស្សា។ ម្យ៉ាងវិញទៀត នៅក្នុងពិធីបុណ្យនេះ គឺធ្វើឡើងដើម្បីផ្សាយឧទ្ទិសកុសលដល់ពពួកប្រេតទាំងឡាយ និងញាតិទាំង៧សន្ដានព្រមទាំងតំណញាតិច្រើនមហាកប្បនោះផងដែរ តាមរយៈអានុភាពនៃសង្ឃគតាទក្ខិណាទាន ដែលរស់រងទុក្ខវេទនា កើតជាប្រេតមានកម្មពៀរជាប់ទោសធ្ងន់ រងកម្មក្រហល់ក្រហាយអត់ឃ្លានទាំងអស់នោះ បានរួចផុតពីក្ដីលំបាកសោកសៅទាំងឡាយ។



សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានក្រុមឧត្ដមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្ដេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា ព្រមទាំងក្រុមគ្រួសារ អញ្ជើញចូលរួមកាន់បិណ្ឌទី៩ នៅវត្តចំពុះក្អែក (រូបភាព៖ ក្រសួងធម្មការនិងសាសនា)

## ២-ប្រភេទប្រេតទាំង១២ពួកក្នុងជំនឿខ្មែរ

នៅក្នុងពិធីបុណ្យភ្ជុំបិណ្ឌដែលប្រារព្ធជារៀងរាល់ឆ្នាំ ក្នុងវត្តអារាមនានា ពុទ្ធបរិស័ទខ្មែរ រមែងយកចង្ហាន់ទៅប្រគេនព្រះសង្ឃនៅពេលព្រឹក ឬថ្ងៃត្រង់ដើម្បីបង្សុកូលឧទ្ទិសបុណ្យជូនទៅដល់ពពួកប្រេត និងក្រុមញាតិទាំង៧សន្តានដែលបានចែកឋានទៅ។ ភ្ជុំបិណ្ឌនេះមានរយៈពេល១៥ថ្ងៃដោយចាប់ផ្ដើមពីថ្ងៃ១រោចទៅដល់ថ្ងៃ១៥រោច ខែភទ្របទ។

សូមជម្រាបថា នៅក្នុងមួយឆ្នាំមានតែរយៈកាលនេះទេ ដែលយមរាជដោះលែងពួកប្រេតម្ដងដើម្បីបានមកទទួលនូវចំណីអាហារដែលកូនចៅឧទ្ទិសឱ្យ។ សាសនិកខ្លះមានការភ័យខ្លាចថាញាតិសន្តានរបស់ខ្លួនដែលស្លាប់ទៅ បានក្លាយទៅជាប្រេតដោយអំពើបាបកម្មគ្រប់ប្រភេទ ដែលបានធ្វើពីជាតិមុនៗ ពួកគេក៏យកអាហារនំចំណីទៅវត្តដើម្បីឱ្យព្រះសង្ឃឧទ្ទិសមគ្គផលដល់ពួកប្រេតអាសុរកាយទាំងនោះ។ តាមទំនៀមទម្លាប់ប្រពៃណីរបស់ប្រជាជនខ្មែរ អ្នកធ្វើបុណ្យត្រូវក្រោកឡើងនៅម៉ោង៤ជិតភ្លឺ ដាំបាយដំណើបលាយជាមួយល្ង ហើយពូតជាដុំៗដាក់ក្នុងចានដោយដាក់ទឹកជាមួយផង រួចហើយកាន់តាមខ្លួនយកទៅវត្ត។ បន្ទាប់មកពួកគេម្នាក់ៗ ក៏យកបាយដំណើប ផ្លែឈើដូចជា ក្រូច ចេក មៀន និងនំនែកជាដើម និងដោតធូបផង ដើម្បីឧទ្ទិសឱ្យខ្មោចជូនតាមកទទួលសំណែនទាំងនោះ។

សូមជម្រាបថា តាំងពីបុរាណកាលមករហូតដល់សម័យក្រោយៗមកទៀត ហើយសូម្បីតែនៅសម័យទំនើបនេះក្ដី ក៏ពុទ្ធសាសនិកខ្មែរនៅតែជឿលើបុណ្យបាបកម្មពៀរវេរានេះដែរ។ ពួកប្រេតទាំងនោះសុទ្ធសឹងតែមានមុខគឺជាមនុស្សដូចគេដូចឯង ក៏ប៉ុន្តែ ដោយសារតែអំពើអាក្រក់ កាចសាហាវអធម៌ដែលខ្លួនបានសាងទើបពេលទទួលមរណកាលទៅបានក្លាយជាប្រេត។

នៅក្នុងជំនឿពុទ្ធសាសនា ប្រេត ត្រូវបានព្រះពុទ្ធបរមគ្រូត្រាស់សម្ដែងថាមានដល់ទៅ១២ពួក ដែលអាស្រ័យទៅតាមកម្រិតនៃបាបកម្មដែលពួកគេបានសាងរៀងៗខ្លួន។ ប្រេតនីមួយៗមានឈ្មោះខុសៗគ្នា យោងតាមជំនឿ និងការរៀបរាប់តំណាលតៗមក។ ការតាំងឈ្មោះប្រេតទាំងនោះ គឺអាស្រ័យលើអំពើបាបកម្មដែលខ្លួនបានសាងពីមុនៗ ម៉្យាងវិញទៀត ប្រេតខ្លះក៏មានរូបសញ្ញាផ្ទាល់ខ្លួនដែរ។

ប្រេតទី១ឈ្មោះ **វន្តាសា** ប្រេតនេះមានភ្នែកក្រលួង មានមុខក្រញូវ ដុះរោមច្រើនស្រមូវ មាត់រៀចកំប៉ូវខ្នងកោងកំពួរ សក់រួញក្រញង់ដោះប៉ោងកំប៉េង ខ្លួនជំក្លិនខ្លួរ ដៃជើងក្រញង់ធ្មេញដុះខុសជួរ មានរូបរាងខ្ពស់ចង្រ្កាង ស្គមដូចកុកគ្រោង ដំបៅពេញកាយរាប់រយលានឆ្នាំមិនដែលស្គាល់បាយ ស៊ីតែកំហាកដែលស្ដោះចេញពីទឹកមាត់គេ។ ប្រេតទាំងនេះមកពីមិន

បានធ្វើបុណ្យដោយចិត្តជ្រះថ្លា ស្ពោះទឹកមាត់ដាក់អាហារឱ្យអ្នកដែលមានសីលខ្ពស់។

ប្រេតទី២ឈ្មោះ **កុណាបា** គឺមានពោះធ្លាក់ត្រយោក មុខខ្ទីកំប៉ុក ភ្នែកប៉ុនត្រឡោកចង្កាយាស្តោក ធ្មេញធំប៉ុនដប សក់វែងអូសដីច្រមុះខោចខ្ទី កស្តួចដូចដប ក្បាលធំជាងខ្លួនមិនសមប្រកប ធំក្លិនស្អុយអសោច ស៊ីតែសពខ្មោច។ ប្រេតនេះអត់បាយរាប់កោដិឆ្នាំ ស៊ីតែខ្ទុះឈាមនៃសាកសពខ្មោចឥតបានប្រយោជន៍ទេ បើស៊ីណាស់កាន់តែឃ្លានណាស់ ព្រោះផលកម្មចាស់បានសាងឡើង។

ប្រេតទី៣ឈ្មោះ **គូថ** ប្រេតនេះ មានភ្នែកទទឹង មាត់ខើចសំពេញ ដុះរោមជិត ច្រមុះត្រង់ក្ងឹង កខ្ទីដូចហ៊ីង។ ក្បាលធំក្រមាង សក់ដុះខាង។ កណ្តាលរលីង ត្រចៀកកំប៉ិត ពោះធំកំក្ងឹង រូបរាងស្គមរីង ស៊ីតែលាមក ក្លិនស្អុយខ្មោះៗ សាច់ស្រែងកក្រោះ ដៃជើងធំស្ទក់ ខំដើរស្កាត់រកគំនរលាមកមកធ្វើជាចំណី។ ប្រេតនេះគឺរស់នៅរបៀបនេះរាប់រយកោដិឆ្នាំ រស់ដោយកម្ម គឺពៀរវេរាពីជាតិមុន ជាជនពាលអត់មានសទ្ធា កោងកាចអប្រិយ។

ប្រេតទី៤ឈ្មោះ **អគ្គិជាល** គឺមានភ្លើងឆេះពេលពាលពេញខ្លួនប្រាណ ភ្នែកហើមលានភ្លើងឆេះ រន្ធមាត់ មានដំបៅខ្លាំងស្រែកយំគគ្រុកសាច់ស្បែកឡើងរលួយ ភ្លើងឆេះទាំងនេះ គឺឆេះទាំងយប់ទាំងថ្ងៃ។ ពួកប្រេតនេះ គឺចង្រៃព្រោះមានកម្មសាងមកពីជាតិមុន គឺជាមនុស្សប៉ោឡៃ លលេងនឹងព្រះសង្ឃបញ្ឆោតលេងសប្បាយ។ ប្រេតនេះច្រើនតែរស់នៅដងព្រៃជ្រៅញកបព្វតា ក្បែរមាត់សមុទ្រ លើដុំសិលាស្រេកឃ្លានអាហារស្រេកទឹកពុំអាចផឹចំណីបាន។

ប្រេតទី៥ឈ្មោះ **សុចិ** មុខមាត់ស្រួចដូចម្ជុល ក្បាលធំត្រមែង រន្ធមាត់ប៉ុនរន្ធក្តិតម្ជុល ដៃជើងធំបែក រាងរលទុលមុល ធំប៉ុនភ្នំ ភ្នែកលៀនក្រឡោត ក្រចកដៃសោតស្រែងស៊ីសុះដុំ ដុះវែងក្រាលចោតដូចជើងភ្នំ សក់ក្បាល ពុកមាត់ចង្កាដុះដូចព្រឹក្សា។ ពួកប្រេតនេះច្រើនរស់នៅតាមបព្វតាព្រៃជ្រៅភ្នំគិជ្ឈកូដ ហើយប្រេតនេះស្រេកឃ្លានអាហារ ចាក់ទឹកមិនចូល ញាត់បាយមិនទៅ ចេះតែរស់នៅ ដោយផលកម្មដែលខ្លួនបានសាង។ កាលពីជាតិមុន មិនបានធ្វើបុណ្យមានទ្រព្យច្រើន តែកំណាញ់មិនដាក់ទានឱ្យអ្នកក្រខ្សត់ សូម្បីតែមាតាបិតាក៏មិនឱ្យលោកពិសាគ្រប់គ្រាន់ដែរ។

ប្រេតទី៦ឈ្មោះ **កណ្ឋជិ** មានរូបរាងធំខ្ពស់ពេញចិត្ត ដៃជើងធំៗ ខ្លួនធំដូចយក្ស សាច់សពញាក់ពពាល ឡើងចាង កវែង ក្បាលផ្អៀងភ្នែកស្រលៀង ច្រមុះធំខខិ រោមស្រមាម ដៃជើងក្រញាង ធ្មេញពីរសំញេញ បបូរមាត់ស្តេះ យារធ្លាក់សំយែះ ពោះប៉ោងក្រអាញ ធំវែងដូចភ្នំសាច់ស្បែកស្តោតសាញដៅសែស្រមាញ។ ប្រេតនេះច្រើនរស់នៅក្នុងព្រៃជ្រៅដាច់ពីគេឯងហើយស្រេកឃ្លានអាហារ ព្រោះស៊ីមិនបានស្រេកទឹកខ្លាំងណាស់ ឃើញបឹងស្រះ ស្ទុះទៅរក ប៉ុន្តែប្រែក្លាយទៅជាក្រួសថ្មទៅវិញ។

ប្រេតទី៧ឈ្មោះ **និជ្ឈា** មានរូបរាងកាយគ្រាំគ្រាគ្មានពេលស្បើយទេ ប្រេតនេះ គឺមានកម្មក្រាស់ណាស់បើមានចំណីគឺពុំអាចស៊ីបានទេ គឺមាត់ដុះកន្ទុយ។ ចំពោះរូបរាងវិញ គឺរូបរាងអាក្រក់ ពោះប៉ោងកំប៉ិត ផ្ចិតទុលលៀនស្អុយ ប្រមុះកញ្ចត ភ្នែកដូចទីទុយ ដុះរោមច្រើន មាត់ស្អុយខ្មួរខ្មោះ សាច់ខ្មៅក្រងឹត រាងខ្ពស់ស្គមស្គិត ដៃជើងកគ្រោះ ម្រាមដៃដុះចង្កា។ ត្រចៀកបាក់ធ្លាក់យារដោយដល់ស្មា សក់វែង ប្រះស្មា អាក្រក់ពេកក្រៃ ប្រេតនេះច្រើនរស់នៅក្នុងព្រៃជ្រៅឆ្ងាយដាច់ពីគេ ឬនៅលើកោះតែម្នាក់ឯង ព្រោះខ្លាចចង្រៃ ប្រព្រឹត្តតក់ម៉ក់ពេលឃើញសាមណៈ ឬស្មូមយាចក ប្រើពាក្យអាក្រក់ជេរស្តីឱ្យលោកនិយាយពាក្យចាក់ចោទឡូកឡឺយ បញ្ឆោតអ្នកមានសីលឱ្យអាប់កិត្តិយស។

ប្រេតទី៨ឈ្មោះ **សព្វង្កា** មានដំបៅពេញរាងកាយ ក្នុងសាច់សុទ្ធតែពងរុយ មានខ្ទុះពាសពេញប្រាណក្លិនស្អុយគគ្រុក ភ្នែកធំលៀន ប្រមុះធំវែង ពោះធ្លាក់ទ្រយុក ស្រែកថ្ងូរងទុក្ខដោយមានសេចក្តីស្រេកឃ្លាន ខំយកដៃខ្វារពាសពេញប្រាណ ក្រចកវែង មុតខេះរហែកសាច់បាន គឺសាច់ខ្លួនឯងយកមកស៊ីជាអាហារ។ ប៉ុន្តែ បើស៊ីណាស់រឹតតែឃ្លាន ព្រោះវាមានកម្មក្រាស់ណាស់។ នៅក្នុងព្រៃជ្រៅ លើកោះក៏មានច្រើនណាស់ គរគោករាប់ម៉ឺនសែនលាន កាលពីជាតិមុនអត់បានធ្វើបុណ្យមានចិត្តអាក្រក់ ប្រេតនេះច្រើនរស់នៅឬស្សា ប្រកែកជាមួយម៉ែឪព្រមទាំងវាយគាត់ប្រើពាក្យប្រមាថជីដូនជីតាញាតិសន្តាន បំភ្លេចគុណគេ បែរជាឱ្យទោសគេទៅវិញ។

ប្រេតទី៩ឈ្មោះ **បព្វង្កា** មានដៃខ្វីជើងខ្វី ខ្លួនវែងជង្រ្គក់ ធំខ្ពស់ដូចភ្នំក្បាលតូច កខ្វីសាច់រឹងដូចដំរី ចំពោះខ្លួនប្រាណវិញ គឺមានភ្លើងឆេះរងំ ឆេះទាំងយប់ឆេះទាំងថ្ងៃ ដូចភ្លើងឆេះភ្នំ ស្រេកឃ្លាន អាហាររាប់កោដិឆ្នាំឃ្លានអត់មានស្រាករឹតតែមិនស្លាប់ព្រោះបានធ្វើបានកម្មច្រើន និងទ្រាំរស់នៅនេះរាប់រយឆ្នាំទៀត លុះអស់កម្មពៀរ។ ប្រេតនេះច្រើនរស់នៅក្នុងព្រៃជ្រៅ នាហេមពាន្តភ្នំកិជ្ឈកូដ កាលពីជាតិមុនគឺជាមនុស្សទុរជនមានចិត្តរឹងរូស ចង់គំនុំ ឈ្មោះប្រកែកនិងតាមព្យាបាទគេឯងអត់ មានកោតក្រែងអំពើអាក្រក់ដែលខ្លួនបានសាង។

ប្រេតទី១០ឈ្មោះ **អជគរៈ** មានក្បាលច្រើនប្រភេទដូចជា ពស់ថ្លាន់ សត្វខ្លា ជាឆ្មា គោក្របី។ ប្រេតនេះចម្លែកមានរូបរាងប្លែកខុសប្រក្រតី ខ្លួនជាពស់ថ្លាន់ធំ វៀនលើដីធំ លើដំរីធំវែង ដូចភ្នំ។ ភ្លើងឆេះព័ទ្ធទាំងយប់ទាំងថ្ងៃ ស្រេកឃ្លានអាហារគ្រប់ពេលវេលា ចេះតែថ្ងូរស្រែកទុក្ខខ្លាំងពេកក្រៃ។ ប្រេតនេះរស់នៅក្នុងព្រៃជ្រៅឬបព្វតាក្បែរសមុទ្រ លើដុំសិលា។ ប្រេតនេះពីជាតិមុនមិនបានធ្វើបុណ្យ ប៉ោឡៃ មិនខ្លាចឪម៉ែជីដូនជីតា ជេរអ្នកមានគុណថាឆ្កែថាឆ្មា ព្រះសង្ឃក៏មិនខ្លាចប្រើពាក្យប្រមាថទៅទៀត ទើបធ្វើឱ្យប្រេតនេះឯងមានភ្លើងគ្រប់ពេលវេលាបែបនេះ។

ប្រេតទី១១ឈ្មោះ **វេមានិក** មានរូបធំទ្រមឹង រាង ធាត់ក្រអាញ ដុះរោមជិតឈឹង ពោះប៉ោងត្រង់ ភ្នឹងសម្បើមអស្ចារ្យ ប៉ុន្តែសុខទុក្ខស្មោះគ្មានតាម ធម្មតា ដែកាន់អាវុធបិត្តកាចក្លៀវក្លា។ ប្រេតនេះ គេហៅថា មវាជទៅកាប់សត្វរកឈាមប្រឡាក់ ព្រាចពីព្រឹកដល់ល្ងាចអត់បាយអត់ទឹក វាយសួរ ចម្លើយកាត់ទោសគ្រប់នរកត្រួតត្រាទាំងអស់។ ពេលដែលសោយសុខ គឺក្លាយខ្លួនទៅជាទេវ បុត្រកំលោះរូបល្អឥតខ្ចោះ នៅក្នុងឋានសួគ៌ ស្រី ទេពអប្សរចោមរោមសុំស្នេហ៍។ ដល់ពេល សោយទុក្ខកើតជាប្រេតចង្រៃរងទុក្ខវេទនាទាំង យប់ទាំងថ្ងៃ ប្រេតនេះកាលពីជាតិមុនជាមនុស្ស ស៊ិយប្រព្រឹត្តិលីលាបានធ្វើទានខ្លះធ្វើតាម ទម្លាប់ គឺបុណ្យក៏ធ្វើបាបក៏ធ្វើក្នុងន័យប្រមាថ ដូច្នេះហើយទើបរងផលកម្មសងទាំងពីរបែប នេះ។

ប្រេតទី១២ឈ្មោះ **មហិទ្ធកៈ** រូបល្អពេញ ទីជាស្តេចនៃប្រេត អ្នកមានឫទ្ធីល្អអត់មានពីរ ស្មើរូបទេព្តាមានគ្រឿងស្លៀកពាក់ស្រស់ស្អាត ពេកក្រៃ ទាល់តែស្រេកអាហារអ្វីៗគ្រេកអរ លើសលន់ ខំស្ទុះទៅចាប់ភ្លើងឆេះពេកពន់ បើ មិនដូច្នេះទេឃើញហើយខំស្ទុះចាប់កើបស្រវា បានដាក់ក្នុងមាត់ លេបទៅកាលណាស្រាប់តែ ក្លាយទៅជាដុំដែកក្រហមឆ្អាល ឆេះឆាបក្នុង មាត់ស្រេកឃ្លានណាស់ ព្រោះមានកម្មច្រើនក្លិន ស្អុយអស្ចារ្យ ល្អតែរូបកាយ។ ប្រេតនេះកាលពី ជាតិមុនបួសក្នុងសាសនាប្រមាថសុះសាយ បួស មិនប្រព្រឹត្តិវិន័យបួសធាន់តែបាយប្រព្រឹត្ត អាក្រក់ ធ្វើមិច្ឆាចារ ឆបោកគ្រហស្ថ ប្ងន់លាភ សាសនាវិន័យសិក្ខាប្រតិបត្តិ។[4]

ដោយមានការត្រាស់សម្តែងយ៉ាងនេះ ហើយ ទើបនាឱកាសរដូវភ្ជុំបិណ្ឌនេះ ប្រជាពុទ្ធ បរិស័ទតែងតែប្រារព្ធនូវកិច្ចទំនៀមកាន់បិណ្ឌ រយៈពេល១៥ថ្ងៃ ព្រមទាំងមានរៀបចំកិច្ចបង្សុ កូល វេរចង្ហាន់ គ្រឿងទេយ្យទានប្រគេនព្រះ សង្ឃ អាចារ្យ អ្នកមានសីលជាដើម ដើម្បីឧទ្ទិស មគ្គផលបុណ្យកុសលជូនដល់ញាតកាទាំង៧ សន្តាន ក្រែងថាញាតិទាំងនោះឆ្លោយបុណ្យ ធ្លាក់កាយទៅចាប់កំណើតជាប្រេត នរក ឬកើត នៅទីមិនសមគួរណាមួយដើម្បីឱ្យអស់លោក ទាំងនោះបានទទួលនូវនិសង្ស និងធាប់រួចចាក ទុក្ខអកុសលនាទីដ្ឋានដ៏វេទនាទាំងនោះ។[5]

---

[4] មីសែល ត្រាណេ៖ ***មូលដ្ឋានគ្រឹះអរិយធម៌ខ្មែរ*** ភាគ២ ការ ផ្សាយរបស់គ្រឹះស្ថានបោះពុម្ពខ្មែរ គ. ស. ២០១៤។

[5]https://plus.freshnewsasia.com/index.php/en/knowledge/313799-2023




*ប្រភេទប្រេតទាំង១២ពួក ក្នុងជំនឿខ្មែរ* (*ប្រភព៖* https://www.google.com)

*ជាទីអវសាននេះ យើងខ្ញុំសូមជម្រាបផងដែរថា ការលើកយកប្រេតទាំងនោះមកបរិយាយ ក្រោមរូបភាពជាមនុស្ស ឬក៏ជាសត្វដែលមានលក្ខណៈផ្សែផ្សំនេះត្រូវបានអ្នកសិក្សាស្រាវជ្រាវចាត់ទុកថា ជាការស្តែងចេញពីក្នុងទឹកចិត្ត ឬអារម្មណ៍របស់មនុស្សដែលជួនកាលល្អ ជួនកាលអាក្រក់តែប៉ុណ្ណោះ។ ការយករូបតំណាងប្រេតទាំងនោះមកបង្ហាញ គឺដើម្បីឆ្លុះបញ្ចាំងអំពីផ្នត់គំនិតរបស់ខ្មែរយើងទាក់ទងទៅនឹងភាពសម្បូរបែបនៃជំនឿរបស់ខ្មែរយើង ជាពិសេសជំនឿទៅលើពួកប្រេត ក្នុងរដូវបុណ្យភ្ជុំបិណ្ឌនេះ។*

# គន្ថនិទ្ទេស


1. ជួន ណាត ៖ *វចនានុក្រមខ្មែរ* ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ គ. ស. ១៩៦៧។
2. ឈិន ឃួន ៖ *ជំនឿផ្សេងៗនៃជនជាតិខ្មែរ* ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ គ. ស.១៩៩៩។
3. ត្រឹង ង៉ា ៖ *អរិយធម៌ខ្មែរ* ការផ្សាយរបស់អ្នកនិពន្ធ គ. ស. ១៩៧៥។
4. មីសែល ត្រាណេ ៖ មូលដ្ឋានគ្រឹះអរិយធម៌ខ្មែរ ភាគ២ ការផ្សាយរបស់គ្រឹះស្ថានបោះពុម្ពខ្មែរ គ. ស. ២០១៤។
5. រាជបណ្ឌិត្យសភាកម្ពុជា ៖ មរតកនៃជំនឿខ្មែរ ០៩ មិថុនា គ. ស. ២០១៤។
6. https://www.google.com
7. https://freshnewsasia.com/index.php/en/localnews/313879-2023
8. https://plus.freshnewsasia.com/index.php/en/knowledge/313799-2023

# អំពីជំនឿខ្មែរ

(**ភាគ ១**)

បណ្ឌិត **ភ្លាន់ ធុល**
មន្ត្រីនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា,
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសង្គម,
រាជបណ្ឌិត្យសភាកម្ពុជា

នៅក្នុងជីវភាពប្រចាំថ្ងៃ**ជំនឿ** គឺជាអាហារស្មារតីរបស់មនុស្សដែលគេត្រូវបរិភោគជារៀងរាល់ថ្ងៃ។ អាហារខ្លះមានរសជាតិពុលដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពដែលពេលខ្លះវាអាចបង្កឱ្យគ្រោះថ្នាក់ដល់ជីវិតក៏មាន។ ឯអាហារខ្លះទៀតមានរស់ជាតិឆ្ងាញ់ដែលអាចជួយទ្រទ្រង់សុខភាពជីវិត។ ជំនឿក៏ដូច្នេះដែរ។ ជំនឿខ្លះអាចដឹកនាំអ្នកជឿទៅរកគ្រោះថ្នាក់ដោយសារតែជំនឿនោះខ្វះ សច្ចភាពគ្មានមូលដ្ឋានហេតុផលច្បាស់លាស់ ហើយអ្នកជឿចេះតែជឿទៅតាមឥន្ទ្រិយរបស់ខ្លួនតាមការឮឬការមើលឃើញជាដើម។ ចំណែកឯជំនឿខ្លះទៀតអាចដឹកនាំអ្នកជឿទៅរកវិបុលភាពនៃជីវិតដោយសារតែជំនឿនោះមានសច្ចភាព និងមានមូលដ្ឋានហេតុផលច្បាស់លាស់ ហើយអ្នកជឿប្រើប្រាស់វិចារណញ្ញាណជាមូលដ្ឋាន។ សព្វថ្ងៃអ្នកជឿគ្មានហេតុផលមួយចំនួនធំបាននិងកំពុងរងគ្រោះថ្នាក់ដោយការចាញ់បោកអស់ទ្រព្យធនអស់កេរ្តិ៍ឈ្មោះបែកបាក់គ្រួសារអស់ជីវិតជាដើម។ ដើម្បីទទួលយកជំនឿពីគេ និងប្រើប្រាស់ជំនឿរបស់ខ្លួនឱ្យមានប្រយោជន៍គេត្រូវមានពុទ្ធិជាពិសេសវិចារណពុទ្ធិ ដើម្បីស្គាល់ច្បាស់លាស់ពីជំនឿ, ប្រភេទជំនឿ, ប្រភពជំនឿ, ជំនឿខុស, ជំនឿត្រូវ, វិធីស្វែងរកជំនឿត្រូវ, ហើយនិងសារៈប្រយោជន៍នៃជំនឿត្រូវ។

## ១. ខ្លឹមសារជំនឿ

នៅក្នុងពុទ្ធិវិទ្យាផ្ទៃប្ចូបានកំណត់ និយមន័យពុទ្ធិថាជា *ជំនឿយុត្តិកម្ម* (justified belief) បូករួមនឹង *និមិត្តសញ្ញា* (*logos*) នានាផង។ *ជំនឿ* គឺជាបញ្ញត្តិសំខាន់មួយនៅក្នុងពុទ្ធិវិទ្យា។ ការពិភាក្សាជាច្រើននៅក្នុងទ្រឹស្តីពុទ្ធិទទួលយក *ជំនឿ* ជាងទទួលយកពុទ្ធិថា ជាចំណុចចាប់ផ្តើមរបស់ពួកវា។ ជាទូទៅគេគិតថា *ជំនឿ* គឺទាក់ទងគ្នាពីធម្មជាតិមក ហេតុដូច្នេះ ហើយបានជាវាត្រូវការ កម្មវត្ថុមួយ។ *ជំនឿ* ជារឿយៗ

ត្រូវបានបង្ហាញថាជាសភាពមួយដែល អាចប្រើជាប្រយោជន៍ចំពោះ អន្តបនិជ្ឈាន (introspection) ជាមួយនឹងទំនាក់ទំនងជាក់លាក់មួយទៅនឹងរូបភាពបច្ចុប្បន្នឬភាពស្មុគស្មាញនៃរូបភាព។ វត្ថុជំនឿត្រូវបានគេយល់ផ្សេងៗគ្នាថាជាសភាពអារម្មណ៍ជាក់ស្តែងឬមានសុពលមួយ,ជាសភាពកិច្ចការឬជាសំណើរមួយ។ សំណើរថា «ខ្ញុំជឿលើ P» មានន័យថា ខ្ញុំមានឥរិយាបថ ទទួលយកចំពោះ P ដោយមានហេតុផលមួយចំនួន (ទំនងជាមិនអាចសន្និដ្ឋានបាន)។ ប៉ុន្តែលទ្ធិមុខងារនិយម (functionalism) ជំទាស់នឹងទស្សនៈថា ជំនឿត្រូវតែមានកម្មវត្ថុមួយ។ ជាប្រពៃណី ជំនឿត្រូវបានគេចាត់ទុកថាជាសភាពចិត្តមួយ ដែលបម្រើជាកត្តាហេតុមួយនៅក្នុងឥរិយាបថប៉ុន្តែ លោក **រ៉ៃល** (Ryle) បានអះអាងថា ជំនឿគឺជាទំនោរត្រូវនិយាយ ឬ ត្រូវធ្វើ អ្វីមួយជាជាងសភាពចិត្ត។ ការវិភាគជំនឿភាគច្រើនចាត់ទុកថា ជំនឿមានលក្ខណៈពិតផងនិងមិនពិតផង បើទោះជាអ្នកអព្ភន្តរញ្ញាណនិយម (intuitionists) បានចាត់ទុកថា ជំនឿមួយចំនួន ពិតក៏មិនពិត ហើយខុសក៏មិនខុសដែរ។ លើសពីនេះ **លទ្ធិភវនិយម** (probabilism) ឬ ទ្រឹស្តីភវនភាព (probability theory) លើកឡើងថា ជំនឿមានទៅតាមកម្រិត។ វាក៏មានការបដិសេធជំនឿចោល(eliminativist rejection of belief) ផងដែរដែលថាជាអង្គឧបធារណ៍ (postulated entity) មួយនៅក្នុងចិត្តវិទ្យាប្រជាប្រិយហួសសម័យផងដែរ។ បញ្ហាទស្សនវិជ្ជាចម្បងៗអំពីជំនឿបូករួមទាំង លទ្ធភាពនៃជំនឿពិតប្រាកដ ដែលជាការធ្វើយុត្តិកម្មពីជំនឿកំពូលផ្សេងៗដទៃទៀត, ទំនាក់ទំនងជំនឿជាមួយនឹងការទទួលយក, ការគិតហេតុផល, សមត្ថភាពបញ្ញត្តិកម្មនិងភាសាវិទ្យា, ទំនាក់ទំនង រវាងជំនឿពិតដែលគេបានធ្វើយុត្តិកម្មនិងពុទ្ធិ និងភាពខុសគ្នារវាងជំនឿ *de re* (ជាជំនឿអំពីវត្ថុដែលគេនិយាយ) និងជំនឿ *de dicto* (ជាជំនឿអំពីអ្វីដែលគេនិយាយ)ផងដែរ។ ប្រតិមតិ (paradox) របស់ **ម៉័រ** (Moore) ដែលកើតចេញមកពីការនិយាយមិនសមហេតុផលថា «P ប៉ុន្តែ ខ្ញុំមិនជឿថា P» ទេ ហើយនិងចេតនាភាពនៃការពិភាក្សាជំនឿ (belief sentences) បានចោទជាសំណួរសំខាន់ៗអំពីធម្មជាតិនៃជំនឿ។

«ដើម្បីជឿ ដូច្នេះគឺគ្មានអ្វីក្រៅពីដើម្បីទទួលយកអ្វីមួយ ដែលអ្វីមួយនោះខ្ញុំមិនទាន់ប្រាកដនៅក្នុងចិត្តដោយតក្កវិជ្ជានៅឡើយទេ។ ម្យ៉ាងទៀត ជំនឿក៏ជាការទទួលយកថាពិតគ្រប់គ្រាន់ដោយការប្រតិបត្តិផងដែរ»[2]។

ជំនឿគឺជាឥរិយាបថអត្តនោម័តិដែលថាអ្វីមួយឬសំណើរពិត។ នៅក្នុងពុទ្ធិវិទ្យាទស្សនវិទូ ប្រើពាក្យ «ជំនឿ (belief)» ដើម្បីសំដៅទៅ

---

[1]Nicholas Bunnin And Jiyuan Yu, *The Blackwell Dictionary of Western Philosophy*, USA, First published, 2004, p 79-80

[2]Kant, Lectures on Logic in Nicholas Bunnin And Jiyuan Yu, *The Blackwell Dictionary of Western Philosophy*, USA, First published, 2004, p 79-80

លើសវិយាបថអំពី**ពិភពលោក** ដែលអាចពិតផងនិងមិនពិតផង។ដើម្បីជឿអ្វីមួយ គឺត្រូវ យកវាទៅជាការពិត។ ជាឧទាហរណ៍ ដើម្បីជឿថា ព្រិលមានពណ៌ស គឺអាចប្រៀបធៀបទៅនឹងការទទួលយកសច្ចភាពនៃសំណើថា «ព្រិលមានពណ៌ស»។ តែ ទោះជាយ៉ាងណាក៏ដោយ ការមានជំនឿមួយមិនតម្រូវឱ្យមានអន្តោបនិជ្ឈាន (introspection) សកម្មនោះទេ។ ជាឧទាហរណ៍ មានមនុស្សតិចតួចណាស់ដែលគិត ដោយប្រុងប្រយ័ត្នថា តើព្រះអាទិត្យនឹងរះនៅថ្ងៃស្អែក ឬអត់នោះ ដោយគ្រាន់តែសន្មត់ដោយសាមញ្ញថាវានឹងរះ។ ជាងនេះទៅទៀត ជំនឿមិនចាំបាច់កើតឡើងទេ (ឧ.មនុស្សម្នាក់គិតយ៉ាងសកម្មថា«ព្រិលមានពណ៌ស») ប៉ុន្តែវាអាចជាអារម្មណ៍ទៅវិញទេ(ឧ.អ្នកដែលសួរអំពីពណ៌ព្រិលនឹងអះអាងថា «ព្រិលមានពណ៌ ស»)។

ជារួម តាមខ្លឹមសារដែលយើងបានដឹងជាទូទៅនៅក្នុងជីវិតជាក់ស្តែងបានទទួលយកជំនឿថាជាការចុះចិត្តស៊ប់ដោយយល់ថាពិត ឬការយកចិត្តទុកដាក់ថាជាការមែន។ឧទាហរណ៍ ត្រូវជឿកម្មហើយនិងផលរបស់វា[3]។ឬអាចនិយាយម្យ៉ាងទៀតថា ជំនឿគឺជាការមានអារម្មណ៍ប្រាកដថា អ្វីមួយមានអត្ថិភាពឬមានពិត។ ឧ.(១)៖រាល់ជំនឿសាសនានិងនយោបាយអហិង្សា សុទ្ធតែគួរឱ្យគោរពស្មើៗ គ្នា។ ឧ.(២)៖ ខ្ញុំមានជំនឿថា អាវុធនុយក្លេអ៊ែរគឺអសីលធម៌។ ឧ.(៣)៖ ជំនឿរបស់គាត់ទៅលើព្រះបានផ្តល់ក្តីសង្ឃឹមដល់គាត់នៅក្នុងគ្រាលំបាក[4]។

## ២. ប្រភេទជំនឿ

បើតាមបទពិសោធន៍ដែលគេធ្លាប់រស់នៅនៅក្នុងសង្គម ជំនឿមានពីរប្រភេទគឺ ជំនឿរូបី១ និងជំនឿអរូបី១។ ជំនឿទាំងពីរមានធម្មជាតិមិនដូចគ្នាដូចខាងក្រោម៖

### ២.១. ជំនឿរូបី

ជំនឿគឺជាការជឿ ឬការជឿស៊ុបទៅលើអ្វីមួយដែលមានអត្ថិភាពជាក់ស្តែងនៅក្នុងពិភពតថឬពិភពធម្មជាតិ។ នេះមានន័យថា ជំនឿកើតឡើងរវាងប្រធានវិស័យ (មនុស្ស) ហើយនិងវត្ថុវិស័យ (មនុស្ស, វត្ថុ, ឬរុក្ខជាតិ) អាចតាមរយៈស្មារតី (mind) ផ្ទាល់ខ្លួនរបស់ប្រធានវិស័យ ឬតាមរយៈការបកស្រាយពន្យល់របស់ប្រធានវិស័យមួយផ្សេងទៀត។ នៅពេលនេះ ជំនឿអាចកើតមានបានតែត្រង់ថា ពិតនិងមិនពិតវាទាមទារនូវការបង្ហាញភស្តុតាងមួយទៀត។

នៅក្នុងលទ្ធិ **លទ្ធិប្រតិបត្តិនិយម** (prag-matism) លោក **ឆ.ស.ភៀស** (Charles San-ders Peirce (១៨៣៩-១៩១៤)ដែលបានទទួលឥទ្ធិពលមកពី **គោលការណ៍អំណះអំណាង**

[3] ជួនណាត *វចនានុក្រមខ្មែរ*រក្សាសិទ្ធិដោយ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ២០០៨, ទំព័រ *ជឿ*

[4] Cambridge Advanced Learner's Dictionary, 3rd ed. p intuition, p *beliefs*

**ពរបស់ព្រះយេស៊ូ** ថា «គេនឹងបានយល់ច្បាស់ពីវាតាមរយៈផ្លែផ្ការបស់វា។» ឈរលើមូលដ្ឋាននេះ**កៀស**បានបង្កើត**ទ្រឹស្តីសច្ចភាពការណ៍និយម** (the pragmatic theory of truth) ដូច្នេះថា៖ **គំនិតមួយពិតទៅបានប្រសិនបើគំនិតនោះ អាចដំណើរការបាន** (workable) **ហើយមានវិបាក** (consequence) **គួរជាទីពេញ ចិត្តនិង អាចអនុវត្តបាន**។ តែទោះជាយ៉ាងណាក៏ដោយ**ទ្រឹស្តីឬសម្មតិកម្ម**(hypothesis)ណាមួយបើស្តាប់មើលទៅល្អតែប្រសិនបើវានឹងមិនដំណើរការ ឬមិនមានលទ្ធផលជាក់ស្តែង (concrete), អាចប្រតិបត្តិបាន (practical)និងគួរជាទីពេញចិត្ត (satisfactory) ទេទ្រឹស្តីឬសម្មតិកម្មនោះក៏គ្មានន័យឬគ្មានតម្លៃអ្វីដែរ។ វាប្រព្រឹត្តទៅដោយមិនបាននិយាយថា វាគឺជា**ភាពអាចធ្វើទៅបានគួរឱ្យពេញចិត្ត** (the satisfactory workability) និង**ភាពមានប្រយោជន៍នៃគំនិត** (usefulness of the idea) ដែលមិនត្រឹមតែផ្តល់ឱ្យវានូវ **តម្លៃ** និង**សារៈសំខាន់** នោះប៉ុណ្ណោះទេ តែក៏ធ្វើឱ្យវាមានសុពលភាពនោះផងដែរ។ ឧទាហរណ៍ ប្រសិនបើការចរចារសន្តិភាពដោយរដ្ឋាភិបាលជាមួយនឹងពួកឧទ្ទាម (rebels) ត្រូវគេមានជំនឿថា ជាមធ្យោបាយល្អបំផុត ដោយធានាបាននូវសន្តិភាពយូរអង្វែងនៅពេលនោះ សម្មត្តិកម្មនេះពិតទៅបានលុះត្រាតែក្រោយមក វាត្រូវបានគេមើលឃើញថាដំណើរការស្របតាមការរំពឹងទុកបាន[5]។

ទ្រឹស្តីអំពី *ភាពត្រូវគ្នា* (correspondence) បានលើកឡើងថា **សច្ចភាព**ត្រូវបានគេកំណត់ន័យថាជា «**សច្ចភាពដែលអនុលោមតាមការពិត, ឯកភាពជាមួយនឹងតថភាព, ឆ្លើយតបទៅនឹងស្ថានការណ៍ជាក់ស្តែង**។» ឈរលើមូលដ្ឋាននៃការឱ្យនិយមន័យនេះ **ទ្រឹស្តីសច្ចភាពត្រូវគ្នា**ត្រូវបានគេបង្កើតជាគំរូថា៖ **គំនិតឬការពិពណ៌នាមួយពិត ប្រសិនបើវាឯកភាពជាមួយនឹងវត្ថុដែល គេបានពិពណ៌នា ឬបានសំដៅទៅរកនោះ**។ ការពិពណ៌នាពី**សត្វ ដំរីមួយ** ថាជា **សត្វមានមាឌធំ មួយពិត** ប្រសិនបើនៅក្នុងតថ**ភាព**មាឌសត្វប្រភេទនេះត្រូវទៅតាម**ការពិពណ៌នា**នោះមែន។ បើនិយាយដូចគ្នានេះអំពី**សត្វកណ្តុរ**វិញនោះគឺខុសពីព្រោះនៅក្នុងតថភាព**សត្វកណ្តុរ នេះមានមាឌតូចជាងដំរីច្រើនជងណាស់**។ សេចក្តីពន្យល់ទាំងនេះចង្អុលបង្ហាញថា **កស្តុតាងសុពលភាព គំនិត**ជាកម្មវត្ថុរបស់វាដែលត្រូវ តែត្រូវគ្នាជាមួយនឹងការពិពណ៌នាដែល គេ បានបង្កើតឡើង។

ចំពោះទ្រឹស្តីនៃភាពទៀងទាត់ (consist-ency) វិញ អះអាងថា**គំនិត**មានលក្ខណៈទៀងទាត់ទៅបានប្រសិនបើ**ខ្លឹមសាររបស់វាមិន មានស័ព្ទផ្ទុយគ្នា ដែលតែងតែបដិសេធគ្នាទៅវិញទៅមក**។ សំណើរ ដូចជា«**ឆ្កែគឺជាសត្វ**»,

---

៥ Venancio B. Ardales, "*Introductory text to philosophy,*" 2nd printing, New York, 1974 p.67-68

«**ដើម ឈើគឺជារុក្ខជាតិ**» និង «**កំព្យូទ័រ គឺជាម៉ាស៊ីន**» សុទ្ធតែជាអំណះអំណាងទៀងទាត់ទាំងអស់ពីព្រោះស័ព្ទដែលគេប្រើនៅក្នុងប្រយោគនីមួយៗមិនប្រឆាំងគ្នា។ តែទោះជាយ៉ាងណាក៏ដោយសូមពិនិត្យផ្ទៀងផ្ទាត់មើលពីអំណះអំណាងដូចជា «**មនុស្សមានជីវិតអមតៈ**»«**ថ្មមានសភាពទន់**»។ អំណះអំណាងទី១ គឺជាអំណះអំណាងប្រឆាំងគ្នាព្រោះពាក្យថា **អមតៈ**(immortal) មានន័យថា «**រស់នៅរហូត**»ដែលមិនពិតអំពីមនុស្សដែលនឹងត្រូវស្លាប់ជាយថាហេតុ។ ភាពប្រឆាំងគ្នានេះក៏មានអត្ថិភាពនៅក្នុង អំណះអំណាងទី២ផងដែរ ពីព្រោះ បើតាមតថភាព **ថ្មគឺជាវត្ថុរឹង**[6]។

ជំនឿរូបី អាចចែកទៅជាបីប្រភេទទៀត គឺ ឥន្ទ្រិយជំនឿ, ជំនឿវិទ្យាសាស្ត្រ, និងវិចារណជំនឿ។

### ២.១.១. ឥន្ទ្រិយជំនឿ ( sense beliefs )

ឥន្ទ្រិយ គឺជាប្រភពពុទ្ធិហើយក៏ជាប្រភពជំនឿផងដែរ។ មនុស្សជាច្រើនតែងទទួលបាន **ជំនឿ**តាមរយៈ ឥន្ទ្រិយ ពួកគេមិនចង់ទទួលបានតាមរយៈ**ការធ្វើពិសោធន៍** (exp-erimenttation) ឬ**ការគិតពិចារណាហេតុផល** (reasoning) លំបាកលំបិន និងល្អិតល្អន់ពេកនោះទេ។ ពួកគេ ជ្រើសរើសយកវិធីងាយៗលឿនៗ ហើយស្រួល ពោលគឺតាមរយៈ**កម្លាំងឥន្ទ្រិយ** (the power of senses) មានដូចជា ចក្ខុវិញ្ញាណ, សោតវិញ្ញាណ, ឃានវិញ្ញាណ, កាយវិញ្ញា, និងជីវ្ហាវិញ្ញាណជាដើម។ អ្វីដែលឥន្ទ្រិយទទួលបានមកពីបរិស្ថាន នាំមកនូវមូលដ្ឋានក្នុងការបង្កើតគំនិតអំពីវត្ថុជាក់លាក់មួយឬទំនាក់ទំនងដែលគេស្គាល់។ សរុបមកអ្វីៗដែលយើងជឿ គឺសុទ្ធតែឥន្ទ្រិយរបស់យើងផ្តល់ឱ្យទាំងអស់[7]។

អ្នកតថភាពកញ្ចោតនិយម (អ្នកដែលជឿតាមឥន្ទ្រិយ) ពិតជាយល់ថា **តថភាព** គឺជាអ្វីដែលឥន្ទ្រិយរបស់យើងអាចពិពណ៌នាពីពួកវាយ៉ាងណាៗនោះបានយ៉ាងជាក់លាក់។ ឧទាហរណ៍ ស្ករមានរស់ជាតិផ្អែមឆ្ងាញ់បើតាមជីវ្ហាវិញ្ញាណ; ក្លិនកាកសំណល់ស្អុយរលួយធ្វើឱ្យឃានវិញ្ញាណខ្ញុំធុំក្លិន។ ទាំងនេះសុទ្ធតែខ្ញុំមានបទពិសោធន៍តាមរយៈឥន្ទ្រិយរបស់ខ្ញុំ។ ឥន្ទ្រិយប្រាប់យើងពីការពិតអំពីបទពិសោធន៍; ពួកវាគឺជា «កត្តារឹងមាំនៅក្នុងជីវិត ជាភាពឯករាជ្យនៃឆន្ទៈរបស់យើង ហើយនិងផ្តល់ឱ្យយើងនូវទំនាក់ទំនងជាមួយតថភាពខាងក្រៅ។ ប្រសិនបើ**គ្មាន**ឥន្ទ្រិយទេ នោះក៏គ្មានបទពិសោធន៍ដែរ ហើយបើគ្មានបទពិសោធន៍ នោះក៏គ្មានការគិត និងការជឿដែរ ពីព្រោះការគិតការជឿត្រូវចាប់ផ្តើមជាមួយនឹងអ្វីដែលឥន្ទ្រិយបានផ្តល់ឱ្យយើងចំពោះការដឹង

---

៦ Venancio B. Ardales, "*Introductory text to philosophy,*" 2nd printing, New York, 1974 p.66-67

៧ Venancio B. Ardales, "*Introductory text to philosophy,*" 2nd printing, New York, 1974 p.56

ការជឿរបស់យើង។ អ្នកតថភាពកញ្ចោតនិយមទទួលថា អ្វីដែលផ្តល់ឱ្យមកតាមឥន្ទ្រិយរបស់យើង គឺច្បាស់លាស់ ហើយ វត្ថុនានាដែលឥន្ទ្រិយមិនអាចយល់ដឹងបាន គឺវាគ្រាន់តែជាគំនិតដែលគេមិនអាចផ្ទៀងផ្ទាត់បានតែប៉ុណ្ណោះ[៨]។

ប៉ុន្តែ តើយើងអាចជឿទុកចិត្តលើឥន្ទ្រិយរបស់យើងបានដែរឬទេ? ប្រសិនបើពឹងផ្អែកទៅ លើបទពិសោធន៍មុនៗរបស់យើងធ្វើជាមូលដ្ឋានគ្រឹះ នៅពេលនោះយើងអាចនឹងឆ្លើយបានថា «មិន ជឿទុកចិត្តទេ»។ ដូចបានចង្អុលបង្ហាញរួចមកហើយថា **ឥន្ទ្រិយរបស់យើង** មិនសូវដែលបានផ្តល់ ឱ្យយើងនូវ**ធម្មជាតិពិតរបស់វត្ថុ** ដោយជោគជ័យនោះទេ។ **ធម្មជាតិពិតរបស់វត្ថុ** នោះមាន**តថភាព ច្រើន** ដែលនៅហួសពី**ឥន្ទ្រិយ**របស់យើង។ **បទពិសោធន៍ខាងក្នុង** ពោលគឺ **ឧត្តមភាព** (ideals) និង**តម្លៃ** (values)សច្ចភាពសុទ្ធតែឥន្ទ្រិយមិនអាចពិនិត្យផ្ទៀងផ្ទាត់បានទេ។ និយាយឱ្យខ្លី **ការយល់ដឹងដោយឥន្ទ្រិយខ្លួនវាផ្ទាល់**មិនមែនជាការពិនិត្យផ្ទៀងផ្ទាត់សច្ចភាពល្អទេ។

ជំហររបស់អ្នកពិសោធន៍និយមនៅក្នុងការសម្រេចបានជំនឿនេះ ត្រូវជួបប្រទះនឹងការជំទាស់យ៉ាងធ្ងន់ធ្ងរ។ នៅពេលយើងពឹងផ្អែកទៅលើ**ឥន្ទ្រិយ** របស់យើងចំពោះការពិត និងទំនាក់ទំនង ពិសេសៗមួយចំនួននៅក្នុងពិភពរស់នៅប្រចាំថ្ងៃរបស់យើងមានរឿងជាច្រើន នៅពេលដែលឥន្ទ្រិយរបស់យើងបំភាន់ករណីដូចជា នៅពេលយើងក្តៅខ្លួនខ្លាំង ភ្នែករបស់យើងមិនបានផ្តល់ឱ្យយើងនូវរូបរាង និងពណ៌វត្ថុពិតនៅចម្ងាយជាក់លាក់នោះទេ។ ករណីបំភាន់ដូចគ្នានេះដែរ ផ្លូវដែកពីរស្របគ្នា បើគេមើលនៅក្នុងចម្ងាយដ៏ឆ្ងាយមួយ គេនឹង រកឃើញថា ផ្លូវដែកទាំងពីរនោះជួបគ្នានៅត្រង់ចំណុចមួយយ៉ាងពិតប្រាកដ។ ឧទាហរណ៍មួយទៀត អំពីការភ្ញាក់ផ្អើលរឿង **ឌឹប្លែកហូល** (the Black whole) ដែលអ្នកផ្សព្វផ្សាយ បង្អើលថា មានទឹកលិចផែនដី ហើយមានតែនាំគ្នាទៅភ្នំគូលែនប៉ុណ្ណោះទើបអាចជួយរួចជីវិតបាន ពីព្រោះមានតែទីនោះប៉ុណ្ណោះដែលខ្ពស់ជាងគេក្នុងពិភពលោក។ នៅមានការបំភាន់ច្រើនដទៃទៀត ដែលមានលក្ខណៈប្រហែលៗនេះ និងជ្រាលជ្រៅជាង នេះ តាមយៈ *ភ្នែក, ច្រមុះ, ត្រចៀក, អណ្តាត, និងកាយ*។ ឧទាហរណ៍ បើមានការលួងលោម បបោសអង្អែលថ្នមៗ ឬច្រៀងបំពេរយ៉ាងពិរោះក្រអៅក្រអួន នោះគេនឹងត្រូវលង់លក់យ៉ាងភ្លេចខ្លួនព្រោះតែជឿកាយជឿត្រចៀក។ លើសពីនេះទៀត មានតថភាពដែល**ឥន្ទ្រិយ**របស់យើងមិនអាចដឹងបាន ដូចជា **សារជាតុអាតូម**, **រលកសម្លេង**, **រលកពន្លឺអេឡិចត្រូនិច** មួយចំនួនទៀត។ គួរកត់សម្គាល់ផងដែរថា ទិន្នន័យឥន្ទ្រិយគឺជា**បទពិសោធន៍**ផ្ទាល់របស់យើង។ ពួកវាអាចទទួលឥទ្ធិពល

[៨] Venancio B. Ardales, "*Introductory text to philosophy,*" 2nd printing, New York, 1974 p.61-62

*យ៉ាងផ្ដាយដោយ**បុរេនិច្ឆ័យ*** (prejudice) និង ***ការរំជួលចិត្ត*** (emotions) *ពីព្រោះយើងអាចជ្រើសរើស«ការពិត»ដើម្បីគាំទ្រសេចក្ដីអះអាងឬសេចក្ដីសង្ឃឹមរបស់យើងបាន។*

*សរុបសេចក្ដីមក គេមិនអាចជឿទុកចិត្តលើឥន្ទ្រិយរបស់គេបានឡើយ។ ហេតុនេះដើម្បីឱ្យគេអាចមានជំនឿទុកចិត្តរឹងមាំបាន គេត្រូវពឹងពឹងផ្អែកទៅលើការស្វែងរកជំនឿទៅតាមបែបវិទ្យាសាស្ត្រវិញ។*

**២.១.២. ជំនឿវិទ្យាសាស្ត្រ** ( scientific beliefs )

*ជំនឿវិទ្យាសាស្ត្រ ក៏ដូចជាពុទ្ធិវិទ្យាសាស្ត្រដែរ។ ជំនឿវិទ្យាសាស្ត្រជា**អង្គជំនឿមួយដែលមានការពិនិត្យផ្ទៀងផ្ទាត់, ធ្វើពិសោធន៍ដើម្បីបង្ហាញភស្តុតាង, និងរៀបចំជាប្រព័ន្ធក៏ដូចជាវិធីក្នុង ការទទួលបានជំនឿនោះដែរ។** ការខ្វល់ខ្វាយចម្បងរបស់អ្នកវិទ្យាសាស្ត្រ គឺ រកឱ្យឃើញពី **សច្ចភាព** ក្នុងគោលបំណងយល់ដឹងពីវាជាមុន **បន្ទាប់មក**ដើម្បីធ្វើអ្វីមួយអំពីវានោះ[៩]។ វិទ្យាសាស្ត្របង្ហាញឱ្យឃើញពី**ទំនោររិះគន់ និងបើកចំហ, ការតស៊ូ** និង **ឆន្ទៈ** គោរពទៅតាមបទពិសោធន៍និងវិចារណញ្ញាណ ហើយនិងកង្វល់មិនលំអៀងចំពោះសច្ចភាព។ ជំនឿវិទ្យាសាស្ត្រមានលក្ខណៈអាចផ្ទៀងផ្ទាត់បាន។ អ្នកវិទ្យាសាស្ត្រមានបំណងចង់សម្រេចឱ្យបាននូវ **អង្គពុទ្ធិដែលមានការរៀបចំ និងចងក្រងជាប្រព័ន្ធ** ដើម្បីឱ្យជំនឿឈានទៅដល់សច្ចភាពមួយដែលគេអាចទទួលយកបាន។*

*ពុទ្ធិវិទ្យាសាស្ត្របង្កើតឱ្យមានជំនឿវិទ្យាសាស្ត្រ។ ពុទ្ធិនេះមិនមានសុក្រិតភាពពេញលេញអាចឱ្យយើងជឿទុកចិត្តបានទាំងស្រុងនោះឡើយ ថ្វីត្បិតតែវាមានការស្រាវជ្រាវ និងមានការធ្វើពិសោធន៍ច្បាស់លាស់ក៏ដោយ លើកលែងតែគំនិតរបស់ព្រះពុទ្ធ គឺគេគ្រាន់តែអាចទទួលយកវានៅក្នុងកម្រិតប្រហាក់ប្រហែលមួយប៉ុណ្ណោះ។ ឧទាហរណ៍ ៖*

- ២ + ២ = ៤ (១)
- ២ + ២ = ៤ (២)

*ចំនួន ៤ នៃផលបូកអង្គទី១ និងចំនួន៤ នៃផលបូកអង្គទី២ វាគ្រាន់តែមានផលបូកចំនួន៤ ស្មើឬដូចគ្នា តែសច្ចភាពរបស់មិនដូចគ្នាទេ។*

*ហេតុនេះ ផ្ដើមចេញពី គំនិតអសុក្រិត ទើបនាំឱ្យការប្រតិបត្តិគំនិតនៅក្នុងវិទ្យាសាស្ត្រក៏ អសុក្រិត ឬក៏អាចនិយាយបានម្យ៉ាងទៀតថា បើទោះជាគំនិតសុក្រិត (មានគំនិតព្រះពុទ្ធជាដើម) ក៏ដោយ ក៏ការប្រតិបត្តិគំនិតនៅតែមិនសុក្រិតដូចគំនិតដើមរបស់ព្រះអង្គដែរ។ ចំពោះបញ្ហានេះផ្ទេថូបានលើកឡើងអំពី**សិល្បៈ**ដែលថា «សិល្បៈគឺជា**ការត្រាប់នៃការត្រាប់**»។ លោកពន្យល់ថា សិល្បៈគឺជាការត្រាប់តែពុំមែនជាការត្រាប់តាម **វត្ថុវេទយិត**ទេ គឺជាការត្រាប់តាមគំនិត។ វិចិត្រករធ្វើត្រាប់តាម**វត្ថុវេទយិត**។*

[៩] Venancio B. Ardales, *"Introductory text to philosophy,"* 2nd printing, New York, 1974 p. 3

ឧទាហរណ៍ វិចិត្រករឆ្លាក់ *រូបសេះមួយ* តាម *សត្វសេះពិត* (រូបី)។ រីឯសត្វសេះពិតគឺ ជាការត្រាប់តាម *បញ្ញត្តិសេះ* ឬ *គំនិតស្តីពីសេះ* ដែលជាបញ្ញត្តិឬគំនិតអរូបី។ ហេតុនេះ បើតាមគំនិតផ្ទុយ *រូបសេះឆ្លាក់*អន់ជាង *សត្វសេះពិត* ហើយវាក៏កាន់តែអន់ជាង *បញ្ញត្តិ សេះ* ឬ *គំនិតស្តីពីសេះ* ទៅទៀត[10]។ ហេតុនេះ លោកមិនទទួលស្គាល់អត្ថន័យនៃសិល្បៈដែលយកតម្រាប់តាមវត្ថុជាក់ស្តែង ពោលគឺ លោកបានបដិសេធស្នាដៃសិល្បៈរបស់សិល្បៈករនៅក្នុងសហកាលរបស់លោកស្ទើរតែទាំងអស់។

ជាបទពិសោធន៍នៅក្នុងជីវភាពរស់នៅសព្វថ្ងៃ គេសង្កេតឃើញបញ្ហាទាំងនេះថា វិទ្យាសាស្ត្រកាន់តែរីកចម្រើន និងកាន់តែជឿនលឿនការរស់នៅរបស់មនុស្សក៏កាន់តែមានការគំរាមកំហែងច្រើនដែរ។ ការអភិវឌ្ឍវិទ្យាសាស្ត្រមានពីរបៀប, របៀបទី១ គឺការអភិវឌ្ឍវិទ្យាសាស្ត្រដោយមហិច្ឆតាលោភលន់ ដែលយើងហៅថា *វិទ្យាសាស្ត្រលោភលន់*។ ការអភិវឌ្ឍបែបនេះនាំឱ្យបញ្ហាជាច្រើន បានកើតឡើងនៅក្នុងជីវភាពរស់នៅរបស់មនុស្ស។ ជាកស្តុតាងនៅក្នុងការអភិវឌ្ឍវិស័យបច្ចេកវិទ្យាបានធ្វើឱ្យវិស័យនានាដែលទាក់ទង មានដូចជាវិស័យយោធាមានសព្វាវុធកាន់តែទំនើប ហើយការឈ្លានពាននិងការសម្លាប់មនុស្សក៏កាន់តែឃោរឃៅ,ការគំរាមកំហែងសង្គ្រាមនុយក្លេអ៊ែរ ; វិស័យព័ត៌មាននៅខាងផ្នែកបណ្តាញសង្គមហ្វេសប៊ុក មានកើតនូវជំងឺបាក់ទឹកចិត្ត,ដំណើរដាច់ ដោយឡែកពីក្នុងចំណោមមនុស្ស,ភាពចិត្តដាច់, ការបាត់បង់ភាពចេះជួយគ្នា,ចោរអ៊ីនធើណិត; អ្នកបោកប្រាស់តាមអ៊ីនធើណិត; វិស័យសុខាភិបាលកើតមាននូវជំងឺស្ពារ,ជំងឺកូវីដនាឆ្នាំថ្មីៗនេះ; វិស័យកសិកម្មកើតមាននូវចំណីអាហារកែច្នៃ,ការចិញ្ចឹមសត្វដោយប្រើចំណីកែច្នៃ បាត់បង់នូវលក្ខណៈធម្មជាតិ ដែលនាំឱ្យកើតនូវជំងឺទឹកនោមផ្អែម-ប្រៃ,ខ្វាញ់ក្នុងឈាមជំងឺដាច់សសៃឈាម ក្នុងខួរក្បាល, លើសឈាម...។ ហេតុនេះការអភិវឌ្ឍវិទ្យាសាស្ត្រប្រកបដោយមហិច្ឆតាលោភលន់ មិនមែនជាមូលដ្ឋាននៃជំនឿទុកចិត្តល្អរបស់មនុស្សនោះទេ។ របៀបទី២ គឺការអភិវឌ្ឍវិទ្យាសាស្ត្រដោយមនសិការទទួលខុសត្រូវ ដោយគុណធម៌ ដោយសីលធម៌វិជ្ជាជីវៈ ដែលយើងឱ្យឈ្មោះថា *វិទ្យាសាស្ត្រសុខុមាលភាព*។ ការអភិវឌ្ឍវិទ្យាសាស្ត្របែបនេះអាចធានាបាននូវសុខមាលភាពរបស់មនុស្ស។

ចំពោះការអភិវឌ្ឍវិទ្យាសាស្ត្រសុខុមាលភាពនេះ ព្រះពុទ្ធបានបង្កើតទ្រឹស្តីអប់រំទាំងផ្លូវកាយនិងផ្លូវចិត្តល្អឥតខ្ចោះ ដូចជាទ្រឹស្តីអំពីចតុរារិយសច្ចមាន ១- *សម្មាវាចា* (right speech), ២-*សម្មាកម្មន្ត* (right action), ៣- *សម្មាអាជីវៈ* (right livelihood), ៤- *សម្មាវាយាម* (right effort), ៥-

[10] ធុយ យីហ៊ាង, «*ប្រវត្តិទស្សនវិជ្ជាបស្ចឹមប្រទេស, ប្រវត្តិទស្សនវិជ្ជាបូរាណសម័យក្រិក*», សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ១៩៩៤, ទំព័រ៦៤

*សម្មាសតិ* (right mindfulness), ៦- *សម្មាសមាធិ* (right concentration), *៧- សម្មាសង្កប្ប* (right thoughts), *៨- សម្មាទិដ្ឋិ* (right views)។ *អរិយសច្ចទី១, ២, និង៣ ទាក់ទងទៅនឹងការអប់រំបណ្តុះ សីល* (ឥរិយាបថមានសីលធម៌) ជាពិសេសគឺ *សីល៥; អរិយសច្ច ទី៤, ៥, និងទី៦ ជាប់ទាក់ទងទៅនឹងការអប់រំបណ្តុះ សមាធិ (ការអប់រំចិត្តឱ្យមានលំនឹង); អរិយសច្ចទី៧ និងទី៨ ជាប់ទាក់ទងទៅ នឹង បញ្ញា* (ការស្គាល់ពីធម្មជាតិពិតរបស់វត្ថុ)[11]។ *ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ គេក៏នៅតែឃើញអ្នកកាន់ពុទ្ធសាសនាខ្លះមានបញ្ហាផ្លូវចិត្ត ប្រើហឹង្សា ប្រាស់ចាក សីល៥ មានសេចក្តីលោភលន់ មានចម្លោះវិវាទគ្នា... នេះ មកពីការយល់និងការប្រតិបត្តិមិនបាន ត្រូវទៅដល់ជម្រៅនៃខ្លឹមសារទ្រឹស្តីឬព្រះធម៌របស់ព្រះពុទ្ធ។ ហេតុនេះ គេត្រូវមានការយល់ដឹងពុទ្ធធម៌ឱ្យបានដល់ជម្រៅ ហើយប្រតិបត្តិឱ្យបានត្រឹមត្រូវ នោះគេនឹងអាចជឿទុកចិត្តបាន។ នៅត្រង់ចំណុចនេះ មានពុទ្ធដីកាមួយប្រយោគនៅមុនពេលព្រះអង្គយាងចូលបរិនិព្វានថា «ម្នាលអានន្ទ ធម៌ក្តី វិន័យក្តី ដែលតថាគតបានសម្តែងហើយ បញ្ញត្តិហើយ ដល់អ្នកទាំងឡាយ ព្រះធម៌ និង វិន័យនោះ លុះឥតពីតថាគតទៅ នឹងទៅជាគ្រូរបស់អ្នកទាំងឡាយហើយ។ តថាគតគឺជាព្រះពុទ្ធ មួយអង្គដែលតែងតែប្រៀនប្រដៅដល់អ្នកទាំងឡាយតែឥឡូវនេះ តថាគតនឹងបរិនិព្វានហើយ»* [12]។

*សរុបសេចក្តីមក ពុទ្ធិវិទ្យាសាស្ត្រមានលក្ខណៈសុក្រិត អាចឱ្យគេទុកចិត្តបាន ពីព្រោះវាជា ពុទ្ធិសួរដេញដោល រកហេតុរកផលមានការពិនិត្យសង្កេត និងបង្ហាញភស្តុតាងដោយការធ្វើពិសោធន៍ច្បាស់លាស់។ តែទោះជាយ៉ាងណាក៏ដោយ បើមនុស្សនៅតែអភិវឌ្ឍវិទ្យាសាស្ត្រប្រកបដោយ មហិច្ឆតាលោភលន់ការរស់នៅរបស់មនុស្សនៅតែជួបគ្រោះថ្នាក់ ដែលនាំឱ្យគេមិនអាចជឿទុកចិត្តវាបានទេ។ គេត្រូវតែអភិវឌ្ឍវិទ្យាសាស្ត្រសុខុមាលភាពទៅតាមគោលការណ៍ទ្រឹស្តីរបស់ព្រះពុទ្ធ ទើបគេអាចជឿទុកចិត្តបាន។ តែទោះជាយ៉ាងណាក៏ដោយ សមត្ថភាពក្នុងការយល់ដឹង និងសមត្ថភាពនៅក្នុងការប្រតិបត្តិរបស់មនុស្សនៅមានកម្រិត ហេតុនេះ ជំនឿវិទ្យាសាស្ត្រមិនអាចឱ្យគេជឿទុកចិត្តបានទាំងស្រុងឡើយ។*

**២.១.៣. វិចារណជំនឿ** (rational beliefs)

*ការគិតពិចារណា ឬការវែកញែកហេតុផលគឺជាប្រភពនៃវិចារណពុទ្ធិ ហើយក៏ជាប្រភពមូលដ្ឋាននៃវិចារណជំនឿផងដែរ។* ***លទ្ធិវិចារណញ្ញាណនិយម*** (rationalism) *យល់*

[11] *ញ៉ែម គឹមតេង "ផ្លូវកណ្តាល", វត្តមហាមន្ត្រី (ភ្នំពេញ), បោះពុម្ពលើកទី១និង២, ព.ស.២៥៦០ (គ.ស.២០១៦), ទំព័រ ១៨៥-១៩០។*

[12] *ហ មណីចិន្តា, "មគ្គទេសក៍ជីវិត", អន្ទង់វិល, បោះពុម្ពលើកទី៣, ១៩៩៧, ទំព័រ ៤៣។*

ថា គេអាចសម្រេចបានពុទ្ធិតាមរយៈ **ការគិតពិចារណា** (reasoning) ច្រើនជាងតាមរយៈ**បទពិសោធន៍ឥន្ទ្រិយ**។ អ្នក**វិចារណញ្ញាណនិយម** (rationalists) អះអាងថា **ស្មារតី**មានកម្លាំងអាចយល់ដឹងបានពី**សច្ចភាព**(the truth) ដោយខ្លួនវាពោលគឺ តាមរយៈការប្រើប្រាស់**ទម្រង់ការវិចារណញ្ញាណជាក់លាក់** តែមួយប៉ុណ្ណោះ។ ទម្រង់ការ**វិចារណញ្ញាណនិយម**ធ្វើឱ្យមនុស្សមានលទ្ធភាពអាចទទួលបាននូវ**ពុទ្ធិខ្ពង់ខ្ពស់បំផុតមួយ**ពោលគឺជា**ពុទ្ធិ**ដែលស្ថិតនៅក្នុងកាលៈទេសៈណាក៏មិនចេះខុស។ **ទម្រង់ការវិចារណញ្ញាណនិយម** អះអាងយ៉ាងមុតមាំថា **បទពិសោធន៍ឥន្ទ្រិយ** មិនអាចនាំមកឱ្យមនុស្សនូវ **ពុទ្ធិត្រឹមត្រូវជាច់ខាត**ទៅតាមវិធីណាមួយនោះបានទេ។ នៅទីបំផុតមនុស្សត្រូវតែវិលទៅរក**អំណាចវិចារណញ្ញាណ** (reasoning faculty)របស់គេវិញដោយខានមិនបាន[13]។

**វិចារណញ្ញាណនិយម** បែកចេញទៅជាពីរទម្រង់សំខាន់ៗ គឺ**ទម្រង់វិចារណញ្ញាណនិយមកម្រិតទាប**និង**ទម្រង់វិចារណញ្ញាណនិយមកម្រិតខ្ពស់**។ **ទម្រង់វិចារណញ្ញាណនិយមកម្រិតទាប**បង្រៀនថា **ស្មារតី** មានសមត្ថភាពយល់ដឹងពី **សច្ចភាពជាក់លាក់ផ្សេងៗ** អំពីសាកលលោក ដែលឥន្ទ្រិយរបស់យើងតែម្យ៉ាងមិនអាចផ្តល់ឱ្យបាន។ តែទោះជាយ៉ាងណាក៏ដោយក៏ **ទម្រង់វិចារណញ្ញាណនិយមកម្រិតទាប** នេះទទួលស្គាល់ពីវិភាគទានរបស់ឥន្ទ្រិយ ដូចជា ចក្ខុ,សោត,ឃាន,ជីវ្ហា,និងកាយវិញ្ញាណជាដើម ក្នុងការជួយឱ្យយើងសម្រេចបាននូវពុទ្ធិនេះផងដែរ។ ឥន្ទ្រិយ និងបទពិសោធន៍ផ្សេងៗរបស់យើងបានរៀបចំឡើងដោយ**ស្មារតី**ឱ្យទៅជាប្រព័ន្ធខ្ទឹមសារមួយមុន ពេលវាក្លាយទៅជាពុទ្ធិដែលស្ថិតនៅក្នុង**ទម្រង់បញ្ញត្តិ** (forms of concepts),**គោលការណ៍** (principles) និង**ច្បាប់** (laws)។ **ទម្រង់វិចារណញ្ញាណនិយមកម្រិតខ្ពស់** ជាទម្រង់ដែលមើលស្រាលលើ**វិភាគទាននៃបទពិសោធន៍ ឥន្ទ្រិយ** ក្នុងការសម្រេចបានពុទ្ធិ។ ទម្រង់នេះអះអាងថា មនុស្សមានលទ្ធភាពអាចចាប់យក **ពុទ្ធិគ្មានទីបញ្ចប់** (unquestionable knowledge) បានដោយគ្មាន**ជំនួយពីបទពិសោធន៍ឥន្ទ្រិយ**ឡើយ។ ទម្រង់នេះជម្រុញយើងឱ្យជំនួស **ការគិតពិចារណាអនុមានញែក** (deductive reasoning) របស់យើងដោយ **ការពិនិត្យសង្កេតខាងពិសោធន៍** (empirical observation) វិញ។ ការដែលធ្វើបែបនេះ យើងអាច «ឈានទៅទទួលយកប្រព័ន្ធមួយដែលមាន **ភាពស៊ីសង្វាក់តក្កវិជ្ជា** (logical consistency) ក៏ប៉ុន្តែ វាមានចំណងទាក់ទងតិចតួចទៅនឹងពិភពដែលយើងរស់នៅៗក្នុងនោះ»[14]។

---

[13] Richard H. Popkin and Avrum Stroll, *Philosophy Made Simple.* New York: Doubleday and Co., Inc., 1967, pp. 128-129.

[14] Venancio B. Ardales, "*Introductory text to philosophy,*" 2nd printing, New York, 1974 p. 57

ការគិតពិចារណា ឬការវែកញែកហេតុផល គឺជាសមត្ថភាពរបស់មនុស្សដែលជាគុណជាតុ (attribute) តែមួយគត់របស់គេ ដែលរៀបចំខ្លួនគេឱ្យដាច់ដោយឡែកពីសត្វមានជីវិតដទៃៗ នៅក្នុង**ការស្គាល់** (knowing) និង**ការវិនិច្ឆ័យ** (judging) មនុស្សបានបង្ហាញពីសមត្ថភាពរបស់ខ្លួនចំពោះ «ច្បាប់កែប្រែមិនបាន (inexorable law) និងភាពមិនប្រែប្រួល នៃវិស័យរូបធាតុ (rigi-dity of the realm of matter)»។ ចំពោះ **ផ្លេចូ វិចារណញ្ញាណ** ជាផ្នែកព្រលឹងជាន់ខ្ពស់បំផុត។ វា **ឯករាជ្យ** និង **អមតៈ** ហើយវា[15]គឺជា **សម្បទានតែមួយគត់** ដែលជួយឱ្យមនុស្សមានលទ្ធភាពអាចជ្រៀតចូលជ្រៅទៅក្នុង**ធម្មជាតិរបស់វត្ថុនានា** (the very nature of things) បាន។ **អ៊ែរីស្តូថឺល** យល់ស្របគំនិតផ្លេចូចំពោះ **វិចារណញ្ញាណភាព** (rationality) នេះ ដោយលោកបន្ថែមថា វាគឺជា**សម្បត្តិដ៏មានតម្លៃ** (valued possession) របស់មនុស្សដែលធ្វើឱ្យពួកគេខុសប្លែកពីទម្រង់ សត្វដទៃទៀត។ អ្នកគាំទ្រចំពោះទស្សនៈវិចារណញ្ញាណនេះអះអាងថា «មនុស្សត្រូវបានគេយល់ជាចម្បងមកពី **ទស្សនៈធម្មជាតិ** *(the viewpoint of the nature)* និង *លក្ខណៈពិសេសនៃកម្លាំងវិចារណញ្ញាណ* (*uniqueness* of rational powers) របស់គេ។ ស្មារតី (mind) គឺជាគោលការណ៍រួមដែលខុសប្លែកពីរូបកាយ។» រ៉ូប៊ីនសុន (Robinson) ពោលថា៖ «គេចាត់ទុកស្មារតីថា ជារបស់និងជាឧបករណ៍ពិសិដ្ឋ (chief glory) របស់មនុស្សដែលធ្វើឱ្យមនុស្សមានលទ្ធភាពអាចដោះស្រាយចម្ងល់អរិយធម៌ (the wonders of civili-zation) សព្វយ៉ាងបាន។ គេអាចពិចារណារកហេតុផលដែលសត្វដទៃទៀតមិនអាចធ្វើបានដោយហេតុដូច្នេះហើយ ទើបបានជាមនុស្សបង្កើត សាសនា, សិល្បៈ, ស្ថាប័ន, កាសា**ប្រព័ន្ធ**ទស្សនវិជ្ជា, និងទេវវិទ្យាដ៏មហិមាជច្រើនឡើង, ទទួលបានពុទ្ធិអំពីពិភពលោកនិង ភាវៈដទៃៗទៀត (inhabitants) ហើយនិងអាចស្វែងរកការបង្កើតថ្មីៗជាច្រើនដើម្បីចិញ្ចឹមជីវិត ដូចជា៖ ស្លៀកពាក់, ការការពារ, ការតុបតែងហើយ និងដើម្បីធ្វើឱ្យខ្លួនគេសប្បាយរីករាយទៅតាមបែបដែលគេមិន ធ្លាប់ស្គាល់ចំពោះបុព្វបុរស ដែលមានអារ្យធម៌អនថយ(savage ancestors) របស់ពួកគេ។ ហេតុដូច្នេះ ស្មារតីមានលក្ខណៈអស្ចារ្យ និងសំខាន់ក្រៃលែង។[16]»

**រ៉ូប៊ីនសុន** បន្ថែមថា **ស្មារតីរបស់មនុស្សបានវិវត្តន៍ទៅកាន់កម្រិតខ្ពស់បន្តិចម្តងៗ ជាងស្មារតីរបស់មនុស្សមុនៗ និងប្រកបដោយការរីកចម្រើនមិនទៀងទាត់។** ហេតុដូច្នេះ **ដំណើរខួរក្បាល** (mental processes) គឺជាជាតុសំខាន់នៅក្នុង**អរិយធម៌** ហើយ**វិចារណញ្ញាណ**

---

[15] Venancio B. Ardales, "*Introductory text to philosophy,*" 2nd printing, New York, 1974 p. 38

[16] James Harvey Robinson, "*Characteristics of Early Man,*" in Hoople and Others, *op. cit.*, p. 30

គឺជាមោទនភាព (the pride) និងជាភាពអស្ចារ្យ (glory) របស់មនុស្ស។

ចំពោះ **សក្រឹធីហ្ស** (Socrates), **ផ្លេតូ** (Plato) និង សាវ័ករបស់ពួកលោក **បញ្ញា** (intelligence) គឺជា**មូលដ្ឋានគ្រឹះនៃគុណធម៌របស់មនុស្ស**។ ការស្គាល់ពីអ្វីដែលត្រឹមត្រូវ គឺនៅមិនទាន់ គ្រប់គ្រាន់ទេ ប៉ុន្តែគេត្រូវអនុវត្តវាទៀត ទើបគ្រប់គ្រាន់។ **អវិជ្ជា** (ignorance) ផ្តល់ឱ្យមាន **បាប ធម៌** (vice)។ ចំពោះទស្សនវិទូទាំងនេះ **គោលដៅនៃការខិតខំរបស់មនុស្ស និង អត្ថន័យនៃការរីកចម្រើន** «***គឺជាអភិវឌ្ឍន៍មុខងារ** (functions) **និង សមត្ថភាព** (capabilities) **របស់មនុស្ស ដោយរលូនតាមរយៈបរមានុភាព** (supremacy) **និងសុក្រិតភាពនៃវិចារណញ្ញាណដែលមាននៅក្នុង មនុស្សនិងសង្គម**។*[17]»

**ខាងក្រោមនេះគឺជា**លក្ខណៈខុសប្លែកដទៃទៀតរបស់មនុស្សចំពោះសត្វដទៃ៖

បើទោះជាអ្នកវិទ្យាសាស្ត្រភាគច្រើនបានចាត់ទុក **មនុស្សជាផ្នែកមួយនៃលំដាប់ធម្មជាតិ ដែលមានរូប** ក៏ដោយ ក៏មនុស្សមានការខុសប្លែកគ្នានៅក្នុងលក្ខណៈដែលថា ពួកគេមានជីវិត ដែលធ្វើឱ្យខ្លួនគេខុសប្លែកពីសត្វមានជីវិតដទៃៗទៀតដែរ ហើយមនុស្សនេះឯងមាន**កម្លាំងវិចារណញ្ញាណ** (reason power) ដែលរៀបចំខ្លួនគេឱ្យខុសប្លែកពីប្រភេទវត្ថុគ្មានជីវិតដទៃហើយពួកគេមានសមត្ថភាពពិចារណា ដែលរៀបចំខ្លួនគេឱ្យខ្ពស់ជាងសត្វដទៃទៀត។

លក្ខណៈផ្សេងទៀតដែលធ្វើឱ្យមនុស្សខុសពីទម្រង់សត្វខ្ពស់ៗដទៃទៀតនោះគឺ **លក្ខណៈសង្គម** (social), **វប្បធម៌** (cultural) និង **បញ្ញា** (intellectual)។ បើតាមរូបសាស្ត្រ ឥរិយាបថ របស់មនុស្សគឺឈរត្រង់ដែលអាចជួយឱ្យគេប្រើដៃទាំងពីរបានដោយសេរី និងដោយប៉ិនប្រសប់នៅក្នុងការធ្វើការងារនានា[18]។ មនុស្សមានម្រាមដៃដាច់ៗនិងមានមេដៃអាចចាប់កាន់ ដែលធ្វើឱ្យគេមានលទ្ធភាពអាចចាប់កាន់វត្ថុនានាបាន។ មនុស្សមានដៃដែលអាច បត់បាន ដោយសេរី។ **សម្បទានពីធម្មជាតិ** (endowment) ដ៏មានតម្លៃបំផុតរបស់មនុស្សគឺមានខួរក្បាលនិងក្បាលធំ ហើយនិងប្រព័ន្ធសសៃប្រសាទសាំញ៉ាំ និងមានការរៀបចំ យ៉ាង ខ្ពស់។ សម្ប ចេះផ្លាស់ប្តូរ និងមានឥរិយាបថប៉ិនប្រសប់។

នៅក្នុង **លក្ខណៈវប្បធម៌**, **សង្គម**, និង **បញ្ញា** មនុស្សមានលក្ខណៈប្លែកៗជាច្រើនទៀតដូចតទៅ៖

១- មនុស្សចេះប្រើភាសាសំណើ (a propositional language) ចេះបង្កើតឃ្លា,ប្រយោគ ហើយនិងចេះសន្ទនា

[17] Venancio B. Ardales, *"Introductory text to philosophy,"* 2nd printing, New York, 1974 p. 39

[18] Venancio B. Ardales, *"Introductory text to philosophy,"* 2nd printing, New York, 1974 p.40

គ្នា។

៣- មនុស្សគឺជាសត្វសង្គម ២- មានតែមនុស្សទេដែលចេះច្នៃប្រឌិត (inventive) ចេះបង្កើតឧបករណ៍ប្រើប្រាស់ និង ចេះបង្កើតម៉ាស៊ីន។ និងនយោបាយ (a social and political creature) ដែលចេះធ្វើច្បាប់ ចេះបង្កើតច្បាប់ទូន្មានខ្លួន (rules of conduct) ចេះសហប្រតិបត្តិការ គ្នានៅក្នុងក្រុមធំៗ។

៤- មានតែមនុស្សប៉ុណ្ណោះដែលមានការយល់ដឹងពីប្រវត្តិសាស្ត្រ និងមានប្រពៃណីវប្បធម៌ចម្រើន។

៥- មនុស្សចេះវាយតម្លៃសោភ័ណវិជ្ជា (aesthetic appreciation) ចេះបង្កើតសោភ័ណភាព និងចេះរីករាយនឹងសោភ័ណនោះ។

៦- មនុស្សស្គាល់ខុស,ស្គាល់ត្រូវ (sense of right and wrong) និងស្គាល់តម្លៃគេជាសត្វមានសីលធម៌និងមានមនសិការសីលធម៌ (ethical creature with a moral conscience)។

៧- មនុស្សគឺជាភាវៈមានសាសនា (religious being) ក្នុងន័យថា គេគោរពបូជា និង ចូលរួមប្រតិបត្តិពិធីបុណ្យ[19]។

សរុបសេចក្តីមក វិចារណជំនឿ ជាជំនឿសុក្រិត ដែលទាំងអ្នកវិទ្យាសាស្ត្រនិងទស្សនវិទូជឿ ទុកចិត្តគ្រប់កាលៈទេសៈ នៅក្នុងការស្វែងរកសច្ចភាពនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ នៅមាន (ត)

[19] Venancio B. Ardales, "*Introductory text to philosophy,*" 2nd printing, New York, 1974 p. 41

# **គន្ថនិទ្ទេស**


1. *ឆយ យីហ៊ាង»វចនានុក្រមខ្មែរ រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ២០០៨។*
2. *ឆយ យីហ៊ាង, «ប្រវត្តិទស្សនវិជ្ជាបស្ចឹមប្រទេស, ប្រវត្តិទស្សនវិជ្ជាបូរាណសម័យក្រិក», សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ១៩៩៤។*
3. *ជួនណាត វចនានុក្រមខ្មែរ រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ២០០៨។*
4. *ញ៉ែម គឹមតេង "ផ្លូវកណ្ដាល", វត្តមហាមន្ត្រី (ភ្នំពេញ), បោះពុម្ពលើកទី១និង២, ព.ស.២៥៦០ (គ.ស.២០១៦)។*
5. *ហ មណីចិន្ដា, "មគ្គុទេសក៏ជីវិត", អន្ទង់វិល, បោះពុម្ពលើកទី៣, ១៩៩៧។*
6. Cambridge Advanced Learner's Dictionary, 3rd ed.
7. Kant, Lectures on Logic in Nicholas Bunnin And Jiyuan Yu, *The Blackwell Dictionary of Western Philosophy*, USA, First published, 2004.
8. Nicholas Bunnin And Jiyuan Yu, *The Blackwell Dictionary of Western Philosophy*, USA, First published, 2004.
9. Richard H. Popkin and Avrum Stroll, *Philosophy Made Simple.* New York: Doubleday and Co., Inc., 1967.
10. Venancio B. Ardales, "*Introductory text to philosophy,*" 2nd printing, New York, 1974.

# អំពីជំនឿខ្មែរ

**(ភាគ ២)**

*ដោយ ៖ បណ្ឌិត* **ភ្លាន់ ធុល**

*មន្ត្រីនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា,*

*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសង្គម,*

*រាជបណ្ឌិត្យសភាកម្ពុជា*

**២.២.អបិយជំនឿ**

*ជំនឿអរូបិយឬអបិយជំនឿ គឺជាជំនឿឥតរូប,មានតែជំនឿមានឈ្មោះ ឬពាក្យហៅ ប៉ុន្តែឥតរូបទេ។ អបិយជំនឿដូចគ្នានឹងពាក្យអរូបធម៌ឬនាមធម៌ (អ្វីៗដែលមានតែនាមឥតរូប),អរូបនាម(នាមសព្ទដែលឥតរូប ដូចជា ចិត្ត,វិញ្ញាណ,វេទនា,សញ្ញា,សភាព,សេចក្ដី,បំណង,បំណងជាដើម)អរូបព្រហ្ម(ព្រហ្មឥតរូប),អរូបភព (លោកជាទីនៅនៃអរូបព្រហ្ម)ដែរ។*

*ធម្មជាតិមានទិដ្ឋភាពពីរបែប។ មួយបែបជាទិដ្ឋភាពមានរូបដែលមនុស្សអាចទាក់ទងដោយឥន្ទ្រិយរបស់ពួកគេបាន ដូចជា ការមើលឃើញ,ការយល់ដឹងជាដើម ហើយដែលអាចបង្កបង្កើតបានទៅជាជំនឿរូបី។ ឯទិដ្ឋភាពមួយបែបទៀតជាទិដ្ឋភាពឥតរូប និង មានលក្ខណៈ អាថ៌កំបាំងដែលមនុស្សធម្មតាអាចយល់ដឹងបានហើយនិងអាថ៌កំបាំងដ៏ក្រៃលែងដែលមនុស្សធម្មតាពិបាកនឹងយល់ដឹងបានមានតែមនុស្សដែលមានចំណេះដឹងពិសេសៗប៉ុណ្ណោះ ទើបអាចយល់ដឹងបាន ហើយបានបង្កបង្កើតទៅជាជំនឿអរូបី ឬអបីជំនឿ។ ធម្មជាតិអរូបី ឬអបីជំនឿធម្មជាតិនេះ មានឥទ្ធិពលឬឬទ្ធានុភាពដ៏មហិមាមកលើមនុស្សរហូតដល់ធ្វើឱ្យពួកគេមិនមានលទ្ធភាពគ្រប់គ្រាន់អាចគ្រប់គ្រងតតាំងឬកែប្រែទៅតាមទំនើងចិត្តរបស់ខ្លួនបានឡើយ។ ប្រការនេះនាំឱ្យមនុស្សយល់ដោយស្មានៗថា បាតុភូតធម្មជាតិដែលកើតមានគ្រប់បែបនិងគ្រប់សណ្ឋាន ដូចជា បាតុភូតច័ន្ទគ្រាស-សូរ្យគ្រាស,បាតុភូតរញ្ជួយដី,បន្ទុះភ្នំភ្លើង,ទឹកជំនន់, បាតុភូតផ្គររន្ទះ ជាដើមនេះ គឺពិតជា បណ្ដាលមកពីកម្លាំងអាថ៌កំបាំងដែលបុថុជ្ជនមិនអាចយល់ដឹងបាន។ នេះហើយ គឺជាហេតុដែលធ្វើឱ្យមនុស្សគោរព,កោតខ្លាច,និងស្ញប់ស្ញែង ហើយក៏បង្កើតឱ្យមានការបន់ស្រន់បួងសួងអង្វរលន់តួសុំការសន្ដោស*

ប្រណីពីធម្មជាតិនោះ។ ធម្មជាតិដ៏អាថ៌កំបាំងនិងដ៏អស្ចារ្យនេះមនុស្សឱ្យឈ្មោះថា *អធិធម្មជាតិ*(supernature) ន័យ ទី១ គឺសំដៅ ដល់*អាទិទេព*(God)ឬ*ទេព្តា*/ទេពធីតា (gods) ដែលជាអ្នកបង្កើតធម្មជាតិឡើងរួមទាំងមនុស្សលោកផង;ន័យទី២ សំដៅដល់ព្រលឹងធម្មជាតិដែលជាម្ចាស់ទឹក ម្ចាស់ដី វត្ថុស័ក្តិសិទ្ធ អ្នកសច្ចំបង់បទ, ព្រលឹងបុព្វបុរសដែលក្លាយមកជាអារក្ស អ្នកតា ខ្មោច ព្រាយ បិសាចជាដើម។

អធិធម្មជាតិជាទម្រង់អបិយជំនឿធម្មជាតិឬទម្រង់សាសនាធម្មជាតិ។ អធិធម្មជាតិមានទិដ្ឋភាព៣៖

-ទិដ្ឋភាពទី១ គឺជាអតិសេដ្ឋធម្មជាតិដ៏លើសលុបហួសពីកម្រិតធម្មតានៃពិភពរូប។

-ទិដ្ឋភាពទី២ នៅក្នុងទេវវិទ្យានិងទស្សនវិជ្ជា អធិធម្មជាតិគឺជាដែនអធិធម្មជាតិមួយដែលទៅហួសឬនៅដោយឡែកពីការបង្កើតពិភពនៃពិភពរូប។

-ទិដ្ឋភាពទី៣ អធិធម្មជាតិ គឺជាប្រព័ន្ធអធិធម្មជាតិមួយដែលទៅហួសឬនៅក្រៅពីច្បាប់ធម្មជាតិ។

**២.២.១.ប្រភពអបិយជំនឿ**

*អបិយជំនឿ*មិនមែនជាជំនឿចំពោះខ្លួនឯង (កម្លាំងឬសមត្ថភាពរបស់មនុស្ស)នោះទេ តែជាជំនឿទាំងឡាយដែលពឹងទៅលើ*កម្លាំងក្រៅខ្លួនមនុស្ស*។ នៅក្នុងសង្គមខ្មែរ ជំនឿទាំងឡាយដែលពឹងទៅលើកម្លាំងក្រៅខ្លួនមនុស្សនេះមានប្រភពមកពីបីប្រភេទគឺ ប្រភព**ជំនឿលើ*ព្រលឹង*,** ប្រភពជំនឿលើ*វត្ថុ ដើម សក្តិសិទ្ធ*,និងប្រភព**ជំនឿលើ *អាទិទេព*។**

*ក. ប្រភពជំនឿលើព្រលឹង*

តើពាក្យថា "*ព្រលឹង*" ហើយនិងពាក្យថា"*វិញ្ញាណ*" គឺជាពាក្យតែមួយមានន័យតែមួយ ហើយអាចប្រើជំនួសឱ្យគ្នាបានដែរ ឬទេ?

ពាក្យថា "***ព្រលឹង***"មានន័យថា *ដំណើរជីវិត,ស្មារតី,វិញ្ញាណ*[1]។ចំពោះពាក្យថា"វិញ្ញាណ"វិញមានន័យថាធម្មជាតិដឹងច្បាស់នូវអារម្មណ៍គឺចិត្ត។ ឧ.បាត់វិញ្ញាណ, រលត់វិញ្ញាណ, រលត់ចិត្ត, ភ័យស្លុតខ្លាំងស្ទើរបាត់វិញ្ញាណ,វិញ្ញាណកទ្រព្យ(គោ,ក្របី,ដំរី,សេះ) អវិញ្ញាណកទ្រព្យ (ផ្ទះ)[2]។ នៅត្រង់ចំណុចនេះយើងមានការកត់សម្គាល់មួយថា នៅក្នុងពាក្យ ព្រលឹង មានពាក្យ វិញ្ញាណ ប៉ុន្តែនៅក្នុងពាក្យ វិញ្ញាណ

---

[1] ជួនណាត វចនានុក្រមខ្មែរ រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ,២០០៨,ទំព័រ ព្រលឹង។

[2] ជួនណាត ដ.ឯ.ម. ទំព័រ វិញ្ញាណ។

មិនមានពាក្យព្រលឹងនេះទេ។ នេះបញ្ជាក់ថា វិញ្ញាណមាននៅក្នុងព្រលឹង ប៉ុន្តែព្រលឹងមិនមាននៅក្នុងវិញ្ញាណទេ។ ក្នុងន័យនេះ ព្រលឹងជាអ្នកដំណើរការរូបរាងកាយឱ្យមាន ជីវិត ឯវិញ្ញាណ គឺជាអ្នកធ្វើឱ្យព្រលឹងចេះគិត ចេះពិចារណា មានហេតុមានផលស្គាល់ខុសស្គាល់ត្រូវដែលនាំឱ្យរូបរាងកាយនេះ ក្លាយទៅជាមនុស្សដែលជាសត្វមានវិចារណញ្ញាណ។ វិញ្ញាណនៅត្រង់ចំណុចនេះមានន័យស្មើ ចិត្ត។

បើតាមទស្សនៈទ្វីនិយម (dualism) យល់ថា **មនុស្សផ្សំឡើងពីធាតុមិនប្រែប្រួលពីរ** គឺ **រូបធាតុ** (matter) ឬ **រូបកាយ** (body) និង**វិញ្ញា**(spirit)ឬ**ព្រលឹង** (soul)[3]។ បើយោលទៅតាម **ថូមឹស អឺគ្វៃ ណឹស** [Thomas Aquinas (១២២៥-១២៧៤) ជាទស្សនវិទូ និងជាទេវ វិទូអ៊ី តាលី] បានឱ្យនិយមន័យ **ព្រលឹង** ថាជា "គោលការណ៍ជីវិតដំបូងដែលមាននៅក្នុងវត្ថុនានា ដែលយើងរស់នៅ"[4]។ **ទស្សនៈទ្វីនិយម** ចែកចេញជា ២ប្រភេទ៖ ប្រភេទទី១យល់ឃើញថា មនុស្សផ្សំឡើងដោយ**រូបធាតុ** (matter) និង**វិញ្ញាណ**(spirit)។ ឯប្រភេទទី២ថា មនុស្សផ្សំឡើងដោយ**រូបធាតុ-វិញ្ញា**(matterspirit)។ ប្រភេទទី១ បញ្ជាក់ថា **រូបធាតុ**និង**វិញ្ញាណ** គឺជាអង្គពីរដាច់ដោយឡែកពីគ្នា ប៉ុន្តែវាមានអន្តរកម្មជាមួយគ្នាដោយទៀងទាត់។ ទស្សនៈ នេះមានការគាំទ្រយ៉ាងទូលំទូលាយពី **ថូ មឹសអឺគ្វៃណឹស**[5], **ខាល ជុង** (Carl Jung), **ស៊ិហ្គម៉ាន្ត ហ្វ្រយ**(Sigmund Freud)និងបិចាម៉ិនប.វ៉ុលមែន(Benjamin B.Wol-man)[6]។ ជាអង្គពីរដាច់ដោយឡែកពីគ្នាវាងាយធ្វើឱ្យ**វិញ្ញាណ**មានលទ្ធភាពអាចចាកចេញពី**រូបកាយ**ជាបណ្ដោះអាសន្ននៅពេល**មនុស្សសន្លប់**ឬអាចចាកចេញជារៀងរហូតនៅពេល**មនុស្សស្លាប់**។ ឯប្រភេទទី២វិញយល់ថា **មនុស្ស** កើតឡើងពីបន្សំធាតុពីរ គឺ **រូបធាតុ-វិញ្ញាណ**(matterspirit)ចូលគ្នា។ បើគេបែងចែកពួក វាទាំងពីរឱ្យដាច់ដោយឡែកពីគ្នាពោលគឺ **រូបធាតុ**និង**វិញ្ញាណ**នោះមិនមែន

---

[3] មានសំណេរ ដែលបានកំណត់ពីភាពខុសគ្នារវាងវិញ្ញាណនិងព្រលឹង។នៅទីនេះពាក្យទាំងពីរមានអត្ថន័យដូចគ្នាហើយអាចប្រើជំនួសគ្នាបានទៀតផង។

[4] Thomas Aquinas, "*The Nature of the Soul*," New York, 1967, p. 54

[5] Venancio B. Ardales, "Introductory text to philosophy," 2nd printing, New York, 1974, p 36

[6] Ibit. p.37

ជា**មនុស្ស**ទេ(ព្រលឹង=ខ្មោច;រូបកាយ = សាកសព, ព្រលឹង+រូបកាយ=មនុស្ស)។ **វិញ្ញាណ** នឹងចាកចេញទៅឆ្ងាយហើយអ្វីដែលនៅសល់នោះគឺ **រូបធាតុគ្មានជីវិត** (lifeless matter)។ បើគ្មានរូបកាយទេ វិញ្ញាណក៏គ្មានអត្ថិភាពដែរ ជាពិសេសចំពោះអ្នកទាំងឡាយណាដែលមានជំនឿថា **តថភាព**(reality)ពឹងអាស្រ័យទៅលើ **ការយល់ដឹងរបស់មនុស្ស**។

បើចំពោះគ្រិស្តសាសនិកជនវិញ មិនយល់ស្របតាមទស្សនៈណាមួយខាងលើនេះទេ។ ដោយយកគម្ពីរធ្វើជាមូលដ្ឋាន គ្រិស្តសាសនិកអះអាងថា "**មនុស្ស** គឺជាភាវៈដែលមានធាតុ៣(tripartite being) គឺរូបកាយ(body) ព្រលឹង(soul) និង វិញ្ញាណ (spirit)។ រាងកាយគឺជាផ្នែកខាងក្រៅរបស់មនុស្សដែលគេអាចមើលឃើញ, ស្ដាប់ឮ,កាន់បាន,ភ្លក់និងហិតបាន។តាមរយៈរូបកាយមនុស្សមានលទ្ធភាពអាចទាក់ទងជាមួយនឹងពិភពដែលនៅជុំវិញខ្លួនគេបាន។ ឯព្រលឹងវិញ គឺជាផ្នែកខាងក្នុងរបស់មនុស្សដែលគេមិន អាចមើលឃើញបាន។ ព្រលឹងមាន៣ ផ្នែកស្មារតី(the mind), វេទនារម្មណ៍ (the emotions) និង **ឆន្ទៈ**(the will)។ ជាមួយនឹង**ស្មារតី** មនុស្សអាចជ្រើសរើសអ្វីៗបានទាំងអស់។ **វិញ្ញាណ** គឺជាផ្នែកខាងក្នុងបំផុតរបស់មនុស្សដែលអាចទាក់ទងជាមួយនឹងព្រះជាម្ចាស់បាន។ **វិញ្ញាណ** គឺជាផ្នែកសំខាន់នៃ**ធម្មជាតិរបស់មនុស្ស**(man's nature) ជា **ប្រភពជីវិតមនុស្សភាលរូប។ អាទិទេព**គឺជា**វិញ្ញាណ** ,**មនុស្ស**គឺជា**វិញ្ញាណ** ដូច្នេះ វាសំខាន់ជាង **ពិភពរូបធាតុ**(the material universe)។ **វិញ្ញាណ** គឺជា**ភាវៈអរូបធាតុ**(immaterial being) ដែលគេចផុតពីការធ្វើពិសោធន៍របស់ជីវវិទូនិង គីមីវិទូ។[7]"គំនូសបំព្រួញអំពីទីតាំងនៃរូបកា,ព្រលឹង, និងវិញ្ញាណ




ក.១.ប្រភពជំនឿលើព្រលឹងធម្មជាតិ

ប្រភពជំនឿលើព្រលឹងនៅក្នុងសង្គមខ្មែរ គេអាចសង្កេតឃើញមានពីរប្រភព គឺ ប្រភពជំនឿលើ***ព្រលឹងធម្មជាតិ*** ឬជំនឿលើ ***វិញ្ញាណនិយម***(animism) និងប្រភពជំនឿលើ ***ព្រលឹងបុព្វបុរស***។

ប្រភពជំនឿលើ ***ព្រលឹងធម្មជាតិ***ឬ

[7] Venancio B. Ardales, *"Introductory text to philosophy,"* *op cit*, 1974, p 37

***វិញ្ញាណនិយម*** (animism) គឺជាជំនឿថា វត្ថុ ធម្មជាតិទាំងអស់ដូចជា រុក្ខជាតិ,សត្វ ,ថ្ម,ផ្កាយ និងការរញ្ជួយដីជាដើមសុទ្ធតែ មានវិញ្ញាណ ហើយនិងអាចមានឥទ្ធិពល ទៅលើព្រឹត្តិការណ៍របស់មនុស្សទៀត ផង[៨]។ ជំនឿនេះ ប្រជាជនខ្មែរជឿថា នៅតាមព្រៃភ្នំក្រំថ្ម,កោះ,អូរ,ទន្លេ,បឹងបួរសុទ្ធតែមានអ្នកថែរក្សាដែលពួកគេហៅថា ម្ចាស់ទឹក ម្ចាស់ដី, វត្ថុស័ក្តិសិទ្ធ,អ្នកសច្ចំបង់បទដែលជាអ្នកថែរក្សាឱ្យសេចក្តីសុខ សេចក្តីចម្រើនដល់ពួកគេនៅពេលពួកគេឈប់សុំចតស្នាក់ អាស្រ័យនៅទីណាមួយហើយពួកគេតែង ដុតធូបឬដាក់បាយត្រីឬច្រូចស្រាសែនថ្វាយដល់ម្ចាស់ទឹក ម្ចាស់ដីឬវត្ថុស័ក្តិសិទ្ធទាំងនោះ។ ជំនឿនេះគេនៅតែសង្កេតឃើញប្រជាជនខ្មែរគោរព និងប្រតិបត្តិនៅទូទាំងប្រទេសរហូតមកដល់សព្វថ្ងៃ។

ទាក់ទងទៅនឹងការគោរព និងការដឹង គុណដល់ម្ចាស់ទឹកម្ចាស់ដី ការប្រារព្ធធ្វើ "*ពិធី បុណ្យអុំទូក, បណ្តែតប្រទីប, អកអំបុក សំពះ ព្រះខែ*" នៅខែតុលា វិច្ឆិកា ត្រូវនឹងថ្ងៃ១៤ កើត ១៥កើត និងថ្ងៃ១រោជខែ កត្តិក គឺនៅចំពេលដែលទឹកទន្លេបឹងបួរទាំងឡាយដែលកាលពីរដូវវស្សាបានទទួលទឹកជំនន់មកពីទន្លេមេ គង្គតាមរយៈបឹងទន្លេសាបនោះ បានចាប់ផ្តើមហូរចេញពីព្រែក ទន្លេ បឹងបួរ ទាំងនោះចូលមកបឹងទន្លេសាបហើយហូរចាក់ចូលមកទន្លេមេគង្គពីជើងមកត្បូងវិញ ដើម្បីសម្តែងមនោសញ្ចេតនា ដឹងគុណចំពោះទន្លេមេគង្គនិងទន្លេបឹងបួរនានាដទៃទៀតដែលបាននាំដី ល្បាប់ដ៏មានជីជាតិសម្រាប់ការបង្កបង្កើតផល កសិកម្ម និងធនធានជលផលសម្បូរបែបដទៃទៀតដល់ប្រជាជនកម្ពុជា[៩]។ រូបភាពបង្ហាញពីការគោរព និងការ ដឹងគុណដល់ម្ចាស់ទឹកម្ចាស់ដី



ទិដ្ឋភាពនៃពិធីបុណ្យអុំទូក



ទិដ្ឋភាពនៃពិធីលយប្រទីប

[8] Cambridge Advanced Learner's Dictionary, 3rd ed. p animism

[៩] គង់ សំអុល, "ប្រវត្តិបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក," ព.ស ២៥៤៥ / គ.ស ២០០១, ទំ ព័រ ៣-៤។

ដោយឡែកពីជំនឿលើម្ចាស់ទឹក ម្ចាស់ដីជំនឿលើវត្ថុស័ក្តិសិទ្ធគេអាចសង្កេតឃើញតាមសំណេរប្រវត្តិសាស្ត្ររបស់ស្រាវជ្រាវពិសេសសំណេរប្រវត្តិសាស្ត្ររបស់ ត្រឹង ងា ដែលសរសេរថា "អ្នកស្រុកនៅអាណាចក្រភ្នំចូលចិត្តប្រើវិធីអស្ចារ្យដើម្បីរក**សេចក្តីពិត** (សច្ចភាព)។ កាលណាមានបាត់របស់អ្វីមួយគេក៏យកបាយមួយពំនូតទៅដាក់នៅចំពោះព្រះកក្រ្តទេព្ណា រួចគេអង្វរសុំឱ្យព្រះអង្គជួយបង្ហាញមុខជនទុច្ចរិត។ ស្អែកឡើងគេយកបាយនោះទៅចែកឱ្យពួកខ្ញុំនៅក្នុងផ្ទះដើម្បីបរិភោគ៖ ក្នុងមាត់របស់ចោរនឹងមានឈាមហូរចេញយ៉ាងដាក់ស្តែងហើយវាមិនអាចទំពារបាយផងឯមាត់របស់ជនទៀងត្រង់ បាយនោះអាចរអិលទៅក្នុងមាត់យ៉ាងស្រួល ។ ម្យ៉ាងទៀត បើកាលណាមានជនត្រូវចោទ គេឱ្យជននោះអត់បាយបីថ្ងៃ រួចគេតម្រូវឱ្យលូកយកវត្ថុផ្សេងៗចេញពីទឹកកំពុងពុះ ឬកាន់ពូថៅ ឬប្រវាក់ដុតក្រហមដើរ៧ជំហាន។ បើមានកំហុសមែន ដៃជននោះត្រូវរលាករលួយ ផ្ទុយទៅវិញគឺគ្មានហ្មងអ្វីទាំងអស់[10]។ ជំនឿលើវត្ថុស័ក្តិសិទ្ធ អាចគិតបូកបញ្ចូលមានដូចជា ចែជ្រូកព្រៃ,យ័ន្តគាថា,យ័ន្តក្បាល៤,យ័ន្តក្បាល៨,ការស្លូតមន្តអាគមន៍គាថា, ចាក់ទឹករំដោះគ្រោះ, ស្លូតមន្តរំដោះគ្រោះឧបទ្រពចង្រៃ,បុណ្យបារមីព្រះសិរ្យអាមេត្រិយ, ព្រះពោធិសត្វ,ព្រះបាទធម្មិក,អ្នកមានបុណ្យ ...។ ជំនឿនេះនៅបន្ត មានអត្ថិភាពរហូតមកដល់សព្វថ្ងៃ។ មែនទែនទៅ ជំនឿនេះត្រូវបានប្រជាជនខ្មែរ ទាំងអ្នកប្រកបរបរកស៊ីតូចធំ,ទាំងអ្នកតូចអ្នកធំ អ្នកមាន អ្នកក្រ ពោលដោយខ្លី គឺប្រជាជនគ្រប់លំដាប់ថ្នាក់មានជំនឿគោរពប្រតិបត្តិយ៉ាងមុតមាំណាស់សឹងតែជាងព្រះពុទ្ធសាសនាទៅទៀតផង ថ្វីត្បិតតែព្រះពុទ្ធសាសនាដែលត្រូវបានលើកទៅជាសាសនាផ្លូវការរបស់រដ្ឋក៏ដោយ។

រូបភាពបង្ហាញពីការគោរពបូជាចំពោះវត្ថុសក្តិសិទ្ធ




យ័ន្តគាថាស្នេហ៍ និងយ័ន្តគាថាបន្ទន់ចិត្ត

ប្រភព៖ Internet

10 ត្រឹង ងារ,"ប្រវត្តិសាស្ត្រខ្មែរភាគ១និង២ (សម្រាប់មធ្យម និងឧត្តមសិក្សា),"ភ្នំពេញ, ព.ស.២៥១៧,



ជំនឿលើការដាំស្លឹកគ្រៃបញ្ចាសចុះ ដើម្បីកុំឱ្យ
មេឃភ្លៀងនៅក្នុងពិធីមង្គលការ
នៅភូមិឈើទាល, ឃុំស្ដេចគង់ខាងលិច,
ស្រុកបន្ទាយមាស, ខេត្តកំពត
ប្រភព ៖ អត្ថបទកាសែត ឆ្នាំ២០១០



ជំនឿលើការព្រោះព្រំ
ប្រភព ៖ Internet

ចំណែកឯជំនឿលើអ្នកសច្ចំបង់បទ ពាក្យនេះទំនងជាក្លាយមកពីពាក្យថា "បាំងបាត់"ដ្បិតមានគេនិយាយតំណាលថាទេព្រក្ស ឬអ្នកតាទាំងនោះ ចួនកាលបំបាំងទ្រព្យរបស់មនុស្សណាមួយដែលធ្វើទាស់ខុសឱ្យបាំងបាត់មើលមិនឃើញ, លុះតែអង្វររករបន់ស្រន់ត្រូវទើបឱ្យមើលឃើញវិញ;អ្នកស្រុកខ្លះហៅថាអស់លោក។

ជំនឿដូចបានរៀបរាប់រួចមកខាងលើនេះ បានកើតមានដោយប្រជាជនខ្មែរតាំងពីកកើតទឹកដីមកម្ល៉េះ មានន័យថាតាំងពីមុនព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនាផ្សាយចូលមកទៅទៀត។

ក.២.ប្រភពជំនឿលើព្រលឹងបុព្វបុរស

គួកត់សម្គាល់ថា មនុស្សជាន់ដើមជឿថា **មនុស្សស្លាប់ទៅមិនសូន្យទេគឺមានព្រលឹង**ទៅចាប់ជាតិថ្មីទៀត។ **ពួកខ្មែរលើ**ដែលរស់នៅលើខ្ពង់រាបសព្វថ្ងៃ (១៩៧៣) ក៏នៅមានជំនឿបែបនេះដែរ ពួកនេះចែក**ព្រលឹង**ជា៣ប្រភេទគឺ**ព្រលឹងធំ**ដែលចេញពីខ្លួនមនុស្ស៦ខែ មុនពេលស្លាប់ ឯ**ព្រលឹងតូច** ចេញទៅនៅពេលស្លាប់ និង **ព្រលឹងខ្លះទៀត** ស្លាប់៦ខែហើយទើបព្រមចេញ។ ដល់កាលណាមនុស្សស្លាប់ទៅគេយក**សាកសព**ទៅកប់ ហើយគេយកគ្រឿងប្រដាប់ដែលបុគ្គលនោះ ធ្លាប់ប្រើទៅកប់ជាមួយដែរ ដើម្បីទុកឱ្យប្រើប្រាស់តទៅទៀត។ ខ្មែរយើងសម័យឥឡូវ(១៩៧៣) បើកាលណាមានមនុស្សស្លាប់ គេតែងរៀប**គ្រឿង បន្ទង់** (សព្វថ្ងៃក៏មានដែរ) ប្រគេនចំពោះព្រះ សង្ឃដើម្បីបញ្ជូនឱ្យ**អ្នកស្លាប់**នោះដែរ។ ជំនឿដែលថា **មនុស្សស្លាប់ទៅ**មិនសូន្យនេះបានក្លាយមកជា ***អារក្ស-***

ជំនឿលើ **អ្នកតាចាស់ស្រុក** គឺជាជំនឿលើព្រលឹងបុព្វបុរសដែលបានចែកឋានទៅហើយ ក៏បានក្លាយទៅជា **អ្នកតា** សម្រាប់ថែរក្សាកូនចៅនៅតាមស្រុកភូមិៗ ក្នុងជំនឿរបស់ខ្មែរយើង **អ្នកតា** គឺជាអង្គមួយស័ក្តិសិទ្ធិឬក៏ជាបារមីមួយពិសិដ្ឋ មានឫទ្ធានុភាពយ៉ាងខ្លាំងក្លាបំផុតសម្រាប់ថែរក្សាភូមិស្រុក ឬទឹកដីណាមួយដូចជា ***អ្នកតាក្រហមក*** នៅលើភ្នំសន្ទុកនៃខេត្តកំពង់ធំ ***អ្នកតាឃ្លាំងមឿង*** នៅខេត្តពោធិសាត់ ***លោកតាឌី*** នៅប្រាសាទព្រះវិហារ ***លោកតាដំបងក្រញូង*** នៅខេត្តបាត់ដំបង **លោកយាយម៉ៅឬដូនម៉ៅ** នៅភ្នំពេជ្រនិលជាដើម។ អ្នកតាមានឋានៈមិនស្មើគ្នាទេ គេបានបែងចែកអ្នកតាតាមជាន់តាមថ្នាក់ ពោលគឺមានតូចមានធំតាមលំដាប់លំដោយហើយ នៅរាយគ្នាពាសពេញភូមិសាស្ត្រទឹកដីនៃប្រទេសកម្ពុជា។ **ព្រលឹង** ដែលនៅក្នុងផ្ទះច្រើនហៅថា **ជំនាងផ្ទះ**, នៅក្នុងភូមិហៅថា **ព្រះភូមិ**, នៅប្រចាំតំបន់ហៅថា **អ្នកតា**,នៅតាម**ដើមឈើ** ក្នុងព្រៃឬនៅតាមទីកប់ដុតសពហៅថា **ខ្មោចព្រាយ** ឬ **បិសាច**, នៅតាមបឹងបួរ ឬទន្លេហៅថា **អារក្សទឹកឬជើងកប**,នៅប្រចាំ ***អ្នកតា*** (បើស្រីហៅថា **អ្នក ដូន**)នេះឯង (ជំនឿលើខ្មោច។ ***អ្នកតា***ជា ព្រលឹងនៃជនដែលស្លាប់ទៅហើយ តែនៅថែរក្សាមើលសុខទុក្ខដល់កូនចៅតទៅទៀត។ ខ្មែរយើងសព្វថ្ងៃនៅមានជំនឿលើអ្នកតាច្រើននៅឡើយ ជាពិសេសក្នុងចំណោមអ្នកស្រែចំការ៖ **ខ្ទមអ្នកតា** គេឃើញមានពាសពេញភូមិស្រុក ហើយ ***ពិធីសែនឡើងអ្នកតា*** ក៏គេប្រារព្ធធ្វើរៀងរាល់ឆ្នាំដែរ។ ពួកខ្មែរលើ ក៏មានជំនឿដូច គ្នានេះដែរ ហើយគេហៅ***អ្នកតា***ថា "***ព្រះ***"ដូច្នេះ យើងឃើញថា **ពួកអ្នកស្រុកអាយ** មានទម្លាប់គោរពបូជា ***ដូនតា*** នេះស្រេចទៅហើយនៅមុនពេល***ឥណ្ឌា*** ផ្សាយចូលមកដល់។ លុះ ***លទ្ធិពុទ្ធសាសនា*** ត្រូវផ្សាយចូលមកជំនឿដែលចាត់ទុកថា ***មនុស្សស្លាប់ទៅមិនសូន្យ*** ព្រោះមាន***វិញ្ញាណ*** ទៅកើត ជារូបថ្មីទៀត ក៏មានលក្ខណៈប្រហាក់ប្រហែលនឹង **ជំនឿរបស់ អ្នកស្រុកអាយ** (**ព្រលឹង** និង **វិញ្ញាណ** មិនដូចគ្នាបេះបិទទេ) ហើយក៏បានពួកនេះទទួលយកទៅ។ សព្វថ្ងៃនេះ **បុណ្យភ្ជុំបិណ្ឌ** គឺជាបុណ្យសំយោគរវាង **ជំនឿអ្នកស្រុក អាយនិងជំនឿ**តាមបែបពុទ្ធ***សាសនា***[11]។

---

[11] *ត្រឹង ងា, "ប្រវត្តិសាស្ត្រខ្មែរ (សម្រាប់មធ្យម និងឧត្តមសិក្សា)" ភ្នំពេញ, ១៩៧៣, ទំព័រ ៤២-៤៣*

ត្រកូលគ្រួសារនីមួយៗហៅថា **អារក្ស**, ព្រលឹងនៅតាមទីវត្តអារាម ហៅថា**ខ្មោច** ក៏មានហៅថា **បារមី** ក៏មានឬជួនកាលហៅថា **អាគ្រក់** (អាគ្រៈ) ក៏មានតែបច្ចុប្បន្ននេះ ខ្មោចអាគ្រក់ នេះដូចជាមិនសូវឮទៀតទេ, ព្រលឹងនៅតាមហាងជួយឱ្យមានភ្ញៀវច្រើននៅតាមហាងហៅថា នាងបក់នាងបោយ។ ប្រពៃណីគោរព**ព្រលឹង**របស់ខ្មែរមានតាំងពីយូរយារណាស់មកហើយ គឺ**តាំងពីមុនឥណ្ឌាចូលស្រុក**[12]។ **ជំនឿអ្នកតាចាស់ស្រុក**គឺជាមូលដ្ឋាននៃ***ជំនឿសាសនា***និង***អរិយធម៌*** ខ្មែរយើង[13]។

ទំនាក់ទំនងរវាង *ព្រលឹង* ហើយ និង *មនុស្ស* គឺជាជំនឿដ៏មានឥទ្ធិពលមួយរបស់ខ្មែរតាំងពីបុរាណរហូតមកដល់បច្ចុប្បន្ន។ ***រូបកាយ***និង***ព្រលឹង*** **គឺជាអង្គពីរដាច់ដោយឡែកពីគ្នា។ រូបកាយមានលក្ខណៈរូបីឯព្រលឹងមានលក្ខណៈអរូបី** ប៉ុន្តែពួកវាមានអន្តរទំនាក់ទំនងឬអន្តរកម្មយ៉ាងជិតស្និទ្ធជាមួយគ្នា។ នៅពេលមនុស្សកំពុងមានជីវិតរស់នៅមានន័យថា ព្រលឹងកំពុងមានអត្ថិភាពនៅក្នុងរូបកាយរបស់មនុស្ស។ វាធ្វើឱ្យមនុស្សចេះគិតស្គាល់ខុសស្គាល់ត្រូវ មានទំនួលខុសត្រូវនូវរាល់អំពើដែលខ្លួនបានធ្វើនិងធ្វើឱ្យមនុស្សចេះបង្កើតវិទ្យាសាស្ត្រនានា។ នៅពេលមនុស្សអស់ជីវិតទៅ(ស្លាប់)មានន័យថាព្រលឹងលែងមានអត្ថិភាពនៅក្នុងរូបកាយមនុស្សតទៅទៀតហើយ។ ពេលនោះរូបកាយក្លាយជា *សាកសព* ឯព្រលឹងក្លាយជា *ខ្មោច* គឺពួកវាលែងមានអន្តរទំនាក់ទំនងឬអន្តរកម្មជាមួយគ្នានិងលែងចេះគិតលែងស្គាល់ខុសស្គាល់ត្រូវតទៅទៀតហើយ។ រូបកាយរលាយចូលទៅក្នុងបរិយាកាសក្លាយជាទឹក ជាដី ជាភ្លើង និងជាខ្យល់ ឯព្រលឹង បើតាមជំនឿខ្មែរមិនបានបាត់បង់ឡើយ គឺនៅមានអត្ថិភាពតទៅទៀត អាចបន្តនៅក្នុងធម្មជាតិឬចុះនរកឬឡើងឋានសួគ៌ តាមកម្លាំងកម្មដែលខ្លួនបានសាងកាលពីនៅរស់។ ជំនឿដែលថាមនុស្សស្លាប់ទៅ *ព្រលឹងមិនសូន្យ* នេះបានបង្កើតឱ្យមានជំនឿ, ការបន់ស្រន់, និងការធ្វើពិធីបុណ្យនានាដើម្បីឧទ្ទិសដល់ព្រលឹងអ្នកដែលស្លាប់ទៅនោះ។

ប្រជាជនខ្មែរបានបន្តជំនឿគោរពព្រលឹងបួងសួងព្រលឹង ថ្វាយដង្វាយឬ

---

[12] *យិន គឹមវាណ "ព្រលឹងវប្បធម៌ជាតិ", រោងពុម្ពវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត, ២០០៣, ទំព័រ២១-២៦។*

[13] *មីសែល ត្រាណេ, "ប្រព័ន្ធគំនិតខ្មែរ", សម្ព័ន្ធនិស្សិតខ្មែរពីបរទេស,១៩៩៨, ទំព័រ១១១-១១២។*

សូត្រធម៌ឧទ្ទិសឱ្យ**ព្រលឹង** ដោយរៀបចំជាវិធី តូចធំរួមទាំងចំណាយទ្រព្យធនហូបចុក ជប់លៀង ក៏សន្មតហៅថា **ការធ្វើបុណ្យ** ដែលមានទម្រង់ការទូទៅតែមួយប្រភេទបែបនេះ។ ជាពិសេស**ព្រលឹងអ្នកតា**នៅតែមានតួនាទីយ៉ាងសំខាន់រហូតមកដល់បច្ចុប្បន្ននៅក្នុងពិធីការជាច្រើនមានពិធី **សុំ ទឹកភ្លៀង** ឬ**បញ្ឈៀសភ្លៀង,ពិធីសុំបញ្ឈៀសជម្ងឺតំកាត់ឬរោគរាតត្បាតផ្សេងៗកុំឱ្យចូលមកក្នុង**ភូមិស្រុក,ការបន់ស្រន់សុំជាសាក្សីចំពោះការសន្យាណាមួយ, ពិធីសច្ចាប្រណិធានមុនចូលកាន់មុខតំណែងនៃរដ្ឋសភា, ពិធីសច្ចាប្រណិធានឬ**សម្បថរបស់គូក្តីនៅពេលកាត់សេចក្តីរកយុត្តិធម៌នៅសាលាដំបូង** ឬនៅទីណាមួយក្រៅតុលា, **ពិធីផឹកទឹកសម្បថ**, **បុណ្យសពនៅពេលស្លាប់ បុណ្យសព៧ថ្ងៃឬ១០០ថ្ងៃ**, **មេបាចាស់ទុំកាច់** កាលណាកូនចៅដែលជាសាច់សាលោហិតប្រព្រឹត្តខុសគន្លងប្រពៃណីទំនៀមទម្លាប់ដូនតាពីបុរាណ ដូចជាការលួចមានសាហាយស្មន់ឬកូនក្រមុំកូនកំលោះលួចស្រលាញ់គ្នាដោយមិនបានប្រាប់ដូនតាឱ្យបានដឹងឬដោយមិនបានរៀបការជាមុន ឬដោយកូនចៅឈ្លោះខឹងសម្បាតមមាត់មិននិយាយស្តីគ្នាជាដើមនឹងត្រូវ**មេបាចាស់ទុំកាច់**។ ហេតុនេះគេត្រូវរៀបចំ **ពិធីបូលពងមាន់** ដើម្បីស្វែងរកអ្នកប្រព្រឹត្តខុសគន្លងហើយនិយាយអង្វករដល់ដូនតាដោយសន្យានឹងរៀបចំឱ្យបានត្រឹមត្រូវទៅតាមគន្លងប្រពៃណីវិញ។ ធ្វើដូច្នេះទើបដូនតាឈប់ខឹងសម្បាទៀត។ កិច្ចសន្យានេះ គេត្រូវតែធ្វើដោយមិនអាចបំភ្លេចបានជាដាច់ខាត បើមិនដូច្នេះទេ**ចាស់ទុំ** នឹងកាច់ករអ្នកណាមួយឱ្យស្លាប់ជាមិនខាន។

ពិនិត្យជារួមការប្រតិបត្តិរបស់ប្រជាជនខ្មែរទៅតាម**ជំនឿដើមរបស់ខ្លួន**ដែលមានដឹតដាមរហូតមកដល់បច្ចុប្បន្នមិនមានចំណុចអវិជ្ជមានណាមួយដែលជម្រុញឱ្យមានអំពើខុសឆ្គង ឬការបន្ទាប**តំលៃមនុស្ស**ក្នុងសង្គមនោះឡើយ។ ផ្ទុយទៅវិញ ការប្រតិបត្តិទាំងឡាយទាំងពួងតាមជំនឿដើមនេះបង្ហាញឱ្យឃើញពីកក្តីភាពការគោរពប្រតិបត្តិការគោរពបូជា និងកតញ្ញូតាធម៌របស់កូនចៅជំនាន់ក្រោយៗចំពោះបុព្វបុរសរបស់ខ្លួន។ ពិសេសតាមរយៈការប្រតិបត្តិទាំងនេះការជួបជុំគ្នា កាប្តូរយោបល់គ្នា ការពួតដៃគ្នាជាផ្ទុងមួយបានកើតមានឡើង។

ជំនឿលើព្រលឹងដូនតា គឺជាជំនឿលើទំនាក់ទំនងរវាង ព្រលឹងអ្នកស្លាប់និងនៅរស់ ដែលនៅតែបន្តមានអន្តរកម្មជា

មួយគ្នាយ៉ាងសកម្មនៅក្នុងជីវភាពរស់នៅរបស់អ្នកនៅរស់។ អ្នកនៅរស់អាចសុំឬអង្វករសុំឱ្យព្រលឹងអ្នកស្លាប់នៅតាមជួយថែរក្សា និងជួយឱ្យពួកគេរកស៊ីមានបានដោយការបន់ស្រន់ឬសែនព្រេនឬថ្វាយតង្វាយមានផ្លែចេកផ្លែឈើ មាន់ស្ងោរទាឬជ្រូកខ្វៃជាដើម ដោយពួកគេជឿជាក់ថា ព្រលឹងទាំងនោះនឹងតាមថែរក្សាពួកគេពីគ្រោះភ័យន្តរាយទាំងឡាយបានហើយ បើទោះជាមិនមានកស្តុតាងច្បាស់លាស់ក៏ដោយនិងជួយឱ្យពួកគេមានសិរីសួស្តីរកស៊ីមានបាន។ ហេតុដូច្នេះ ហើយបានជាគេប្រទះឃើញមានខ្ទម អ្នកតាពនព្រះភូមិ អាសនៈជំនាងផ្ទះ ហើយ និងការបន់ស្រន់នោះដូចជាការរៀបអាសនៈ និងការសែនជំនាងផ្ទះរៀងរាល់ថ្ងៃសីលខ្ទមព្រះភូមិហើយនិងការសែនព្រះភូមិ នាងបក់នាងបោយសែនផ្នូរ(ខ្មែរកាត់ចិន)សែនកុងម៉ាហើយនិងការដុតធូបផ្សេងៗ។

ជំនឿលើព្រលឹងដូនតាគឺជាទម្រង់សាសនាដើមមួយរបស់ខ្មែរ។ វាជាទម្រង់គំនិតមួយជាវប្បធម៌មួយ និងជាប្រពៃណីទំនៀមទម្លាប់មួយរបស់ខ្មែរ ដែលបង្ហាញនូវការគោរពការដឹងគុណចំពោះអ្នកស្លាប់។ *វប្បធម៌គោរព* និង *វប្បធម៌ដឹងគុណនេះ* មិនមែនធ្វើតែចំពោះអ្នកនៅរស់នោះទេ តែក៏ធ្វើចំពោះបងប្អូន ឪពុកម្តាយ មាមីងជីដូចជីតា ញាតិការទាំង៧សន្តានដែលបានចែកឋានទៅហើយនោះផងដែរ។ មូលហេតុដែលនាំឱ្យកើតនូវវប្បធម៌ ទាំងនេះ ដោយប្រជាជនខ្មែរយល់ឃើញថាព្រលឹងអ្នកស្លាប់អាចនឹងភ្លាំងភ្លាត់ធ្លាក់ចូលទៅក្នុងអបាយភូមិ មាននរកប្រេតឬកើតទៅជាសត្វតិរច្ឆានណាមួយដោយកម្លាំងនៃអំពើបាបដែលពួកគេបានសាងកាលពីនៅរស់ ហើយដោយទឹកចិត្តអាណិតស្រលាញ់របស់អ្នកនៅរស់ទើបពួកគេធ្វើបុណ្យបាយមួយវែក សណ្តែកមួយក្តួរដើម្បីឧទ្ទិសកុសលផលបុណ្យទៅឱ្យសំដៅដើម្បីឱ្យព្រលឹងអ្នកដែលស្លាប់នោះ មានម្ហូបអាហារបរិភោគនឹងគេ (ជាមួយព្រលឹងដទៃទៀត) ខ្វាចក្រែងមានការខ្វះខាត់ដោយប្រការណាមួយឬមួយដើម្បីជួយយិតយោងព្រលឹងទាំងនោះឱ្យបានទៅសោយសុគតិភពនេះប្រការមួយ។ ប្រការពីរ *វប្បធម៌គោរព* និង *វប្បធម៌ដឹងគុណរបស់ខ្មែរនេះ* បង្ហាញឱ្យឃើញពីគំនិតគោរពចំពោះម្ចាស់ទឹក, ម្ចាស់ដី,អ្នកសច្ចំបងបទ,អារក្សអ្នកតាព្រៃភ្នំដែលជាម្ចាស់ ជាអ្នកថែរក្សាទឹកដី ព្រៃភ្នំ ពីព្រោះចាស់បុរាណខ្មែរយល់ថា ទីឋានណាក៏ដោយ គឺសុទ្ធតែមានអ្នកថែរក្សា ហេតុនេះ

ដើម្បីបានសេចក្ដីសុខពួកគាត់ត្រូវសុំការអនុញ្ញាតកន្លែងទឹកដីព្រៃភ្នំជ្រកកោនឬស្ នាក់អាស្រ័យមួយរយៈមុននឹងបន្តដំណើរទៅមុខទៀតរួចហើយពួកគាត់ក៏ដាក់ដង្វាយមានបាយម្ហូបអាផ្សេងៗឱ្យ។ ប្រការ បីទាក់ទងទៅនឹង *វប្បធម៌គោរព* និង *វប្បធម៌ដឹងគុណ* នេះដែរ នៅតាមទីកន្លែងដែលនាំឱ្យកើតនូវការសាងសង់វត្តអារាមព្រះពុទ្ធសាសនា មិនមែនធ្វើឡើងតាមតែការនឹកឃើញឬតាមតម្រូវការឬតាមចំនួនអត្រាប្រជាជនដូចសព្វថ្ងៃនេះនោះទេ។ ពីបុរាណប្រការដែលនាំឱ្យមានការសាងសង់វត្តអារាមនៅទីណាមួយ គឺមកពីនៅទីកន្លែងនោះ មានការបន់ស្រន់ទៅពូកែសក្ដិសិទ្ធិ។ ទីកន្លែងពូកែសក្ដិសិទ្ធិនោះអាចជាទីកន្លែងដែលមានដើមឈើធំៗដែលមានដំបូកដុះឬប្រុបតាមមាត់ស្ទឹងមាត់ទន្លេលើកោះ ឬទីកន្លែងដែលមានប្រាសាទបុរាណនៅក្នុងជំនឿព្រហ្មញ្ញសាសនា...គឺទីកន្លែងពូកែសក្ដិសិទ្ធិទាំងនោះហើយដែលនាំឱ្យកើតនូវការសាងសង់វត្តអារាមព្រះពុទ្ធសាសនា។ *គួរកត់សម្គាល់ផងដែរថា នៅពេល* ទីកន្លែងពូកែសក្ដិសិទ្ធិទាំងនោះត្រូវបានជ្រើសរើសធ្វើជាទីកន្លែងវត្តអារាមព្រះពុទ្ធសាសនា ម្ចាស់ទឹក ម្ចាស់ដី អារក្សអ្នកតាដែលជាអ្នកថែរក្សាទឹក ដី ព្រៃ ភ្នំដើមនៅទីនោះមិនត្រូវបានគេបោះបង់ចោលនោះទេ គឺគេនៅថែរក្សាឱ្យនៅទីនោះដដែលដោយគេរៀបចំឱ្យទៅជាខ្ទមមួយដែលគេហៅថា *ខ្ទមអ្នកតាដាក់នៅទិស*ឥសាន។ នៅត្រង់ចំណុចនេះ បង្ហាញឱ្យឃើញពីផ្នត់គំនិត *គោរពនិងដឹងគុណរបស់ចាស់បុរាណខ្មែរ ចំពោះម្ចាស់ដើម*សមដូចសុភាសិតបុរាណខ្មែរពោលថា "*ផឹកទឹកនឹកដល់ប្រភព*។" ឬក៏ថា "*ជ្រកក្រោមឈើធ្វើគារវៈដល់អ្នកដាំ*។"



*ការបន់ស្រន់អ្នកតាឃ្លាំងមឿង ខេត្តពោធិសាត់*

ប្រភព៖ Internet

សរុបសេចក្ដីមក ជំនឿលើព្រលឹងរបស់ ដូនតាខ្មែរ គឺជាជំនឿអរូបិយមួយដែលគេចាត់ទុកថា ជាជំនឿលើកម្លាំងក្រៅខ្លួនមនុស្សៗថ្វីត្បិតតែជំនឿនេះមានលក្ខណៈអរូបិយក៏ពិតមែនតែវាក៏បានក្លាយទៅជាទម្រង់សាសនាដើមមួយជាវប្បធម៌មួយ

និងជាទម្រង់ប្រពៃណីមួយរបស់ខ្មែរតាំងពីព្រេងនាយរហូតមកដល់សព្វថ្ងៃ។ ទម្រង់ជំនឿនេះឥតបានបង្ហាញឱ្យឃើញនូវផ្នត់គំនិតអន់ថយឬថោកទាបអ្វីឡើយ តែវាបង្ហាញឱ្យឃើញនូវតម្លៃនៃការគោរពនិងដឹងគុណចំពោះបុព្វបុរសរបស់ខ្លួនតាំងពីនៅរស់រហូតដល់ស្លាប់។ តែទោះជាយ៉ាងណាក៏ដោយ ជំនឿអរូបិយងាយនឹងធ្វើឱ្យអ្នកជឿទទួលរងនូវផលអវិជ្ជមានណាស់។ វាអាចនឹងបណ្ដាលឱ្យ ពួកគេអស់ទ្រព្យធនប៉ះពាល់ដល់រាងកាយឬក៏អាចបាត់បង់ជីវិតក៏មាន។ គេអាចជឿបានតែដើម្បីឱ្យការជឿរបស់គេនោះមានប្រសិទ្ធិភាព គេត្រូវជឿដោយប្រើបញ្ញារិះរកហេតុនិងផលនៃជំនឿនោះឱ្យបានច្បាស់លាស់មុននឹងទទួលយកពី ព្រោះវាមានអាថ៌កំបាំង ហើយមានគ្រូប្រដៅជំនឿច្រើនណាស់ដែលឆ្លៀតឱកាសប្រើល្បិចកិច្ចកលដើម្បីនិយាយបំភាន់បោកបញ្ឆោតកេងយកប្រយោជន៍នៅពេលអ្នកជឿកំពុងជឿដក់ស្លុង ភ្លេចប្រើបញ្ញាដើម្បីរកសេចក្ដីពិត។ និយាយជារួមអ្នកជឿជឿកុំភ្លេចខ្លួនទោះជានៅក្នុងកាលៈទេសៈណាក៏ដោយដើម្បីកុំឱ្យគ្រោះថ្នាក់។ (នៅមានត)

**(ជំនឿជឿដោយបញ្ញាគ្រោះភាចនានាវិនាសសូន្យទាំងអស់)**

# គន្ថនិទ្ទេស

## ១- ស្នាដៃនិពន្ធជាភាសាខ្មែរ

1- គង់ សំអុល, "ប្រវត្តិបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក," ព.ស ២៥៤៥/ គ.ស ២០០១។

2- ជួន ណាត វចនានុក្រមខ្មែរ រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ២០០៨។

3- ត្រឹង ង៉ា "ប្រវត្តិសាស្ត្រខ្មែរ ភាគ១និង២(សម្រាប់មធ្យមនិងឧត្តមសិក្សា)"ភ្នំពេញ, ព.ស. ២៥១៧, គ.ស. ១៩៧៣។

4- ឃិន គឹមវាណ"ព្រលឹងវប្បធម៌ជាតិ"រោងពុម្ពវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត ២០០៣។

5- សែល ត្រាណេ"ប្រព័ន្ធគំនិតខ្មែរ" សម្ព័ន្ធ និស្សិតខ្មែរពីបរទេស,១៩៩៨។

## ២- ស្នាដៃនិពន្ធជាភាសាអង់គ្លេស

6- Cambridge Advanced Learner's Dictionary, 3rd ed.

7- Thomas Aquinas, "The Nature of the Soul," New York, 1967

8- Venancio B. Ardales, "Introdu-ctory text to philosophy," 2nd printing, New York, 1974

# អំពីជំនឿខ្មែរ

## (ភាគបញ្ចប់)

បណ្ឌិត **ត្នាន់ ធុល**
មន្ត្រីនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា,
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសង្គម,
រាជបណ្ឌិត្យសភាកម្ពុជា

### ខ. ប្រភពជំនឿលើវត្ថុដើមសន្តតិវង្ស

ប្រភពជំនឿទៅលើវត្ថុដើមសន្តតិវង្សឬជំនឿថូថឹមនិយម(ហតាមអ្នកស្រាវជ្រាវខ្លះ)ពាក្យថាថូថឹមនិយម (totemism) គឺជាប្រព័ន្ធជំនឿដែលគេនិយាយថា មនុស្សមានញាតិសន្តាន (kinship) ឬទំនាក់ទំនងអាថ៌កំបាំង (mystical relationship) ជាមួយនឹងវិញ្ញាណ (spiritbeing) ដូចជាសត្វឬរុក្ខជាតិនៅក្នុងនោះៗ គេគិតថា អង្គ (entity) ឬថូថឹម(totem)ធ្វើអន្តរកម្មជាមួយក្រុមញាតិសន្តានដែលគេបានផ្តល់ឱ្យឬបុគ្គលណាមួយ និងដើម្បីបម្រើជានិមិត្តសញ្ញា (emblem)ឬជានិមិត្តរូប(symbol)របស់ពួកគេ[1]ៗ

ចំពោះបញ្ហាជំជឿ "ថូថឹម" របស់ជនជាតិ ខ្មែរនៅក្នុងគ្រាបឋម ខ្មែរជឿថា



ការដុតធូបបន់ស្រន់បារមីបង្កាន់ដៃនាគនៃស្ពាន ប្រាប់ទិស ឬស្ពានកំពង់ក្តី ស្រុកជីក្រែង ខេត្ត សៀមរាប
ប្រភព៖ Internet

ពួកគេតពូជពង្សចេញមកពីដូនតាដែលជាសត្វ,ជាដើមឈើឬក៏ជាទេវតាៗ ឧទាហរណ៍ តាមគន្ថងសម័យគោកធ្លក ខ្មែរបូរាណជឿថាបុព្វបុរសរបស់ពួកគេគឺជាសត្វនាគដែលនាំឱ្យពួកគេគោរពបូជាស្តេចភុជង្គនាគ (ស្តេចនាគ)ដែលជាម្ចាស់នគរគោកធ្លកៗ ដោយសារតែឥទ្ធិពលអំណាចដ៏ស័ក្តិសិទ្ធិរបស់សត្វដើម

[1] Internet, totemism

សន្តតិវង្ស ដែលនាំមកនូវភាពសុខសប្បាយ វឌ្ឍនភាពដល់មនុស្ស នេះ ហើយទើបអ្នកស្រុកតែងគោរពបូជា "តូតឹម" ឬ "និមិត្តរូប" ទាំងនោះ[2]។

ដោយមូលហេតុនេះហើយបានជាមានការហាមប្រាមមិនឱ្យធ្វើអ្វីមួយប៉ះពាល់ដល់សត្វឬរុក្ខជាតិដែលគេសន្និដ្ឋានជាវត្ថុស័ក្តិសិទ្ធិនិមិត្តរូបសម្រាប់តំណាងពួកគេ។ ឧទាហរណ៍ដ៏ជាក់ស្តែងមួយចំពោះខ្មែរខ្លះនៅតាមព្រៃភ្នំគឺមិនបរិភោគជាដាច់ខាតនូវសាច់សត្វត្រកួត ព្រោះគេជឿថាសត្វនេះតំណាងព្រលឹងដូនតាគេ ដែលចែកឋានទៅ។ បើដោយប្រការណាមួយមាននណាសម្លាប់សត្វត្រកួតអំពើនេះពិតជានាំមកនូវចង្រៃ ឧបទ្រពសៅហ្មងពុំខាន។ ដើម្បីរំដោះគ្រោះកម្មនេះ គេត្រូវធ្វើបុណ្យធ្វងឬបុណ្យកាត់គ្រោះ[3]។

## គ. ប្រភពជំនឿលើអាទិទេព

ដោយឡែកពីជំនឿលើព្រលឹង និងជំនឿលើវត្ថុដើមសន្តតិវង្សរបស់ខ្មែរ ជំនឿលើអាទិទេព គឺជាជំនឿក្រៅខ្លួនមួយទៀតរបស់ប្រជាជនខ្មែរ នោះគឺ ជំនឿព្រហ្មញ្ញសាសនា។

ព្រហ្មញ្ញសាសនាបានផ្សាយចូលមកឥណ្ឌាប្រហែលក្នុងឆ្នាំ១៨០០ ឬ១៥០០ មុនគ.ស. ដោយសារការពតត្បាតមួយដែលចេញមកពីទិសពាយ័ព្យ។ ពួកអ្នកពតត្បាតទាំងនោះត្រូវបានគេស្គាល់ថាជាពួកអារ្យ័ន។ នេះគឺជាពាក្យមួយដែលគេបានសំដៅទៅរកពួកមនុស្សនៅទ្វីបអឺរ៉ុបខាងកើត។ កំណើតដើមរបស់ពួកអារ្យ័ន នេះស្ថិតនៅក្នុងតំបន់វាលស្មៅដែលលាតសន្ធឹងពីប្រទេសប៉ូឡូញដល់ប្រទេសរុស្ស៊ីភាគខាងលិច។ ពួកនេះជាទូទៅគឺជាអ្នកគង្វាលចៀមសាត់អណ្តែត។ ពួកគេមានអារ្យធម៌ឈានមុខខាងចំណូលចិត្តធ្វើសង្គ្រាមវាតទី ដែលរស់រានមានជីវិតបានដោយសារតែជ័យភ័ណ្ឌទ្រព្យសម្បត្តិលួចប្លន់មួយភាគធំដែលពួកគេប្រមូលបានមកពីប្រជាជន ដែលពួកគេច្បាំងឈ្នះក្នុងពេលចូលទៅកាន់កាប់ទីតាំង។ ពេលដែលពួកអារ្យ័ន បានមកដល់ប្រទេសឥណ្ឌា ពួកគេបានបំផ្លាញអស់ យ៉ាងឆាប់ណាស់នូវអារ្យធម៌ជ្រលងទន្លេ ឥណ្ឌុសរបស់ឥណ្ឌា ហើយបានសាបព្រោះ[4]

[2] មីសែល ត្រាណេ, "ប្រព័ន្ធគំនិតខ្មែរ, សម្ព័ន្ធនិស្សិតខ្មែរពីបរទេស,១៩៩៨, ទំព័រ ២៧-២៨

[3] -ដ- ទំព័រ២៩

[4] Peter D. Santina (ប្រែដោយ ឈន អៀម), "ធម៌ គ្រឹះនពុទ្ធសាសនា", ភ្នំពេញ (ការផ្សាយរបស់ ពុទ្ធសា

អារ្យធម៌ដែលជាសាសនារបស់ខ្លួនមកលើប្រជាជនឥណ្ឌា។ សាសនារបស់ពួកអារ្យ៉ន មានលក្ខណៈជាសាសនាលោកីយទាំងស្រុង គឺមានភាពស្របគ្នាដ៏ជិតស្និទ្ធយ៉ាងច្រើនជាមួយនឹងសាសនារបស់ជនជាតិក្រិក។ ជំនឿលើអាទិទេពមួយចំនួនរបស់ពួកអារ្យ៉នគឺជាជាតួអង្គតំណាងឱ្យបាតុភូតធម្មជាតិ។ ជាឧទាហរណ៍ គេមានព្រះឥន្ទ្រ[5] ដែលជាអាទិទេពរន្ទះ និងផ្គរលាន់, គេមានព្រះអគ្គី ជាអាទិទេពភ្លើង និងព្រះវារុណជាអាទិទេពទឹក។ គំនិតដែលពួកអារ្យ៉ន និយាយថា ពួកគេបានដល់ឋានសួគ៌ជាឋានសួគ៌មួយយកគំរូតាមរូបភាពដ៏សុក្រិតនៃជីវិតលោកីយនេះ[6]ឯង។

ព្រហ្មញ្ញសាសនាមានអត្ថិភាពដោយបានអភិវឌ្ឍចេញមកពីលទ្ធិវេទនិយម (១៥០០ ឆ្នាំដល់៥៥០ ឆ្នាំមុនគ.ស.) គឺនៅក្នុងកំឡុងឆ្នាំ៥៥០ ឆ្នាំមុនគ.ស.ដល់ស.វ.ទី១០ នៃគ.ស.ដែលសព្វថ្ងៃសាសនា នេះមានអត្ថិភាពនៅក្នុងទម្រង់ជាលទ្ធិ ហិណ្ឌូនិយម[7] ។

ព្រហ្មញ្ញសាសនាបានផ្សាយចូលមកស្រុកខ្មែរ ទំនងតាំងពីមុនព្រះពុទ្ធសាសនាទៅទៀត តាមរយៈជនជាតិឥណ្ឌាដែលជាពួកឈ្មួញ ដែលបានធ្វើដំណើរមកទាក់ទងរកស៊ីលក់ដូរជាមួយអ្នកស្រុក ហើយនិងពួកបញ្ញវន្តឥណ្ឌាដែលជាអ្នកចេះដឹងខាងសាសនាព្រាហ្មណ៍ ដែលមានជំនឿលើអាទិទេពនេះ[8]។

### គ.១. ទេវៈបង្កើតលោក

ព្រហ្មញ្ញសាសនា (Brahmanism) ជាសាសនាដែលមានការជាប់ទាក់ទងដោយសេចក្តីប្រកាន់ជឿថា "មហាព្រហ្មជាអ្នកបង្កើតពពួកសត្វ"[9]។ ពួកព្រាហ្មណ៍ ដែលប្រកាន់ខ្លួនថាជាបុត្ររបស់ ព្រះព្រហ្មបានកាន់កាប់និងប្រតិបត្តិសាសនានេះ ទើបបានជាហៅថា "សាសនាព្រាហ្មណ៍ ឬព្រហ្មញ្ញសាសនា"[10]។

ចំពោះបញ្ហាជំនឿព្រហ្មញ្ញសាសនាបានទទួលយកជំនឿទៅលើទេវៈ ដែលយកធម្មជាតិធ្វើជាទេវៈ។ ទេវៈ ដែលពួកនេះជឿ

សនបណ្ឌិត្យ, បោះពុម្ពលើកទី១, ព.ស. ២៥៤៤/ គ.ស. ២០០០, ទំព័រ១៥

5 -ដ-, ទំព័រ១៧

6 -ដ-, ទំព័រ១៨

7 ត្រឹង ងា "អរិយធម៌ខ្មែរ, ភ្នំពេញ? បោះពុម្ពលើកទី៣, ព.ស.២៥១៨/គ.ស.១៩៧៤, ទំព័រ ៣០

8 ឥន្ទ ឱមសាម៉េង, "ប្រវត្តិទស្សនៈ, សាសនា, សីលធម៌, នយោបាយ", សាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច, ២០០៥, ទំព័រ១៩

9 ជួន ណាត, "វចនានុក្រមខ្មែរ", រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ២០០៨, ទំព័រព្រហ្ម

10 ឥន្ទ ឱមសាម៉េង,ដ.ឯ.ម, ទំព័រ១៩

មានច្រើនដូចជា ព្រះឥន្ទជាទេវៈតំណាងផ្គរ-រន្ទះ, ព្រះអគ្គីជាទេវៈភ្លើង, ព្រះគិរុណជាទេវៈបង្កើតភ្លៀងនិងទឹក...[11]។ ការគោរពទេវៈច្រើនអង្គបែបនេះ គេឱ្យឈ្មោះថា ទស្សនៈពហុទេវនិយម (polytheism)។ លុះមកដល់ចុងសម័យវេទនិយមទស្សនៈនេះមានទំនោរទៅរក ទស្សនៈគោរព អាទិទេពតែមួយអង្គវិញដែលគេឱ្យឈ្មោះថា ទស្សនៈឯកទេវៈនិយម (monothei-sm) គឺគេបង្រួមទេវៈច្រើនអង្គខាងលើឱ្យមកតែមួយអង្គវិញ ដែលគេ ចាត់ទុកថាជា អាទិទេពដើមបង្អស់ ដែលបានបង្កើតទេវៈឯទៀតៗ និងអ្វីៗទាំងអស់ក្នុងលោកនេះ។ អាទិទេពមួយអង្គនោះគឺ ព្រះព្រហ្ម នេះឯង។ នៅក្នុងទស្សនវិជ្ជាឥណ្ឌា ទស្សនៈមិមំសា និង ទស្សនៈវេទន្តចែងថា ព្រះព្រហ្មជាអាទិទេពធំដែល បង្កើតទេវៈនិងសភាវៈឯទៀតៗ។ ចំណែកឯ ទស្សនៈវៃសេសិកៈ-ន្យាយ-យោគៈបានលើកឥស្វរជា អទិទេពធំជាងគេ ហើយគេថា ឥស្វរៈនេះបានបែងភាគជាអាទិទេព ៣ទៀត ដែលបង្កើតបានជា ទស្សនៈមួយឈ្មោះ ថាទស្សនៈត្រីមូ៌តិ (Trinity)[12] ពោលគឺ ព្រះព្រហ្ម,ព្រះវិស្ណុ,និងព្រះសិវៈ នេះឯង។

**គ.១.១.ព្រះព្រហ្ម** (Brahma)

ព្រះព្រហ្ម គឺជាអាទិទេពបង្កើតលោក។ ព្រះអង្គមានមុខបួន (heads) អាចមើលទៅទិសទាំងបួនហើយនិងមានដៃបួន (hands) ចង្អុលទៅទិសទាំងបួន។ មុខបួនតំណាងឱ្យវេទទាំងបួនដែលកើតចេញមកពីមាត់ព្រះអង្គ[13]។ ឯពូជមនុស្សបួនពួកទៀតមានពូជ ព្រាហ្មណៈ (Brahmana) កើតពីព្រះឱស្ឋព្រហ្ម តម្រូវឱ្យជាម្ចាស់សាសនាមានមុខការខាងបង្រៀនប្រៀនប្រដៅវេទមន្តវិជ្ជា ផ្សេងៗ; ក្សត្រិយៈ ឬខត្តិយៈ (Kshatriya) កើតពី ព្រះពាហាព្រហ្ម មានមុខការគ្រប់គ្រងនិងរក្សាប្រទេស; វៃស្យៈ ឬវេស្សៈ (Vaishya) កើត

[11] ត្រឹង ងា "អរិយធម៌ខ្មែរ" ដ.ឯ.ម ទំព័រ ៣៦-៣៧

[12] -ដ- ទំព័រ៣៨-៣៧

[13] https://en.wikipedia.org/wiki/Brahma



ព្រះព្រហ្ម
វត្តបាសិត ខេត្តបាត់ដំបង រចនាបថកោះកេរ
សតវត្សទី១០ ថ្មភក់ តាំងនៅសារមន្ទីរGuimet
ទីក្រុងប៉ារីស។
ប្រភព៖Internet

ពីព្រះឱរុព្រហ្ម មានមុខងារធ្វើកិច្ចការខ្ពស់ខ្ពស់ចុះរងពីក្សត្រិយៈមក ឬកិច្ចការធម្មតា; និងពូជ សូទ្រៈ ឬ សុទ្ទៈ (Shudra) កើតពី បាទព្រហ្មមានមុខការស៊ីឈ្នួលឬការថយថោកផ្សេងៗ[14]។ មនុស្សទាំង បួនពួកនេះ មានបញ្ញត្តិឱ្យស្លៀកដណ្តប់សំពត់ព័ណ៌ផ្សេងគ្នា គឺ ព្រាហ្មណៈ ត្រូវប្រើសំពត់ព័ណ៌ ស, ក្សត្រិយៈត្រូវប្រើ សំពត់ព័ណ៌ក្រហម, វៃស្យៈប្រើព័ណ៌ លឿង,សូទ្រៈប្រើព័ណ៌ ខ្មៅ។ បវេណី ក្នុងកម្ពុជរដ្ឋបានលើកថ្នាក់វង្សក្សត្រិយ៍ជាទី១, បារគូបុរោហិត(ដែលសន្មតថាព្រាហ្មណ៍) ជាទី២,វៃស្យៈ(ពូជព្រៃងារ)ជាទី៣, សូទ្រៈ(ពូជអ្នកងារ) ទៅជាទី៤(តែឥឡូវពូជសូទ្រៈលើកលែងមិនឱ្យមានទេ, រាប់បញ្ចូលជាប្រជាជនស្មើមុខគ្នាជាមួយវៃស្យៈទាំងអស់); ចំពោះព័ណ៌សំពត់ស្លៀកដណ្តប់គ្មានបញ្ញត្តិ, គឺមានកំណត់ឱ្យប្រើសំពត់ព័ណ៌ ផ្សេងគ្នា តែក្នុងព្រះរាជពិធីធំម្តងៗ, ចំពោះតែក្សត្រិយ៍និងមន្ត្រីប៉ុណ្ណោះ, ប្រើតាមថ្នាក់ទាំង៤សម្រាប់គឺ១-សម្រាប់ឯក (សម្រាប់ក្សត្រិយ៍ទ្រង់រាជ្យ) ប្រើសំពត់ព័ណ៌ ក្រហម; ២-សម្រាប់ទោ (សម្រាប់ក្សត្រិយ៍ឧភយោរាជ) ត្រូវប្រើព័ណ៌បៃតង; ៣-សម្រាប់ត្រី (សម្រាប់ក្សត្រិយ៍ឧបរាជ ឬ ឧបយុវរាជ) ប្រើព័ណ៌ស្វាយ; ៤-សម្រាប់ចត្វា (សម្រាប់ សម្តេចព្រះវររាជជននី) ប្រើព័ណ៌ខៀវ។ ព័ណ៌ផ្ទិតសមណស័ក្តិសម្រាប់បព្វជិតជារាជាគណៈឋានានុក្រមក៏ប្រើព័ណ៌ទៅតាមលំដាប់ថ្នាក់ទាំង៤ សម្រាប់នុះដែរគឺ សម្រាប់ឯក ផ្ទិតព័ណ៌ក្រហម;សម្រាប់ទោ ផ្ទិតព័ណ៌ បៃតង; សម្រាប់ត្រី ផ្ទិតព័ណ៌ស្វាយ; សម្រាប់ចត្វា ផ្ទិតព័ណ៌ខៀវ[15] ។

[14] ជួន ណាត, វ.ឯ.ម.

[15] ជួន ណាត វ.ឯ.ម., ទំព័រវណ្ណៈ

នៅក្នុងសង្គមខ្មែរ ព្រះព្រហ្មមិនសូវមានអ្នកគោរពបូជាច្រើនទេ ហើយមានប្រាសាទតិចតួចណាស់ដែលគេកសាងឧទ្ទិសថ្វាយចំពោះព្រះអង្គ[16] ។

### គ.១.២.ព្រះវិស្ណុ ( Visnu )

ព្រះវិស្ណុ គឺជាអាទិទេពជំមួយទៀតនៅក្នុងទស្សនៈត្រីមូ៌តិនៃលទ្ធិហិណ្ឌូ ហើយក៏ជាអាទិទេព ជំមួយអង្គនៅក្នុងប្រពៃណីលទ្ធិវៃស្ណព(vaishnavism)ផងដែរ[17]។ ព្រះវិស្ណុមាននាទីជាអ្នកថែរក្សា លោកឱ្យនៅគង់វង់។ នៅក្នុងនាទីជាអ្នករក្សាលោកនេះ ព្រះអង្គត្រូវបែងភាគជា១០អវតារ (avatars )ចុះមកកើតក្នុងស្ថានមនុស្ស លោកដើម្បី ផ្ចាញ់សភាវៈអាក្រក់[18] ។

ក្រៅពីអវតារទាំង១០ ព្រះវិស្ណុនៅមានលក្ខណៈសម្គាល់ពិសេសផ្សេង ទៀត ដូចជា មានព្រះ កេស១ មានមួកពង សុីឡាំង ; មានដៃ២, ៤, ឬ៨ [ដៃ ឆ្វេងខាង មុខកាន់ផ្កាឈូក (ធាតុខ្យល់), ដៃស្តាំខាង មុខកាន់មោងស័ក្ត (ធាតុដី), ដៃឆ្វេងខាង



បដិមាព្រះវិស្ណុដៃ៤ មកពីរូបអារក្សលើ ភ្នំគូលែន, ថ្មភក់ សតវត្សទី៨, សារៈមន្ទីរគ្វីមេត (Guimet) ក្រុងប៉ារីស ប្រទេសបារាំង

ប្រភព៖ Internet

---

16 https://en.wikipedia.org/wiki/Brahma

17 https://en.wikipedia.org/wiki/Brahma

18 ត្រឹង ងា "អរិយធម៌ខ្មែរ" ជ.ឯ.ម ទំព័រ ៤៣

ក្រោយកាន់ខ្សែស័ង្ខ (ធាតុទឹក), និងដៃស្ដាំខាងក្រោយ កាន់ចក្រ (ធាតុភ្លើង) ដែលគេគិតថា មានឫទ្ធានុភាពបំផុតនៅក្នុងលទ្ធិហិណ្ឌូ។[19] សម្បៀកបំពាក់ពណ៌លឿង; ជិះគ្រុឌ ឬនាគជាយានជំនិះ; វិមាននៅកំពូលភ្នំកៃឡាស; មានមហេសីឈ្មោះនាងលក្ស្មីជាទេពធីតាតំណាងទ្រព្យសម្បត្តិ[20]។

ចំពោះបញ្ហាកំណើតរបស់ព្រះវិស្ណុ មានគម្ពីរខ្លះនិយាយថាព្រះវិស្ណុមានកំណើតពីដំណក់ញើសថ្ងាស់របស់ព្រហ្មក្នុងពេលព្រះអង្គកំពុងបំពេញតបៈ[21]។

**គ.១.៣. ព្រះសិវៈ** ( Shiva )

ព្រះសិវៈ "អ្នកជាក់ត្រជំ (The Auspicious One)" ឬ "អ្នកបំផ្លាញ (The Destroyer)" ជាអាទិទេពធំទី៣មួយទៀតនៅក្នុងទស្សនៈត្រីមូ៌តិនៃលទ្ធិហិណ្ឌូដែលមាននាទីជាអ្នកបំផ្លាញ និង បំលែងហើយ ក៏ជាអាទិទេពធំនៅក្នុងលទ្ធិសៃវនិយម (Shaivism) ផងដែរ[22]។

លក្ខណៈសំខាន់ៗរបស់ព្រះសិវៈគឺមាន ព្រះនេត្រ៣, ព្រះ នេត្រទី១ និងទី២ដូចមនុស្សធម្មតា តែព្រះនេត្រទី៣នៅលើថ្ងាស និងមានព្រះច័ន្ទ ចាំងរស្មីមួយចំណិតនៅលើ ក្នុងសក់។

▶ ព្រះនេត្រទី៣ ឬអគ្គីនេត្រ

ភ្នែកនេះបិទជានិច្ច ពីព្រោះជាភ្នែកក្រឡេក ឆេះក្នុងន័យមួយ។ ក្នុងន័យមួយទៀត ព្រះនេត្រទី ៣ គឺជា ចក្ខុញាណ



ព្រះសិរសិវៈ, ចម្លាក់ថ្មភក់ខ្មែរ
រវាងគ.ស. ៩០០ ដល់ គ.ស.៩២៥
សារៈមន្ទីរគ្វីនេត(Guimet) ក្រុងប៉ារីស

---

[19] https://en.wikipedia.org/wiki/Vishnu

[20] https://km.wikipedia.org/wiki/ព្រះវិស្ណុ

[21] ត្រឹង ង៉ា, ដ.ឯ.ម, ទំព័រ ៤២

[22] https://en.wikipedia.org/wiki/Shiva

(Mind's eye)ឬនេត្រកំបាំង(inner eye) គឺនេត្រអាថ៌កំបាំងទេវកថា (mystical invisible eye) ដែលជាធម្មតាមានទីតាំងនៅលើថ្ងាស អាចឱ្យព្រះសិវៈដឹងបានលើសពីភ្នែកធម្មតា។ នៅក្នុងលទ្ធិហិណ្ឌូ ព្រះនេត្រទី៣ សំដៅទៅលើអាជ្ញា (Ajna)ឬចក្រ (chakra)។ ទាំងនៅក្នុងព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ព្រះនេត្រទី៣ ដែលស្ថិតនៅចំកណ្ដាលថ្ងាសនោះគឺជាការតំណាងឱ្យអ្នកដែលបានត្រាស់ដឹង (enlightenment) តាមរយៈការធ្វើសមាធិ។

ជាពិសេសនៅក្នុងការអនុវត្តផ្លូវចិត្តរបស់ពួកបូព៌ាប្រទេស ព្រះនេត្រទី៣ សំដៅទៅលើច្រកដែលនាំទៅដល់ពិភពខាងក្នុង (inner realms) ហើយនិងលំហរនៃសេចក្ដីដឹងខ្ពស់ៗ (spaces of higher consciousness) ហើយជារឿយៗតំណាងឱ្យសភាពនៃការត្រាស់ដឹងនេះឯង។ ព្រះនេត្រទី៣ ជារឿយៗត្រូវបានផ្សារភ្ជាប់ជាមួយនឹងចក្ខុវិស័យសាសនា, ការចេះមើលឃើញច្បាស់ពីអតីតកាលនិងអនាគតកាល (clairvoyance) សមត្ថភាពក្នុងការសង្កេតមើលចក្រ (វដ្ដ) និងផ្នែកថាមពល (auras)ការយល់ដឹងជាមុន, និងបទពិសោធន៍ក្រៅរាងកាយ (out-of-body experiences)[23]។

▸ ព្រះច័ន្ទចាំងរស្មីមួយចំណិតនៅលើផ្នួងសក់៖

មានប្រភពមកពីជម្លោះរវាងពួកអសុរៈ និងពួកទេវៈ នៅក្នុងរឿងកូរសមុទ្រទឹកដោះ ដែលដណ្ដើមគ្នាកាន់កាប់និងគ្រប់គ្រងលើភពទាំងឡាយ។ ដើម្បីយកជ័យជំនះលើពួកអសុរៈបាន ពួកទេវៈបាននាំគ្នារិះរកមធ្យោបាយដោយគិតថាមានតែទឹកអម្រឹតមួយគត់ដែលអាចជួយឱ្យទេវៈទាំងឡាយមានជីវិតអមតៈ ហើយនិងអាចយកជ័យជំនះលើពួកអសុរៈបាន។ ពួកទេវៈគិតបែបនេះរួចហើយក៏យល់ថា ជាមធ្យោបាយល្អ ហើយក៏និយាយបញ្ចុះបញ្ចូលបបួលពួកអសុរៈឱ្យចូលរួមក្នុងការកូរសមុទ្រទឹកដោះនោះ ដោយសន្យាថានឹងធ្វើការបែងចែកទឹកអម្រឹតដែលទទួលបានមកពីការកូរនោះ ដល់អ្នកកូរទាំងអស់គ្នា។ ដោយមានការលោភលន់ និងចង់បានជីវិតអមតៈផងនោះ ពួកអសុរៈក៏សម្រេចចិត្តយល់ព្រមសហការជាមួយពួកទេវៈ។ បន្ទាប់មកពួកគេទាំងពីរក្រុមក៏ចាប់ផ្ដើមបើកកិច្ចប្រតិបត្តិការកូរសមុទ្រទឹកដោះ ដើម្បី

[23] https://en.wikipedia.org/wiki/Brahma, Shiva, *the third eye*

ស្វែងរកទឹកអមតៈ ដោយមូលមតិគ្នាថា យកភ្នំមន្ទរៈមកធ្វើជាខ្នរ និងយកពស់វាសុកិដែលជាស្តេចពស់ដែលរស់នៅបាតសមុទ្រមកធ្វើជាខ្សែរពួរ ដើម្បីទាញបង្វិលខ្នរនោះ។ ការកួរសមុទ្រទឹកដោះនេះបានប្រព្រឹត្តិទៅអស់រយៈពេល១០០០ឆ្នាំ។ ក្នុងការកួរនេះពួកទេវៈសម្រេចចិត្តនៅខាងកន្ទុយពស់ចំណែកឯពួកអសុរៈនៅខាងក្បាល។ លុះស្រុះស្រួលគ្នា ហើយ ពួកគេទាំងពីរក្រុមបាននាំគ្នាកួរសមុទ្រទឹកដោះ ដើម្បីស្វែងរកទឹកអម្រឹត។ ប៉ុន្តែនៅពេលការកួរប្រព្រិត្តិទៅបានពាក់កណ្តាលទី ក៏ស្រាប់តែភ្នំមន្ទរៈត្រូវធ្លាក់ស្រុតចុះទៅក្នុងបាតសមុទ្រ។ ឃើញសភាពមិនស្រួលបែបនេះព្រះវិស្ណុក៏បានបែងភាគជាអណ្តើកធំមួយឈ្មោះកុម៌ៈ មុជចុះទៅកល់ភ្នំមន្ទរៈពីក្រោមរហូតធ្វើឱ្យភ្នំអាចឈរត្រង់ដូចដើមវិញ។ បន្ទាប់ពីភ្នំមន្ទរៈត្រូវបានកល់ទប់បញ្ឈរឱ្យត្រង់មានលំនឹងដូចដើមឡើងវិញ ហើយក្រុមពួកទេវៈនិងក្រុមពួកអសុរៈក៏បានចាប់ផ្តើមកួរបន្តទៅទៀត។ ដោយកម្លាំងទាញទៅវិញទៅមកយ៉ាងស្វាហាប់ស្មើដៃគ្នាធ្វើឱ្យកម្លាំងកួរមានចលនាកាន់តែខ្លាំងទៅៗស្វាហាប់ឡើងៗ កម្លាំងទឹកកួរក៏កាន់តែមានសន្ទុះឡើងៗជាលំដាប់លើសមុនបានធ្វើឱ្យសត្វទឹកទាំងឡាយ ដែលកំពុងស្ថិតនៅជិតខ្នរកួរត្រូវដាច់ខ្ទួនជាពីរ ឬជាកំណាត់ៗបណ្តាលមកពីកម្លាំងទឹកគួចដែលមានសន្ទុះដ៏ខ្លាំងមហិមា។ សន្ទុះនៃការកួរមានសភាពកាន់តែខ្លាំងក្លាឡើងៗធ្វើឱ្យស្តេចពស់ក្តៅក្រហល់ក្រហាយទ្រាំពុំបានក៏ក្អែរពិសដ៏គ្រោះថ្នាក់ចេញមកក្រៅ។ ពិសពស់នេះមានឫទ្ធានុភាពដ៏គ្រោះថ្នាក់បំផុត។ បើវាធ្លាក់ទៅលើឋានទេវលោក វានឹងត្រូវឆេះឋានទេវលោក តែបើវាធ្លាក់ទៅលើឋានមនុស្សលោក វានឹងត្រូវឆេះឋានមនុស្សលោកឬបើវាធ្លាក់ចូលទៅក្នុងសមុទ្រវានឹងត្រូវឆេះសមុទ្រ ហើយសត្វនានានឹងត្រូវវិនាសហិនហោចអស់។ ដោយទតឃើញសភាពមិនស្រួលបែបនេះ ព្រះសិវៈក៏បានក្បង់ពិសទាំងនោះលេបចូលទៅក្នុងមាត់បាត់ទៅ។ ដោយអានុភាពនៃពិសរបស់ស្តេចពស់បាននេះធ្វើឱ្យបំពង់កព្រះសិវៈឈឺចុកចាប់ក្តៅអន្ទះអន្ទែងរហូតដល់ទ្រាំមិនបាន ព្រះសិវៈក៏យកព្រះហស្តឈោងចាប់ព្រះច័ន្ទយកមកដាក់លើក្ខួងសក់ព្រះអង្គដើម្បីឱ្យបំពង់កព្រះអង្គបានត្រជាក់ដូចដើមវិញ[24]។

សូមបញ្ជាក់ថា រឿងដែលបណ្តាល

[24] Vasundhara Filiozet" បាឋកថាស្តីអំពីរឿងកួរសមុទ្រទឹកដោះ(និទាន)",មហាវិទ្យាល័យបុរាណវិទ្យានៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ២០០២, Internet

ឱ្យព្រះសិវៈមានសម្បុរពណ៌ខៀវក្រម៉ៅ នេះ គឺ បណ្ដាលមកពីព្រះអង្គលេបពិសពស់វាសុកិនេះឯង។ ចំណែកឯការដែល



ព្រះវិស្ណុកូរសមុទ្រទឹកដោះនៅប្រាសាទអង្គរវត្តនៅកណ្ដាលក្បាច់ផុស ព្រះវិស្ណុសម្ដែងខ្លួនជាពីរ ទម្រង់៖ ខាងក្រោមជាទម្រង់កុម៌ៈ គឺជាអណ្ដើកកល់ទ្រភ្នំមុន្ទរៈកុំឱ្យលិចនិងខាងលើជាទម្រង់ដៃ៤ ដៃពីរកាន់ដាវនិងចក្រឯដៃពីរទៀតកាន់ពស់ទាំងសងខាងធ្វើជាអ្នកដឹកនាំប្រតិបត្តិការ។ រូបខាងលើខ្នងភ្នំមុន្ទរៈ គឺជាព្រះឥន្ទ្រដែលជាស្ដេចនៃទេវៈ។

ដោយMichael Gunther ឆ្នាំ ២០១៤

ប្រភព: Internet

ព្រះសិវៈ យកព្រះហស្ដឈោងចាប់ព្រះច័ន្ទមកដាក់លើក្បួងសក់ព្រះអង្គ គឺដើម្បីឱ្យបំពង់កព្រះអង្គបានត្រជាក់។ រឿងនេះចាស់បុរាណមានជំនឿថា ព្រះច័ន្ទ គឺជា និមិត្តរូបទឹកដែលមានធាតុត្រជាក់ត្រជុំខុសពីព្រះអាទិត្យដែលជាភ្លើងមានធាតុក្ដៅ។ ដោយហេតុនេះហើយទើបបានជាបដិមាព្រះសិវៈមាន ជាប់ព្រះច័ន្ទនៅលើក្បួងសក់នោះ។

▸ បដិមាសិវលិង្គ ឬ លឹង្គព្រះឥសូរ

នៅក្នុងពិភពសិល្បៈខ្មែរ សិល្បៈករបានកសាងបដិមាព្រះសិវៈទៅជាទម្រង់ផ្សេងៗជាច្រើន ប៉ុន្តែទម្រង់បដិមាដែល គេឃើញមានការនិយមច្រើននិងខ្លាំងជាងគេនោះគឺ សិវលិង្គ។ ការដែលនាំឱ្យកើតទៅជាការគោរពសិវលិង្គនេះនោះ គឺមាន ដំណើររឿងដែលទាក់ទងទៅនឹង កំណើត ព្រះសិវៈ ដែលមានដំណើររឿង ដូចខាងក្រោម៖

មានគម្ពីរឈ្មោះ វាយុបុរាណ បានថ្លែងថា នៅថ្ងៃមួយ គឺនៅពេលដែលព្រះព្រហ្ម និង ព្រះវិស្ណុកំពុងតាំងខ្លួនជាអ្នកបង្កើតលោកស្រាប់តែមានសសរភ្លើង ធំមួយផុសឡើងនៅចន្លោះអាទិទេពទាំងពីរនោះ។ ដោយចង់ដឹងអំពីប្រភពនៃសសរភ្លើងនោះ ព្រះព្រហ្ម ក៏បាន តាំណែងខ្លួនជាសត្វស្វាបហោះទៅរកមើលផ្នែកខាងលើនៃសសរ។

ឯ ព្រះវិស្ណុក៏បាន តំណែងខ្លួនជាជ្រូកព្រៃឈ្មួសដីរកមើល ផ្នែកខាងក្រោម។ បន្ទាប់ពីរកមើលគល់ និងចុងនៃសសរភ្លើងពុំឃើញអស់ពេល ជាច្រើនពាន់ឆ្នាំមក អាទិទេពទាំងពីរក៏ទទួលស្គាល់សសរភ្លើងធំនោះថាជា អាទិទេពមានឫទ្ធានុភាពជាងខ្លួន ហើយក៏នាំគ្នាគោរពរាប់អានតមក។ ក្រោយមក ព្រះសិវៈក៏លេចចេញពីកណ្ដាលសសរភ្លើងមក ហើយក៏ប្រាប់ឱ្យដឹងថា អាទិទេពទាំងពីរនេះជាចំហាយចេញពីកាយព្រះអង្គ បានសេចក្តីថា ព្រះព្រហ្ម និង ព្រះវិស្ណុ ជាការបែងភាគរបស់ ព្រះអង្គ។ ដូចនេះពាក្យ ឥស្វរៈ ដែលយើងប្រើសម្គាល់អាទិទេពដើមគេនោះគឺ ព្រះសិវៈនេះឯងឬ ព្រះឥសូរ ដែលខ្មែរយើងនិយមហៅ[25]។

អាទិទេពក្នុងទ្រឹស្តីត្រីមូរ្តិ ព្រះឥសូរ ជាអាទិទេពដែលខ្មែរនិយមជាងគេបំផុត។ គេបាន កសាងភាគច្រើនជារូប លិង្គ ដែលគេហៅថា សិវៈលិង្គ ដែលជានិមិត្តរូបនៃសសរភ្លើងនៅក្នុង គ្រាតាំងខ្លួនជា អ្នកបង្កើតលោក ជាមួយព្រះព្រហ្មនិងព្រះវិស្ណុ។ ចម្លាក់រូបលឹង្គព្រះឥសូរ នេះគេប្រទះឃើញមានការកសាងតាំងពីមុន សម័យអង្គរមកម៉្លេះ។ លុះមកដល់ ស.វ.ទី ៩ ទើបមានការ កសាងរូបផ្សេងៗតំណាងព្រះសិវៈវិញ[26]។

- សិវៈលិង្គ (Lingam/Linga) គឺជាអង្គជាតរបស់ ព្រះសិវៈ ដែលមានបដិមាជាលិង្គ តំណាងឱ្យព្រះអង្គផង និង អំណាចបង្កើតលោករបស់ព្រះអង្គផង។ លឹង្គ គេឆ្លាក់មាន រាងជា៤ជ្រុងនៅគល់, រាង៨ជ្រុងនៅកណ្ដាល និងរាងមូលនៅខាងចុង។ នៅសម័យ អាណាចក្រខ្មែរដែលគោរពព្រះឥសូរ លិង្គត្រូវបានគេសាងឡើងធ្វើជានិមិត្តរូបព្រះមហាក្សត្រតម្កល់នៅក្នុងប្រាសាទ។ លិង្គ ដែល បានបន្សល់ទុក មកពីសម័យ អង្គរ ជា ទូទៅគេធ្វើពីថ្មផុស។ លិង្គសម័យ អង្គរមានប្រភេទមិនដូចគ្នាទេះ

លិង្គ មួយចំនួនគេដាក់នៅកន្ទេងផ្ទៃរាបរាងការ៉េ ដែលគេឱ្យឈ្មោះថា យោនី (yoni) គឺជានិមិត្តរូបនៃ អវៈយវៈភេទស្រ្តី។

លិង្គ មួយចំនួន គេឆ្លាក់មុខព្រះសិវៈ នៅលើនោះ។ ដូចជា លិង្គ ដែលគេហៅថា មុខលិង្គ (mukhalingas)។

[25] ត្រឹង ងា៖អរិយធម៌ខ្មែរ ដ.ឯ.ម ទំព័រ ៤៩

[26]-ដ- ទំព័រ ៤៦



មុខលិង្គ
សតវត្សទី ៧-៨
ប្រភព Internet

លិង្គមួយចំនួនទៀតត្រូវបានគេបែកជាបីផ្នែកៈ ផ្នែករាងការ៉េជានិមិត្តរូបព្រហ្ម,ផ្នែកកណ្តាលជានិមិត្តរូបព្រះវិស្ណុ,និងផ្នែកចុងរាងមូលជានិមិត្តរូបព្រះសិវៈ[27]។

- ឯយោនី(yoni) វិញ គឺជា"ទ្វារមាស" ឬ"ស្បូន" ជានិមិត្តរូបទេពធិតាសក្តិ (Shakti) ទេវី(Devi)ក្នុងលទ្ធិហិណ្ឌូ។ បើនៅក្នុងលទ្ធិសៃវៈនិយមវិញ យោនីជានិមិត្តរូប និងគោរពបូជាដល់មហសីរបស់ព្រះសិវៈ។ យោនីជាគូនឹងលិង្គ។ សម្ព័ន្ធភាពនៃភេទទាំងពីរនេះ គឺ តំណាងឱ្យដំណើរអមតៈនៃការបង្កើតលោកហើយ និងការផុះដាល[28]។




សម្ព័ន្ធនៃយោនីនិងសិវលិង្គ
ជានិមិត្តរូបបង្កើតលោក
ប្រភព ៖ រូបភាពស្រាវជ្រាវ នៅក្រសួង
អភិរក្សអង្គរ ឆ្នាំ២០០៦

### គ.១. វដ្តជីវិត

វដ្តជីវិតឬគេអាចហៅបានម្យ៉ាងទៀតថា សង្សារវដ្តគឺជាដំណើរវិលកើតវិលស្លាប់ស្ទើរតែរកទីបញ្ចប់គ្មាននៃជីវិតរបស់សព្វសត្វ។ វដ្តជីវិតនៅក្នុងព្រហ្មញ្ញសាសនាខុសប្លែកគ្នាឆ្ងាយពីព្រះពុទ្ធសាសនាដែលថាសត្វលោកវិលកើតវិលស្លាប់ដោយសារ

27 https://en.wikipedia.org/wiki/Khmer_architecture, Linga

28 https://en.wikipedia.org/wiki/Khmer_architecture, Yoni

តែកម្លាំងអត្តកម្ម ដែលមាននៅក្នុងខ្លួនផ្ទាល់របស់សព្វសត្វឥតចេញមកពីប្រភពខាងក្រៅដែលមានអាទិទេពជាប្រភពផ្តល់ឱ្យនោះឡើយ។ ចំណែកឯនៅក្នុងព្រហ្មញ្ញសាសនាវិញ ប្រភពដែលនាំឱ្យជីវិតសព្វសត្វវិលកើតវិលស្លាប់នៅក្នុងសង្សារវដ្តមិនងាយបានទៅដល់បរមសុខនោះ គឺបណ្តាលមកពី ព្រហ្ម័ន, អាត្ម័ន, និងជាពិសេសគឺកម៌ដែលមានប្រភពដើមមកពីអាទិទេព ពោលគឺព្រះព្រហ្មនេះឯង ។ ព្រហ្មញ្ញ សាសនិកមានជំនឿថា សព្វសត្វទាំងឡាយមានមនុស្សសត្វ និងធម្មជាតិឯទៀតៗជាច្រើនកើតឡើងដំបូងពុំមែនដោយសារការជប់របស់ព្រះព្រហ្មនោះទេ គឺភាវៈទាំងនោះកើតឡើងដោយធាតុល្អិតល្អន់បរិសុទ្ធរបស់ព្រះព្រហ្ម ដែលហៅថា ព្រហ្ម័ន។ ព្រហ្ម័ន គឺជាព្រលឹងសាកល ដែលនៅក្នុងព្រលឹងធំនេះមានព្រលឹងតូចៗល្អិតនៅរួមជាមួយ ដែលហៅថា អាត្ម័ន[29]។

អាត្ម័នត្រូវគ្នានឹងពាក្យថា អាត្មា ដែលមានន័យថាខ្លួន, ឬចិត្ត។ តាមលទ្ធិខ្លះអាត្ម័នប្រែថា "ព្រលឹង"។ តើមានការខុស ប្លែកគ្នាដូចម្តេចរវាង ព្រហ្ម័ននិងអាត្ម័ន? គេអាចសម្គាល់ថា ព្រហ្ម័នជាព្រលឹងធំ រីឯ អាត្ម័នជាព្រលឹងតូច។ គេនិយាយថា ក្នុងរូបយើងមានអាត្ម័ន, កាលណា យើងដេកលក់ស៊ប់, ចួនកាលអាត្ម័នចេញពីរូប ត្រាច់ចរទៅខាងក្រៅ,លុះដល់វេលា ទើបវិលត្រឡប់ចូលមកក្នុងរូបវិញ[30]។ ព្រហ្ម័នប្រៀបដូចជាទឹកសមុទ្រ ឯអាត្ម័នប្រៀបដូចជាទឹក ភ្លៀង[31]។ អាត្ម័នគឺជាឯកធាតុពិសេស ដែលបានបែកចេញពីព្រហ្ម័នទៅ បង្កើតភាវៈឯទៀតៗ។ នៅពេលនោះកម៌ន ដែលជាអំពើឬកម្លាំងម្យ៉ាងក៏កើតមានឡើងដែរ។ ឯមនុស្សឬសត្វក៏ចាប់មានជីវិតមានចលនាហើយក៏ត្រូវស្លាប់ទៅវិញនៅទីបំផុត។ នៅពេលស្លាប់ រូបកាយត្រូវវិនាសទៅវិញ ឯអាត្ម័នពុំស្លាប់ទេ ហើយវាចេញពីរូបកាយនោះ ដោយមានកម្លាំងកម៌

29 ត្រឹង ង៉ា "អរិយធម៌ខ្មែរ", ដ.ឯ.ម, ទំព័រ ៣២

30 ជួន ណាត ដ.ឯ.ម., ទំព័រ អាត្ម័ន

31 ត្រឹង ង៉ា "អរិយធម៌ខ្មែរ", ដ.ឯ.ម, ទំព័រ ៣២

នរុញច្រាន ឱ្យទៅចូលក្នុងរូបកាយថ្មីទៀតយ៉ាងនេះ វៀងដរាបទៅតាមអំពើដែលបានកសាងពីមុនមក។ ការវិលវល់[32] ចេញពីរូបមួយចូលទៅរូបមួយទៀតមិនចេះអស់មិនចេះហើយនេះហៅថា *សំសារៈ*។ ដូចនេះ ឧបសគ្គដែលនាំឱ្យ អាត្ម័នពុំងាយបានវិលទៅជួប *ព្រហ្មន័*វិញ គឺ *កម៌*នេះឯង។

## សេចក្តីសន្និដ្ឋាន

ជំនឿចែកចេញទៅជាជំនឿរូបីនិងជំនឿអរូបី។ ជំនឿរូបីជា ជំនឿឥន្ទ្រិយពោល គឺ គេអាចប្រើភ្នែកប្រើច្រមុះ ប្រើត្រចៀក ដើម្បីមើលហិត និងស្តាប់ឱ្យទៅជាការ យល់ដឹងបាន ប៉ុន្តែគេនៅតែមិនអាចជឿទុកចិត្តលើវាទាំងស្រុងបានទេ។ តាមបទពិសោធន៍នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ ជំនឿឥន្ទ្រិយជានិច្ចកាលតែងតែបោកបញ្ឆោតនិងដឹកនាំយើងទៅរកមាយាការដែលនាំឱ្យយើងមានជំនឿខុសករណីដូចជាការមើលផ្លូវដែកស្របគ្នាពីរនៅក្នុងចម្ងាយឆ្ងាយមួយគេនឹងឃើញថាជួបគ្នា។ ហេតុនេះ គេត្រូវតែពិនិត្យសង្កេតធ្វើពិសោធនិងពិចារណារកហេតុផលឱ្យបានច្បាស់លាស់ចាំដាក់ចិត្តជឿដើម្បីកុំឱ្យមានកំហុស។ កាន់តែពិបាកជាងនេះ ជំនឿអរូបីឬអបិយជំនឿ ដែលមិនមែនជាជំនឿឥន្ទ្រិយ វាងាយនឹងដឹកនាំយើងទៅរកគ្រោះ ថ្នាក់ជាទីបំផុត។ ជាចុងក្រោយវាទាមទារឱ្យយើងត្រូវតែវិលទៅរកការពិនិត្យសង្កេតធ្វើពិសោធនិងពិចារណារកហេតុផលឱ្យ បានច្បាស់លាស់ដូចជំនឿឥន្ទ្រិយដែរ។

ជំនឿ ទោះរូបីក្តី អរូបីក្តីសុទ្ធតែមានសារៈ ប្រយោជន៍ សុទ្ធតែអាចជួយអភិវឌ្ឍការយល់ដឹងអាចអភិវឌ្ឍជីវិតយើងបានល្អដូចគ្នាតែវាតម្រូវឱ្យយើងប្រើបញ្ញាគ្រប់ កាលៈទេសៈទាំងអស់ដើម្បីមើលឱ្យឃើញសច្ចភាពដែលស្ថិតនៅក្នុងអាថ៌កំបាំងនៃជំនឿនោះ។

តាមគំរូល្អរបស់ដូនតាទៅលើការប្រើជំនឿត្រឹមត្រូវនៅសម័យព្រេងនាយ។ លោកបានប្រែក្លាយពីជំនឿអរូបីទៅជាជំនឿរូបី។ ករណី

---

[32] -ដ- ទំព័រ ៣៣

ប្រាសាទអង្គរវត្តនៅក្នុងរឿងទេវកថា ភ្នំព្រះសុមេរុ ប្រែក្លាយមកជាប្រាសាទពិតនៅលើផែនដី។ ប្រែក្លាយមហាសាគរដែលព័ទ្ធជុំវិញភ្នំព្រះសុមេរុមកជា គូរទឹកព័ទ្ធជុំវិញប្រាសាទ មកជាបារាយណ៍ ដែលអាចទាញយកជាប្រយោជន៍នៅក្នុងជំនឿសាសនាផងនិងជាប្រយោជន៍សម្រាប់ប្រើប្រាស់នៅក្នុងវិស័យកសិកម្មដែលជាប្រភពសេដ្ឋកិច្ចនៅក្នុងជីវិតពិតផង។ លើសពីនេះទៀតព្រះ បាទជយវរ្ម័នទី២ នៅក្នុងជំនឿលើព្រះឥសូរនៃលទ្ធិព្រហ្មញ្ញសាសនា បានប្រែក្លាយព្រះអង្គឯងទៅជាព្រះឥសូរនៅលើផែនដីនៃនគរខ្មែរ។

# គន្ថនិទ្ទេស


១- ស្នាដៃនិពន្ធជាភាសាខ្មែរ

1. ជួន ណាត, "វចនានុក្រមខ្មែរ",រក្សាសិទ្ធិដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ, ២០០៨
2. ត្រឹង ង៉ា "អរិយធម៌ខ្មែរ",ភ្នំពេញ?បោះពុម្ពលើកទី៣,ព.ស.២៥១៨/គ.ស.១៩ ៧៤
3. Peter D. Santina (ប្រែដោយ ឈន អៀម), "ធម៌គ្រឹះនពុទ្ធសាសនា", ភ្នំពេញ (ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ), បោះពុម្ពលើកទី១, ព.ស. ២៥៤៤/គ.ស. ២០០០
4. មីសែល ត្រាណេ,"ប្រព័ន្ធគំនិតខ្មែរ",សម្ព័ន្ធនិស្សិតខ្មែរពីបរទេស,១៩៩៨
5. ឥន្ទ ឱមសាម៉េង, "ប្រវត្តិទស្សនៈ, សាសនា, សិលធម៌, នយោបាយ", សាកល វិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រ សេដ្ឋកិច្ច, ២០០៥

២- ព្រឹត្តិប័ត្រ, ទស្សនាវដ្ដី, សារពត៌ មាន និង Internet

1- https://en.wikipedia.org/wiki/ Brahma

2- Internetotemism, t

3- https://en.wikipedia.org/wiki/ Brahma

4- https://en.wikipedia.org/wiki/ Vishnu

5- https://km.wikipedia.org/wiki/ព្រះ វិស្ណុ

6- https://en.wikipedia.org/wiki/ Brahma,Shiva, the third eye

7- Vasundhara Filiozet "បាឋកថា ស្ដីអំពី រឿងកួរសមុទ្រទឹកដោះ (និទាន)", មហាវិទ្យាល័យបុរាណ វិទ្យានៃសាកល វិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ២០០២

8- https://en.wikipedia.org/wiki/Khmer_architecture, Linga

9- https://en.wikipedia.org/wiki/Khmer_architecture, Yoni

# លទ្ធិទេវរាជ

## (ទស្សនវិជ្ជានយោបាយខ្មែរ)

*បណ្ឌិត* **ឆ្កាន់ ធុល**

*មន្ត្រីនាយកដ្ឋានទស្សនវិជ្ជានិងសង្គមវិជ្ជា,*

*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសង្គម,*

*រាជបណ្ឌិត្យសភាកម្ពុជា*

*ព្រះបាទជ័យ**វរ្ម័នទី២** បានយាងត្រឡប់ពីប្រទេសជ្វាប្រហែលជាគ.ស៨០០។ ពេលដំបូងព្រះអង្គយាងទៅគង់នៅ**ឥន្ទ្របុរ**ទំនងជាត្រង់បន្ទាយ**ព្រៃនគរ**ស្រុកត្បូងឃ្មុំខេត្តកំពង់ចាម។ គឺនៅទីនោះហើយដែលព្រះអង្គបានទទួលឱ្យព្រាហ្មណ៍ **សិវកៃវល្យ** ចូលធ្វើជា**រាជបុរោហិត**របស់ព្រះអង្គ។ មុននឹងឡើងសោយរាជ្យនៅក្នុង**ព.ស១៣៤៥** (គ.ស៨០២) ព្រះអង្គត្រូវធ្វើការបង្រួបបង្រួមទឹកដីឱ្យបានមួយភាគសិន ដោយហេតុនេះហើយបានជាព្រះអង្គត្រូវផ្លាស់ប្តូររាជធានីញឹកញាប់។ ជាចុងក្រោយយាងទៅគង់នៅលើ**ភ្នំគូលែន** (មហេន្ទ្របវ៌ត) ហើយព្រាហ្មណ៍ **សិវកៃវល្យ** ក៏និមន្តទៅជាមួយព្រះអង្គដែរ។ គឺនៅលើ**កំពូលភ្នំគូលែន**នេះហើយដែលព្រះបាទ**ជ័យវរ្ម័នទី២** ទ្រង់ប្រារព្ធធ្វើពិធីថ្មីមួយហៅថា "**ពិធីទេវរាជ**"[1] ជ័យ។*

### ១- ខ្លឹមសារ

*ពាក្យ "**ទេវរាជ**" ភាសាសំស្ក្រឹតថា "Devarāja/devaraja" ឬភាសាអង់គ្លេស "God King/ deified monarch" អាចនឹងមានន័យខុសៗគ្នាដូចជា "**ស្តេចអាទិទេព** (god-king)" **ឬ** "**ស្តេចនៃពពួកទេព្តា** (king of the gods)។ ក្នុងទេវឋានហិណ្ឌូ ព្រះនាម ស្តេចនៃពពួកទេព្តាតែងតែត្រូវបានកំណត់យកចំពោះ **ព្រះសិវៈ** (Shiva)ឬ **ព្រះវិស្ណុ**(Vishnu)។ ហេតុនេះអាណាចក្រមនុស្សនៅលើផែនដីនេះបានឆ្លុះបញ្ចាំងពីអាណាចក្រសួគ៌នៃពពួកទេព្តា ជាគំនិតសំដៅទៅលើស្តេចដែលជា អាទិទេពដែលមានជីវិត នៅលើផែនដីនេះ។*

***លទ្ធិទេវរាជ** គឺជាលទ្ធិសាសនាមួយរបស់ព្រហ្មញ្ញសាសនាដែលគេគោរពនៅអាស៊ីអគ្នេយ៍នេះ។ លទ្ធិនេះ បង្រៀនថា **ស្តេច** គឺជា*

[1] *ត្រឹង ង៉ា, "ប្រវត្តិសាស្ត្រខ្មែរ ភាគ១និង២ (សម្រាប់មធ្យមនិងឧត្តមសិក្សា)," ភ្នំពេញ, ព.ស.២៥១៧, គ.ស.១៩៧៣, ទំព័រ ១១០។*

អ្នកគ្រប់គ្រងសាកលលោក ជាអាទិទេពមួយ អង្គជាអវតារនៃអាទិទេព ដែលគេតែងសន្មត់យក***ព្រះសិវៈ***ឬ***ព្រះ វិស្ណុ*** ជាមូលដ្ឋាន។ គំនិតនេះចាត់ទុក***ស្ដេច*** (the monarch)ថាជាអ្នកមាន***គុណសម្បត្តិអតិសេដ្ឋ*** (transcendental quality) គឺ ***ស្ដេច***ដែលគង់នៅជា***អាទិទេពមានជីវិត*** (the living god) នៅលើផែនដីនេះ។ បញ្ញត្តិនេះទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងបញ្ញត្តិឥណ្ឌា***ចក្រវ័ទិន*** (Chakravartin) ដែល មា ន ន័ យ ថា ***ស្ដេ ច ចក្រវាឡ***(universal monarch)។ នៅក្នុងនយោបាយ លទ្ធិនេះត្រូវបានគេចាត់ទុកថាជា***យុត្តិកម្មទេវភាព*** (the divine justification) នៃការគ្រប់គ្រងរបស់ស្ដេច។ បញ្ញត្តិនេះត្រូវបានបង្កើតឡើងជាស្ថាប័ន (institutionalized) និង បង្ហាញដ៏ឧឡារិក នៅកោះជ្វា និងកម្ពុជាបុរាណនៅទីនោះបូជនីយដ្ឋានដូចជាប្រាសាទប្រាមបាណន (Prambanan) របស់ឥណ្ឌូនេស៊ី



ប្រាសាទប្រាមបាណន(Prambanan) យោគ្យាការតា (Yogyakarta) ប្រទេសឥណ្ឌូនេស៊ី។
ប្រភព៖ https://www.photodharma.net/Indonesia/26-Prambanan/index.htm

និងប្រាសាទអង្គរវត្ត (Angkor Wat) របស់ខ្មែរ ត្រូវបានគេសង់ឡើងដើម្បីអួតសសើរពីការគ្រប់គ្រងបែបអាទិទេព របស់ស្ដេចនៅលើផែនដី។



គំនិតអំពីទេវរាជបានធ្វើឱ្យស្ដេចខ្មែរមានលទ្ធភាពអាចចាប់ផ្ដើមគម្រោងធំៗបាន ដូចជាការសាងសង់ប្រាសាទអង្គរវត្តជាដើម។
ប្រភព ៖ រូបថតស្រាវជ្រាវ

និយាយជារួម ក្នុងនយទូទៅនៅក្នុង ភូមភាគអាស៊ីអគ្នេយ៍ទាំងមូល និងក្នុងន័យ ដោយឡែកនៅស្រុកខ្មែរ ក្នុងសម័យមហានគរលទ្ធិទេវរាជគឺសំ ដៅ លើ កត ម្កើង ឬ អភិ សេក ព្រះ រា ជា (ព្រះបាទជយវរ្ម័នទី២,គ.ស.៨០២)ឱ្យមានឋានៈជា *ទេវរាជ* (ស្ដេចអាទិទេព) ដែលពាក្យខ្មែរបូរាណ ហៅថា *កម្រតេងជគតរាជ្យ* (ស្ដេចដែលជាម្ចាស់នៃចក្រវាឡ)[2] ។

## ២-ប្រភព

គេតែងចោទសួរថា តើ***ពិធីទេវរាជ*** នេះមនដើមកំណើតមកពីណាមកពី***ជ្វា***ដែលជាទីកន្លែងដែលព្រះបាទ ***ជយវរ្ម័នទី២*** បានគង់នៅ

---

[2] ត្រឹង ង៉ា, "ប្រវត្តិសាស្ត្រខ្មែរ" ជ.ឯ.ម, ទំព័រ ៧៨។

ទីនោះឬយ៉ាងណា? ប្រវត្តិសាស្ត្រ**ឥណ្ឌូនេស៊ី**បានឱ្យដឹងថា គេបានរកឃើញ**សិលាចារឹកសំស្ក្រឹត** មួយផ្ទាំងមានចុះកាលកំណត់ **គ.ស ៧៦០** នៅភូមិភាគខាងកើតនៃ**កោះជ្វា**។ សិលាចារឹកនេះ បាននិយាយពី**ស្តេចជ្វា** ដែលគោរពបូជា **លឹង្គបូតិកេស្វរ** ដែលជាតំណាង**ទេវរាជ**។ ចំណែកឯប្រវត្តិសាស្ត្រ**ចាម** ក៏បានឱ្យដឹងផងដែរថាន**ស.វទី៤** ព្រះបាទ**ភទ្រវរ្ម័ន**បានកសាង**ប្រាសាទ**មួយឧទ្ទិសចំពោះ **ព្រះសិវៈភទ្រេស្វរៈ** ដែលគេឃើញក្សត្រនៅ**ចេនឡា** បានគោរពបូជានៅប្រាសាទ **វត្តភូ** ដែលជាហេតុនាំឱ្យគេសន្និដ្ឋានថា **ភទ្រេស្វរៈ** នេះជា**ព្រះឥសូរ** រួមរបស់**ជនជាតិខ្មែរ**និង**ជនជាតិចាម** ផងពីព្រោះពេលក្រោយៗមកទៀត **ព្រះរាជា**នៅ**អង្គរ** ទ្រង់នៅតែគោរពបូជាដូចជាព្រះបាទ**យសោវរ្ម័នទី១**នៅ**ប្រាសាទ** **ព្រះវិហារ**និងព្រះបាទ**រាជេន្ទ្រវរ្ម័នទី២**នៅប្រាសាទ**ប្រែរូប**។ នៅសម័យ**អាណាចក្រភ្នំ****ព្រះរាជា**មានឋានៈជាតំណាង**ព្រះឥសូរ** ហើយតែងតែយាងទៅលើ**ភ្នំម៉ូតាន**ដើម្បីគោរពបូជាចំពោះព្រះអង្គ។ នៅសម័យ**ចេនឡា**សិលាចារឹកឆ្នាំ**៧១៣** របស់ព្រះនាង**ជយទេវី** បាននិយាយចំពោះព្រះបាទ**ជយវរ្ម័នទី១**ថា ជា "ក្សត្រដែលបានយាងទៅ**កាន់សិវបុរ**"ឯសិលាចារឹកឆ្នាំ៨០៣ បាននិយាយថាព្រះបាទបុស្ករក្ស (?) មាន**ព្រះ មរណនាម**ថា **ឥន្ទ្រលោក**។

ទាំងនេះបង្ហាញឱ្យឃើញថា នៅភូមិភាគ **អាស៊ីអាគ្នេយ៍** យើងនេះ គ្រប់តែរដ្ឋដែលទទួលយក**ទស្សនៈសិវនិយម**ខាង**រាជាធិបតេយ្យ**សុទ្ធតែមានការគោរពបូជាយ៉ាងផ្តេកផ្តួលចំពោះ**សិវលិង្គ**ព្រមទាំងមាន**គំនិតរំលាយខ្លួន**ជាមួយ**ទេវៈ**នេះថែមទៀត។ ព្រះបាទ**ជ័យវរ្ម័នទី២** គ្រាន់តែបានធ្វើឱ្យលទ្ធិនេះមានរូបរាងច្បាស់លាស់ឡើងដោយបានទទួលឥទ្ធិពលពីជ្វាប៉ុន្តែហេតុដែលគួរឱ្យកត់សម្គាល់គឺនៅឥណ្ឌូនេស៊ីក្តីនៅចាម្ប៉ាក្តីគេមិនឃើញមានប្រាសាទភ្នំដូចនៅស្រុកខ្មែរយើងទាល់តែសោះ។ ដូចនេះ យើងអាចចាត់ទុកថា ប្រាសាទភ្នំជាស្នាដៃស្ថាបត្យកម្មទេពកោសល្យខ្មែរ[3] ពីព្រោះថាបុព្វបុរស ខ្មែរមានជំនឿនៅលើទីខ្ពស់ ស្របទៅតាមគំនិតថា ព្រះឥសូរមានលំនៅនៅលើ*ភ្នំកៃលាស* សិវលិង្គដែលជាតំណាងព្រះឥសូរផង ជាតំណាងព្រះរាជាផងក៏ត្រូវយកទៅតំកល់លើភ្នំដែរ។ ប្រសិនបើគ្មានភ្នំធម្មជាតិទេ គេត្រូវកសាងប្រាសាទដែលមានយឿនច្រើនជាន់ឱ្យមានកំពស់ដូចភ្នំ ហើយដែលគេហៅថាប្រាសាទភ្នំ។ ប្រាសាទភ្នំត្រូវស្ថិតនៅចំកណ្តាលរាជធានីដែលគេចាត់ទុកថា នៅចំស្ដូលនៃចក្រវាល។ នៅលើភ្នំគូលែនគេសន្មតថាប្រាសាទ*ព្រះ អារាមរោងចិន* ជាប្រាសាទភ្នំទី១ ដែលបានកសាងដោយព្រះបាទជយវរ្ម័នទី២[4]។

## ៣-ការរៀបចំពិធី

ប្រទេសខ្មែរ នៅរជ្ជកាលព្រះបាទជយ

---

[3] ត្រឹង ង៉ា, "ប្រវត្តិសាស្ត្រខ្មែរ", ដ.ឯ.ម, ទំព័រ ៧៩-៨០។

[4] -ដ-, ទំព័រ ១-៤

វរ្ម័នទី២ ព្រះអង្គទ្រង់បញ្ជាឱ្យគេនិមន្តព្រាហ្មណ៍ម្នាក់ឈ្មោះ **ហិរណ្យទាម** ដែលមានចំណេះវិជ្ជាយ៉ាងច្រើនខាងមន្តអាគមនៅស្រុកជនបទ ។



ព្រះបាទជ័យវរ្ម័នទី២ ជាស្ដេចខ្មែរសតវត្សទី៩
ប្រារព្ធពិធីទេវរាជចំពោះព្រះសិវៈ
នៅមុនពេលឡើងសោយរាជ្យ។
ប្រភព ៖ ត្រឹង ង៉ា,"ប្រវត្តិសាស្ត្រខ្មែរ" ទំព័រ ៧៩

ព្រាហ្មណ៍នេះបានធ្វើពិធីមួយតាមគម្ពីរ **វិនាសិខ**។ ព្រាហ្មណ៍**សិវកៃវល្យ** ក៏បានរៀនពីព្រាហ្មណ៍ នេះនូវគម្ពីរ៤ គឺគម្ពីរ**វិនា សិខ**, **នយោត្តរ?សម្មោហ?**,និងគម្ពីរ **សិរច្ឆេទ** ព្រមទាំងរបៀបប្រារព្ធធ្វើពិធីទេវរាជទៀតផង។ ព្រះរាជាព្រមទាំងព្រាហ្មណ៍**ហិរណ្យ ទាម**បានធ្វើសច្ចាថាអំណើះតទៅមានតែសមាជិកគ្រួសារនៃព្រាហ្មណ៍**សិវកៃវល្យ**ទេ ដែលអាចប្រារព្ធធ្វើពិធីទេវរាជនេះបាន។

តាមយោបល់លោក **ហ្ស. សឺដែស** (G. Coedés) ទាក់ទងទៅនឹងរឿងពិធីទេវ រាជនេះ លោកបានរំលឹកទៅដល់រឿងដែលឈ្មួញអារ៉ាប់ឈ្មោះ **សូឡៃម៉ាន់** បាននិទានដោយមានបញ្ជាក់ពីការដែល**ជ្វា**មកលុកលុយប្រទេស **ចេនឡា** ដោយចាប់បាន**ព្រះរាជាខ្មែរ** ហើយកាត់**ព្រះសិរ** ផងនោះ ហើយដើម្បីឱ្យប្រទេសនេះរួចផុតពី **អំណាចជ្វា**វិញ គេអាចសន្មត់ថាក្នុង**ពិធីលើភ្នំគូលែន**នោះ ប្រហែលជាមានធ្វើឧបកិច្ចផ្ដាច់ **ព្រះសិរបដិមា** ជាតំណាង**ស្ដេចជ្វាវង្សសៃលេន្ទ្រ**ស្របតាមគម្ពីរ**សិរច្ឆេ** (កាត់ក្បាល) ជាមិនខាន។ ក្នុងពេលជាមួយគ្នានេះ គេអភិសេក **សិវ លិង្គ** ដែលគេសន្មត់ថាបានមកពី **ព្រះ ឥសូរ** តាមរយៈ**ព្រាហ្មណ៍**។ ធ្វើដូច្នេះ គេអាចចាត់ទុកថា **អាត្ម័នពិសិដ្ឋ** របស់ព្រះរាជាបានទៅសណ្ឋិតនៅក្នុង **សិវលិង្គ** នោះ ដែលបានក្លាយជាតំណាងឬ**និមិត្តរូប**នៃ**ទេវរាជ**។ បើនិយាយឱ្យងាយយល់គឺថា ក្រោយពីធ្វើ **ពិធីអភិសេក** នេះហើយ **ព្រះ រាជា**ក៏ក្លាយទៅជា **ព្រះឥសូរបែងភាគ**(មិនមែនគ្រាន់តែជាតំណាងទេ) ដែលមាន**អំណាច**គ្រប់គ្រងទៅលើ**សព្វសត្វ**។ ចាប់ពីពេលនោះទៅ**បញ្ជា**របស់**ព្រះរាជា**ក៏ជាបញ្ជារបស់ **អាទិទេព** នេះឯង[5]។

## ៤- គោលបំណង

គំនិតទេវរាជត្រូវបានប្រារព្ធឡើងតាម

[5] ត្រឹង ង៉ា,"ប្រវត្តិសាស្ត្រខ្មែរ",ដ.ឯ.ម,ទំព័រ ៧៨-៧៩។

រយៈពិធីសាសនា។ លទ្ធិនេះជួយឱ្យព្រះរាជាមានលទ្ធភាពប្រកាសពីអំណាចអាទិទេពដែលគេអាចប្រើប្រាស់ទៅលើការទទួលខុសត្រូវចំពោះភាពពេញច្បាប់ខាងនយោបាយ (political legitimacy) ការគ្រប់គ្រងសណ្តាប់ធ្នាប់សង្គម, ទិដ្ឋភាពសាសនានិងនយោបាយ។ នៅក្នុងទិដ្ឋភាពនយោបាយលទ្ធិនេះជួយលើកតម្កើងយុត្តិកម្ម(the justification) របស់ព្រះរាជាហើយនិងសន្តតិវង្សគ្រប់គ្រង ដែលជាអ្នកគ្រប់គ្រងផែនដីពេញច្បាប់។ លទ្ធិទេវរាជ ក៏ត្រូវបានគេយកទៅប្រើផងដែរនៅក្នុងការថែរក្សាសណ្តាប់ធ្នាប់សង្គម,លើកតម្កើងព្រះរាជាជាអាទិទេពដែលមានជីវិតរស់នៅដែលបានផ្តល់យ៉ាងទៀងទាត់នូវការបម្រើនិងភក្តីភាពរបស់ប្រជានរាស្ត្ររបស់ព្រះអង្គដ៏ខ្ពស់បំផុត។ ការផ្សាយចូលមកនៃប្រព័ន្ធវណ្ណៈឥណ្ឌាក៏បានកំណត់ន័យវណ្ណៈសង្គម,មុខងារ(occupations)ក៏ដូចជារបៀបរស់នៅរបស់ប្រជាជនដែរ។

លទ្ធិទេវរាជ ក៏អាចធ្វើឱ្យព្រះរាជាមានលទ្ធភាពអាចចាប់ផ្តើមការងារសាធារណៈកម្រិតធំទូលាយ ហើយនិងគម្រោងធំៗបានផងដែរ ដោយការកេណ្ឌប្រជារាស្ត្រដើម្បីបង្កើតហើយនិងថែទាំប្រព័ន្ធធារាសាស្ត្រដ៏ស្មុគស្មាញដើម្បីស្រោចស្រពកសិកម្មដំណាំស្រូវដ៏ធំទូលំទូលាយ ឬក៏ដើម្បីស្ថាបនាវិមាននិង ប្រាសាទដ៏ធំស្កឹមស្កៃនានានៅក្នុងព្រះ កិត្តិយសព្រះមហាក្សត្រ។ ឧទាហរណ៍អំពីគម្រោងដ៏ធំនេះដូចជាបារាយណ៍នៅអង្គរ (មាន៤ធំៗតែបារាយណ៍ដែលធំជាងគេ គឺបារាយណ៍ទឹកថ្លាខាងលិចមានទំហំ៨គីឡូម៉ែត្រ X២.២គីឡូ ម៉ែត្រ,ជម្រៅ៧ម៉ែត្រពីខ្នងទំនប់, អាចស្តុកទឹកបានពី៤២-៧០លានម៉ែត្រគីប,មានលទ្ធភាព អាចស្រោចស្រពលើផ្ទៃដី១១០០០ហិចតា,ជីកនៅស.វទី១១។)និងប្រាសាទប្រាមបាណន (Prambanan) ជាដើម។




អាងស្តុកទឹក ឬបារាយណ៍ខាងលិច
ឬបារាយណ៍ទឹកថ្លា, ខេត្តសៀមរាប
ប្រភព ៖ រូបថតស្រាវជ្រាវឆ្នាំ២០០៦

លទ្ធិទេវរាជត្រូវបានព្រះបាទ**ជ័យវរ្ម័នទី២**ប្រារព្ធធ្វើនៅលើភ្នំគូលែនក្នុងគោលបំណង៖

**ទី១**៖ដើម្បីអភិសេកព្រះរាជា ឱ្យមានឋានៈជា **ស្តេចអាទិទេព**។

**ទី២**៖ ដើម្បីបង្រួបបង្រួមឱ្យមាន**ការឯកភាពជាតិ** ដែលបានបែកបាក់នៅសម័យចេនឡាក្រោមការដឹកនាំរបស់ព្រះរាជាដែលជាស្តេចអាទិទេព។

ទី៣ ៖ ដើម្បី **រំដោះប្រទេសជាតិឱ្យ** មាន

*ឥស្សរភាព* ពោលគឺ ប្រកាសឯករាជ្យជាតិពីជ្វា[6]។

ទី៤៖ **បង្កើតជំនឿទុកចិត្តចំពោះប្រជារាស្ត្រ** ដែលនាំឱ្យព្រះរាជាមានអំណាចទូលំទូលាយ។

## ៥- លទ្ធិទេវរាជជាទស្សនវិជ្ជានយោបាយខ្មែរ

សម័យមហាអង្គរជាសម័យកាលដ៏រុងរឿងបំផុត។ ភាពរុងរឿងនេះមិនមែនបានមកដោយចៃដន្យនោះទេ។ គឺបានមកដោយភាពវៃឆ្លាតរបស់ព្រះរាជាដែលចេះផ្សំរវាង**កត្តាមនុស្ស** និង**កត្តាសាសនា**។ កត្តាទាំងពីររួមផ្សំគ្នាបង្កើតទៅជា**កម្លាំងនយោបាយដ៏ខ្លាំងក្លាមួយ** ដែលអាច ព្យាបាលអាណាចក្រចេនឡាដែលបានបែកបាក់ទៅជាចេនឡាទឹកនិងចេនឡាគោកឱ្យមកស្រុះស្រួលនិងរួបរួមគ្នាបង្កើតទៅជាសម័យអង្គរមួយដ៏រុងរឿងនិងអស្ចារ្យ។

និយាយពីកត្តាមនុស្សគឺនិយាយពីកត្តានៃអ្នកដឹកនាំដែលជា ***ព្រះរាជា*** និងកត្តានៃអ្នកដែលត្រូវគេដឹកនាំគឺ ***ប្រជារាស្ត្រ***។ ព្រះរាជាដែលជាអ្នកដឹកនាំត្រូវតែជាអ្នកបរិបូរដោយគុណសម្បត្តិ៣ ប្រការគឺ *សុខភាព១*, *សមត្ថភាព ១*, និង*គុណធម៌៧*។

***សុខភាព*** ព្រះបាទជ័យវរ្ម័នទី២ ទ្រង់ជាស្តេចដែលបរិបូរដោយសុខភាពទាំងផ្លូវកាយ និងទាំងផ្លូវចិត្ត។

***សមត្ថភាព៣*** ព្រះបាទជ័យវរ្ម័នទី២ ក៏ទ្រង់ជាស្តេចដែលបរិបូរទៅដោយសមត្ថភាពដែរ ពោលគឺ បទពិសោធន៍ ដែលជាចំណេះដឹងទាំងខាងសាសនាចក្រ (ព្រហ្មញ្ញសាសនា) និងទាំងខាងអាណាចក្រគឺថា ព្រះអង្គយល់ និងមើលឃើញពីវិធីដែលត្រូវបង្រួបបង្រួម និងផ្សះផ្សាអាណាចក្រដែលបែកបាក់ឱ្យមករួបរួមគ្នាទៅជាអាចក្រតែមួយ និងទៅជាកម្លាំងតែមួយក្រោមការដឹកនាំរបស់ព្រះអង្គ។ ព្រះអង្គស្គាល់ច្បាស់ពីសមត្ថភាពរបស់ព្រះអង្គ (ស្គាល់ខ្លួនឯង) ហើយក៏ស្គាល់ច្បាស់ពីប្រជារាស្ត្រ (អ្នកក្រៅខ្លួន/អ្នកដទៃ)របស់ព្រះអង្គដើម្បីធ្វើការបញ្ចុះបញ្ចូលឱ្យមានការរួបរួមគ្នាហើយ និងស្គាល់ច្បាស់ថានឹងត្រូវយកអ្វីមកធ្វើជាឧបករណ៍សម្រាប់ធ្វើការបង្រួបបង្រួមឱ្យមានការឯកភាពទៅជាឯកភាពជាតិនេះហើយ។

ចំណែកឯគុណធម៌វិញ គឺជាគុណសម្បត្តិទាក់ទងទៅនឹងផ្លូវចិត្ត ហើយនិង ការប្រព្រឹត្តិដោយសីលធម៌។ ព្រះបាទជយវរ្ម័នទី២ ទ្រង់ជាស្តេចមានគុណធម៌ គោរពទៅតាមពាក្យសច្ចៈមានយុត្តិធម៌មិនផ្តាច់ការ មានធម៌សន្តោសប្រោសប្រណីពោល គឺ គោរពទៅតាមគុណធម៌ធំៗពីរគឺ *ទសពិធរាជធម៌ និងព្រហ្មវិហារធម៌*[8]។

[6] រស់ ចន្ទ្រាបុត្រ "ប្រវត្តិសាស្ត្រខ្មែរភាគ១ (ភាគ រឿងព្រេងនិទាននិងតាមរយៈសិលាចារឹក), ទំព័រ១៩៦-១៩៧។

[7] ហ.មណីចិន្តា,ព្រះបាទធម្មិក,អន្ទង់វិល,បោះពុម្ពលើកទី៣, ១៩៩៦, ទំព័រ៥៨។

[8] ហ. មណីចិន្តា, ព្រះបាទធម្មិក,អន្ទង់វិល,បោះពុម្ព លើក

*គុណសម្បត្តិទាំង៣ ប្រការដូចបានរៀបរាប់មក នេះ មានឈ្មោះថា អ្នកដឹកនាំជោគជ័យនិង មានតម្លៃ ពោលគឺ គុណភាពនៃការដឹកនាំរបស់ អ្នកដឹកនាំនេះឯង។*

*ចំណែកឯប្រជារាស្ត្រវិញ គឺប្រៀប ដូចជាហ្វូងគោព្រៃដូច្នេះដែរ ពោលគឺ ជាអ្នក ដែលរង់ចាំតែគោរពនិងដើរតាមព្រះតម្រិះរបស់ អ្នកដឹកនាំ(ព្រះរាជា)ប៉ុណ្ណោះ។ នេះមិនមាន ន័យថា អ្នកដឹកនាំចង់ធ្វើអ្វីតាមអំពើចិត្តដោយ ប្រាស់ចាកពីគុណធម៌ដូចបានរៀបរាប់ខាងលើ នោះឡើយពីព្រោះថា មានបទពិសោធន៍ជាមេ រៀនអំពីការបែកបាកនៅសម័យចេនឡាជាមេ រៀនស្រាប់។ ព្រះបាទជ័យវរ្ម័នទី២ ទ្រង់យល់ ច្បាស់ពីរឿងនេះ។*

*ចំណែកឯ**កត្តាសាសនា**វិញ បើនិយាយ ពី**កត្តាសាសនា** គឺនិយាយពី**បញ្ហាជំនឿ**(ចំណេះ ដឹង) និង**បញ្ហាចិត្តសាស្ត្រ**។ ព្រះបាទជ័យវរ្ម័ន ទី២ ទ្រង់យល់ច្បាស់ពីសារៈសំខាន់នៃសាសនា នៅក្នុងតួនាទីបង្កើតជំនឿទុកចិត្ត និងកម្លាំង ចិត្តសាស្ត្រ។ ព្រះអង្គអាចនឹងមានព្រះតម្រិះថា អ្នកដឹកនាំអាចដឹកនាំដោយជោគជ័យទៅបាន គឺអាស្រ័យលើ**មានការជឿទុកចិត្ត**ពីប្រជារាស្ត្រ។ ដើម្បីឱ្យ**មានការជឿទុកចិត្ត**នេះ ព្រះអង្គមើល ឃើញពីតួនាទីសំខាន់របស់សាសនាពោលគឺ ព្រហ្មញ្ញសាសនានៅក្នុងការបង្កើនជំនឿរឹងមាំ ទៅលើព្រះអង្គ។ ពីព្រោះថា ក្នុងព្រះកេរ្តិ៍ឈ្មោះ ព្រះអង្គក្នុងឋានៈជាស្តេចសោយរាជ្យតែម្យ៉ាង ឃើញថា មិនសូវជាមានជំនឿមុតមាំនិងរឹងមាំ ចំពោះព្រះអង្គឡើយ តែបើរៀបចំពិធីសាសនា ដើម្បីលើកព្រះឋានៈព្រះអង្គឱ្យទៅជាស្តេចអាទិ ទេពដែលមានជីវិតរស់នៅជាមនុស្សនៅលើ ផែនដីឃើញថាវាជា ការធ្វើឱ្យប្រជារាស្ត្រមើល មកព្រះអង្គក្នុងឋានៈជាស្តេចដ៏មានមហិទ្ធិរិទ្ធ ជា**ព្រះឥសូរបែងភាគ**(មិនមែនគ្រាន់តែជា តំណាងទេ)។ ហេតុដូច្នេះហើយបានជាព្រះអង្គ ទ្រង់បញ្ជាឱ្យគេនិមន្តព្រាហ្មណ៍**ហិរណ្យទាម** ដែលមានចំណេះវិជ្ជាយ៉ាងច្រើនខាងមន្តអាគម នៅស្រុកជនបទមករៀបចំប្រារព្ធពិធីសាសនា ពោលគឺ **ពិធីទេវរាជ** នៅលើភ្នំគូលែននោះ។*

*បើកាលណាគេនិយាយពីកត្តាជំនឿគេ ក៏មិនភ្លេចនិយាយពីកត្តាចិត្តសាស្ត្រនេះផង ដែរ។ ចិត្តសាស្ត្រគឺចង់សំដៅដល់បញ្ហាផ្លូវចិត្ត របស់ប្រជានរាស្ត្រដែលមិនមានលំនឹងដែល តែងតែប្រែប្រួលម្តងសុខម្តងទុក្ខគ្រប់ខណៈ ពេល ហើយតែងត្រូវការ របស់ជាទីពឹងដើម្បី បានកក់ក្តៅ និងមានលំនឹងដែលជាប្រភពនៃ សេចក្តីសុខ និងសេចក្តីចម្រើនចៀសផុតពី ភ័យន្តរាយនានា។ ហេតុដូចនេះពួកគេចង់បាន ព្រះរាជាមួយអង្គដែលល្អអស្ចារ្យពូកែស័ក្តិសិទ្ធ ដូចអាទិទេពដែលអាចបំពេញតម្រូវចិត្តទៅ តាមតម្រូវការរបស់ពួកគេនៅពេលណាពួក គេត្រូវការព្រះអង្គឱ្យជួយ។ ឧទាហរណ៍គ្រោះ ធម្មជាតិទឹកជំនន់,គ្រោះរាំងស្ងួត,អំពើអយុត្តិ ធម៌... បើប្រជារាស្ត្រចង់ឱ្យជួយជំនួយក៏នឹងមក*

---

*ទី៣, ១៩៩៦,ទំព័រ៥៨។*

ដល់ក្លាមដូចបំណាំងជាដើម។

ហេតុនេះ កត្តាមនុស្សនិងកត្តាសាសនាជាអង្គពីរដែលមិនអាចផ្តាច់ ចេញពីគ្នាបាន។ ពួកវាមានអន្តរកម្មជាមួយគ្នា។ ព្រះបាទជ័យវរ្ម័នទី២ទ្រង់យល់ច្បាស់ និងមើលឃើញពីសារៈប្រយោជន៍ នៃដំណើរអន្តរកម្មនេះ។

ប្រជារាស្ត្រអាចជឿទុកចិត្តបានគឺ ទាក់ទងទៅនឹង**ភាព អស្ចារ្យរបស់ព្រះរាជា ដែលជាអ្នកដឹកនាំ**។ ភាពអស្ចារ្យនៅត្រង់ ចំណុចនេះ គឺភាពស័ក្តិសិទ្ធពាក្យសច្ចភាពជាគំរូរបស់អ្នកដឹកនាំ។ បើព្រះរាជានិយាយអ្វីៗនោះត្រូវតែកើតឡើងជាដាច់ខាតដែរ។ នេះគេហៅថាសម្តីសក្តិសិទ្ធិសម្តីមានសច្ចភាព (បើថាត្រូវធ្វើតែបើធ្វើត្រូវថា)។ ទាំងការគិត,ទាំងសម្តី,និងទាំង ទង្វើឱ្យដូចជាអាទិទេពដែលប្រៀបដូចជាព្រះអង្គជប់ឱ្យកើតឡើងដូច្នេះដែរ។ ព្រះ បាទជ័យទី២ទ្រង់យល់ច្បាស់ពីសារសំខាន់នៃកត្តាចិត្តសាស្ត្រនេះ។ **លទ្ធិទេវរាជ** មានលក្ខណៈជាសាសនាផង,ជាអំណាចផង,ជាបារមីឬជាឫទ្ធចេស្តារផង, និងជាចិត្តសាស្ត្រនោះផងដែរ។ ការរៀបចំធ្វើពិធីទេវរាជនៅលើភ្នំគូលែនគឺ ដើម្បីអភិសេកព្រះអង្គឱ្យមានឋានៈជា **អាទិទេព** នេះជាភាពអស្ចារ្យទី១។ អាទិទេព មានសមត្ថភាពខ្លាំងក្លាយ៉ាងណា ព្រះរាជាក៏មានសមត្ថភាពខ្លាំងក្លាប៉ុណ្ណោះដែរ។ ហេតុដូច្នេះហើយបានជាគេឃើញសមិទ្ធផលដ៏អស្ចារ្យកើតមានពេញផ្ទៃប្រទេសខ្មែរ បន្សល់មកដល់សព្វថ្ងៃ។ នេះជាភាពអស្ចារ្យទី២។ **បញ្ញារបស់ព្រះរាជា** គឺជាបញ្ញារបស់**អាទិទេព**។ **ដីធ្លី,ច្បាប់**(អំណាចទាំងបីរបស់រដ្ឋស្ថិតនៅលើដៃព្រះអង្គតែមួយអង្គ), **កងទ័ព**, **សាសនា**, និង**ស្ថេរភាពសង្គម** រួមទាំង**ជីវិត** និង**ជោគវាសនា**ផង គឺព្រះរាជាជាអ្នកសម្រេច (នេះជាអំណាចដែលមានប្រភពមកពីអាទិទេពដែលលទ្ធិទេវរាជបាននាំមក)។ កត្តាអស្ចារ្យធ្វើឱ្យព្រះបាទជយវរ្ម័នទី២ក្លាយទៅជាព្រះរាជាដ៏មានអំណាចនិងបារមី។ ទ្រឹស្តីនយោបាយនៃលទ្ធិទេវរាជនៅសម័យនោះចែងថា "*អ្នកដែលគោរព ប្រតិបត្តិតាមបញ្ញាព្រះអាទិទេពនឹងនាំមកនូវកុសលផលបុណ្យដល់អ្នកដែលបានប្រព្រឹត្តិអំពើនោះ*"[១]។ ទស្សនៈនេះមានបង្កប់ នូវខ្លឹមសារចិត្តសាស្ត្រដែលបង្កភាពងាយស្រួលក្នុងនយបាយដឹកនាំរបស់ព្រះបាទជយវរ្ម័នទី២ ហើយឆ្លើយតបទនឹងទស្សនៈ នេះផលបុណ្យដែលប្រជារាស្ត្រទទួលបានគឺការរស់នៅដោយសុខសាន្ត។ នេះជានយោបាយដឹកនាំតាមបែបទ្រឹស្តីផ្សារភ្ជាប់នឹងការអនុវត្តដែលធ្វើឱ្យទ្រឹស្តីទេវរាជ និងការដឹកនាំរបស់ព្រះរាជាមានតម្លៃគោរព។ ប្រការនេះហើយដែលធ្វើឱ្យប្រជារាស្ត្រមិនហ៊ានប្រឆាំង ឬធ្វើអ្វីទាស់ខុសនឹងនយោបាយដឹកនាំរបស់ព្រះរាជាឡើយ។ នេះជាចិត្តសាស្ត្រនយោបាយយ៉ាងជ្រាលជ្រៅនៃលទ្ធិទេវរាជ។ ក្នុងន័យចិត្តសាស្ត្រនេះដែរនៅពេលយាងទៅណាមកណាព្រះបាទជ័យវរ្ម័នទី២ ទ្រង់បញ្ជាឱ្យគេយក**ទេវរូប**ដង្ហែរតាម

---

[១]ត្រឹង ងា,"ប្រវត្តិសាស្ត្រខ្មែរ",ដ.ឯ.ម, ទំព័រ ៧៩។

ដើម្បីឱ្យរាស្ត្រជឿ និង គោរពថា ទ្រង់ជាទេវរាជមួយអង្គ។ ជាងនេះទៀតព្រះ រាជាដែលជាតំណាងអាទិទេពខិតខំប្រឹងសម្តែងឫទ្ធានុភាពឱ្យ អស្ចារ្យឱ្យសក្តិសមជាអាទិទេពពិតៗនៅលើផែនដីនេះ។ ហេតុដូច្នេះហើយបានជាគេឃើញពីរជ្ជកាលមួយទៅរជ្ជកាលមួយព្រះរាជាដែលដើរតាមលទ្ធិទេវរាជខិតខំកសាងសមិទ្ធិផលមានប្រាសាទជាដើមកាន់តែធំ,កាន់តែច្រើន,កាន់តែល្អជាងរជ្ជកាលមុនៗជាដរាប។ នេះគឺជាបុព្វហេតុនៃព្រះកិត្តិយសក្នុងនាមជាជាស្តេចអាទិទេពនៅលើផែនដី[10]។ ព្រះរាជាថ្វីត្បិតតែព្រះ អង្គជា**អគ្គបញ្ញាការកងទ័ព** ប៉ុន្តែព្រះរាជាជាមេទ័ពដឹកនាំទ័ពចេញប្រយុទ្ធសត្រូវនៅសមរភូមិតែម្តង។ អត្ថបទសិលាចារិកជាច្រើនបានកោតសរសើរចំពោះគុណសម្បត្តិយោធារបស់ព្រះរាជាសុទ្ធសឹងតែមានតេជដៃខ្លាំងពូកែមានជ័យជំនះលើសត្រូវជានិច្ច។ នេះជាគំរូចិត្តសាស្ត្រដ៏ល្អមួយសម្រាប់បំផុសទឹកចិត្តក្លាហានរបស់ទាហានក្នុងការប្រយុទ្ធការពារទឹកដី,ពង្រីកអំណាច,ពង្រីកទឹកដីតាមលទ្ធិទេវរាជ។ ទាហានដែលមានគុណបំណាច់ចំពោះជាតិត្រូវបានលើកតម្កើងជាអតិបរមាដោយមានការកសាងរូបបដិមានិងប្រាសាទសម្រាប់រំលឹកគុណ។ គួរកត់សម្គាល់លើកត្តាចិត្តសាស្ត្រសំខាន់មួយទៀតថា ព្រះរាជាថ្វីត្បិតតែព្រះអង្គមានអំណាចដែលមានប្រភពមកពីអាទិទេពមានលក្ខណៈទូលំទូលាយក៏ពិតមែន ប៉ុន្តែ មិនមានន័យថាព្រះអង្គជាអ្នកកាន់អំណាចផ្តាច់ការទេព្រះអង្គត្រូវគោរពវិន័យវណ្ណៈក្សត្រិយៈ,គោរពសិក្ខាបទសាសនាពោល គឺទ្រង់ត្រូវប្រកបដោយ *ទសពិធរាជធម៌* សិលាចារិកព្រះគោស្តោកទី៣ និយាយពី ព្រះបាទឥន្ទ្រវរ្ម័នទី១ថា "**ស្រីឥន្ទ្រវរ្ម័នធ្វើឱ្យប្រជារាស្ត្រសម្បូរសប្បាយ ដោយការប្រត្តិបត្តិនូវវិន័យទាំង៣ប្រការ**"[11]។

សាសនាបើមើលមួយភ្លេតអាចនឹងយល់ស្របតាមទស្សនៈរបស់កាលម៉ាក្សដែលថា "**សាសនាជាអាភៀនចំពោះ មនុស្ស**"។ តែបើយើងសិក្សាវិភាគឱ្យស៊ីជម្រៅ យើងនឹងមើលឃើញពីសារៈសំខាន់របស់សាសនាដូចព្រះបាទជ័យវរ្ម័នទី២ជាមិនខានមើលឃើញជាពុំខាន។ សាសនាជាប្រភពនៃជំនឿ និងការដោះស្រាយបញ្ហាផ្លូវចិត្ត។ មនុស្សទូទាំងពិភពលោកមានចំនួនតែ១៦.៣% ប៉ុណ្ណោះដែលមិនជឿសាសនា។ បើបោះបង់ចោលសាសនា គឺបោះបង់ចោលជំនឿនិងការ ដោះស្រាយបញ្ហាផ្លូវចិត្ត (សាសនាគឺជាចំណីស្មារតីរបស់មនុស្ស)។ បើបោះបង់ចោលជំនឿ និងការដោះស្រាយបញ្ហាផ្លូវចិត្តគឺបោះបង់ចោលនូវទំនុកចិត្តនិងការឯកភាពជាតិ និយាយជារួម គឺបោះបង់ចោលនូវការរីកចម្រើនរបស់មនុស្សជាតិ នេះតែម្តងពីព្រោះ

[10] សរ សារុន,"វប្បធម៌និងអរិយធម៌ខ្មែរ(សម្រាប់ថ្នាក់ទីបញ្ចប់ ថ្នាក់ត្រៀមនៃឧត្តមសិក្សា)",បណ្ណាគារពន្លឺវិទ្យា ភាគ២,១៩៧០,ទំព័រ ១៥៥។

[11] ត្រឹង ង៉ា,"ប្រវត្តិសាស្ត្រខ្មែរ",ដ.ឯ.ម, ទំព័រ ១១០។

ភាពជោគជ័យក្នុងការងារអ្វីមួយមានការដឹកនាំជាតិការបង្រួបបង្រួមជាតិគឺសុទ្ធតែចាប់ផ្តើមពីការជឿ បើទុកចិត្តលើខ្លួនឯងក្តី លើអ្នកដទៃក្តី នោះ ការងារតូចធំសុទ្ធតែអាចសម្រេចបានទាំងអស់តែបើបាត់ជំនឿបាត់បង់ទំនុកចិត្តការងារងាយស្រួលយ៉ាងណាក៏ទៅមិនរួចដែរ។ ករណីដូចជាមនុស្សបាក់ទឹកចិត្តនៅក្នុងសមរភូមិ អ្នកមានវិបត្តិនៅក្នុងរឿងស្នេហ៍ បើសូម្បីតែខ្លួនឯងក៏មិនទុកចិត្តផងនោះ គឺគ្មានអ្វីដែលអាចធ្វើជាទីពឹងបាននោះមានតែផ្លូវបញ្ចប់ជីវិតមួយប៉ុណ្ណោះទើបដោះស្រាយបាន។ លោកចូបាយដិន (Joe Biden) ប្រធានាធិបតីអាមេរិក



ចូបាយដិនប្រធានាធិបតីអាមេរិក សុំទោសកូន
លោកចចផ្លយពីរឿងមរណភាពរបស់ឪពុកវា
ប្រភព ៖ joe biden News

ប្រហែល១០ដាង) ដែលត្រូវប៉ូលីសស្បែកសសង្កត់ករហូតដល់ស្លាប់ក្នុងរឿងរើសអើងពូជសាសន៍តាមគណិត លោកដោលណាត្រាំនៅក្នុងអណត្តិលោកដោលណាត្រាំ(Dolna Trum)។ នេះ ជាការដោះស្រាយបញ្ហាផ្លូវចិត្តដ៏សក្តិសិទ្ធមួយចំពោះអាមេរិកស្បែកខ្មៅជាមួយនឹងអាមេរិកស្បែកស។

នៅសម័យកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) សាសនាគ្រប់ទម្រង់ត្រូវបានបំផ្លាញចោល ដោយពួកខ្មែរក្រហម យល់ថា "**សាសនាគឺជាអាភៀនរបស់មនុស្ស**" តាមគន្លងទស្សនៈរបស់កាលម៉ាក្សដែលមានន័យដូចគ្នាថា "**សាសនាជាចំណីស្មារតីរបស់មនុស្ស**" ដែលធ្វើឱ្យមនុស្សវីវក់ឈ្ងក់ងប់ងល់វង្វេងវង្វាន់និងធ្វើឱ្យស្មារតីញៀនតែនឹងរឿងសាសនាផ្តាច់មិនបាន (ចំនួន ៨៣,៧%ត្រូវការសាសនា)។ នេះជារឿងឥតប្រយោជន៍។ ដោយមូលហេតុនៃទស្សនៈនេះហើយ ទើបបានជាពួកខ្មែរក្រហមបំបាត់ជំនឿសាសនាចោល ដោយគិតបូករួមទាំងព្រះពុទ្ធសាសនាផង។ នៅពេលអង្គការបំបាត់ជំនឿព្រះពុទ្ធសាសនាចោល តើវានឹងមានរឿងអ្វីកើតឡើងខ្លះក្នុងសង្គម?

វិស័យព្រះពុទ្ធសាសនាត្រូវបានបំបិទ មានន័យថា ទីវត្តអារាមនៃព្រះពុទ្ធ សាសនាក៏ត្រូវបានបំបិទទាំងស្រុង ព្រះ សង្ឃក៏ត្រូវបានផ្សឹកទាំងអស់នៅទូទាំងប្រទេស។ ហេតុនេះ ការបំបាត់ពុទ្ធ សាសនា មានន័យថា **បំបាត់ធម៌អហិង្សា, បំបាត់ការសន្តោសប្រណី, បំបាត់ការអធ្យា ស្រ័យ, បំបាត់ មនុស្សធម៌ ធ្វើឱ្យសង្គមគ្មានគុណធម៌, គ្មានច្បាប់ទម្លាប់, គ្មានការ ចែករំលែកសុខទុក្ខគ្នាទៅវិញទៅមក**។ ដាក់ស្តែងនៅក្នុងសង្គមនៃរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនរស់នៅដោយគ្មានសិទ្ធិសេរីភាពរស់នៅដោយភ័យខ្លាចរស់នៅក្រោមអំពើព្រៃផ្សៃ

យ៉ាងវេទនាជាទីបំផុត។ ***ការបំបាត់វត្តអារាម*** មានន័យថា ***បំបាត់អត្តសញ្ញាជាតិ, បំបាត់វប្បធម៌, អក្សរសាស្ត្រ, សាលារៀន, ប្រវត្តិសាស្ត្រ ក្បួន គម្ពីរផ្សេងៗជាដើម។*** ការរស់នៅក្នុង របបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនពុំមានសិទ្ធិធ្វើបុណ្យតាមប្រពៃណីជាតិទេ។ បុណ្យដែលសំខាន់ជាងគេនៃកម្ពុជាប្រជាធិបតេយ្យគឺថ្ងៃជ័យជំនះ ១៧ មេសា ១៩៧៥ ដែលអង្គការបានកំណត់យកជា ថ្ងៃបុណ្យចូលឆ្នាំថែមទៀតផង។ ការបំបាត់វត្តអារាមមានន័យថា បំបាត់សីលធម៌ចាស់ទុំទំនៀមទម្លាប់ប្រពៃណីព្រោះព្រះសង្ឃជាអ្នកប្រៀនប្រដៅសីលធម៌ និងជាអ្នកអប់រំបង្ហាញផ្លូវនៃជីវិតរស់នៅក្នុងសង្គមដល់ពុទ្ធបរិស័ទ។ ការបំបាត់វត្តអារាម មានន័យថា បំបាត់សាមគ្គីភាពក្នុងសង្គមបំបាត់ទំនាក់ទំនងសង្គម។ យើងឃើញថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យប្រជាជនរស់នៅក្រោមគោលជំហរដែលកំណត់ដោយអង្គការថា ***ឯករាជ្យម្ចាស់ការក្បាលអ្នកណាសក់អ្នកហ្នឹងខ្លួនទីពឹងខ្លួន***ជាដើម។

ដូចនេះ អវត្តមាននៃជំនឿពុទ្ធ សាសនាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពិតជាបានធ្វើឱ្យ សង្គមនាពេលនោះកើតមានបញ្ហាច្រើន ពិសេសការធ្វើឱ្យប្រជាជន រស់នៅក្នុងសភាពភ័យខ្លាចជាប់ជានិច្ច។ អង្គការបានប្រកាន់នូវមនោគមន៍វិជ្ជាបដិវត្តន៍ឆ្វេងនិយមជ្រុលបានធ្វើឱ្យកុមារយុវ ជនក៏ដូចជាជនបដិវត្តន៍មួយចំនួនមានចរិកដាច់ខាតមិនអាចសម្រុះសម្រួលបាន គឺបាត់បង់សីលធម៌ សុជីវធម៌ គុណធម៌ ការសន្តោស ការអធ្យាស្រ័យក្នុងសង្គម យើងឃើញមានតែការយកជាតិសាសន៍ ឯងធ្វើជាសត្រូវដោយចោទប្រកាន់ថាជា ខ្មាំងប្រឆាំងបដិវត្តន៍ ហើយនិងការសម្លាប់ ជាតិសាសន៍ឯងដោយមិនញញើត[12]។ គឺការមានគំនិត "***សាសនាជាអាភៀនរបស់ មនុស្ស***" តាមទស្សនៈកាលម៉ាក្សនេះ ហើយទើបបានជាពួកខ្មែរក្រហម***ធ្វើបដិវត្តន៍វប្បធម៌*** សំដៅលាងខួរក្បាលមនុស្សដែលនាំឱ្យរបបនេះក្លាយជារបបទមិឡតិច្ចានគួរឱ្យស្អប់និងខ្ពើម ដែលអ្នកស្រាវជ្រាវខ្លះឱ្យឈ្មោះថា ***របបឆ្នាំសូន្យ*** ឬ ***របបគុកឥតជញ្ជាំង។*** គំនិតដឹកនាំបែបនេះ មានលក្ខណៈអវិជ្ជមានខ្លាំងចំពោះ អភិវឌ្ឍន៍សុខុមាលភាពសង្គម និងមនុស្ស ហេតុដូចនេះហើយបានជារបបនេះត្រូវ វិនាសអន្តរធានក្នុងរយៈពេលដ៏ខ្លី ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ។

ដោយមើលឃើញពីគ្រោះថ្នាក់នៃ អវត្តមានជំនឿសាសនា ពិសេសព្រះពុទ្ធ សាសនានៅក្នុងនយោបាយដឹកនាំប្រទេស ទើបក្រោយថ្ងៃរំដោះ៧ មករា ១៩៧៩ វិស័យព្រះពុទ្ធសាសនាត្រូវបានបើកឱ្យដំណើរការជាដរាបរហូតមកដល់សព្វថ្ងៃ។

---

[12] ណុន សុខា "អវត្តមានជំនឿពុទ្ធសាសនានៅក្នុង សង្គមខ្មែរ ករណីសិក្សាសម័យកម្ពុជាប្រជា ធិបតេយ្យ", រាជបណ្ឌិត្យសភាកម្ពុជា, ឆ្នាំ ?, ទំព័រ ទី១-២។

## សេចក្ដីសន្និដ្ឋាន

ជាសេចក្ដីសន្និដ្ឋាន ***កត្តាសាសនា*** គឺជាកម្លាំងឬជាអាវុធដ៏ពិសិដ្ឋមួយ។ ***កម្លាំង*** ឬ ***អាវុធនេះ*** អាចមានសក្ដានុពលបែបណាមួយបានក៏អាស្រ័យទៅលើ***កត្តាមនុស្ស***។ នេះមានន័យថា ***សាសនាល្អ*** ឬ យ៉ាងណាមួយ គឺវាអាស្រ័យទៅលើបទពិសោធន៍យល់ដឹងរបស់មនុស្ស។ ករណីព្រះបាទជយវរ្ម័នទី២ ទី៧ ដែលមើលឃើញ***សាសនា***ទៅតាមផ្លូវមួយដ៏មានសក្ដានុពលសម្រាប់បង្រួបបង្រួម និងអភិវឌ្ឍន៍ជាតិ។ ចំណែកឯ ប៉ុល ពតមើលឃើញ***សាសនា***ទៅតាមផ្លូវមួយថាជាគ្រឿងញៀនទៅវិញ។ មនុស្សមើល ឬយល់ឃើញបែបណាវាអាស្រ័យលើ ***បទពិសោធន៍***របស់ពួកគេ ហើយពួកគេក៏យកទៅអនុវត្តន៍បែបនោះដែរ។ ហេតុនេះ មនុស្សត្រូវតែមានបទពិសោធន៍ទៅក្នុងសម្មាទិដ្ឋិ និងសម្មាសង្កប្បចំពោះអ្វីៗដែលនៅជុំវិញខ្លួនពួកគេដើម្បីនាំទៅរកសក្ដានុពលនៃអភិវឌ្ឍន៍បែតង។ ខុង ជឺ ពោលថា"អ្វីៗទាំងអស់សុទ្ធតែបែតង តែមានមនុស្សតិចតួចណាស់ដែលមើលឃើញពីភាពបែតងនេះ"។

## គន្ថនិទ្ទេស


1. ត្រឹង ង៉ា, "*ប្រវត្តិសាស្ត្រខ្មែរ ភាគ១ និង ២ (សម្រាប់មធ្យមនិងឧត្តមសិក្សា)*", ភ្នំពេញ, ព.ស. ២៥១៧, គ.ស. ១៩៧៣
2. ណុន សុខា "*អវត្តមានជំនឿពុទ្ធសាសនានៅក្នុងសង្គមខ្មែរ ករណីសិក្សាសម័យកម្ពុជាប្រជាធិបតេយ្យ*", រាជបណ្ឌិត្យសភាកម្ពុជា, ឆ្នាំ ?
3. *វស់ ចន្ទ្រាបុត្រ "ប្រវត្តិសាស្ត្រខ្មែរភាគ ១ (ភាគ រឿងព្រេងនិទាននិងតាមរយៈ សិលាចារឹក)*
4. សរ សារុន,"*វប្បធម៌និងអរិយធម៌ខ្មែរ (សម្រាប់ថ្នាក់ទីបញ្ចប់ ថ្នាក់ត្រៀមនៃឧត្តមសិក្សា)*", បណ្ណាគារពន្លឺវិទ្យា ភាគ ២, ១៩៧០
5. ហ. មណីចិន្តា, *ព្រះបាទជម្ពូក*, អន្ទង់ វិល, បោះពុម្ពលើកទី៣, ១៩៩៦
6. https://www.photodharma.net/Indonesia/26-Prambanan/index.htm

# ស្វែងយល់ពីពិធីបុណ្យភ្ជុំបិណ្ឌ

*ដោយៈ លោកស្រីបណ្ឌិត* **ជា វណ្ណី**
*ប្រធាននាយកដ្ឋានធម្មសាស្ត្រ ចរិយាសាស្ត្រ និង យេនឌ័រ*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*
*នៃរាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

***ពិធីបុណ្យភ្ជុំបិណ្ឌ*** *ជាពិធីបុណ្យមួយក្នុងចំណោមពិធីបុណ្យធំៗនៃព្រះរាជពិធីទ្វារទេសមាស។ ប្រជាជនខ្មែរទូទាំងព្រះរាជាណាចក្រកម្ពុជាតាំងពីបុរាណរៀងមក (ពុំដឹងពេលណាច្បាស់លាស់) តែងតែនាំគ្នាប្រារព្ធពិធីបុណ្យនេះមិនដែលអាក់ខានឡើយ គឺចាប់ពីថ្ងៃ១រោច ខែភទ្របទ រហូតដល់ថ្ងៃទី១៥រោច ដែលមាន រយៈពេល១៥ថ្ងៃ។ ក្នុងរយៈពេល១៥ថ្ងៃនេះ យើងហៅថា បិណ្ឌទី១ បិណ្ឌទី២... រហូតដល់ថ្ងៃបញ្ចប់គឺជាថ្ងៃ"**ភ្ជុំបិណ្ឌ**"។ បុណ្យភ្ជុំបិណ្ឌ ត្រូវបានធ្វើឡើងតាមបែបព្រះពុទ្ធសាសនា។ ជារៀងរាល់ឆ្នាំនៅពេលដល់វេលាដែលត្រូវប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ បងប្អូនកូនចៅជាសាច់ញាតិសន្តានទាំងអស់ទោះនៅទីជិតឬទីឆ្ងាយក្តី តែងតែធ្វើដំណើរទៅជួបជុំគ្នាជាមួយឪពុកម្តាយដើម្បីរៀបចំម្ហូបអាហារផ្កាភ្ញីយកទៅប្រគេនព្រះសង្ឃដែលគង់នៅតាមទីវត្តអារាម។*

## ១.ប្រវត្តិបុណ្យភ្ជុំបិណ្ឌ

*ពាក្យថា "**ភ្ជុំបិណ្ឌ**" មកពីពាក្យ "ភ្ជុំ" រួមគ្នាជាមួយពាក្យ "**បិណ្ឌ**" ដែលមានន័យថា ភ្ជុំគឺការប្រមូលផ្តុំ ឬប្រជុំបិណ្ឌ។ បើតាមវចនានុក្រម សម្តេច ជួន ណាត លោកបានពន្យល់ថាៈ ភ្ជុំ (កិ.) ធ្វើឱ្យជុំ,ឱ្យជួបជុំគ្នា,ឱ្យប្រជុំគ្នាៈ ភ្ជុំគ្នា,ភ្ជុំពល។ ភ្ជុំជាតក ឬ ភ្ជុំជាតិ រួបរួមជាតិកំណើតពួកអ្នកដែលអន្ទោលមកកើតជួបគ្នា ដោយព្រះសព្វញ្ញុពុទ្ធទ្រង់សរញ្ញាណឃើញច្បាស់ហើយទ្រង់ត្រាស់សម្តែងប្រាប់។ ភ្ជុំបិណ្ឌ(ម.ព.បិណ្ឌ)។ បិណ្ឌ បិន-ឌៈ ឬ បិន សំ. បា.(ន.) ការប្រមូលឱ្យមូលឬពូនឱ្យជាដុំ, ដុំ; ការចិញ្ចឹមជីវិត។ ខ្មែរយើងប្រើពាក្យនេះជាឈ្មោះនៃវិធីធ្វើទានមួយយ៉ាង (តាមប្រពៃណីរបស់ប្រទេស) ធ្វើបានពីត្រឹម*

ថ្ងៃទី១រោច ខែភទ្របទទៅដល់ថ្ងៃខែដាច់ (១៥ថ្ងៃ)...ហៅថា បុណ្យកាន់បិណ្ឌ ឬបុណ្យរោច ខែភទ្របទ ហៅថា ថ្ងៃភ្ជុំបិណ្ឌ... ឧបាសកឧបាសិកាតែងទៅប្រជុំគ្នាធ្វើទានឯវត្ត មិនសូវមានអ្នកណាមួយខានឡើយ។ ដូច្នេះយើងអាចសម្គាល់ពាក្យនេះតាមវិធីងាយបានថា គឺជា "ការប្រជុំ ឬប្រមូលផ្តុំដុំបាយ"(ការពូតដុំបាយជាដុំៗដែលយើងហៅថា "បាយបិណ្ឌ")។

បើតាមតម្រាចារតាមប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាយើងបានបង្ហាញថា ពិធីបុណ្យភ្ជុំបិណ្ឌគឺកើតមានតាំងពីបុរាណកាលមកម៉្លេះ ដោយនៅក្នុងពិធីនេះគេមានបែងចែកចេញជាពីរដំណាក់កាល។ ដំណាក់កាលដំបូង គឺគេចាប់ផ្តើមធ្វើចាប់ពីថ្ងៃ១រោច រហូតដល់ថ្ងៃ១៤រោច ជាវារកកត្ត(កត្តធ្វើតាមថ្ងៃ) ជាបន្តបន្ទាប់។ ចំណែកមួយដំណាក់កាលទៀតគេធ្វើនៅថ្ងៃ១៥រោច ដែលគេហៅថាបុណ្យភ្ជុំ ហើយពិធីបុណ្យទាំងពីរដំណាក់កាលនេះ បច្ចុប្បន្នត្រូវបានគេបញ្ចូលគ្នា ដោយហៅកាត់ថា ពិធីបុណ្យភ្ជុំបិណ្ឌ។ ពាក់ព័ន្ធនឹងពិធីបុណ្យភ្ជុំបិណ្ឌនេះ មានគម្ពីរ៣ ដែលបកស្រាយពីពិធីបុណ្យកាន់បិណ្ឌគឺ៖

**១. គម្ពីរបេតវត្ថុ៖** បកស្រាយពីរឿងប្រេត គម្ពីរអានិសង្សបិណ្ឌនិយាយអំពីផលនៃការធ្វើបុណ្យដាក់បិណ្ឌ, ហៅខ្លីត្រឹមតែ កាន់បិណ្ឌ ឬដាក់បិណ្ឌ ក៏បាន; ថ្ងៃ១៥

**២. គម្ពីរពិទ្យាធរ ឬគម្ពីរវិជ្ជាធរ៖** តំណាអំពីប្រពៃណីរបស់ជាតិខ្មែរ ដែលមានជាប់ទាក់ទងមកដល់សព្វថ្ងៃ។

**៣.គម្ពីរវិមានវត្ថុ៖**

គម្ពីរធម្មបទជាដើម...។

បើតាមគម្ពីរ "ពិទ្យាធរ ឬវិជ្ជាធរ" មានតំណាលថា កាលនោះមានព្រះថេរៈមួយអង្គព្រះនាម ឧបគុត្តត្ថេរ លោកមានអំណាចមានឥទ្ធិពលច្រើនណាស់ លោកក៏បាននិមន្តទៅធ្វើទស្សនកិច្ចនៅស្ថាននរក ដែលពោរពេញដោយភ្លើងឆេះយ៉ាងសន្ធោរសន្ធៅក្តៅខ្លាំងប៉ុន្តែដោយឥទ្ធិពលរបស់លោកក៏មានលេចចេញនូវផ្កាឈូករ័ត្នមួយធំប៉ុនកងរាជរថ រួចលោកក៏គង់នៅលើផ្កាឈូកនោះ ហើយផ្កាឈូកនោះក៏ហោះកាត់ស្ថាននរកដែលធ្វើឱ្យព្រះអង្គត្រជាក់ស្រួលមិនបណ្តាលឱ្យប៉ះពាល់ដល់ភ្លើងកម្តៅស្ថាននរកឡើយ។ រីឯពួកសត្វនរកវិញគ្រាន់តែដឹងថាព្រះឧបគុត្តត្ថេរ លោកនិមន្តទៅភ្លាមក៏ធ្វើឱ្យពួកសត្វនរកទាំងនោះដោយមានការភ្ញាក់ផ្អើលជាខ្លាំងៗ ពួកសត្វនរកទាំងនោះមានការកោតខ្លាចនូវភាព អស្ចារ្យនេះយ៉ាងខ្លាំង ក៏នាំគ្នាចុះមកអបអរសាទរ ហើយសួរអំពីឫទ្ធិបារមីរបស់ព្រះអង្គ លោកក៏បានពន្យល់សម្តែងធម៌ទេសនាឱ្យពួកសត្វនរកទាំងនោះស្តាប់។ ក្រោយមកលោក

ក៏បានលាត្រឡប់មកស្ថានមនុស្សវិញ ហើយពួកសត្វនរកទាំងនោះបានផ្តាំផ្ញើថា៖"ទូលព្រះបង្គំទាំងអស់គ្នាសព្វថ្ងៃនេះលំបាកវេទនាណាស់ ណាមួយកម្តៅភ្លើងនរកណាអត់អាហារមិនដែលមានសាច់សាលោហិតណាលើកយកអាហារភោជន ឬបច្ច័យបួនមកឧបត្ថម្ភម្តងណាទេ គឺពួកខ្ញុំអត់ឃ្លាននោះខ្លាំងណាស់រោគាព្យាធិជំងឺតម្កាត់ក៏មានច្រើនដែរ អ៊ីចឹងបើព្រះតេជគុណនិមន្តទៅស្ថានមនុស្សលោកវិញ សូមព្រះតេជគុណមេត្តាផ្សព្វផ្សាយឱ្យបងប្អូនញាតិមិត្ត ម៉ែ ឪ ជីដូន ជីតា របស់ខ្ញុំឱ្យធ្វើបុណ្យ និមន្តព្រះសង្ឃមកដាក់បិណ្ឌ ឬកាន់បិណ្ឌផង រួចហើយផ្សព្វផ្សាយពរសព្វសាធុការផល្លានិសង្ឃ បុណ្យដាក់បិណ្ឌដល់ទូលព្រះបង្គំទាំងអស់គ្នាផង ដើម្បីឱ្យបានផលជួបឧបត្ថម្ភឱ្យបានឆ្អែតស្កប់ស្កល់បាត់ទុក្ខវេទនាតទៅ"។

**ព្រះឧបគុត្តត្ថេរ** ក៏នាំយកបណ្តាំទាំងនោះទៅក្រាបបង្គំទូលស្តេចនាពេលនោះទៅ។ គ្រាន់តែថ្វាយព្រះពរប៉ុណ្ណឹង ស្តេចក៏ធ្វើជាចុតហ្មាយផ្សព្វផ្សាយដល់ប្រជារាស្ត្រគ្រប់ៗគ្នាក្នុងអាណាចក្រ ដើម្បីឱ្យប្រជារាស្ត្រទាំងអស់ធ្វើបុណ្យដាក់បិណ្ឌ ឬកាន់បិណ្ឌនៅក្នុងរដូវវស្សា ដោយផ្តាំផ្ញើទៀតថា ឱ្យធ្វើឱ្យចំនៅថ្ងៃ១រោច ខែកទ្រូបទ រហូតដល់ ថ្ងៃ១៥រោច ខែកទ្រូបទ ឬដាច់ខែ។ ដោយហេតុនេះហើយដែលនាំឱ្យមានពិធីកាន់បិណ្ឌជាប្រពៃណី តាំងពីពេលនោះរហូតមកដល់សព្វថ្ងៃនេះ។

## ២. មូលហេតុនៃការប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌ

ប្រជាជនខ្មែរក៏តែងតែចងចាំ និងយល់គ្រប់ៗគ្នាថា "បុណ្យភ្ជុំបិណ្ឌ" គឺជាការធ្វើបុណ្យដាក់បិណ្ឌ ដើម្បីឧទ្ទិសដល់បេតបុគ្គល ជាឪពុកម្តាយ បងប្អូន ឬញាតិសន្តានទាំងឡាយ ដែលបានចែកស្ថានទៅ ហើយមិនដឹងជាទៅចាប់កំណើតជាអ្វីៗ ប៉ុន្តែបើតាមអត្ថបទរបស់លោក សុង ស៊ីវ វិញការធ្វើបុណ្យភ្ជុំបិណ្ឌពុំមែនមានន័យតែប៉ុណ្ណឹងទេ គឺលោកបានបកស្រាយដោយលើកយកអត្ថន័យថា៖

- ដើម្បីឧទ្ទិសកុសលចំពោះបេតបុគ្គល ឬប្រេតបុគ្គល (ពាក្យ "បេត" ជាពាក្យបាលី ឯពាក្យ "ប្រេត" ជាពាក្យសំស្ក្រឹត) ដើម្បីឱ្យបានសេចក្តីសុខចម្រើន មានសិរីសួស្តីដែលកើតពីផលទានរបស់ខ្លួន តាមរយៈការប្រគេនចង្ហាន់ និងទេយ្យវត្ថុដល់ព្រះសង្ឃក្នុងអំឡុងពេលគង់ចាំព្រះវស្សា។
- ដើម្បីបង្កើតសាមគ្គីរបស់ជាតិ គឺការស្រុះស្រួលគ្នាទាំងពេលវេលាកំណត់ទាំងការធ្វើនំគម អន្សម ពេញទូទាំងព្រះរាជាណាចក្រកម្ពុជា យើងក៏អាចកត់សម្គាល់នូវពាក្យមួយទៀតថា "បុណ្យសែនដូនតា" ដែលជាពាក្យសាមញ្ញសម្រាប់ប្រជារាស្ត្រខ្លះ ព្រោះថាពាក្យទាំងពីរគឺមានន័យដូចគ្នា។

កាលពីសម័យបុរាណកាល គេធ្វើពិធីបុណ្យនេះ គឺដើម្បីរៀបចំធ្វើសង្ឃកត្ត ទំនុកបម្រុងព្រះសង្ឃដែលគង់ចាំវស្សាក្នុងវត្តរយៈ

ពេល៣ខែ ចាប់ពីថ្ងៃចូលវស្សារហូតដល់ថ្ងៃចេញវស្សា។ នៅក្នុងចំណោរកាលបុរាណបានចារថា ដោយនៅក្នុងរដូវវស្សាមានភ្លៀងធ្លាក់ជោកជាំ រលឹមពព្រិចធ្វើឱ្យមានការលំបាកដល់ព្រះសង្ឃក្នុងពេលធ្វើគោចរបិណ្ឌបាត។ ហេតុដូច្នេះទើបបណ្ដាពុទ្ធបរិស័ទនាំគ្នារៀបចំពិធីនេះ ដើម្បីផ្គត់ផ្គង់ព្រះសង្ឃប្រចាំថ្ងៃរហូតដល់ថ្ងៃចេញវស្សា។ ម្យ៉ាងវិញទៀតនៅក្នុងពិធីបុណ្យនេះ គឺធ្វើឡើងដើម្បីផ្សាយឧទ្ទិសកុសលដល់ពពួកបេតជនញាតិ និងញាតិទាំង៧សន្ដានព្រមទាំងតំណញាតិច្រើនមហាកប្បនោះផងដែរ តាមរយៈអនុភាពនៃសង្ឃគតាទក្ខិណាទានដែលរស់រងទុក្ខវេទនា កើតជាប្រេតមានកម្មពៀរ ជាប់ទោសធ្ងន់រងកម្មក្រហល់ក្រហាយអត់ឃ្លានទាំងអស់នោះ បានរួចផុតពីក្ដីលំបាកសោកសៅ។

## ៣. រដូវបុណ្យភ្ជុំបិណ្ឌ

ចាប់តាំងពីសម័យបុរាណកាលរហូតមកដល់បច្ចុប្បន្ននេះ ពិធីបុណ្យភ្ជុំបិណ្ឌនេះ គេតែងតែប្រារព្ធនៅក្នុងរដូវវស្សា ព្រោះនៅក្នុងរដូវនេះពពួកប្រេតអាចមានឱកាសច្រើនក្នុងការស្វែងរកចំណីអាហារជាងរដូវផ្សេងៗទាំងអស់។ ម្យ៉ាងវិញទៀតនៅក្នុងវស្សានរដូវ អាហាររបស់ពួកប្រេត ដូចជាកក់ជ្រាំ ស្ទេស្នំ កំហាក សាកសព និងកាកសំណល់អសោចិ៍សម្បូរនៅក្នុងខែភ្លៀងផ្គរពព្រិច។ នៅក្នុងរដូវបុណ្យភ្ជុំបិណ្ឌរយៈពេល១៥ថ្ងៃនេះ មានពពួកបេតជន (ពួកប្រេត) សាច់ញាតិទាំងប្រាំពីរសន្ដាន ព្រមទាំងតំណញាតិច្រើនមហាកប្ប ដែលអត់ឃ្លានអាហារអស់រយៈពេលជាច្រើនខែមកហើយនោះ ត្រូវបានរួចផុតពីការឃុំឃាំងអនុញ្ញាតឱ្យមកស្វែងរកសាច់ញាតិនៅតាមវត្តអារាមផ្សេងៗ ដែលនាំយកចំណីអាហារផ្សេងៗ មកឧទ្ទិសកុសលឱ្យខ្លួន។ ម្យ៉ាងវិញទៀត បើតាមសម្ដីចាស់ៗបុរាណនិយាយតៗគ្នាថា ក្នុងរយៈពេល១៥ថ្ងៃ បើពពួកបេតជនទាំងអស់នោះដើរស្វែងរកញាតិចំនួន៧វត្ត នៅតែមិនឃើញនោះ ពពួកប្រេតទាំងអស់នោះនឹងស្រែកយំទន្ទ្រាំដើង ព្រោះតែការខកបំណងនិងភាពស្រេកឃ្លានក្រហល់ក្រហាយក្នុងចិត្ត។ ជាពិសេស មានបុគ្គលខ្លះជំនឿថា ពពួកបេតជនទាំងអស់នោះ នឹងជេរដាក់បណ្ដាសាដល់សាច់ញាតិកូនចៅ។

## ៤. ការប្រារព្ធពិធីបុណ្យបិណ្ឌភ្ជុំ

ចំពោះបុណ្យបិណ្ឌភ្ជុំនេះ បុរាណាចារ្យរាជបណ្ឌិតខ្មែរបានរៀបចំរយៈពេល១៥ថ្ងៃ ដោយចាប់គិតពីថ្ងៃទី១រោច ដល់ថ្ងៃទី១៥រោច ខែភទ្របទ ជាពិធីមួយសម្រាប់ឧទ្ទិសកុសលទៅដល់បេតជនញាតិដែលបានស្លាប់ទៅ។ នៅក្នុងរយៈពេល១៤ថ្ងៃ នៃការកាន់បិណ្ឌឬដាក់បិណ្ឌនេះ ពុទ្ធបរិស័ទចំណុះជើងវត្តទាំងអស់ ជាពិសេសក្រុមនីមួយៗដែលបានរៀបចំជាក្រុមដើម្បីរៀបចំធ្វើយាគូ ឬធ្វើកត្តាហារ។ ពេលទូងស្គរចំណាំវស្សា អ្នកនៅក្នុងក្រុមវេននីមួយៗត្រូវចាប់ផ្ដើមធ្វើចង្ហាន់ ហើយយាយតាចាស់ៗក្នុង

ក្រុមវេន ប្រមូលនំនែករៀបចំបាយបិណ្ឌនិងបាយបិត្តបូរ។ រៀបចំរួចហើយត្រូវនាំគ្នាទៅវត្តស្តាប់លោកសូត្រថ្វាយបង្គំធម៌ សុខោ និងធម៌បរាភវសូត្រ។ ចំណែកឯកូនចៅដែលនៅផ្ទះនាំគ្នារៀបចំម្ហូបអាហារ។ លុះដល់ពេលព្រឹកព្រាងអរុណោទ័យ កូនចៅត្រូវនាំគ្នារៀបចំខ្លួនប្រាណកណ្តៀត យួរ កាន់ ទូល រែកចង្ហាន់ទៅវត្ត។ នៅក្នុងវត្ត លោកអាចារ្យត្រូវរៀបចំពីធីរាប់បាត្រនៅលើឧបដ្ឋានសាលា។ បន្ទាប់មកលោកអាចារ្យជាប្រធានត្រូវនាំពុទ្ធបរិស័ទវេរចង្ហាន់ប្រគេនព្រះសង្ឃ វេរបាយបិត្តបូរ។ល។ លុះដល់ពេលព្រះសង្ឃធ្វើបត្តានុមោទនគាថាចប់ មេវេនក្រុមនីមួយៗត្រូវរៀបចំម្ហូបអាហារ នំចំណី ចូលគំនាប់ជូនលោកអាចារ្យវត្ត ព្រមទាំងចាត់ចែងភោជនាហារទទួលភ្ញៀវដែលអញ្ជើញទៅបុណ្យនៅក្នុងថ្ងៃវេនរបស់ខ្លួននោះផងដែរ។ ការប្រគេនចង្ហាន់ដល់ព្រះសង្ឃ ត្រូវបានធ្វើឡើងដើម្បីឧទ្ទិសកុសលឱ្យទៅជីដូនជីតា ឪពុកម្តាយបងប្អូន និងញាតិទាំង៧សន្តាន ដែលបានស្លាប់ក្លាយជាប្រេត ហើយត្រូវបានជាប់ឃុំនៅក្នុងនរក។ ក្នុងការបើកទ្វារនរកនេះ ប្រេតខ្លះមានឱកាសរួចផុតពីការជាប់ទារុណកម្មនៅនរក ខណៈដែលខ្លះទៀតត្រូវបានគេដោះលែងឱ្យនៅក្រៅនរកជាបណ្តោះអាសន្ន ដើម្បីទៅទទួលយកនូវចំណី និងកុសលផលបុណ្យដែលកូនចៅបានឧទ្ទិសឱ្យ ហើយនឹងត្រូវត្រឡប់ទៅទទួលទុក្ខវេទនានៅក្នុងនរកបន្តទៀត បន្ទាប់ពីពិធីភ្ជុំបិណ្ឌនេះត្រូវបានបញ្ចប់។ ចំពោះញាតិសន្តានដែលមិនបាននៅក្នុងនរកក៏ដោយក្តី ក៏ត្រូវបានគេចាត់ទុកថាអាចទទួលបាននូវកុសលពីការឧទ្ទិសក្នុងពិធីបុណ្យនេះផងដែរ។

ក្នុងថ្ងៃបុណ្យភ្ជុំមានការរៀបចំកញ្ចប់ចតុប្បច្ច័យ(ស៊ីង)ប្រគេនគ្រប់ភិក្ខុសាមណេរ ហើយគណៈកម្មការវត្តបានចាត់ចែងនំអន្សម នំគម និងបាយបិត្តបូរឱ្យទៅសិស្សគណ ទុកប្រគេនភិក្ខុសាមណេរតាមចំណែកសម្រាប់ធ្វើចង្ហាន់នៅព្រឹកថ្ងៃបន្ទាប់។ ម្យ៉ាងវិញទៀត ថ្ងៃបុណ្យភ្ជុំបិណ្ឌនេះ កាលពីសម័យបុរាណមានលេងល្បែងប្រណាំងក្របី សេះ ចាប់ពី២-៣គូទៅតាមតំបន់រៀងៗខ្លួន ដើម្បីអបអរនៅក្នុងថ្ងៃបុណ្យឆ្លងបង្ហើយ។ លើសពីនេះទៅទៀតក្របី សេះ និងរបស់ដែលត្រូវប្រកួត គេបានតុបតែងលំអដោយប្រេងលាបពណ៌រលើបរលោង មានពាក់ប្រឡៅ កណ្តឹងត្រដោក ឬចង្រ្កងជាដើម។ កន្លែងខ្លះទៀតមានលេងល្បែងផ្សេងៗខុសពីនេះ។ ប៉ុន្តែរហូតមកដល់ពេលបច្ចុប្បន្ននេះ ទំនៀមទម្លាប់នេះចេះតែបាត់ទៅៗ រួញថយបន្តិចម្តងៗសាសនាកាន់តែកន្លងវែងទៅនាំឱ្យការប្រកាន់ខ្ជាប់នោះ ស្ទើរតែបាត់បង់ច្រើនណាស់ដែរ។

## ៥. ទំនាក់ទំនងបុណ្យភ្ជុំបិណ្ឌ និង បុណ្យចូលវស្សា

បើតាមសង្ឃដីការបស់សម្តេចព្រះមង្គលទេពាចារ្យ អ៊ុំ ស៊ុម បានឱ្យដឹងថា នៅ

សម័យដើម គឺក្រោយពេលដែលព្រះពុទ្ធសាសនាបានផ្សាយចូលមកក្នុងប្រទេសខ្មែរយើងហើយនោះ ភិក្ខុសង្ឃបាននិមន្តទៅបិណ្ឌបាតគ្រប់ច្រកល្ហករាល់ពេលវេលាដោយមិនគិតពីរដូវវស្សា រដូវប្រាំង រដូវក្តៅ ឬរដូវរងាឡើយ។ លុះដល់សម័យស្តេចសោយរាជ្យ គឺរង្ស៊ី" ជ័យវរ្ម័ន" ព្រះអង្គមានព្រះទ័យជ្រះថ្លានឹងព្រះពុទ្ធសាសនា ក៏បានឧបត្ថម្ភព្រះសង្ឃដែលបួសក្នុងព្រះពុទ្ធសាសនា ដោយបច្ច័យបួន មានចង្ហាន់ បិណ្ឌបាត្រ សេនាសណៈ ភេសជ្ជៈនិងចីវរ។ ក្រោយមកទៀត ព្រះអង្គទ្រង់ឈ្វេងយល់ថា នៅរដូវវស្សាព្រះសង្ឃនិមន្តចេញទៅបិណ្ឌបាត្រនោះជួបប្រទះនូវការលំបាកខ្លាំងណាស់ ដូចជា ភ្លៀង ផ្គររន្ទះ ខ្យល់បក់បោកដែលបណ្តាលឱ្យព្រះសង្ឃអង្គខ្លះត្រូវដួលលើភក់ជ្រាំនោះ ក៏នាំឱ្យព្រះអង្គកើតព្រះទ័យសង្វេគផង ជ្រះថ្លាផង ហើយក៏បានបវរណាដល់ព្រះសង្ឃក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យនិមន្តគង់នៅក្នុងវត្តហើយកុំនិមន្តចេញបិណ្ឌបាត្រឯណា ក្នុងរយៈពេល៣ខែ។ មិនតែប៉ុណ្ណោះព្រះអង្គក៏បានធ្វើព្រះរាជប្រកាសផ្សព្វផ្សាយឱ្យប្រជារាស្ត្រទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ជួយឧបត្ថម្ភបច្ច័យបួនដល់ព្រះសង្ឃក្នុងរយៈពេលនៃរដូវវស្សាកុំឱ្យព្រះសង្ឃនិមន្តបិណ្ឌបាត្រនៅខាងក្រៅទៀត។ ការអនុវត្តបែបនេះចេះតែក្លាយបន្តិចម្តងៗ ប្រជារាស្ត្រក៏ធ្វើតាមព្រះរាជារហូតមក គឺឱ្យតែដល់រដូវវស្សា រយៈពេល ៣ ខែ ដោយគិតចាប់ពីថ្ងៃ១រោច ខែអាសាឍ ដល់ថ្ងៃពេញបូរមីខែអស្សុជមិនឱ្យព្រះសង្ឃទៅណាទេ (នៅសម័យនោះគេដាក់បិណ្ឌក្នុងរយៈពេល៣ខែតែក្រោយៗមកក៏សល់រយៈពេលតិចទៅៗរហូតមកដល់សព្វថ្ងៃ អាស្រ័យដោយកត្តាជីវភាពរស់នៅក្នុងសង្គមមានការប្រែប្រួល)។

## ៦. បរាភវសូត្រ

បរាភវសូត្រ (អានថា ប៉ៈ រ៉ា ភៈ វៈ សូត) តែងត្រូវបានព្រះសង្ឃសូត្រនៅក្នុងព្រះវិហារជារៀងរាល់ថ្ងៃនាពេលទៀបភ្លឺនៅក្នុងអំឡុងពេលបុណ្យកាន់បិណ្ឌ។ បរាភវសូត្រមានន័យថា « មាត្រាដែលពោលពីធម្មជាតិដែលគ្មានក្តីចម្រើន ឬធម៌ជាហេតុនាំឱ្យមានក្តីវិនាស»។[1] ធម៌នេះធ្វើឱ្យអ្នកស្តាប់បានដឹងច្បាស់ពីមូលហេតុដែលនាំឱ្យវិនាស ហើយឱ្យគេជៀសវាង ដើម្បីគេចឱ្យផុតពីក្តីវិនាស ហើយប្រសិនបើគេមិនបានស្តាប់ធម៌នេះ គេអាចនឹងមិនដឹងពីហេតុដែលនាំឱ្យវិនាសហេតុនេះអាចនឹងប្រព្រឹត្តខុសជាហេតុនាំឱ្យវិនាសទៅវិញ។ ក្នុងនោះព្រះពុទ្ធបានបង្រៀនពីហេតុផលសាមញ្ញៗ និងជាក់ស្តែងដូចជាថា បុគ្គលដែលមានវ័យចំណាស់ពេកហើយយកមនុស្សក្មេងជាប្រពន្ធប្តី ភាពជាបុគ្គលអកត្តញ្ញូ មិនដឹងគុណឪពុកម្តាយ អ្នកលេងល្បែង៣ប្រការ គឺល្បែងស្រី ល្បែងស្រា និងល្បែងភ្នាល់

1 សូត្រនេះមាននៅក្នុងគម្ពីរសុត្តន្តបិដកខុទ្ទកនិកាយ សុត្តនិបាត តតិយភាគទី៥២ ទំព័រទី៣៦។

គ្រប់ប្រភេទ ភាពជាអ្នកខ្ជិលច្រអូសជាដើម ហេតុនាំមកនូវក្ដីវិនាស។

## ៧. ការបោះបាយបិណ្ឌ

នាពេលព្រលឹម វេលាម៉ោង៤ព្រឹក ប្រជាពលរដ្ឋតែងតែនាំគ្នាដើរទៅវត្តអារ៉ាមនានានៅក្នុងភូមិឬនៅក្បែរផ្ទះរបស់ខ្លួនជាមួយនឹងនំចំណីដែលធ្វើរួចជាស្រេចដើម្បីទៅវត្ត។ ការបោះបាយបិណ្ឌជាជំនឿអរូបិយមួយផងដែរ ដែលប្រជាពលរដ្ឋខ្មែរយើងនិយមធ្វើជារៀងរាល់ព្រឹក ដើម្បីបញ្ជូនឬឧទ្ទិសកុសលឱ្យទៅញាតិសន្ដានសាច់សាលោហិតដែលបានចែកឋានទៅបរលោក។ ការបោះបាយបិណ្ឌ(ការបោះដុំបាយ) ជាសកម្មភាពមួយដែលមិនទាន់មានឯកភាពគ្នានៅក្នុងសង្គមពុទ្ធសាសនិកនៅឡើយ ដោយអ្នកខ្លះបានចាត់ទុកការបោះបិណ្ឌជាកិច្ចដ៏សំខាន់មួយមិនអាចខានបាននៅក្នុងរដូវបុណ្យកាន់បិណ្ឌនេះ ខណៈដែលអ្នកខ្លះបានអះអាង និងរិះគន់ថា ការបោះបាយបិណ្ឌជាទង្វើមិនត្រឹមត្រូវ ជាភាពខ្ជះខ្ជាយ ជាការធ្វើមិនគោរពទានជាដើម។ អ្នកដែលជឿថា បោះបាយបិណ្ឌមានប្រយោជន៍គិតថា បោះបាយបិណ្ឌ គឺបោះឱ្យពួកប្រេត(ហេតុនេះទើបនៅតំបន់ខ្លះមិនហៅបាយបិណ្ឌទេ តែគេហៅថាបាយប្រេត)។ ចំណែកអ្នកពុទ្ធនិយមខ្លះទៀតបានអះអាងថា ការបោះបាយបិណ្ឌជាការធ្វើទានមិនត្រឹមត្រូវតាមការបង្រៀនរបស់ព្រះពុទ្ធឡើយ។

## ៨. ការពូនភ្នំខ្សាច់(វាលុកចេតិយ)ក្នុងពិធីបុណ្យភ្ជុំបិណ្ឌ

ជំនឿដែលពុទ្ធបរិស័ទលើកឡើងអំពីការពូនភ្នំខ្សាច់នៅអំឡុងពេលបុណ្យភ្ជុំបិណ្ឌនេះ វាជាជំនឿមួយដែលខ្មែរយើងទូទៅយល់ថា ល្អនិងមានប្រយោជន៍ ដ្បិតពួកគាត់យល់ថាការពូនភ្នំខ្សាច់ និងការដាក់លុយតាមភ្នំខ្សាច់នីមួយៗដោយមានអុជធូបបួងសួងផងនោះ គឺដើម្បីស្មាលាកំហុសបាបមួយចំនួនដែលខ្លួនបានសាងឡើងហើយដែលមិនបានចាប់អារម្មណ៍កន្លងមក និងម្យ៉ាងវិញទៀតក៏ជាការឧទ្ទិសកុសលមួយជូនដល់ឧបការីជនទាំងឡាយដែលបានលាចាកលោកផងដែរ។ បើតាមក្រុមជំនុំទំនៀមទម្លាប់ខ្មែរ នៃពុទ្ធសាសនបណ្ឌិត្យបានបរិយាយពីការកសាងវាលុកចេតិយ(ពូនភ្នំខ្សាច់)នេះថា៖ ចេតិយដែលគេកសាងដោយដីខ្សាច់សុទ្ធ គឺគេយកដីខ្សាច់មកចាក់គរហើយពូនឱ្យមានរូបជាចេតិយឡើង ដែលគេហៅតាមភាសាបាលីថា «វាលុកចេតិយ» ឬនិយមហៅជាភាសាខ្មែរថា «ពូនភ្នំខ្សាច់» ព្រោះគំនរខ្សាច់ដែលពូនឡើងនោះ មានស្ថានភាពប្រហែលភ្នំ។ វាលុកចេតិយនេះ មានគតិនិយមថា ធ្វើឡើងដើម្បីឧទ្ទិសថ្វាយជាសក្ការបូជាតំណាងព្រះចូឡាមណីចេតិយនៅស្ថានត្រៃត្រឹង្សសួគ៌ដែលពួកទេវតាសាងបញ្ចុះព្រះកេសធាតុ (ព្រះកេ

សា) និងព្រះទាឋាធាតុ (ព្រះចង្កូមកែវ) នៃព្រះសម្មាសម្ពុទ្ធដែលសម្គាល់ថាបានផលានិសង្ស។

វាលុកចេតិយគេតែងសាងនៅទីណា? មានខ្នាតប៉ុណ្ណា? មានទ្រង់ទ្រាយដូចម្ដេច? សាងម្ដងៗ មានប៉ុន្មានតួចេតិយ? មានគ្រឿងប្រកបដូចម្ដេច?

បើតាមទម្លាប់ដែលបុរាណបណ្ឌិតធ្លាប់ធ្វើមក ការពូនភ្នំខ្សាច់ គឺគេធ្វើនៅទីណាដែលមានដីខ្សាច់ល្អ ហើយបើតាមទំនៀមទម្លាប់របស់ប្រទេសកម្ពុជាយើង គេច្រើនធ្វើនៅតាមទីវត្ត ដោយទីនោះជាទីប្រជុំជនផង និងឱ្យបានដីចូលវត្តផង ឯទីដទៃក្រៅពីទីនេះ ក៏មានធ្វើនៅតាមដើមពោធិដែលជាទីសក្ការបូជារបស់ប្រជាជនខ្លះដែរ តែមានតិចៗ តើគេសាងវាលុកចេតិយក្នុងវេលាណា? និងមានខ្នាតទំហំឬកម្ពស់ប៉ុនណា? ចំនួនប៉ុន្មាន?

ការកសាងវាលុកចេតិយ មានរឿងខ្លះកំណត់ថាត្រូវសាងនៅវេលាចូលឆ្នាំ ឯរឿងខ្លះគ្រាន់តែណែនាំឱ្យធ្វើឥតមានកំណត់កាលវេលាទេ។ តែបើតាមទំនៀមរបស់ខ្មែរយើងដែលតែងតែធ្វើទូទៅទាំងស្រុងក្នុងវេលាចូលឆ្នាំ និងបុណ្យភ្ជុំបិណ្ឌ។ ក្រៅពីរដូវនេះគេធ្វើចំពោះបុណ្យចម្រើនអាយុយឺនយូរនិងពេលដែលមាតាឬបិតាឈឺធ្ងន់ ដើម្បីរំដោះគ្រោះ។ ចំពោះខ្នាត ទំហំ និងកម្ពស់នៃការកសាងវាលុកចេតិយវិញ គឺគ្មានតម្រាណាមួយកំណត់ខ្នាតជាកម្រិតទំហំឬកម្ពស់ទេ ស្រេចនៅលើអធ្យាស្រ័យរបស់អ្នកសាងចង់ធ្វើប៉ុនណាក៏បាន។ ហេតុនេះបានជាឃើញគេធ្វើខ្នាតតូចៗ ប៉ុនចានគោមប្រតិស្ឋានលើតុឬថាស ខ្នាតកណ្ដាលទំហំ២–៣ហត្ថកម្ពស់ត្រឹមចង្កេះក៏មាន ខ្នាតធំៗប៉ុនផ្ទឹមស្រូវមានសភាពប្រហែលដំបូកធំ ឬកូនភ្នំក៏មាន។ រីឯចំនួនវិញ គេឃើញមានធ្វើតែមួយក៏មាន ៣ឬ៥ក៏មាន ធ្វើព័ទ្ធជុំវិញព្រះវិហារតាមទិសទាំង៨ក៏មាន។ តែនិយាយពីចំនួន៥វិញ គឺគេធ្វើភ្នំមួយធំខ្ពស់ចំកណ្ដាល (ដែលតាមចាស់ៗនិយមថាធ្វើតំណាងភ្នំសិនេរុ ដែលជាទីតាំងឋានត្រៃត្រឹង្ស) តូចៗបួននៅទិសទាំង៤ គឺទិសបូព៌ ទក្សិណ បស្ចិមឧត្តរ (តំណាងភ្នំយុគន្ធរ ដែលជាទីតាំងឋានចាតុម្មហារាជិកា)។ គ្រឿងប្រកបវាលុកចេតិយដូចម្ដេចខ្លះ? តាមទំនៀមខ្មែរយើង កាលបើគេជញ្ជូនដីខ្សាច់មកចាក់គរពូនឱ្យមានទ្រង់ទ្រាយប្រហែលភ្នំ មានកម្ពស់ និងទំហំធួនល្មមតាមដែលគេត្រូវការហើយ គេច្រើនយកក្អមមួយកំណាត់ឬយកក្អមទាំងមូលមកកប់ឱ្យនៅត្រឹមកដាក់ត្រង់កំពូលគ្រប់ចេតិយឱ្យមានសណ្ឋានដូចក្បាច់ចេតិយមែនទែន និងវត្តខ្លះដែលគេរកដីខ្សាច់ពុំបាន ហើយគេចង់ឱ្យចម្រើនដីវត្ត គេយកដីកណ្ដោងធ្វើជំនួសក៏មានធ្វើហើយគេធ្វើរាជវ័តិព័ទ្ធជុំវិញពីក្រៅចេតិយទាំងនោះ ទុកតែមាត់ទ្វារចេញចូល៤ទិសដោយគេធ្វើរានទេព្ដា៨ ដាក់គ្រប់៨ទិសមានរានមួយទៀតគេសន្មតជារានព្រះកាលឬព្រះយមរាជ ដាក់នៅទិសបូព៌ មានទាំងឆត្ររូត និង

ទង់រលកដោតគ្រប់ពនទាំងនោះផង ព្រមទាំងបូជាដោយផ្កាភ្ញី និង ស្លាធម៌ ទឹកអប់ ជាដើម។

កាលគេធ្វើគ្រឿងប្រដាប់ដូចរៀបរាប់ខាងលើនេះរួចហើយ វេលាថ្ងៃរសៀលទាប គេយកទៀនធូបទៅអុជ ដោយមានយកផ្កាចម្រុះពណ៌ទៅដោតដាក់បូជា និងយកទង់ធ្វើពីក្រដាស់ពណ៌ផ្សេងៗទៅដោតបូជានៅកំពូលវាលុកចេតិយទាំងនោះ ហើយមានអាចារ្យម្នាក់នាំឧបាសកឧបាសិកាដើរប្រទក្សិណ៣ជុំ រួចនមស្ការព្រះរតនត្រ័យ សមាទានសីល ទើបយកសំពត់សទៅព័ទ្ធឈៀង ដូចអង្ស័ក2 ពីលើវាលុកចេតិយទាំងនោះ រួចនាំសូត្រអធិដ្ឋានវាលុកចេតិយទាំងអស់ ដែលគេហៅតាមសំដីអ្នកស្រុកថា «បំបួសភ្នំ» ឱ្យជាតំណាងព្រះចូឡាមណី ចេតិយនៅឯឋានត្រៃត្រឹង្សសួគ៌ដោយសូត្របាលីថា ឥមំ វាលុកចេតិយំ ចុឡាមណិចេតិយំ អធិដ្ឋាមិ (ប្រែថា) «ខ្ញុំសូមតាំងចិត្តអធិដ្ឋានព្រះចេតិយខ្សាច់នេះឱ្យជារបស់តំណាងព្រះចូឡាមណីចេតិយ» ។

ក្រោយពេលបំបួសភ្នំហើយ នាវេលាយប់គេនាំគ្នាចូលវិហារ ឬសាលាបុណ្យ ដើម្បីនិមន្តព្រះសង្ឃសូត្រព្រះបរិត្ត រួចទេសនាសាស្ត្រាអានិសង្សខ្សាច់។ បើបុណ្យនោះគេធ្វើត្រូវលើថ្ងៃបុណ្យចូលឆ្នាំ លុះចប់ទេសនា គេលេងល្បែងផ្សេងៗ តាមទម្លាប់ស្រុករបស់គេ មានលេងឈូង អង្គញ់ ទាញព្រ័ត្រ ជាដើម។ លុះវេលាព្រឹក គេអង្គាសយាគូថ្ងៃត្រង់ អង្គាសកត្តប្រគេនព្រះសង្ឃទូទៅទាំងវត្តគ្រប់បីថ្ងៃបីយប់។ នៅថ្ងៃគម្រប់៤ គេនិមន្តព្រះធម្មកថិកទេសនាសង្គ្រាយនាធ្វងបុណ្យ ហើយនិមន្តលោកបង្សុកូល រួចប្រគេនវណ្ណាប់ទេយ្យទានមានសំពត់សាដក ឈើគូស ស្ករ តែ ជាដើម ចំពោះព្រះសង្ឃតាមសមគួរដល់សទ្ធា ជាការសម្រេចពិធីបុណ្យសាងវាលុកចេតិយត្រឹមនេះ។

តាមទំនៀមវាលុកចេតិយដែលគេបានអធិដ្ឋាន(បំបួស)ហើយ គេកាន់ថាបានឡើងពេញជាពុទ្ធចេតិយមែនៗ ហើយបើនរណាមួយទៅរំលាយព្រះចេតិយនោះមុនគេផ្សឹកចេញ គេទុកថាជាមានទោសធ្ងន់ណាស់ ដោយហេតុនេះកាលធ្វើបុណ្យធ្វងហើយអាចារ្យក៏ផ្សឹកចេញភ្លាមដោយភាសាបាលីថា ឥមំ វាលុកចេតិយំ បច្ចក្ខាមិ (ប្រែថា) «ខ្ញុំផ្សឹកឥឡូវនេះវាលុកចេតិយនេះគឺដកចិត្តចេញ។

---

2 អង្ស័ក(អង់-ស័ក) នាមសព្ទ ( សំ.បា.អំស "ស្មា", អំសក ឬអំសិក "ដែលទាក់ទងឬជាប់ដោយស្មា" ) កាសាវពស្ត្រមួយយ៉ាងសម្រាប់បព្វជិតពុទ្ធសាសនិកសម័យសព្វថ្ងៃពាក់ពាតលើស្មាខាងឆ្វេងព័ទ្ធមកក្រោមក្លៀកខាងស្តាំប្រើជាទ្រនាប់ញើសពីខាងក្នុងឧត្តរាសង្គ, ជាគ្រឿងបរិក្ខារពាយរង ឬបរិក្ខារពិសេស ប្រើក៏បាន មិនប្រើក៏បាន ព្រោះគ្រឿងបរិក្ខារនេះ ពុំមែនជាពុទ្ធានុញ្ញាតទេ . . . ដូចគ្នានឹង វត្តពន្ធទ្រូង ដែរ ប្រើក៏បាន មិនបាច់ប្រើក៏បាន ជាចីវររាប់ចូលក្នុងបរិក្ខារចោឡៈ ដែលអដ្ឋកថាប្រាប់ថាបព្វជិតប្រើច្រើនប៉ុន្មានក៏បាន ឥតមានកំហុសទេ(ព.វិ.ពុ.) ។ ម. ព. វត្តពន្ធ ផង។ តាមវចនានុក្រមសម្តេច ព្រះសង្ឃរាជ ជួន ណាត។

លែងកាន់ថាជាវាលុកចេតិយហើយ៕ ក្រោយពីនោះទោះនរណារំលោយក៏គ្មានទោសពៃរ៍អ្វីទេ ហើយគេយកដីខ្សាច់ភ្នំនោះទៅស្ថាបនាជាវត្ថុអ្វីៗក្នុងវត្តតាមត្រូវការ។

មានសូត្រមួយឈ្មោះ មហាសំការសូត្រ ដែលសំដែងពីដើមកំណើតរឿងបុណ្យសាងវាលុកចេតិយថាបានផលានិសង្សណាស់ មានសេចក្ដីដូចស្រង់មកដោយសង្ខេបតទៅនេះថា៖

សម័យមួយ ព្រះបរមសាស្ដាទ្រង់ប្រថាប់ក្នុងវត្តជេតពន ទ្រង់សំដែងឆ្លើយប្រស្នាព្រះបាទបសេនទិកោសលថា៖ មហាបពិត្រ! អ្នកដែលបានសាងវាលុកចេតិយបានបូជាវាលុកចេតិយដោយវត្ថុផ្សេងៗ មានផ្កាភ្ញី គ្រឿងក្រអូបនិងទៀនធូបជាដើម បានផលច្រើន បានទៅកើតក្នុងត្រកូលក្សត្រ ត្រកូលព្រាហ្មណ៍។ អ្នកដែលបានដោះលែងសត្វក្នុងឱកាសសង្ក្រាន្តចូលឆ្នាំថ្មី រមែងមានអាយុយឺនយូរមានសេចក្ដីសុខច្រើន អ្នកណាបានផ្ងូតទឹកមាតាបិតា គ្រូឧបជ្ឈាយ៍អាចារ្យក្ដី បានរក្សាសីលក្ដីបានជីកស្រះក្ដី បានសង់ស្ពានក្ដី បានធ្វើផ្លូវថ្នល់ក្ដី ។ល។ ព្រះចតុលោកបាលតែងកត់ឈ្មោះអ្នកនោះទុកលើផែនមាស បើអ្នកណាមិនស្គាល់គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មិនធ្វើបុណ្យ ធ្វើតែបាប ព្រះចតុលោកបាលតែងកត់ឈ្មោះអ្នកនោះទុកលើស្បែកឆ្កែ។ល។ក្រៅពីមហាសំការសូត្រ ដែលថ្លែងមកខាងលើនេះ មានរឿងនិទាន២ទៀតសុទ្ធតែនិយាយពីដើមកំណើតនៃការកសាងវាលុកចេតិយទាំងអស់គឺ៖

និទានទី១ តំណាលពីព្រះពោធិសត្វនាមបារិកៈ ជាឈ្មួញសំពៅ បើកសំពៅទៅជួញបានឃើញផ្នូកខ្សាច់ល្អនៅឆ្នេរសមុទ្រ ក៏បបួលពាណិជឯទៀតកសាងជាវាលុកចេតិយឧទ្ទិសជាតំណាងព្រះចូឡាមណីចេតិយនៅឋានត្រៃត្រឹង្សសួគ៌ ដែលបញ្ចុះព្រះកេសានិងព្រះចង្កូមកែវនៃព្រះសម្មាសម្ពុទ្ធ ដោយបានបេះផ្កាឈើបូជានិងដើរប្រទក្សិណ ៣ជុំ ទើបបើកសំពៅចេញទៅ។ លុះបារិកៈពោធិសត្វនិងឈ្មួញទាំងនោះរំលាង3 បញ្ចក្ខន្ធទៅ ក៏បានទៅកើតជាទេវបុត្រនៅឋានសួគ៌ច្រើនជាតិ ច្យុតពីឋានសួគ៌មកកើតជាស្ដេចចក្រពត្តិ ជាស្ដេចឯករាជ្យច្រើនជាតិ។ ទីបំផុតបារិកពោធិសត្វ បានត្រាស់ជាព្រះពុទ្ធ ឈ្មួញឯទៀតបានជាពុទ្ធសាវ័កដោយអំណាចផលដែលបានសាងនូវវាលុកចេតិយនោះឯង។

និទានទី២ តំណាលថា មានអ្នកនេសាទម្នាក់បានសម្លាប់សត្វចិញ្ចឹមជីវិតតាំងពីក្មេងរហូតដល់ចាស់មិនដែលធ្វើបុណ្យម្ដងណាសោះ។ ថ្ងៃមួយអ្នកនេសាទកំពុងតែលីលំពែងស្ពាយបាយកញ្ចប់ចេញទៅព្រៃស្វែងរកសត្វ ក៏មានភិក្ខុ១អង្គបិណ្ឌបាតចង្ហាន់។ ដោយសារភិក្ខុអង្គនោះទទូចមិនលែងសោះ អ្នកនេសាទក៏ពួត

3 រំលាង កិរិយាសព្ទ (ស.លាងឬលាងផ្លាញ អ.ថ.ល៉ាងឬផ្លាន )ធ្វើឱ្យវិនាស;បំផ្លាញ;ទម្លាយ;ផ្ដាច់ផ្ដិល,បំបាត់ជីវិតគេ រំលាងប្រយោជន៍,រំលាងវង្ស,រំលាងជីវិតគេ។ រំលាងខន្ធស្លាប់។ លុះបុរសនោះរំលាងខន្ធ ក៏ទៅកើតជាបុត្រសេដ្ឋី . . . ។

បាយ១ពំនូតប្រគេន។ លុះអ្នកនេសាទស្លាប់ទៅក៏ត្រូវពួកយមបាលចាប់ខ្លួនទៅសួរពីរឿងធ្វើបុណ្យបាបកាលនៅជាមនុស្ស អ្នកនេសាទក៏តបថាមិនបានធ្វើបុណ្យសោះធ្វើតែបាប។ កាលនោះយមបាលក៏ចាប់អ្នកនេសាទបោះទៅក្នុងភ្លើងនរក។ អ្នកនេសាទក្រឡេកឃើញភ្លើងសម្បុរដូចត្រៃចីវរ ក៏នឹកដល់ទានរបស់ខ្លួនទើបឆ្លើយប្រាប់ថា កាលខ្លួននៅជាមនុស្សបានធ្វើទានបាយ១ពំនូត ដល់ភិក្ខុ១អង្គដែរ។ ព្រដូច្នោះយមបាលប្រាប់ថា បើដូច្នេះអ្នកឯងត្រូវបានឡើងទៅកើតឯឋានសួគ៌៧ថ្ងៃដល់ថ្ងៃទី៨យើង នឹងយកអ្នកឯងមកទម្លាក់នរកវិញ។ នេសាទក៏បានទៅកើតឯឋានសួគ៌ ឈ្មោះថា អន្ទំលោកកង្សិនីទេវបុត្រ មានវិមាន មានបរិវារ មាននាង សុវណ្ណឱរ៉ៃជាទេពី។ អន្ទំលោកកង្សិនីទេវបុត្រសោយសុខបាន៦ថ្ងៃ បាននឹកដល់ពាក្យយមបាលក៏ទោមនស្សហើយចូលទៅដេកយំ។ នាងសុវណ្ណឱរ៉ៃ សាកសួរដំណើរដើមទងគាត់ក៏ប្រាប់តាមដំណើរ។ នាងថា បើដូច្នេះយើងត្រូវសាងវាលុកចេតិយហើយធ្វើបុណ្យធ្វើង ទើបរួចចាកកម្មពៀរនោះ។ អន្ទំលោកកង្សិនីទេវបុត្រ ក៏ចាត់ការកសាងវាលុកចេតិយជាស្រេចក្នុងថ្ងៃទី៧។

លុះដល់ថ្ងៃទី៨ យមបាលក៏ទៅរក តែនាងសុវណ្ណឱរ៉ៃ ប្រាប់ថាស្វាមីយើងបានកសាងវាលុកចេតិយ បានធ្វើបុណ្យធ្វើងបានរួចស្រឡះចាកកម្មពៀរហើយ បើអ្នកនៅតែត្រូវការយកខ្លួនទៅធ្វើទោសទៀត ចូរអ្នករាប់គ្រាប់ខ្សាច់១ពែងនេះសិន បើរាប់អស់ទើបយកទៅបាន។ ពួកយមបាលក៏រាប់តាំងពីព្រឹកដល់ថ្ងៃត្រង់ គ្រាប់ខ្សាច់ដែលរាប់ហើយដាក់ក្រៅពែងកម្ពស់ចុងត្នោត រីឯក្នុងពែងនៅតែពេញដដែលទើបយមបាលព្រមចាញ់ចំណោះក៏ត្រឡប់ទៅយមលោកវិញ ហើយ អន្ទំលោកកង្សិនីទេវបុត្របាននៅក្នុងឋានសួគ៌ដរាបមកដោយអំណាចអានិសង្សកសាងវាលុកចេតិយនោះឯង។

និទានទី៣ តំណាលថា មានក្មេងម្នាក់ចេះតែទៅពូនភ្នំខ្សាច់លេងនៅផ្នូកខ្សាច់ក្បែរផ្ទះដោយតាំងចិត្តជាបុណ្យតាមនិស្ស័យក្មេង ពូនហើយដេកនឿលលើដីខ្សាច់ក្បែរភ្នំនោះរាល់ថ្ងៃ ទាល់តែអ្នកស្រុកគេហៅក្មេងនោះថា ចៅកំដិលខ្សាច់ ។

ថ្ងៃមួយ ព្រះឥន្ទបើកទិព្វចក្ខុមកឃើញចៅកំដិលខ្សាច់ពូនភ្នំខ្សាច់ ក៏ចាត់ឱ្យនាងទេពធីតាដ៏ល្អ១រូបមកធ្វើជាភរិយា។ ទទួលវេលានោះព្រះរាជាម្ចាស់ផែនដីទ្រង់ព្រះទិវង្គត គ្មានព្រះរាជបុត្រស្នងរាជសម្បត្តិ ពួកសេនាបតីគិតឃើញថា ចៅកំដិលខ្សាច់គួរធ្វើជាព្រះរាជា ក៏ចាត់ការផ្សងបុស្សរថ (រថផ្កា) រកអ្នកមានបុណ្យបុស្សរថក៏រត់ទៅត្រូវលើចៅកំដិលខ្សាច់ ទើបគេនាំគ្នាអញ្ជើញចៅនោះទៅសោយរាជ្យ និងអភិសេកនាងទេពធីតាជាអគ្គមហេសី។

សូត្រ និងនិទានខាងលើនេះ សុទ្ធតែជាសាស្ត្រាស្លឹករិត ជាគម្ពីរតែងឡើងខាងក្រោយមហាសំការសូត្រភាសាបាលីនិទានទាំង៣ ក៏

សម្រាយមកជាភាសាខ្មែរ ដែលអ្នកផងតែងហៅនិទានទាំងនោះថា សាស្ត្រាអានិសង្សខ្សាច់។ សាស្ត្រាទាំងនោះបើមិនមួយក៏មួយ ធម្មកថិក[4] ជាច្រើនបានយកមកទេសនានៅពេលធ្វើបុណ្យកសាងវាលុកចេតិយ ព្រោះហេតុនេះទើបខ្មែរយើងមានសទ្ធាជ្រះថ្លានាំគ្នាធ្វើបុណ្យនេះជាប់ជាប្រពៃណីរៀងមកដរាបដល់សព្វថ្ងៃនេះ។

បណ្ដាសូត្រនិងនិទានដែលមាននិយាយពីការកសាងវាលុកចេតិយទាំងប៉ុន្មាន ដូចបានស្រង់មកថ្លែងដោយសង្ខេបខាងលើនេះ មហាសំការសូត្រ និទានបារិកៈពោធិសត្វ និងនិទានចៅកំដិលខ្សាច់គ្រាន់តែសំដែងថាពូនភ្នំខ្សាច់ផ្ដាច់កម្មពៀរ។ ហេតុនេះបានជាជនសាមញ្ញនិយមជឿតាមនិទាននេសាទថា ពូនភ្នំខ្សាច់ផ្ដាច់បាប តែសម្រាប់ជនជាបណ្ឌិត ដែលយល់ការណ៍ ពិតតាមគោលពុទ្ធវចនៈ មិននិយមដូច្នោះទេ បើពូនភ្នំខ្សាច់ក៏ពូនឧទ្ទិស ថ្វាយជាតំណាងព្រះចូឡាមណីចេតិយត្រង់ៗ យកផលានិសង្សដើម្បីបានសេចក្ដីសុខ សេចក្ដី ចម្រើនក្នុងលោកនេះ និងលោកខាងមុខ។

## ៩. ប្រេត

ប្រេត អានថា ប្រែត តាមសំនៀងខ្មែរ គឺជាពាក្យខ្ចីមកពីភាសាសំស្ក្រឹត។ ចំណែកពាក្យខ្ចីមកពី ភាសាបាលីវិញ ហៅថា "បេត" អានថា ប៉េតៈ។ អត្ថន័យដើមរបស់ពាក្យ ប្រេត គឺជាមនុស្សដែលស្លាប់ ឬព្រលឹងខ្មោច។ នៅក្នុងវចនានុក្រមខ្មែរសម្ដេចសង្ឃរាជ ជួន ណាត ៖ ប្រេតប្រែថា សត្វកើតក្នុងអបាយភូមិ ពួកមួយ។ បើប្រើជាគុណនាមវិញ ប្រេត មានន័យថា(អ្នក) ដែលធ្វើមរណកាលទៅកាន់បរលោកហើយ។

ក្រោយមក ពុទ្ធសាសនាមហាយានបានជ្រាបទៅដល់ប្រទេសចិន ហើយជនជាតិចិនបានបកប្រែពាក្យ ប្រេត ពីភាសាសំស្ក្រឹតទៅជាភាសាចិនថា "អេគុយ" (egui) ដែលមានន័យផ្សេងថា "ខ្មោចស្រេកឃ្លាន" ដែលជាប់អត្ថន័យនៅក្នុងគម្ពីរព្រះត្រៃបិដក ក៏ដូចជាផ្នត់គំនិតខ្មែរ និងសាសន៍ផ្សេងៗទៀតដែលកាន់ពុទ្ធសាសនានិកាយថេរវាទរហូតមកដល់សព្វថ្ងៃ។ ទស្សនៈអំពីខ្មោចឬព្រលឹង នៅក្នុងវប្បធម៌របស់ជនជាតិឥណ្ឌានិងជនជាតិចិនគឺមានដូចគ្នា។ ដូច្នេះការបកប្រែភាសានិងការបង្រៀនទ្រឹស្ដីពុទ្ធសាសនាក៏មានការប្រែប្រួលដែលនាំឱ្យកើតមានទស្សនៈថ្មីនាជំនាន់ក្រោយៗ។

ប្រេត បើតាមគម្ពីរព្រះពុទ្ធសាសនាបានចែងថា មនុស្សដែលស្លាប់ទៅតែងទៅកើតទីផ្សេងៗតាមកម្មរបស់ខ្លួន។ មនុស្សចិត្តអាក្រក់ដែលបានធ្វើបាបកម្មផ្សេងៗ លុះស្លាប់ទៅតែង

---

4 ធម្មកថិក (ធ័ម-មៈកៈថិក) នាមសព្ទ (បា. ; សំ. ធម៌កថិក) អ្នកសំដែងធម៌។ ខ្មែរប្រើពាក្យនេះជាងារនៃភិក្ខុអ្នកចេះសំដែងធម៌ ថ្នាក់ជាឋានានុក្រម ជាសហការីនៃព្រះរាជាគណៈ ជាចៅអធិការវត្តធំៗក្នុងព្រះរាជធានី ឬជាសហការីនៃមេគណ កាលបើត្រូវការឱ្យមានព្រះធម្មកថិកសហការីនៃ... (ម. ព. ធម្មធរ និង វិន័យធរ ទៀតផង)។

តែកើតជាប្រេត៤ប្រភេទ គឺប្រេតដែលចិញ្ចឹមជីវិតដោយខ្ទុះឈាម ប្រេតស្រេកឃ្លានអាហារជានិច្ច ប្រេតដែលភ្លើងឆេះជានិច្ច និងប្រេតដែលចិញ្ចឹមជីវិតដោយផលដែលបុគ្គលដទៃឧទ្ទិសទៅឱ្យ។ គេតែងនិយមជ្រើសរើសចំថ្ងៃរនោច ខែភទ្របទ ព្រោះពេលវេលានោះព្រះចន្ទពុំសូវមានពន្លឺ ហើយចេះតែងងឹតទៅៗ ហើយជាឱកាសដែលយមរាជដោះលែងពួកប្រេតទាំងនោះឱ្យមករស់នៅលាយឡំជាមួយមនុស្សចាំទទួលភោគផលដែលបងប្អូនញាតិសន្តានឧទ្ទិសឱ្យ ព្រោះពួកប្រេតតែងខ្វាចពន្លឺណាស់។ ប្រសិនបើរយៈពេល១៥ថ្ងៃ ពួកប្រេតដើររកគ្រប់វត្តពុំមានឃើញបងប្អូនញាតិសន្តានណាធ្វើបុណ្យបញ្ជូនកុសលទៅឱ្យទេ ពួកគេនឹងអត់បាយអត់ទឹកស្រេកឃ្លានរងទុក្ខវេទនាយ៉ាងក្រៃលែង ហើយក៏មានជំនឿថា ប្រេតនឹងជេរប្រទេចផ្តាសាដល់បងប្អូនញាតិកាទាំងឡាយឱ្យហិនហោចទ្រព្យសម្បត្តិ ព្រាត់ប្រាស់ឪពុកម្តាយ ប្តីប្រពន្ធ កូនចៅ ញាតិផៅទាំងប្រាំពីរសន្តានផងដែរ។

បើតាមឯកសារប្រវត្តិសាស្ត្រខ្មែរភាគ១ របស់លោក ត្រឹង ង៉ា បានបញ្ជាក់ថា បុណ្យភ្ជុំបិណ្ឌអាចមានទំនាក់ទំនងជាមួយលទ្ធិបុគ្គលនិយមរបស់ព្រះបាទឥន្ទ្រវរ្ម័នទី១(៨៧៧-៨៨៩) ដែលព្រះអង្គបានកសាងប្រាសាទរាជ្យផង និងប្រាសាទសម្រាប់ថ្វាយមាតាបិតា ដែលលើកឋានៈស្មើទេវៈទេវី។[5] សូមបញ្ជាក់ថា មុនរាជ្យរបស់ព្រះអង្គ គឺពុំមានការកសាងប្រាសាទសម្រាប់លទ្ធិបុគ្គលនិយមនោះទេ។ អត្ថន័យនៃទស្សនវិជ្ជានេះ ក្រៅពីការដឹងគុណដល់អតីតព្រះមហាក្សត្រមុនៗ ដើម្បីបង្កើតសុខដុមនីយកម្មក្នុងសង្គមជាតិ ក៏ជាឱកាសនៃការប្រកួតប្រជែងនៃស្នាដៃសំណង់ស្ថាបត្យកម្មរបស់ព្រះមហាក្សត្រដែលកំពុងគ្រប់គ្រងប្រទេសផងដែរ។

ពួកប្រេតដែលអាចទទួលអាហារពីញាតិសន្តានកូនចៅក្នុងរដូវបុណ្យភ្ជុំបិណ្ឌបានមានតែបួនពួក ប៉ុណ្ណោះ ដែលជាប្រេតមានកម្មស្រាលរស់នៅប្រឡូកប្រឡល់ជាមួយនឹងស្រុកមនុស្សយើងនេះដែរគឺៈ

១- បរទត្តូជីវិកប្រេត ពួកប្រេតនេះ រស់នៅអាស្រ័យអ្នកដទៃ គេឧទ្ទិសកុសលទៅ។

២- ខុប្បិបាសិកវន្តប្រេត ពួកប្រេតនេះរស់នៅដោយសេចក្តីស្រេកឃ្លានជាប្រចាំ មានចិត្តរំជើបរំជួល ស្រេកឃ្លានអាហារគ្រប់ពេល រស់នៅអាស្រ័យអណ្តាតដោយការលិទ្ធនូវវត្ថុផ្សេងៗ។

៣- និជ្ឈាមតណ្ហិកប្រេត ប្រេតប្រភេទនេះមានសេចក្តីក្តៅក្រហាយប្រចាំកាយគ្រប់ពេល។

៤- អទិស្សមាណកាយប្រេត ប្រេតពួកនេះមានកាយមិនប្រាកដ មានកម្មស្រាលជាង

[5] ត្រឹង ង៉ា **ប្រវត្តិសាស្ត្រខ្មែរភាគ១** បោះពុម្ពឆ្នាំ១៩៧៣ ទំព័រ៨២។

គេ ប្រេតពួកនេះ កាលណាបានទទួលកុសល ផលបុណ្យហើយក៏រួចចាកទុក្ខភ្លាម។

សូមបញ្ជាក់ថា ពួកប្រេតទាំងបួនប្រភេទ នេះ មានទោសស្រាលរង់ចាំតែចំណែកផល បុណ្យពីញាតិឧទ្ទិសទៅឱ្យនឹងបានរួចផុតអត្ត ភាពជាប្រេតនោះភ្លាម។ ប្រេតជំពូកនេះ រស់នៅ លើភពផែនដីច្របូកច្របល់ជាមួយមនុស្ស ពេលខ្លះក៏បង្ហាញខ្លួនឱ្យឃើញផងដែរ ជា ពិសេសនៅកន្លែងណាដែលស្ងាត់ ហើយសម្បូរ ទៅដោយគ្រឿងអសុភសាកសព ព្រោះច្រើនតែ ទៅស៊ីវត្ថុមិនស្អាត លុះពេលមនុស្សដើរទៅចំ ពេលកំពុងស៊ី ក៏បង្ហាញខ្លួនបន្លាច ព្រោះខ្លាច មនុស្សមកដណ្តើមអាហាររបស់ខ្លួន។ ហេតុនេះ ហើយមនុស្សតែងពោលថា ខ្មោចលង ប៉ុន្តែបើ មនុស្សមិនខ្លាច ប្រេតជំពូកនេះក៏គេចខ្លួនដោយ ឯកឯង ជាពិសេសប្រេតទាំងនេះខ្លាចអ្នកមាន សីលនិងមានសទ្ធាជាទីបំផុត។

តាមន័យនៅក្នុងគម្ពីរ បេតវត្ថុនៃគម្ពីរ ព្រះត្រៃបិដករបស់ពុទ្ធសាសនា និកាយថេរវាទ ពាក្យថា ប្រេត គឺជាបុថុជ្ជន ឬជនសាមញ្ញដែល ស្លាប់រួចបានកើតជាសត្វក្នុងអបាយភូមិ ពោល គឺ អបាយភូមិបេតវិស័យ ដោយសារតែពួកគេ បានប្រព្រឹត្តអកុសលកម្មផ្សេងៗកាលពីនៅរស់ ជាមនុស្ស។

បើពិចារណាតាមលក្ខណៈវិទ្យាសាស្ត្រ មនុស្សស្លាប់គ្មានបន្សល់អ្វីជាគ្រឿងសម្រាប់ចង ចាំទេ។ ទោះបីសាច់ញាតិយកសាកសពទៅដុត កំទេចចោល យកទៅកប់ក្នុងដី បោះចោលក្នុង ទឹកសមុទ្រឬទន្លេ ឬកាត់ចិញ្ច្រាំឱ្យត្មាតស៊ីក៏ ដោយ ក៏សាកសពនោះគ្មានអ្វីសល់សេចក្តីចង ចាំឬព្រលឹងវិញ្ញាណអ្វីឡើយ។ បើញាតិកប់ ខ្មោចក្នុងដី សាច់រាងកាយនឹងផុយរលួយមុនគេ ក្រោយមកឆ្អឹងក៏នឹងរលាយទៅជាដីបាត់នៅថ្ងៃ ណាមួយជាប្រាកដ។ តើខ្មោចនោះមានអ្វីសេស សល់ ដែលអាចរក្សាការចងចាំថា បុគ្គលនេះជា សាច់ញាតិរបស់ខ្លួន ឬមានការឈឺចាប់ ស្រេក ឃ្លាន ឬខឹងសម្បារនោះ? សូម្បីមនុស្សនៅរស់ ក៏ មានបញ្ហាលំបាកចងចាំទៅហើយ រហូតមាន ជំងឺមួយចំនួនដែលធ្វើឱ្យអ្នកជំងឺបាត់បង់ការ ចងចាំ ទាំងស្រុងក៏មានចុះទម្រាំខ្មោចផុយ រលួយខួរក្បាលគ្មានសល់ តើឱ្យចាំអ្វីបាន?។

ជំនឿដែលត្រឹមត្រូវមួយចំនួន ត្រូវបាន មនុស្សខំផ្សារភ្ជាប់ទៅនឹងពុទ្ធសាសនានិកាយ ថេរវាទ គឺមិនមែនចាប់បង្ខំឱ្យមនុស្ស លិតលង់ ជឿកាន់យកនិងបន្តអនុវត្តរហូតមកដល់ បច្ចុប្បន្ននោះទេ គឺមានហេតុផលច្បាស់លាស់។ ជំនឿដែលមានភាពប្រាកដនិយមទាំងនោះ បានបន្លាចថាជនណាដែលបានប្រព្រឹត្តអកុ សលកម្ម ដូចជា ការសម្លាប់សត្វ ការលួចទ្រព្យ គេ ការប្រព្រឹត្តខុសក្នុងកាម ការភូតកុហក និង ការផឹកសុរាមេរ័យ ពេលស្លាប់ទៅនឹងទៅកើត ក្នុងភពនរកតិរច្ឆាន ប្រេតឬអសុរកាយ។ ពួកគេ ថែមទាំងបំភ័យថា ទោះមនុស្សក្រុមខាងលើ នេះបានកើតជាមនុស្សក៏ដោយ ក៏បានត្រឹមតែ

ជាមនុស្សប្រកបដោយទុក្ខវេទនាជាខ្លាំង។ អ្នកសិក្សាស្រាវជ្រាវខាងសាសនានានានៅលើពិភពលោក បានរិះគន់យ៉ាងខ្លាំងទៅលើការបង្រៀនសេចក្ដីជំនឿមិនមានប្រាកដនិយមបែបនេះ ព្រោះថាការបង្រៀនបែបនេះ គឺជាវិធីបង្រៀនដែលគ្មានមូលដ្ឋានច្បាស់លាស់តាមបែបវិទ្យាសាស្ត្រ(ចិត្តវិទ្យា) ដើម្បីឱ្យមនុស្សរៀនធ្វើអំពើល្អប្រកបដោយចិត្តមេត្តានិងករុណា។

ក្រុមមនុស្សខ្លះ បកស្រាយថា ប្រេតមានច្រើនប្រភេទ ពួកខ្លះមានឫទ្ធិអំណាច អាចបង្ហាញជារូបរាង ឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍បាន។ ប្រេតពួកខ្លះ ពេលយប់ជាទេវតា សោយសុខសម្បត្តិក្នុងវិមាន ពេលថ្ងៃជាប្រេតសោយទុក្ខវេទនា។ ប្រេតខ្លះអត់ឃ្លាន មានមាត់ប៉ុនម្ជុល ខ្លះត្រូវស៊ីរបស់បដិកូល (របស់មិនស្អាត) ដូចជាសាកសពសត្វជាដើម។ ប្រេតប្រភេទផ្សេងទៀតគ្មានអាហារស៊ីរហូតអស់ពុទ្ធន្តរ (រយៈពេលចន្លោះការត្រាស់ដឹងនៃព្រះពុទ្ធមួយអង្គទៅមួយអង្គទៀត)។ ជំនឿទាំងនេះ បានបន្តបកស្រាយថា ប្រេត ភាគច្រើន មិនអាចទទួលបានអាហារដែលញាតិឧទ្ទិសជូននោះទេ មានតែប្រេតប្រភេទបរទត្តូបជីវកប្រេត ទើបអាចទទួលបាន។ ចុះបើប្រេតមួយចំនួនធំមិនអាចទទួលអាហារ ឬបុណ្យដែលញាតិឧទ្ទិសជូននោះបានផង តើញាតិសារលោហិត ខំប្រឹងបន្តធ្វើបុណ្យឧទ្ទិសកុសលទៅប្រេតទាំងនោះ នៅពេលបុណ្យភ្ជុំបិណ្ឌ ធ្វើអ្វី? គឺដើម្បីញ៉ាំងសាមគ្គីធម៌ផងនឹងរក្សាប្រពៃណីផង និងជាការរឭកដល់អ្នកមានគុណផង។

ទោះបីពុទ្ធសាសនិកជនខ្លះនៅតែជឿថាមានប្រេតមានស្ថាននរកឬស្ថានសួគ៌ក៏តាម ការសិក្សាប្រៀបធៀបអក្សរសិល្ប៍និងជីវភាពមនុស្សនៅក្នុងសង្គមណា បានបង្ហាញថា ប្រេត គឺជាតួអង្គតំណាងឱ្យប្រជាពលរដ្ឋក្រីក្រឬមនុស្សនៅក្នុងក្រុមចណ្ឌាល(ក្រៅវណ្ណៈ) ដែលទទួលរងការជិះជាន់ មើលងាយ មើលថោក កេងប្រវ័ញ្ច គាបសង្កត់ បំបិតសិទ្ធិសេរីភាព ទារុណកម្ម ពីសំណាក់មនុស្សនៅក្នុងវណ្ណៈព្រាហ្មណ៍ និងវណ្ណៈក្សត្រដែលជាក្រុមមនុស្សមានអំណាច និងអ្នកដឹកនាំប្រទេស។ សម័យបច្ចុប្បន្ននៅប្រទេសណា និងនៅប្រទេសជាច្រើនទៀតដែលគ្មានការដឹកនាំតាមលទ្ធិប្រជាធិបតេយ្យ អំពើមិនល្អរបស់មនុស្សនៃវណ្ណៈព្រាហ្មណ៍និងវណ្ណៈក្សត្រ(អ្នកចេះដឹងនិងអ្នកមានទ្រព្យដែលគ្មានគុណធម៌ រួមទាំងអ្នកដឹកនាំប្រទេស) បន្តប្រព្រឹត្តអំពើអានាចារ្យ គាបសង្កត់ បោកប្រាសពលរដ្ឋក្រីក្រតាម គ្រប់រូបភាពរាប់តាំងពីការបំបិតសិទ្ធិប្រជាពលរដ្ឋ មិនឱ្យមានការធ្វើបាតុកម្មប្រឆាំងអំពើលួចប្លន់ទ្រព្យសម្បត្តិពលរដ្ឋ និងការបំបិតសិទ្ធិទទួលបាន ព័ត៌មានត្រឹមត្រូវ។

## ១០. បាយបិណ្ឌ

ក្នុងរយៈពេលនៃពិធីបុណ្យភ្ជុំបិណ្ឌនា វេលាម៉ោង៤ទៀបភ្លឺ ប្រជាពលរដ្ឋខ្មែរតែងតែយកបាយដែលគេបានពូតជាដុំមូលៗលាយចេក សណ្ដែក ល្ង និងដូង ជាដើម ដែលគេឱ្យឈ្មោះថា បាយបិណ្ឌ យកទៅវត្តអារាមនានា ដើម្បីបោះបញ្ជូនឧទ្ទិសកុសលទៅដល់ញាតិសន្ដាន សាច់សាលោហិត ដែលបានចែកឋានទៅបរលោកឬពួកនរកប្រេត។ ការបោះបាយបិណ្ឌនេះ គឺជាជំនឿមួយដែលប្រជាពលរដ្ឋខ្មែរនិយមធ្វើជារៀងរាល់ឆ្នាំ គឺគេចាប់ផ្ដើមធ្វើចាប់ពីថ្ងៃ១រោច រហូតដល់ថ្ងៃ១៥រោច ខែភទ្របទ ដែលជាទូទៅត្រូវនឹងខែកញ្ញាឬតុលា។

នៅវេលានោះ ប្រជាពលរដ្ឋខ្មែរបានធ្វើការសូត្រធម៌បួងសួងឧទ្ទិសទៅដល់សាច់ញាត្តិដែលស្លាប់ និងបោះបាយបិណ្ឌនៅជុំវិញព្រះវិហារ ដោយពួកគេជឿថា វិញ្ញាណទាំងឡាយណាដែលគ្មានសាច់ញាតិត្រូវបានគេដោះលែងពីឋាននរកឱ្យមកកាន់វត្តអារាម ដើម្បីទទួលអាហារពីសាច់ញាត្តិរបស់ពួកគេ នៅវេលាយប់ហើយវិញ្ញាណពួកគេត្រូវត្រឡប់ទៅឋាននរកវិញ នៅមុនពេលព្រះអាទិត្យបញ្ចេញរស្មី។ វិញ្ញាណទាំងនោះនឹងទៅគ្រប់៧វត្ត ដើម្បីរកមើលសាច់ញាតិ និងទទួលអាហារពីពួកគេ។ ប្រសិនបើវិញ្ញាណទាំងនោះ មិនឃើញសាច់ញាតិរបស់ពួកគេមកវត្តទេនោះ ពួកគេនឹងដាក់បណ្ដាសាផ្សេងៗ។ នេះហើយជាមូលហេតុដែលសាច់ញាតិ គួរតែយកចង្ហាន់ទៅវត្ត ទោះបីជាច្រើនឬក៏តិចក៏ដោយ ក្នុងអំឡុងពេលបុណ្យភ្ជុំបិណ្ឌ។

តាមការពិតទៅ ការបោះបាយបិណ្ឌមិនត្រឹមតែជាជំនឿដែលបានចាក់ឫសយ៉ាងជ្រៅទៅក្នុងផ្នត់គំនិត ហើយបានក្លាយទៅជាប្រពៃណីជាទម្លាប់យូរមកហើយរបស់ដូនតាប៉ុណ្ណោះទេ ក៏ប៉ុន្តែដូនតាខ្មែរ ក៏បានបង្កប់ន័យអប់រំនៅក្នុងពិធីនេះផងដែរ។ ក្រៅពីការឧបត្ថម្ភចង្ហាន់ដល់ព្រះសង្ឃ អាចារ្យបានបង្កើតកម្មវិធីបោះបាយបិណ្ឌនេះដើម្បីអប់រំចិត្តមនុស្សតាមរយៈព្រះសង្ឃសូត្រធម៌បរាភវសូត្រ ទាក់ទងនឹងមូលហេតុទាំង១២យ៉ាង ដែលនាំឱ្យមានសេចក្ដីវិនាស ព្រោះការបង្រៀនផ្ទាល់ហាក់ដូចជាគ្មានមនុស្សយកចិត្តទុកដាក់រៀនឡើយ។ ប្រយោជន៍ដែលមនុស្សទទួលបានពីការបោះបាយបិណ្ឌ គឺបានធ្វើទានផង និងចំណេញបានស្ដាប់បានរៀនព្រះធម៌អប់រំចិត្តផង ដើម្បីចៀសវាងពីសេចក្ដីវិនាស គឺមានតែភាពរីកចម្រើន និង សុភមង្គល។ គេក៏ត្រូវយល់ដឹងផងដែរថា ការណ៍ដែលរៀបចំឱ្យមានការបោះបាយបិណ្ឌនាពេលទៀបភ្លឺ ក៏ព្រោះតែកុំឱ្យខាតបង់ពេលវេលាក្នុងការងាររកស៊ីចិញ្ចឹមជីវិតប្រចាំថ្ងៃផងដែរ។

ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្នការបោះបាយបិណ្ឌជាសកម្មភាពមួយមិនទាន់មានការឯកភាពគ្នានៅក្នុងសង្គមពុទ្ធសាសនិកនៅឡើយទេ ដោយអ្នកខ្លះបានចាត់ទុកការបោះ

បាយបិណ្ឌជាកិច្ចដ៏សំខាន់មួយមិនអាចខានបាននៅក្នុងរដូវបុណ្យកាន់បិណ្ឌនេះ ខណៈដែលអ្នកខ្លះបានអះអាង និងរិះគន់ដាច់ខាត ថាការបោះបាយបិណ្ឌជាទង្វើមិនត្រឹមត្រូវ ព្រោះជាជំនឿឥតប្រយោជន៍ និងខាតបង់នូវសេដ្ឋកិច្ច ហើយម្យ៉ាងការបោះបាយបិណ្ឌទៀតសោតក៏ជាការធ្វើទានមិនត្រឹមត្រូវតាមការបង្រៀនរបស់ព្រះពុទ្ធឡើយ។ ក៏ប៉ុន្តែអ្នកដែលជឿថា ការបោះបាយបិណ្ឌមានប្រយោជន៍ដល់ពពួកប្រេតគួរតែបន្តប្រកាន់ជំនឿនេះ ព្រោះជាប្រពៃណីនិងជាទម្លាប់យូរមកហើយរបស់ដូនតា ហើយចាស់ទុំក៏បានបង្កប់ន័យអប់រំ នៅក្នុងពិធីនេះផងដែរ។ សូមចងចាំថា បើកាលណាយើងនាំគ្នាលុបបំបាត់នូវប្រពៃណី ទំនៀមទម្លាប់ទាំងនោះនោះមានន័យថាយើងនឹងបាត់បង់អត្តសញ្ញាណរបស់ជាតិយើងផងដែរ។

## គន្ថនិទ្ទេស


1. *ជួន ណាត វចនានុក្រមខ្មែរភាគ១-២ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ ១៩៦៧។*
2. *ត្រឹង ង៉ា ប្រវត្តិសាស្ត្រខ្មែរភាគ១ បោះពុម្ពឆ្នាំ១៩៧៣។*
3. *ត្រឹង ង៉ា វប្បធម៌ អរិយធម៌ខ្មែរ ឆ្នាំ១៩៧៤។*
4. *វ៉ាន់ ឌីកាអុន សង្គមសាស្ត្រ ការផ្សាយរបស់អ្នកនិពន្ធ ភ្នំពេញ ឆ្នាំ១៩៧៣។*
5. *សរ សារុន វប្បធម៌ អរិយធម៌ខ្មែរ ឆ្នាំ១៩៧០។*
6. *សរ សារុន ល្បងសិក្សាសង្គមវិជ្ជាខ្មែរ បោះពុម្ពលើកទី១ ឆ្នាំ១៩៧៣។*

ទ្រឹស្តីផ្សារភ្ជាប់នឹងការអនុវត្ត ចងភ្ជាប់ដោយលទ្ធផល
ហើយត្រូវមានក្រមសីលធម៌វិជ្ជាជីវៈ